# សេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ខ្ញុំចំពោះលោកយេស៊ូ នាំខ្ញុំមកកាន់សាសនាអ៊ីស្លាម

និពន្ធដោយៈ លោក សាយមិន អាល់ហ្វ្រេដូ ខារ៉ាបាឡូ

ប្រែសម្រួលដោយៈ អាចារ្យ វ៉ាន វ៉ាន់ឌី

# សេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ខ្ញុំចំពោះលោកយេស៊ូ នាំខ្ញុំមកកាន់សាសនាអ៊ីស្លាម

និពន្ធដោយៈ សាយមិន អាល់ហ្វ្រេដូ ខារ៉ាបាឡូ

ប្រែសម្រួលដោយៈ វ៉ាន វ៉ាន់ឌី

# មាតិកា


អារម្ភបទអ្នកបកប្រែ........1
សេចក្ដីផ្ដើម អំពីខ្ញុំ........3
បទពិសោធន៍របស់ខ្ញុំនៅសហរដ្ឋអាមេរិក........10
គម្ពីរបរិសុទ្ធ........15
សុក្រឹត្យភាពនៃព្រះគម្ពីរគួរអាន........29
ដំណើរជីវិត និងព័ន្ធកិច្ចរបស់លោកយេស៊ូ........37
ព្យាការីមូហាំម៉ាត់........47
គោលជំនឿនៃសាសនាអ៊ីស្លាម និងសាសនាគ្រិស្ត........70
ព្រះត្រៃឯក........72
ភាពជាព្រះរបស់លោកយេស៊ូ........77
ភាពជាបុត្ររបស់ព្រះ........84
បាបពីកំណើត........85
សាសនាអ៊ីស្លាមគឺជាសាសនាឯកទេពនិយមរបស់បណ្ដាព្យាការីទាំងឡាយ........98
ជំហានចុងក្រោយរបស់ខ្ញុំមកកាន់សាសនាអ៊ីស្លាម........105
ឥទ្ធិពលនៃសាសនាអ៊ីស្លាមមកលើជីវិតខ្ញុំ........111
ការផ្លាស់ប្រែជំនឿរបស់ខ្ញុំបានជះឥទ្ធិពលដល់អ្នកដទៃទៀត........118
សាសនាដែលអាចឈរជើងបានដោយប្រើការបង្ខិតបង្ខំ........123
លិខិតចំហជូនដល់សម្ដេចប៉ាប និងមេដឹកនាំពិភពលោក........133

# អារម្ភបទអ្នកបកប្រែ

ក្នុងព្រះនាមនៃព្រះអល់ឡោះ ទ្រង់ដ៏សប្បុរស ដ៏មេត្តាករុណា។

*សូមភាពសុខសាន្តកើតមានដល់អស់លោកអ្នកអានទាំងអស់គ្នា!*

៣៣២ថ្ងៃកន្លងផុតទៅ ខ្ញុំបានបញ្ចប់ការបកប្រែសៀវភៅយ៉ាងពិសេសនេះបានជោគជ័យដោយព្រះគុណនៃព្រះ។ ដោយសង្កេតឃើញថា សៀវភៅសម្រាប់សិក្សាបែបប្រៀបធៀបសាសនាមានការខ្វះខាត យ៉ាងនេះហើយខ្ញុំក៏ប្រឹងប្រែងក្នុងការបកប្រែដោយជួបប្រទះនឹងការពិបាកច្រើន ដ្បិតមានពាក្យបច្ចេកទេសប្រើក្នុងទេវវិទ្យាជាច្រើនដែលមិនទាន់មានការបកប្រែជាផ្លូវការជាខេមរៈភាសានៅឡើយ។ ម្យ៉ាងវិញទៀតក្នុងខ្លឹមសារនៃសៀវភៅនេះ ប្រើប្រាស់ពាក្យពេចន៍សម្រួលជាពិសេសសម្រាប់អស់លោកអ្នកជាគ្រិស្តបរិស័ទ ដោយសង្ឃឹមអស់លោកអ្នកនឹងទទួលបានការចង្អុលបង្ហាញពីព្រះដ៏ពិត។ អត្ថបទដកស្រង់ចេញពីគម្ពីរបរិសុទ្ធ អាចនឹងខុសគ្នាបន្តិចបន្តួចពីអត្ថបទគម្ពីរដែលលោកអ្នកប្រើជាប្រចាំ ដោយយើងខ្ញុំជ្រើសរើសយកការបកប្រែដែលត្រឹមត្រូវបំផុតមកប្រើ។ រីឯឈ្មោះតួអង្គ និងព្យាការី ខ្ញុំប្រើតាមគម្ពីរបរិសុទ្ធជាភាសាខ្មែរ ដើម្បីងាយស្រួលសម្គាល់ តែក៏ជាការប្លែកមួយសម្រាប់អ្នកមូស្លីមដែរ។ ខ្ញុំសូមអភ័យទោសចំពោះខ្លឹមសារ ឬការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យត្រង់ណាដោយអចេតនា។ សូមអស់លោកអ្នកអានទទួលយកការគោរពរាប់អាន និងសេចក្តីស្រឡាញ់អំពីខ្ញុំ។

ខ្ញុំសូមបួងសួងឱ្យសៀវភៅនេះបានជាប្រយោជន៍ពង្រឹងដល់អ្នកមានជំនឿ និងបំភ្លឺដល់អ្នកគ្មានជំនឿ បានជាអង្វែងតទៅ! អាមីន!

ពីខ្ញុំ វ៉ាន វ៉ាន់ឌី

ចំណងជើង៖ សេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ខ្ញុំចំពោះលោកយេស៊ូនាំខ្ញុំមកកាន់សាសនាអ៊ីស្លាម

និពន្ធដោយ៖ លោក សាយមិន អាល់ហ្វ្រេដូ ខារ៉ាបាឡូ

ប្រែសម្រួលដោយ៖ អាចារ្យ វ៉ាន វ៉ាន់ឌី

អ្នកត្រួតពិនិត្យ៖ លោកគ្រូ ឧស្មាន ពិន មូហាំម៉ាត់

លោកគ្រូ អាប់ឌុលឡោះ ពិន សាហ្វាអះ

កញ្ញា លី គឹមឡាង

កញ្ញា វិរៈ សិរីមុនីនាថ

ផលិតឆ្នាំ៖ ២០២១

---

## កំណត់សម្គាល់

*អក្សរទ្រេត* ប្រើសម្គាល់ថាជាអត្ថបទដកស្រង់។

**អក្សរដិត** ប្រើសម្គាល់ឈ្មោះមនុស្ស, ទីកន្លែង, ពិធីបុណ្យ, ឈ្មោះគម្ពីរ និងពាក្យគន្លឹះ។

សញ្ញាវង់ក្រចក () ក្រោយ*អក្សរទ្រេត* ប្រើសម្រាប់បញ្ជាក់ប្រភពយោងអត្ថបទ។

សញ្ញាវង់ក្រចក () ក្នុងអត្ថបទធម្មតា ប្រើសម្រាប់បន្ថែមន័យ, បញ្ជាក់ន័យ, បំពេញន័យ។

សម្រាប់ប្រភពយោងគម្ពីរបរិសុទ្ធ ក្នុងវង់ក្រចក()ដំបូងគេគឺឈ្មោះ កណ្ឌគម្ពីរ បន្ទាប់មកលេខជំពូក បន្ទាប់មកលេខខ។ ឧ.(លូកា ៥:១) មានន័យថា អត្ថបទដកស្រង់ចេញពីកណ្ឌគម្ពីរលូកា ជំពូកទី៥ ខទី១។

សម្រាប់ប្រភពយោងព្រះគម្ពីរគួរអាន ក្នុងវង់ក្រចក()ដំបូងគេគឺពាក្យថា គួរអាន បន្ទាប់មកលេខជំពូក បន្ទាប់មកលេខវាក្យខណ្ឌ។ ឧ.(គួរអាន ៥:១) មានន័យថា អត្ថបទដកស្រង់ចេញពីព្រះគម្ពីរគួរអាន ជំពូកទី៥ វាក្យខណ្ឌទី១។

# សេចក្ដីផ្ដើម

# អំពីខ្ញុំ

ក្នុងនាមជាអ្នកកាន់សាសនាកាតូលិកម្នាក់ ខ្ញុំត្រូវបានគេដឹកនាំឱ្យជឿថា មានតែសាសនាកាតូលិកមួយប៉ុណ្ណោះ ដែលជាសាសនាត្រឹមត្រូវពិតប្រាកដ រីឯសាសនាយូដាគ្រាន់តែជាសាសនាមួយ ដែលត្រៀមមុនការមកដល់របស់សាសនាគ្រិស្ត ចំណែកឯសាសនាផ្សេងពីនេះ សុទ្ធតែជាសាសនាខុសឆ្គងទាំងអស់។ មែនទែនទៅ ខ្ញុំទើបតែបានឮពីសាសនាអ៊ិស្លាមជាលើកដំបូងនៅក្នុងឆ្នាំ១៩៧៨។ កាលនោះខ្ញុំបានដឹងថាអ្នកកាន់សាសនាអ៊ិស្លាមជឿលើព្រះដែលមានប្រភពចេញពីសាសនាគ្រិស្ត និងសាសនាយូដា។ ព្រះគម្ពីរ**គួរអាន**បានប្រាប់ថា ព្រះ**អល់ឡោះ** បានបញ្ជូនព្យាការីទៅកាន់រាល់ដែនដីទាំងអស់ ក្នុងបំណងចង្អុលបង្ហាញមនុស្សលោកទៅកាន់មាគ៌ានៃសេចក្ដីពិត និងសេចក្ដីសុចរិត។

ដោយមានគោលបំណងដាប់ឆ្លាក់សេចក្ដីបង្រៀនរបស់សាសនាគ្រិស្ត ឱ្យកាន់តែជ្រៅក្នុងចិត្តគំនិតរបស់ខ្ញុំ ព្រះវិហារកាតូលិកបានរៀបចំកម្មវិធីបំពាក់បំប៉នតាំងពីនៅកុមារ ដែលជាវ័យងាយនឹងចាប់បាន។ កម្មវិធីនេះជះឥទ្ធិពលលើជំនឿ និងឥរិយាបថរបស់មនុស្សអស់មួយជីវិតតែម្ដង។ ក្នុងកម្មវិធីនេះតួអង្គសំខាន់ជាងគេលើលោក**យេស៊ូ** ហើយភាគច្រើននិយាយពីព្រឹត្តិការណ៍ជុំវិញការប្រសូត, ការស្លាប់ និងការរស់ឡើងវិញរបស់លោក។ ចាប់តាំងពីការប្រសូតរបស់លោក ដែលគេសន្មតថា

លោកប្រសូតក្នុងខែធ្នូនោះ រហូតដល់ការណ៍ដែលលោកត្រូវបានគេចងឆ្កាងនៅថ្ងៃ**បុណ្យអ៊ីស្ទើរ**[1]។ ពិធីបុណ្យសាសនាទាំងនេះ ត្រូវបានមនុស្សលោកចេះតែធ្វើបន្តគ្នាអស់ជាច្រើនសតវត្សរ៍ ក្រោយពេលលោកយេស៊ូបានចាកចេញទៅ តែមិនមែនជាការបង្គាប់ពីព្រះឡើយ។

បើតាមប្រពៃណីរបស់ជនជាតិវេណេហ្សុយអេឡា នៅពេលរំលងអធ្រាត្រនៃថ្ងៃទី២៤ខែធ្នូ ខ្ញុំធ្លាប់ទន្ទឹងរង់ចាំការមកដល់របស់លោកយេស៊ូ យកកាដូមកឱ្យខ្ញុំដែលកាដូនោះជាអ្វីដែលខ្ញុំបានប៉ងប្រាថ្នាប្រចាំឆ្នាំ។ ដោយខ្ញុំរស់នៅគ្រួសារដែលមានជីវភាពក្រីក្រ ហើយមានបងប្អូនច្រើនផងនោះ ខ្ញុំអាចយល់បានថា វាជារឿងពិបាកណាស់សម្រាប់លោក**យេស៊ូកុមារ** អាចយកកាដូដូចអ្វីដែលខ្ញុំប៉ងប្រាថ្នាមកឱ្យខ្ញុំបាន។ ប៉ុន្តែខ្ញុំក៏តែងតែនឹកឆ្ងល់មិនអស់ចិត្តថា ប្រសិនបើលោកយេស៊ូពិតជាអាចធ្វើការណ៍អស្ចារ្យបានជាច្រើន ដូចដែលខ្ញុំបានរៀនពីដូនជី និងបូជាចារ្យពិតមែននោះ តើវាពិបាកណាស់ទៅឬ គ្រាន់តែផ្តល់កាដូជាកូនកង់មួយមកឱ្យខ្ញុំ? តើការសម្រេចបំណងប្រាថ្នារបស់ខ្ញុំវាមិនងាយជាងការប្រស់មនុស្សស្លាប់ឱ្យរស់ឡើងវិញទេមែនទេ? ហេតុនេះហើយ អស់រយៈពេលជាច្រើនឆ្នាំដែលជំនឿទាក់ទងនឹងលោក**យេស៊ូកុមារ** ធ្វើឱ្យខ្ញុំខកចិត្តរហូត។

នៅពេលពិធីបុណ្យព្រះ**យេស៊ូមានព្រះជន្មឡើងវិញ**កាន់តែកៀកនឹងមកដល់ ខ្ញុំតែងតែមើលរឿងក្នុងទូរទស្សន៍ដែលគេនិយាយពីការណ៍ដែលលោកយេស៊ូត្រូវបានគេធ្វើបាប រហូតដល់ពេលលោកត្រូវបានព្យួរនៅលើឈើឆ្កាង។ កាលនោះខ្ញុំពិតជាចង់ចូលទៅក្នុងទូរទស្សន៍ដើម្បីជួយសង្គ្រោះលោកយេស៊ូ ទោះដឹងថាបើចូលបានមែនក៏មិនដឹងថាត្រូវជួយលោកដោយវិធីណានោះទេ។ ខ្ញុំខំទូលអង្វរដល់ព្រះឱ្យជួយលោកផង ហើយអង្វរទ្រង់ថា ធ្វើយ៉ាងណាក៏ដោយកុំឱ្យបុត្ររបស់ទ្រង់ត្រូវគេចងឆ្កាង។ នៅទី

[1] បុណ្យអ៊ីស្ទើរ (Easter day) ជាបុណ្យដែលគ្រិស្តបរិស័ទប្រារព្ធរំឭកដល់ថ្ងៃលោកយេស៊ូរស់ឡើងវិញ(តាមជំនឿរបស់គេ)។ បុណ្យនេះប្រារព្ធមួយឆ្នាំម្តងនៅរៀងរាល់ថ្ងៃអាទិត្យដើមនិទាឃរដូវនៃឆ្នាំនីមួយៗ។

បំផុត ខ្ញុំត្រូវពួនហើយយំម្នាក់ឯងពីព្រោះគេតែងបង្រៀនខ្ញុំថា ជាមនុស្សប្រុសមិនត្រូវយំទេ។ ខ្ញុំគិតមិនយល់សោះថា ហេតុអ្វីមនុស្សដែលល្អយ៉ាងនេះត្រូវមកជួបនឹងទង្វើដ៏ឃោរឃៅគ្មានមេត្តាយ៉ាងនេះទៅវិញ។ កាលនោះខ្ញុំនៅជាកុមារ ហេតុការណ៍នេះ បានធ្វើឱ្យខ្ញុំមានក្តីស្រឡាញ់យ៉ាងខ្លាំងចំពោះព្យាការីព្រះរូបនេះ។ សម្រាប់កុមារដទៃទៀតវិញ ប្រហែលជាកាដូជារបស់លេងនៅថ្ងៃណូអែល ឬការសម្រេចបំណងណាមួយរបស់ពួកគេ បានបណ្តាលចិត្តឱ្យពួកគេមានការស្រឡាញ់ទៅចំពោះលោកយេស៊ូដែរ។

ប្រសិនបើព្រះវិហារមានគោលបំណង ធ្វើឱ្យមនុស្សម្នាមានអារម្មណ៍ចង់គោរពលោកយេស៊ូនោះ គឺមានន័យថាគេបានធ្វើជោគជ័យមកលើខ្ញុំហើយ។ ខ្ញុំបានដឹងថាត្រូវស្រឡាញ់លោកយេស៊ូលើសឪពុកម្តាយខ្ញុំទៅទៀត។ យ៉ាងណាមិញ ដោយនៅជាក្មេងនៅឡើយ ខ្ញុំចេះតែងឿងឆ្ងល់ ហើយក៏ចេះតែសួរពីអំណាចរបស់ព្រះ។ គំនិតដែលខ្ញុំយល់ឃើញចំពោះព្រះនោះគឺ ព្រះអង្គអាចធ្វើអ្វីៗបានគ្រប់យ៉ាងតាមដែលទ្រង់ចង់។ ព្រះអង្គបានបង្កើតចក្រវាឡ, ផែនដី, ព្រះអាទិត្យ, ព្រះចន្ទ, ដួងផ្កាយ ហើយនិងមនុស្សលោក។ ខ្ញុំចេះតែនឹកឆ្ងល់ថាហេតុអ្វីបានជាទ្រង់មិនបានសង្គ្រោះលោកយេស៊ូឱ្យរួចផុតពីការចងឆ្កាង។ ដើម្បីស្រាយចម្ងល់ដ៏សម្ងើមនេះ មានពេលមួយនោះខ្ញុំបានឡើងទៅលើរបងទាបមួយនៅក្រោយផ្ទះ ហើយនិយាយភ្នាល់នឹងព្រះថា៖ *ប្រសិនបើទ្រង់មានអំណាចដ៏ខ្លាំងក្លាអាចធ្វើអ្វីៗគ្រប់យ៉ាងតាមដែលទ្រង់ចង់បានមែន អ៊ីចឹងពេលខ្ញុំហក់ចុះពីរបងនេះ ទ្រង់ធ្វើឱ្យខ្ញុំអាចហោះបានទៅមើល! បើមិនដូច្នេះទេ ខ្ញុំមិនជឿសោះឡើយថាទ្រង់មានអំណាចដ៏អស្ចារ្យនោះ ព្រោះទ្រង់មិនអាចជួយលោកយេស៊ូបាននៅគេចាប់គាត់ចងឆ្កាង។* ជាអកុសល របងនោះទាបដែរ ខ្ញុំក៏ធ្លាក់មកលើដី។ រាល់ពេលដែលខ្ញុំព្យាយាមហោះ ខ្ញុំកាន់តែគិតថា ព្រះឥតមានអំណាចអ្វីសោះឡើយ។ ពិតប្រាកដណាស់ នេះហើយជាការវិភាគបែបកូនក្មេង!

រយៈកាលក្រោយមក ខ្ញុំក៏ចាប់ផ្តើមចូលរៀននៅឯវិទ្យាល័យ។ ឪពុកម្តាយខ្ញុំបានអនុញ្ញាតឱ្យខ្ញុំធ្វើការជាមួយបុរសចំណាស់ម្នាក់ដែលគាត់ជាជាងថតរូប ហើយខ្ញុំក៏បានទៅជាធ្វើការជាមួយគាត់នៅកន្លែងជាច្រើន។ ក្រោយមកទើបដឹងថា គាត់ក៏ជាគ្រូទាយ

ដ៏ល្បីម្នាក់ផងដែរ។ កន្លែងណាក៏ដោយដែលពួកយើងទៅដល់ អតិថិជនស្រីៗរបស់គាត់ តែងតែសួរគាត់ពីរឿងហេតុដែលនឹងកើតឡើងក្នុងជីវិតរបស់ពួកគេនៅពេលអនាគត។ ដើម្បីធ្វើកិច្ចទស្សន៍ទាយ គាត់តែងតែជក់បារីមូរពណ៌ត្នោត ហើយបឺតផ្សែងវាឱ្យខ្លាំង ដើម្បីឱ្យផេះបារីនោះធ្លាក់ចុះ។ គាត់ក៏ចាប់ផ្ដើមប្រាប់រឿងរ៉ាវនានាដល់អតិថិជនរបស់គាត់។ ខ្ញុំក៏បានដឹងទៀតដែរថា គាត់ចេះប្រើវិធីសាស្ត្រសណ្ដំមនុស្សដើម្បីបានដឹងរឿងរ៉ាវលាក់កំបាំងក្នុងជីវិតរបស់ពួកគេ ហើយនិយាយប្រាប់ពួកគេវិញទៅតាមអ្វីដែលគេចង់ដឹង។

បទពិសោធន៍ទាំងអស់នេះ បានជិតដាមក្នុងចិត្តគំនិតរបស់ខ្ញុំខណៈពេលដែលខ្ញុំនៅវ័យជំទង់នៅឡើយ។ កំឡុងពេលនោះ ឪពុកម្ដាយខ្ញុំបានទៅចូលរួមក្នុងមជ្ឈមណ្ឌលមួយដែលមានឯកទេសខាង **អធិមនោវិទ្យា**[2] ខ្ញុំបានទៅទីនោះច្រើនដងដែរ ដើម្បីចង់ឃើញថាគេធ្វើអ្វីខ្លះនៅទីនោះ។ ហើយនៅក្នុងមជ្ឈមណ្ឌលនេះឯង ដែលខ្ញុំបានរៀនពីលក្ខណៈនៃការធ្វើសមាធិ, ព្រលឹងវិញ្ញាណ, ការចូលសណ្ឋិត ហើយអ្វីដែលខ្ញុំធ្លាប់ជឿនោះគឺមនុស្សស្លាប់អាចនិយាយជាមួយមនុស្សរស់បាន[3]។ នៅទីនេះខ្ញុំបានរៀនថ្វាយបង្គំក្នុងមួយថ្ងៃ២ដង នៅលើរានអសនៈតូចមួយដែលឪពុកខ្ញុំសាងសង់ឡើងដោយអស់ពីចិត្តពីថ្លើម។ ខ្ញុំបានចូលរួមការជួបប្រជុំមួយ អ្នកដឹកនាំក្រុមបាន

---

[2] Parapsychology ជាការសិក្សាទាក់ទងនឹងផ្លូវចិត្តដូចជា ការសណ្ដំ និងរបៀបទាក់ទងគ្នាដោយប្រើផ្លូវចិត្តជាដើម។

[3] ក្នុងសេចក្ដីពិតនោះ មនុស្សស្លាប់មិនអាចនិយាយជាមួយមនុស្សរស់បានទេ។ វាគ្មានអ្វីក្រៅពីពួកអារក្សបិសាចធ្វើត្រាប់សម្លេងអ្នកស្លាប់នោះហើយទាក់ទងជាមួយមនុស្សរស់នោះឯង។ ម្យ៉ាងវិញទៀតការសូត្រព្រះគម្ពីរគួរអាន និងអនុវត្តន៍តាមរបៀបរបស់ព្យាការី គឺមានប្រសិទ្ធិភាពក្នុងការជួយមនុស្សចេញពីវិញ្ញាណអាក្រក់ទាំងអស់នោះ។ ជាការពិតអ្នកមូស្លីមគ្រប់រូបអាចធ្វើការណ៍នេះបាន គឺជាភស្តុតាងបញ្ជាក់ពីភាព អស្ចារ្យរបស់ព្រះគម្ពីរគួរអាន។ អ្នកណាហើយដែលប្រើប្រាស់វិធីអ្វីផ្សេងក្រៅពីព្រះ គឺគ្មានអ្វីក្រៅពីសហការជាមួយនឹងវិញ្ញាណអាក្រក់ ឬប្រើវិញ្ញាណអាក្រក់ដើម្បីកំចាត់វិញ្ញាណអាក្រក់នោះឡើយ។

ប្រគល់បណ្ដោងស័ក្តិសិទ្ធិមួយមកឱ្យខ្ញុំ ដោយគាត់ប្រាប់ថា វានឹងជួយថែរក្សាការពារខ្ញុំ។ ដូច្នេះហើយនៅពេលដែលខ្ញុំទៅណាមកណាខ្ញុំតែងតែយកវាតាមខ្លួនជានិច្ច។

ស្របពេលជាមួយគ្នានោះដែរ ខ្ញុំនៅតែបន្តគិតពីការណ៍ដែលលោកយេស៊ូត្រូវបានគេចងឆ្កាង។ ពេលនោះឪពុកខ្ញុំមានសៀវភៅមួយក្បាលដែលគាត់តែងតែអានជាប្រចាំ វាមានចំណងជើងថា *ជីវិតរបស់លោកយេស៊ូ លះបង់ដោយខ្លួនលោក* ។ មានម្ដងនោះឪពុកខ្ញុំបានប្រាប់ខ្ញុំថា បើយោងតាមសៀវភៅនេះ លោកយេស៊ូធ្លាប់ធ្វើដំណើរចេញឆ្ងាយពីក្រុង**យេរូសាឡឹម**។ ខ្ញុំក៏ចាប់ផ្ដើមស្វែងរកចម្លើយដើម្បីស្រាយចម្ងល់របស់ខ្ញុំដែលទាក់ទងនឹងការចងឆ្កាងនោះ។

នៅពេលដែលខ្ញុំបានបញ្ចប់ការសិក្សានៅកម្រិតវិទ្យាល័យ ខ្ញុំក៏ទទួលបានអាហារូបករណ៍ទៅសិក្សាផ្នែកវិស្វកម្មនៅឯសហរដ្ឋអាមេរិក ដែលខ្ញុំយល់ព្រមទទួលដោយសេចក្ដីរីករាយ។ យ៉ាងណាមិញ មុនការចេញដំណើរនៅឆ្នាំ១៩៧៧ ខ្ញុំបានជួបរឿងមួយ ដែលប៉ះពាល់យ៉ាងខ្លាំងចំពោះសេចក្ដីជំនឿរបស់ខ្ញុំក្នុងសាសនាគ្រិស្ត។ ខ្ញុំបានឃើញគ្រិស្តបរិស័ទ២នាក់ កំពុងជួយបុរសម្នាក់ដែលកំពុងមានអាការៈស្ពន់ជាន់នៅតាមផ្លូវ។ ប៉ុន្តែក្រោយពីនោះពួកគេបានរាវរកកាបូបលុយរបស់ជនរងគ្រោះ ហើយលួចយកលុយក្នុងកាបូបនោះ[4]។ ការពិតណាស់ ថ្វីបើនេះជាសកម្មភាពបុគ្គលក៏ដោយ

---

[4] ក្នុងគម្ពីរបរិសុទ្ធបានចែងយ៉ាងច្បាស់ពីការហាមឃាត់ក្នុងការលួច ហើយវាជាទង្វើរបស់អារក្សបិសាច។ ក្នុងបទបញ្ញត្តិទាំង១០បានលើកឡើងថា *ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់កូនចៅអ៊ីស្រាអែលដូចតទៅ៖ យើងព្រះអម្ចាស់ជាព្រះរបស់អ្នក... មិនត្រូវគោរពព្រះណាផ្សេង ក្រៅពីយើងឡើយ។ មិនត្រូវឆ្លាក់រូបអ្វី ឬយកវត្ថុដែលជាតំណាងអ្វីមួយ នៅលើមេឃ នៅលើផែនដី ឬនៅក្នុងទឹកក្រោមដី ធ្វើជាព្រះឡើយ។ មិនត្រូវក្រាបថ្វាយបង្គំរូបព្រះទាំងនោះ ឬគោរពបម្រើរូបទាំងនោះឡើយ។ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងមិនចង់ឱ្យអ្នកជំពាក់ចិត្តនឹងព្រះណាផ្សេង ក្រៅពីយើងឡើយ។... មិនត្រូវយកព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ទៅប្រើឥតបានការនោះឡើយ... ចូរគោរពមាតាបិតារបស់អ្នក ដើម្បីឱ្យអ្នកមានអាយុយឺនយូរ នៅលើដីដែលព្រះអម្ចាស់ជាព្រះនៃអ្នក ប្រទានដល់អ្នក។ កុំសម្លាប់មនុស្ស។ កុំប្រព្រឹត្តអំពើផិតក្បត់។ កុំលួចប្លន់គេ។ កុំធ្វើ*

ក៏យើងអាចមើលឃើញពីភាពមានឥទ្ធិពល ឬគ្មានឥទ្ធិពលនៃការបង្រៀនរបស់សាសនានោះបានដែរ។ ព្រឹត្តិការណ៍នេះបានប៉ះពាល់មកលើដួងចិត្តខ្ញុំយ៉ាងខ្លាំង។ ប្រហែលជាមនុស្សជាច្រើនអាចនឹងយល់ឃើញថា នេះជារឿងមិនសំខាន់ប៉ុន្មានទេ ប៉ុន្តែខ្ញុំធ្លាប់បានឃើញដោយផ្ទាល់ភ្នែក នៅពេលដែលឪពុកខ្ញុំដាក់ទណ្ឌកម្មលើបងប្រុសខ្ញុំជាច្រើនដង នៅពេលដែលបងប្រុសខ្ញុំយកប្រាក់មកផ្ទះចំនួន២៥សេន ហើយគាត់មិនអាចប្រាប់ឪពុកខ្ញុំបានថាគាត់បានប្រាក់នេះមកពីណា។

---

*សាក្សីក្លែងក្លាយ ដែលនាំឱ្យអ្នកដទៃមានទោស។ កុំលោភលន់ចង់បានផ្ទះរបស់អ្នកដទៃ កុំលោភលន់ចង់បានប្រពន្ធគេ ឬក៏លោភលន់ចង់បានអ្នកបម្រើប្រុស អ្នកបម្រើស្រី គោ លា ឬអ្វីផ្សេងទៀតដែលជារបស់គេឡើយ។* (និក្ខមនំ ២០:១-១៧) ខទាំងនេះស្របគ្នាជាមួយនឹងព្រះគម្ពីរគួរអាន។ យ៉ាងណាមិញ ការជះឥទ្ធិពលរបស់ខទាំងនេះទៅលើការរស់នៅរបស់មនុស្សស្ទើរតែសាបសូន្យទៅហើយ ព្រោះតែមានខមួយចំនួនទៀតក្នុងគម្ពីរនេះអនុញ្ញាតឱ្យពួកគេបំពាន។ ដោយក្តីមេត្តាករុណាមកលើមនុស្សជាតិព្រះបានបើកបង្ហាញនូវព្រះគម្ពីរគួរអាន ដើម្បីមកកែលម្អនូវអ្វីដែលមានពីមុន។

# បទពិសោធន៍របស់ខ្ញុំ
# នៅសហរដ្ឋអាមេរិក

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំបានមកដល់សហរដ្ឋអាមេរិក ហើយចាប់ផ្តើមការសិក្សារបស់ខ្ញុំនៅឯសកលវិទ្យាល័យ។ ដំបូងបង្អស់ ខ្ញុំត្រូវទៅសាលាដើម្បីរៀនភាសាអង់គ្លេស ហើយនៅទីនោះខ្ញុំបានជួបមនុស្សជាច្រើនដែលមានជំនឿសាសនាខុសៗគ្នាមកពីជុំវិញពិភពលោក។ សាលាភាសាអង់គ្លេសនោះគឺនៅក្រុង **ស៊ីអេថល** រដ្ឋ **វ៉ាស៊ីនតោន**។ ខ្ញុំក៏មានមិត្តរួមបន្ទប់ម្នាក់ឈ្មោះ **ហ្វូអាដ** មកពី**អារ៉ាប៊ីសាអូឌីត**ដែលគាត់មករៀនបន្តយកសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត។ មានថ្ងៃមួយគាត់បានសួរខ្ញុំថា តើខ្ញុំប្រកាន់ទេបើគាត់ថ្វាយបង្គំព្រះនៅក្នុងបន្ទប់ពួកយើង? ខ្ញុំក៏ប្រាប់គាត់វិញថាខ្ញុំមិនមានបញ្ហាអីទេរឿងនេះ។ កាលនោះខ្ញុំភ្ញាក់ផ្អើលណាស់ ព្រោះជាលើកទីមួយហើយដែលបានឃើញអ្នកមូស្លីមថ្វាយបង្គំព្រះ។ មុនពេលចាប់ផ្តើមថ្វាយបង្គំព្រះ គាត់ទៅលាងសម្អាតខ្លួនជាមុនសិន។ គាត់លាងប្រអប់ដៃផង ខ្ពុរមាត់ផង លាងមុខនិងកំភួនដៃ នៅក្នុងឡាបូលាងដៃតូចមួយក្នុងបន្ទប់យើង។ វាក៏ជាលើកទីមួយដែលខ្ញុំបានឃើញគេយកជើងទៅលាងក្នុងឡាបូលាងដៃ។ បន្ទាប់មកខ្ញុំក៏សង្កេតមើលកាយវិការនៃការថ្វាយបង្គំព្រះរបស់គាត់។ គាត់ឈរត្រង់ខ្លួន, ឱនចុះ, លុតជង្គង់ ហើយក្រាបចុះ។ មកដល់ត្រង់នេះខ្ញុំក៏នឹកឃើញដល់កាលដែលយើងថ្វាយបង្គំនៅឯព្រះវិហារប៉ុន្តែគ្រាន់តែលុតជង្គង់ប៉ុណ្ណោះ ប៉ុន្តែអ្វីដែល ហ្វូអាដ បានធ្វើគឺ

ប្លែកខ្លាំងណាស់។ មួយរយៈខ្លីក្រោយមកហ្វូអាដបានចាកចេញពីវិទ្យាស្ថាន ហើយអស់រយៈពេលជាច្រើនខែ ខ្ញុំមិនដែលបានឃើញអ្នកមូស្លីមថ្វាយបង្គំព្រះទៀតនោះទេ។

កំឡុងពេលសម្រាកនៅឯវិទ្យាស្ថានភាសាអង់គ្លេស និស្សិតបរទេសមកពីប្រទេសនានា តែងតែមកជួបជុំគ្នាជជែកពីរឿងផ្សេងៗជាច្រើន។ ខ្ញុំចាំយ៉ាងច្បាស់ថាមានពេលមួយនោះ ពួកយើងនាំគ្នាជជែកពីប្រភពនៃសាសនា និងការថ្វាយបង្គំ។ ខ្ញុំក៏និយាយប្រាប់ពួកគេថា *អ្នកទាំងអស់គ្នានាំគ្នាថ្វាយបង្គំតាមតែអ្វីដែលអ្នកទាំងអស់គ្នាធ្លាប់ធ្វើកន្លងមក ព្រោះដូនតាអ្នកធ្លាប់ថ្វាយបង្គំព្រះរបៀបហ្នឹង* ខ្ញុំក៏និយាយតទៀតប្រាប់ពួកគេថាដូនតារបស់គេធ្លាប់ថ្វាយបង្គំព្រះអាទិត្យ, ព្រះចន្ទ ហើយនិងផ្កាយ នៅពេលយូរទៅវាក្លាយទៅជាប្រពៃណី ហើយត្រូវអនុវត្តបន្តរហូតមកដល់បច្ចុប្បន្ននេះ។ ពេលនោះខ្ញុំក៏ចាប់ផ្តើមសង្ស័យពីឫសគល់នៃជំនឿលើព្រះដែរ ប៉ុន្តែដោយសារតែសាសនាគ្រិស្តបានចាក់ឫសយ៉ាងជ្រៅក្នុងខ្លួនខ្ញុំ ដូច្នេះហើយខ្ញុំមិនក្លាយជាអ្នកលែងជឿព្រះទេ។

ថ្ងៃមួយខ្ញុំបានធ្វើដំណើរទៅព្រះវិហារអ៊ីស្លាមមួយ ហើយសង្កេតមើលមនុស្សម្នាជាច្រើនថ្វាយបង្គំព្រះដូចដែលខ្ញុំធ្លាប់បានឃើញ ហ្វូអាដ ថ្វាយបង្គំព្រះពីមុនដែរ។ ក្រោយពេលថ្វាយបង្គំរួច ពួកគេនាំគ្នាអង្គុយផ្ទាល់នៅលើកម្រាល ដើម្បីស្តាប់ការអធិប្បាយ។ ដោយសារគេអង្គុយចុះគ្រប់គ្នាហើយ ខ្ញុំក៏អង្គុយជាមួយពួកគេ ហើយស្តាប់**អ៊ីមុាំ**ធ្វើការអធិប្បាយ។ អ៊ីមុាំនោះគាត់មានឈ្មោះថា **ចាមីល អាប់ឌុលរ៉ាហ្សាក់** មកពីប្រទេស**អ៊ីរ៉ាក់**។ គាត់ធ្វើការអធិប្បាយជាភាសាអង់គ្លេសអំពី ការនិយាយដើមគ្នា។ ខ្ញុំចាំថាគាត់និយាយសម្លេងតឹង ហើយមានការក្តុកក្តួល។ ពេលគាត់កំពុងនិយាយ គាត់ងាកមើលទៅអ្នកស្តាប់ ដូចជាមាននរណាម្នាក់បាននិយាយអាក្រក់ពីអ្នកដទៃ ប៉ុន្តែគាត់មិននិយាយចំៗថាជានរណាទេ។ ខ្ញុំគិតថាកម្មវត្ថុរបស់គាត់គឺធ្វើឱ្យអ្នកដែលនិយាយអាក្រក់ពីអ្នកដទៃមានអារម្មណ៍ថាខ្លួនបានប្រព្រឹត្តខុស។

នៅថ្ងៃដដែលនោះមានគេផ្ញើស្រោមសំបុត្រមួយមកឱ្យខ្ញុំ ក្នុងនោះមានកូនសៀវភៅមួយចំនួន និយាយពីការប្រៀបធៀបរវាងសាសនាអ៊ីស្លាម និងសាសនាគ្រិស្ត។ ខ្ញុំចំណាយពេលអានវាយូរណាស់ ដោយពេលនោះខ្ញុំរវល់ច្រើនក្នុងការចាប់ផ្តើមរៀនឆ្នាំទី១ នៅសាកលវិទ្យាល័យរដ្ឋ**អូក្លាហូម៉ា**។ ដោយសារតែកូនសៀវភៅនោះហើយទើបខ្ញុំបានដឹងថា សាសនាអ៊ីស្លាម និងសាររបស់លោកយេស៊ូ គឺជាការបើកបង្ហាញពីព្រះមកដូចគ្នា។ លោកយេស៊ូបាននិយាយថា សារដែលលោកបង្រៀននោះមិនមែនមកពីលោក តែគឺមកពីព្រះ៖ *ពាក្យដែលខ្ញុំបាននិយាយនេះ មិនមែនចេញមកពីខ្ញុំទេ គឺព្រះបិតាដែលបានចាត់ខ្ញុំឱ្យមក ទ្រង់បង្គាប់ខ្ញុំនូវសេចក្តីដែលខ្ញុំត្រូវនិយាយនិងថ្លែង។*(យ៉ូហាន ១២:៤៩) ដូចគ្នាដែរ ការបើកបង្ហាញដែលព្យាការី **មូហាំម៉ាត់** បានបង្រៀនទៅកាន់មនុស្សជាតិទាំងអស់នោះ គឺព្រះបានប្រទានចុះមកតាមរយៈទេវតា **កាព្រីយ៉ែល** ៖ *ហើយជាការប្រាកដណាស់ ព្រះគម្ពីរគួរអានគឺជាការប្រទានចុះមកពីព្រះជាម្ចាស់នៃពិភពទាំងអស់។ ដែលកាព្រីយ៉ែលជាទីទុកចិត្តបាននាំវាមក។ ទៅលើដួងចិត្តរបស់អ្នក ដើម្បីឱ្យអ្នកក្លាយជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដាស់តឿនព្រមាន ។*(គួរអាន ២៦:១៩២-១៩៤)

ដូច្នេះហើយ សេចក្តីពិតនៃរាល់សាសនាទាំងអស់ រួមទាំងភស្តុតាងអំពីឬសគល់របស់ព្រះ គឺពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះនៃភាពស្មោះត្រង់ពីប្រភពដើមដែលព្រះបានបើកបង្ហាញ ហើយត្រូវបានថែរក្សាការពារ និងចែកផ្សាយដល់មនុស្សជាតិទាំងអស់។ សារនោះមានកម្រិតនៃភាពជាក់លាក់ខ្ពស់បំផុត ដែលរាល់ពាក្យពេចន៍ត្រូវបានបើកបង្ហាញមកកាន់បណ្តាព្យាការីហើយបញ្ជូននៅកាន់អ្នកដទៃៗទៀត។ ប្រសិនបើពាក្យពេចន៍ទាំងអស់នេះមិនត្រូវបានបញ្ជូនយ៉ាងត្រឹមត្រូវទេនោះ ហើយវាទទួលរងការក្លែងបន្លំវិញនោះ មានន័យថាខ្លឹមសារដើមនឹងត្រូវបាត់បង់ជារៀងរហូត។ ដូច្នេះហើយ ដើម្បីធ្វើឱ្យការប្រៀបធៀបមានលក្ខណៈសុក្រឹត្យមិនលម្អៀងរវាង សាសនាអ៊ីស្លាម និងសាសនាគ្រិស្តនោះ គឺត្រូវកំណត់ថារវាង គម្ពីរបរិសុទ្ធ និងព្រះគម្ពីរគួរអាន តើគម្ពីរមួយណាបានគេចផុតពីការក្លែងបន្លំ ឬការលុបផ្នែកខ្លះ។ ពីព្រោះតែគោលបំណង

សំខាន់គឺដើម្បីឱ្យអ្នកអានបានដឹងពីការពិត និងដោយបានពិចារណា ហើយចំណុចខ្លះ រឿងរ៉ាវផ្ទាល់ខ្លួនខ្ញុំវាមិនទាក់ទាញដល់អ្នកអានមួយចំនួននោះទេ។ អ្វីដែលមាននៅក្នុង សៀវភៅនេះ គឺជាការប្រៀបធៀបយ៉ាងសង្ខេបរវាងសាសនាអ៊ីស្លាម និងសាសនា គ្រិស្ត ដែលសាសនាទាំងពីរនេះជាសាសនាមានឥទ្ធិពលយ៉ាងខ្លាំងបំផុតលើ ពិភពលោក ហើយក៏មានអ្នកកាន់តាមក្នុងចំនួនដ៏ច្រើនបំផុតពីគ្រប់ប្រទេស និងគ្រប់ ជនជាតិ ហើយក៏ជាសាសនាដែលមានទំនាក់ទំនងផ្នែកជំនឿយ៉ាងកៀកគ្នាបំផុតដែរ។ បន្ទាប់ពីការប្រៀបធៀបសាសនា ខ្ញុំនឹងបន្តរៀបរាប់ពីព្រឹត្តិការណ៍ផ្សេងៗ ពី បទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ។ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ដោយព្រះបំណងរបស់ ព្រះ សៀវភៅនេះនឹងជួយបំភ្លឺការពិតជូនដល់លោកអ្នកដែលកំពុងស្វែងរកសាសនា ពិតប្រាកដ។

# គម្ពីរបរិសុទ្ធ

កណ្ឌគម្ពីរចំនួន៤ដែលមនុស្សជាច្រើនបានស្គាល់ ហើយគេឃើញមានក្នុងគម្ពីរ**សម្ពន្ធមេត្រីថ្មី**នោះរួមមានកណ្ឌគម្ពីរ **ម៉ាថាយ**, **ម៉ាកុស**, **លូកា** ហើយនិង **យ៉ូហាន**។ កណ្ឌគម្ពីរទាំងអស់នេះត្រូវបានសរសេរឡើងក្នុងកំឡុងឆ្នាំ ៧០ ដល់ឆ្នាំ ១១៥ ដើមគ្រិស្តសករាជ ប៉ុន្មានទសវត្សរ៍ក្រោយលោកយេស៊ូបានចាកចេញពីផែនដី ហើយកណ្ឌគម្ពីរទាំងនេះត្រូវបានគេសន្មតថា សរសេរដោយយោងតាមឯកសារតែមួយដែលបានបាត់ទៅ។ កណ្ឌគម្ពីរម៉ាកុស ត្រូវបានសរសេរលើកដំបូងជាភាសា**ក្រិក** នៅឯទីក្រុងរ៉ូមប្រម៉ាណ៤០ឆ្នាំក្រោយលោកយេស៊ូចាកចេញពីផែនដី។ កណ្ឌគម្ពីរម៉ាថាយ ក៏ត្រូវបានគេសរសេរជាភាសាក្រិក កំឡុងឆ្នាំ៩០ដើមគ្រិស្តសករាជ។ កណ្ឌគម្ពីរលូកា ត្រូវបានគេសរសេរជាភាសាក្រិកដូចគ្នា ក្នុងឆ្នាំ៨០ដើមគ្រិស្តសករាជ។ កណ្ឌគម្ពីរទាំង៣នេះត្រូវបានគេហៅថា **ដំណឹងល្អត្រៃកណ្ឌ** ពីព្រោះតែកណ្ឌគម្ពីរទាំង៣នេះ ត្រូវបានគេសន្មតថាមានប្រភពមកពីឯកសារតែមួយដែលបាត់បង់ទៅ។ រីឯកណ្ឌគម្ពីរយ៉ូហាន[5]

---

[5] យ៉ូហាននេះមិនមែនជាយ៉ូហានដែលជាសិស្សជំនិតរបស់លោកយេស៊ូឡើយ។ បើយោងតាមសៀវភៅ *Encyclopedia Britannica* និពន្ធរួមគ្នាដោយបញ្ញាវ័ន្តគ្រិស្ទានជាង៥០០នាក់បានលើកឡើងថា៖ *កណ្ឌគម្ពីរយ៉ូហាន គឺច្បាស់ណាស់ហើយក៏ឥតមានសង្ស័យដែរថាជាការសរសេរក្លែង។*

ឯណេះវិញ គឺមានភាពខុសឆ្ងាយពី ដំណឹងល្អត្រៃកណ្ឌ។ នៅក្នុងកណ្ឌគម្ពីរនេះឯង ដែលលើកឡើងពី លក្ខណៈជាព្រះ និងបុរេអត្ថិភាព[6]របស់លោកយេស៊ូ ទាំងដែលលោកយេស៊ូមិនដែលទទួលស្គាល់ ការលើកឡើងបែបនេះក៏ដោយ។ កណ្ឌគម្ពីរនេះទើបតែត្រូវបានគេសរសេរឡើងក្នុងចន្លោះឆ្នាំ ១១០ ដល់ឆ្នាំ ១១៥ ដើមគ្រិស្តសករាជប៉ុណ្ណោះ។

គម្ពីរទាំងនេះត្រូវបានតាក់តែងឡើង នៅពេលក្រោយពីពួកសិស្សជំនាន់ដំបូងបានបែកបាក់គ្នាហើយបែងចែកចេញជានិកាយជាច្រើន។ យើងអាចនិយាយបានថា គម្ពីរទាំងនេះត្រូវបានសរសេរឡើងក្នុងគោលបំណង ឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងរបស់មនុស្សក្នុងនិកាយនីមួយៗ។ បើទោះជាឯកសារដើមត្រូវបានយកមកប្រើជាគោលដើម្បីសរសេរក៏ដោយ ក៏អ្នកនិពន្ធទាំងនោះហាក់ដូចជា មិនបានរក្សាការពារខ្លឹមសារដើម ធ្វើយ៉ាងណាចៀសឱ្យផុតពីការកែប្រែ, ការលុបចេញ ឬការថែមថយជាដើម ហើយអត្ថបទដើមនោះគឺ មានគោលដៅបម្រើឱ្យការយល់ឃើញនិងការចាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកសរសេរទៅវិញ។ រឿងនេះក៏ត្រូវទទួលស្គាល់ ពីសំណាក់អ្នកជំនាញក្នុងសាសនាគ្រិស្ត[7]ផងដែរ មិនតែប៉ុណ្ណោះ ព្រះគម្ពីរគួរអានក៏លើកឡើងពីបញ្ហារបស់គម្ពីរទាំងនេះតាំងពីជាង១៤០០ឆ្នាំមុនមកម្ល៉េះ។

---

[6] ភាពដែលលោកយេស៊ូមានវត្តមានមុនអ្វីៗទាំងអស់។

[7] យោងតាមសៀវភៅ *Encyclopedia Britannica* បានលើកឡើងថា៖ សំខាន់ណាស់ ដែលថាការកែប្រែដោយចេតនា រួមទាំងការបន្ថែម និងការបន្ថយចំពោះអត្ថបទទាំងមូល ពិតជាកើតមានមែន..(ភាគ ២ ទំព័រ ៥១៩ ដល់ ៥២១)។ នៅក្នុងចំណុចស្តីពី សេចក្តីផ្តើមនៃគម្ពីរកាតូលិក (ទំព័រ១៣) លើកឡើងថា អ្នកចម្លងគឺពិតជាបានសរសេរបន្ថែមរឿងរ៉ាវជាច្រើន ដែលមិនមែនជាផ្នែកនៃគម្ពីរដើមឡើយ ហើយជាលទ្ធផលនៃអត្ថបទទាំងនោះ យើងរាល់គ្នាទទួលប្រើនូវអត្ថបទដែលខូចទ្រង់ទ្រាយដើម ដែលត្រូវចតចម្លងហើយចែកចាយទាំងអស់។ ជាមួយគ្នានេះដែរ ក្នុងអារម្ភកថារបស់គម្ពីរបរិសុទ្ធ RSV (Revise Standard Version) ដែលចងក្រងដោយក្រុមបញ្ញវន្តគ្រិស្តបរិស័ទ ៣២ រូប និងពិគ្រោះយោបល់ចំនួន៥០រូបទៀត បានសរសេរថា៖ *គម្ពីរ King James Version មានការបាត់បង់ដែលធ្វើឱ្យខ្វះចន្លោះ ហើយកន្លែងខ្វះចន្លោះមានជាច្រើន សុទ្ធតែជាកន្លែងសំខាន់ៗ...។*

គួរចាប់អារម្មណ៍ផងដែរថា មិនមែនមានតែកណ្ឌគម្ពីរទាំង៤នេះទេ ដែលជាឯកសារដែលត្រូវបានសរសេរឡើង ប៉ុន្មានសតវត្សរ៍ក្រោយលោកយេស៊ូចាកចេញពីផែនដី។ ប៉ុន្តែនៅមានកណ្ឌគម្ពីរជាច្រើនទៀតដូចជាកណ្ឌគម្ពីរ **យ៉ាកុប**, **ពេត្រុស**, ដំណឹងល្អរបស់ **ថូម៉ាស**, **ភីលីព** និង **បាណាបាស**។ បើយើងពិចារណាពីកណ្ឌគម្ពីរ **ហេប្រឺ** គឺថាវាជាឯកសារដែល សរសេរជាភាសា **អារ៉ាម** ជាភាសាដែលលោកយេស៊ូនិយាយប្រចាំថ្ងៃ។ កណ្ឌគម្ពីរនេះត្រូវបានប្រើប្រាស់ដោយអ្នកស្រុក **ណាសារ៉ែត** ដែលជាអ្នកបដិសេធពីភាពជាព្រះរបស់លោកយេស៊ូ ហើយទទួលស្គាល់លោកថាជាព្យាការីដ៏ពិសិដ្ឋមួយរូប។ នៅសតវត្សរ៍ទី៤ដើមគ្រិស្តសករាជ កណ្ឌគម្ពីរ ម៉ាកុស, ម៉ាថាយ, លូកា និងយ៉ូហាន ត្រូវបានគេដាក់បញ្ចូលទៅក្នុងគម្ពីរបរិសុទ្ធទាំងមូល ហើយក្រុមជំនុំក៏ប្រកាសថា ឯកសារណាដែលនៅក្រៅពីនេះ គឺស្ថិតនៅក្រៅសាសនា។ យ៉ាងណាមិញ ការកែប្រែនៅតែបន្តកើតមាននៅលើអត្ថបទគម្ពីរទាំងនេះ បើទោះជាគេបានប្រកាសរួចហើយថានេះជា **បន្ទូលព្រះ** ក៏ដោយ។ ច្រើនឆ្នាំកន្លងផុតទៅ កណ្ឌគម្ពីរដដែលហ្នឹង បានលេចចេញនូវអត្ថបទខុសគ្នាពីអត្ថបទដើមទៀត តែមិនមានអ្នកសង្ស័យសោះឡើយ ថាមានការធ្វើឱ្យខូចខាតកណ្ឌគម្ពីរដើមទាំងនេះ។

ក្នុងចំណោមកត្តាជាច្រើន ដែលត្រូវបានគេយកមកពិចារណាឡើងវិញនៅពេលធ្វើការវិភាគទៅលើសុក្រឹត្យភាព នៃគោលការណ៍របស់កណ្ឌគម្ពីរទាំង៤ រួមទាំងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់សារទាំងអស់ដែលមកជាមួយគ្នា មានដូចតទៅ៖

1. គម្ពីរដើមដែលព្រះបានបើកបង្ហាញមកកាន់លោកយេស៊ូ ហើយក៏មានលើកឡើងក្នុងព្រះគម្ពីរគួរអាន[8] ដែលថាគម្ពីរដើមនោះមិនមានវត្តមានទៀតទេសព្វថ្ងៃនេះ[9]។
2. កំណត់ត្រាដំបូងអំពីពាក្យសម្ដីរបស់លោកយេស៊ូ ត្រូវបានកត់ត្រាឡើងក្នុងរយៈពេលខ្លីប៉ុណ្ណោះក្រោយការឡើងទៅលើមេឃរបស់លោកយេស៊ូ ហើយក៏ត្រូវបានបាត់បង់ទៅវិញ។
3. កណ្ឌគម្ពីរត្រូវបានសរសេរឡើងនៅចន្លោះឆ្នាំ ៧០ ដល់ឆ្នាំ១១៥ ដើមគ្រិស្តសករាជ មានន័យថាច្រើនទសវត្សរ៍ក្រោយពេលលោកយេស៊ូចាកចេញពីផែនដី ហើយសរសេរដោយពឹងផ្អែកលើអត្ថបទដើមដែលបាត់បង់ទៅ ហើយបន្សល់ទុកនូវការរៀបចំខ្លឹមសារដោយគ្មានការគិតគូរឱ្យស្របគ្នាទៅនឹងអត្ថបទដើម។
4. មិនមានអ្នកសរសេរគម្ពីរណាម្នាក់បានឃើញ ឬបានឮលោកយេស៊ូផ្ទាល់ទេ ដូច្នេះហើយពួកគេមិនមែនជាសាក្សីដែលឃើញហេតុការណ៍ផ្ទាល់នោះទេ។
5. កណ្ឌគម្ពីរសរសេរឡើងជាភាសាក្រិក ខណៈដែលលោកយេស៊ូនិយាយភាសាអារ៉ាម។
6. គម្ពីរបច្ចុប្បន្ននេះ រួមទាំងសំបុត្រភាគច្រើន មិនត្រូវគេរើសយកមកប្រើជាផ្លូវការទេ រហូតមកដល់សតវត្សរ៍ទី ៤ ដើមគ្រិស្តសករាជ នៅពេលដែលការរកដំណោះស្រាយរបស់ក្រុមប្រឹក្សាក្រុង **នីសៀ** សម្រេចថាដាក់ឱ្យប្រើប្រាស់ក្នុង

---

[8] ព្រះមានបន្ទូលអំពីលោកយេស៊ូថា៖ *ហើយយើងបានប្រទានឱ្យគេនូវគម្ពីរដំណឹងល្អ (Gospel) ដែលមានការចង្អុលបង្ហាញ និងពន្លឺ។* (គួរអាន ៥:៤៦)

[9] *ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា នៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល កាលណាគេប្រកាសដំណឹងល្អ គេក៏នឹងតំណាលអំពីកិច្ចការដែលនាងបានធ្វើនេះដែរ ដើម្បីរំឭកអំពីនាង។* (ម៉ាកុស ១៤:៩ និង ម៉ាថាយ ២៦:១៣) ដូច្នេះអ្នកណាដែលចង់សិក្សាពីលក្ខណៈពិតនិងការបង្រៀនរបស់លោកយេស៊ូគួរតែអានព្រះគម្ពីរគួរអាន។

ឆ្នាំ ៣២៥ ដើមគ្រិស្តសករាជ។ មុនការសម្រេចនេះ គម្ពីរមិនទាន់ត្រូវបានគេដាក់ឱ្យមានក្រឹត្យក្រមចំពោះអ្នកសរសេរឡើយ ហើយត្រូវបានកែប្រែដោយពួកអ្នកសរសេរដែលមកពីនិកាយផ្សេងៗ ដើម្បីបំពេញតាមចំណាប់អារម្មណ៍និងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។ រហូតមកទល់បច្ចុប្បន្ននេះ ការរុករានចំពោះអត្ថបទគម្ពីរនៅតែមានជាធម្មតា។

7. ផ្នែកដែលទូលំទូលាយជាងគេនៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី គឺជាការតាក់តែងរបស់សាវ័ក **ប៉ូល** និងសិស្សរបស់គាត់។ សាវ័កប៉ូលក៏ជាអ្នកមិនដែលបានឃើញ ឬបានឮលោកយេស៊ូផ្ទាល់ដែរ។ គាត់ក៏ធ្លាប់ជាមនុស្សម្នាក់ដែលជាអ្នកប្រឆាំងដ៏លេចធ្លោម្នាក់ចំពោះកិច្ចការរបស់លោកយេស៊ូ។ មិនតែប៉ុណ្ណោះគាត់ធ្លាប់សម្លាប់ និងចាប់ចងអ្នកតាមលោកយេស៊ូជាច្រើននាក់ផង(កិច្ចការ ៨:៣ , ៩:១-២)។ ក្រោយមកទៀតគាត់បានបង្ខំឱ្យពួកអ្នកដើរតាមទាំងអស់ សារភាពកុហកប្រឆាំងនឹងលោកយេស៊ូ(កិច្ចការ ២៦:១១)។ ប៉ុន្តែនៅពេលលោក**ស៊ូល** (ក្រោយមកហៅថាប៉ូលវិញ) បានកែប្រែខ្លួន គាត់ព្យាយាមចូលរួមនឹងពួកសាវ័ក ប៉ុន្តែពួកសាវ័កទាំងអស់ខ្លាចគាត់គ្រប់គ្នា ហើយមិនមានអ្នកជឿថាគាត់ជាសាវ័កទេ។ ប៉ុន្តែពេលនោះលោក**បាណាបាស** បានទទួលគាត់ ហើយនាំគាត់ទៅជួបពួកសាវ័ក។(កិច្ចការ ៩:២៦-២៧) រឿងនេះបានកើតឡើងបន្ទាប់ពីលោកប៉ូលបានអះអាងថា លោកយេស៊ូបានមកជួបគាត់ ហើយនិយាយជាមួយគាត់នៅតាមផ្លូវទៅក្រុង**ដាម៉ាស**។ គាត់ធ្វើសាក្សីឱ្យខ្លួនគាត់[10] ដោយគ្មាន

---

[10] គ្មានសាក្សីណាបានឃើញផ្ទាល់ភ្នែកចំពោះការអះអាងរបស់លោកប៉ូលឡើយ។ បើយោងតាមគម្ពីរបរិសុទ្ធ ការធ្វើសាក្សីឱ្យខ្លួនឯង នោះគឺមិនយកជាបានការឡើយ៖ *ប្រសិនបើខ្ញុំធ្វើជាបន្ទាល់ឱ្យខ្លួនខ្ញុំផ្ទាល់សក្ខីភាពរបស់ខ្ញុំមិនពិតទេ។*(យ៉ូហាន ៥:៣១) បន្ថែមពីលើនេះ មានការនិទានខុសៗពីគ្នាមួយចំនួនទៀតដូចជា នៅក្នុងកណ្ឌគម្ពីរកិច្ចការ ៩:៧ លើកឡើងថា៖ *រីឯអស់អ្នកដែលធ្វើដំណើរជាមួយលោកសូលនាំគ្នាឈប់ គេនៅស្ងៀម រកនិយាយអ្វីមិនកើត ព្រោះគេបានឮសំឡេង តែពុំឃើញមាននរណាឡើយ។* ប៉ុន្តែនៅកណ្ឌគម្ពីរកិច្ចការ ដដែលត្រង់ ២២:៩ លើកឡើងថា៖ *រីឯអស់អ្នកដែលធ្វើដំណើរជាមួយខ្ញុំ ក៏បានឃើញពន្លឺនោះដែរ តែមិនបានឮសំឡេងនិយាយមកកាន់ខ្ញុំទេ។* ដោយ

ភស្តុតាងឱ្យឃើញជាក់ច្បាស់ឡើយចំពោះការអះអាងរបស់គាត់។ (កិច្ចការ ៩:៣-៨) គួរឱ្យភ្ញាក់ផ្អើលដែរ គាត់ក៏ស្រាប់តែក្លាយជា អ្នកនាំពាក្យក្នុងនាមលោកយេស៊ូ ហើយអះអាងថា គាត់ត្រូវបានលោកយេស៊ូចាត់ឱ្យ ផ្សព្វផ្សាយការបង្រៀនទៅកាន់ពិភពលោក។(កិច្ចការ ៩:៣-៦)[11] លោកប៉ូលក៏បានចោទប្រកាន់ចំពោះអ្នកដែលមិនជឿថាគាត់ជាសាវ័ក ថានឹងត្រូវវង្វេងពីជំនឿ។ (១ធីម៉ូថេ ៦:២០-២១) លោកប៉ូលនិយាយពីលោកបាណាបាសដែលតែងតែប្រព្រឹត្តល្អនឹងគាត់រហូតមកថា ត្រូវគេអូសទាញឱ្យលាក់ពុត។(កាឡាទី ២:១៣) លោកប៉ូលថែមទាំងផ្តល់សិទ្ធិឱ្យខ្លួនឯងធ្វើការបង្រៀន ទាំងដែលសេចក្តីបង្រៀននោះខុសពីសេចក្តីបង្រៀនរបស់លោកយេស៊ូ ហើយទាំងខុសនឹងច្បាប់ដែលលោកយេស៊ូមកបំពេញធ្វើផង[12]។ (កិច្ចការ ២១:២០ និង រ៉ូម ៧:១៣)

---

ការអះអាងបែបនេះលោកប៉ូលសម្រេចបានអ្វីដែលលោកចង់បាន ទាំងការពិតនោះលោកមិនសម្រេចបានឡើយ។

[11] បើយោងតាមកណ្ឌគម្ពីរ ១យ៉ូហាន ៤:១ លើកឡើងថា៖ *កូនចៅជាទីស្រឡាញ់អើយ សូមកុំជឿអស់អ្នកដែលថា ខ្លួនមានព្រះវិញ្ញាណគង់នៅជាមួយនោះឡើយ ត្រូវល្បងលគេមើល ដើម្បីឱ្យដឹងថាវិញ្ញាណនេះមកពីព្រះជាម្ចាស់មែនឬយ៉ាងណា ដ្បិតមានព្យាការីក្លែងក្លាយជាច្រើនបានមកក្នុងលោកនេះ។* លោកប៉ូលបានសារភាពថាខ្លួនបានភូតកុហកពិតមែននៅក្នុងការបង្រៀនរបស់គាត់៖ *មួយវិញទៀត បើការកុហករបស់ខ្ញុំធ្វើឱ្យព្រះហឫទ័យសច្ចៈរបស់ព្រះជាម្ចាស់ លេចចេញមកយ៉ាងច្បាស់ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គមែននោះ ហេតុដូចម្ដេចបានជាខ្ញុំត្រូវតែទទួលទោស ក្នុងនាមជាមនុស្សបាបទៅវិញ?* (រ៉ូម ៣:៧)

[12] កណ្ឌគម្ពីរ ម៉ាថាយ ៥:១៧-១៨ លើកឡើងថា៖ *សុំកុំនឹកស្មានថាខ្ញុំមកលុបបំបាត់គម្ពីរវិន័យ ឬគម្ពីរព្យាការីចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេ គឺខ្ញុំមកធ្វើឱ្យគម្ពីរមានអត្ថន័យពេញលក្ខណៈទៅវិញ។ ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាបានដឹងច្បាស់ថា ដរាបណាផ្ទៃមេឃ និងផែនដីនៅស្ថិតស្ថេរដរាបនោះ គ្មានក្បៀស ឬបន្តក់ណាមួយក្នុងគម្ពីរវិន័យ(សម្ពន្ធមេត្រីចាស់)ត្រូវលុបបាត់ឡើយ គឺគម្ពីរទាំងមូលនឹងនៅស្ថិតស្ថេររហូតដល់ទីបំផុត។* លោកប៉ូលខំប្រមូលអ្នកដើរតាមខ្លួនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន បើទោះជាមធ្យោបាយនោះប្រឆាំងនឹងលោកយេស៊ូ ឬប្រឆាំងនឹងការបង្រៀនរបស់លោកយេស៊ូក៏ដោយ។ ក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៩:១៩-២៣ លោកប៉ូលបានសារភាពពីទង្វើគួរឱ្យស្អប់ខ្ពើមរបស់គាត់គឺការភូតកុហក និងការបោកប្រាស់ ធ្វើយ៉ាងណាឱ្យតែបានសម្រេចបំណងគាត់៖

យើងក៏បានឃើញទៀតដែរថា៖ *លោកប៉ូលមានបំណងទៅជួបប្រជាជន ប៉ុន្តែពួកសិស្សបានឃាត់លោកមិនឱ្យទៅទេ។*(កិច្ចការ ១៩:៣០) ហើយគាត់ក៏បានប្រកាសដែរថា៖ *បងប្អូននៅស្រុកអាស៊ី បានបោះបង់ខ្ញុំចោលទាំងអស់គ្នា។* (២ធីម៉ូថេ ១:១៥) ហើយ៖ *គ្មានបងប្អូនណាម្នាក់មកជួយគាំទ្រខ្ញុំទេ គឺគេបោះបង់ចោលខ្ញុំទាំងអស់គ្នា។* (២ធីម៉ូថេ ៤:១៦)

8. គម្ពីរបរិសុទ្ធសរសេរដោយដៃ ដែលមានអាយុកាលចំណាស់បំផុតដែលយើងឃើញមាននោះរួមមាន៖ *Codexes, Vaticanus, Sinaiticus* ហើយនិង *Alexandrinus* ដែលសុទ្ធសឹងតែមានកាលបរិច្ឆេទចន្លោះសតវត្សរ៍ទី៤ដល់ទី៥នៃគ្រិស្តសករាជ។
9. មានភាពខុសគ្នាជាច្រើនរវាងគម្ពីរសរសេរដោយដៃក្នុងសតវត្សរ៍ទី៤ និងគម្ពីរសរសេរដោយដៃក្នុងសតវត្សរ៍ទី៥[13]។

---

*ព្រោះទោះជាខ្ញុំគ្មានកាតព្វកិច្ចចំពោះអ្នកណាក៏ដោយ ខ្ញុំបានធ្វើឲ្យខ្លួនទៅជាខ្ញុំបម្រើរបស់មនុស្សទាំងអស់ ដើម្បីឲ្យខ្ញុំបានមនុស្សច្រើនបំផុត។ ដូច្នេះ ចំពោះជនជាតិយូដា ខ្ញុំបានធ្វើដូចជនជាតិយូដា ដើម្បីខ្ញុំអាចបានជនជាតិយូដា។ ចំពោះអ្នកដែលនៅក្រោមច្បាប់ ខ្ញុំបានធ្វើដូចអ្នកនៅក្រោមច្បាប់ ទោះជាខ្ញុំមិននៅក្រោមច្បាប់ក៏ដោយ ដើម្បីខ្ញុំអាចបានអ្នកដែលនៅក្រោមច្បាប់។ ចំពោះអ្នកដែលមិននៅក្រោមច្បាប់ ខ្ញុំបានធ្វើដូចអ្នកដែលមិននៅក្រោមច្បាប់ ដើម្បីខ្ញុំអាចបានអ្នកដែលមិននៅក្រោមច្បាប់ ទោះជានៅចំពោះព្រះខ្ញុំមិនមែនជាអ្នកដែលមិននៅក្រោមច្បាប់ក៏ដោយ តែជាអ្នកនៅក្រោមច្បាប់ចំពោះគ្រិស្ត។ ចំពោះអ្នកដែលខ្សោយ ខ្ញុំបានធ្វើដូចអ្នកដែលខ្សោយ ដើម្បីខ្ញុំអាចបានអ្នកដែលខ្សោយ។ ខ្ញុំបានធ្វើដូចមនុស្សគ្រប់ប្រភេទ ដើម្បីខ្ញុំអាចសង្គ្រោះពួកគេខ្លះតាមគ្រប់មធ្យោបាយទាំងអស់។ ប៉ុន្តែខ្ញុំធ្វើអ្វីៗទាំងអស់ដើម្បីដំណឹងល្អ ដើម្បីឲ្យខ្ញុំអាចប្រាប់ដល់អ្នកឯទៀត។*

[13] អ្នកសិក្សាព្រះគម្ពីរខ្លះចង្អុលបង្ហាញថា មានគម្ពីរសរសេរដោយដៃរាប់ពាន់ច្បាប់។ ក៏ប៉ុន្តែតើអ្វីដែលជាគុណតម្លៃពិតនៃគម្ពីរសរសេរដោយដៃទាំងនេះ? បើក្នុងចំណោមរាប់ពាន់ច្បាប់យើងមិនអាចរកបានគម្ពីរពីរច្បាប់ដែលដូចគ្នាផង? យោងទៅតាមការបកប្រែអន្តរជាតិនៃគម្ពីរសញ្ញាថ្មី International Translation of the New Testament បានលើកឡើងថា៖ *គម្ពីរបរិសុទ្ធគ្រប់ប្រភេទដែលបានមកដល់ពួកយើងគឺមិនស្រដៀងគ្នាសោះ។*

10. គម្ពីរបរិសុទ្ធទាំងមូល រួមទាំងសំបុត្រនានាផងនោះ មានភាពមិនប្រក្រតី និងមានបដិវាទភាព[14]ជាច្រើន។ ហើយរឿងសំខាន់មួយទៀតនោះ ក្នុងចំណោមអ្នកសិក្សាគម្ពីរបរិសុទ្ធ គឺមិនទាន់មានភាពប្រាកដប្រជានៅឡើយទេ ថាតើនរណាជាអ្នកសរសេរកណ្ឌគម្ពីរទាំងនោះ។

ចំណុចជាក់ស្តែងដែលលើកមកទាំងអម្បាលម៉ាននេះ គឺជាភស្តុតាងបញ្ជាក់ថា ព្រះគម្ពីរពិតប្រាកដដែលព្រះជាម្ចាស់បានប្រទានមកលោកយេស៊ូ គឺមិនបានរក្សាសភាពដើមទេ នៅពេលគម្ពីរនេះបានមកដល់ពួកយើង។ យ៉ាងនេះហើយ យើងអាចបញ្ជាក់បានថាសៀវភៅដំណឹងល្អទាំង៤រួមទាំងគម្ពីរបរិសុទ្ធសព្វថ្ងៃនេះ ហើយនិងសំបុត្រនានាដែលមកជាមួយគ្នា មិនអាចចាត់ទុកថាស្រដៀងគ្នា ឬស្មើនឹងព្រះគម្ពីរដែលបានព្រះបានប្រទានដល់លោកយេស៊ូនោះទេ។ ដើម្បីជាភស្តុតាងលើការអះអាងនេះ យើងក៏សូមលើកមកបង្ហាញនូវព័ត៌មានបន្ថែមទៀតដូចមានខាងក្រោម៖

គម្ពីរសម្ពន្ធមេត្រីថ្មី ដែលជាគោលលទ្ធិរបស់គ្រិស្តបរិស័ទសម័យនេះ បានឆ្លងកាត់ការផ្លាស់ប្តូរកែប្រែ ស្ទើរតែគ្រប់កំណែនៃការចេញផ្សាយគឺខុសៗគ្នា។ ការកែប្រែខ្លះ ដែលគេកំពុងអនុវត្តដល់សព្វថ្ងៃនេះ គឺការកែប្រែគោលការណ៍គ្រឹះសំខាន់ៗ ដែលការណ៍នេះគឺប្រឆាំងនឹងគោលការណ៍គ្រឹះរបស់គ្រិស្តសាសនា។ ជាឧទាហរណ៍ មានសក្ខីកម្មតែ២ប៉ុណ្ណោះដែលបញ្ជាក់ពីការឡើងលើមេឃរបស់លោកយេស៊ូ គឺនៅក្នុងកណ្ឌគម្ពីរម៉ាកុស និងលូកា ប៉ុន្តែបច្ចុប្បន្ននេះត្រូវបានគេលុបចេញពី គម្ពីរបរិសុទ្ធ RSV (Revise Standard Version) ឆ្នាំ១៩៥២។ ត្រង់វគ្គនេះ មានផ្ទុកនូវភស្តុតាងដែលបញ្ជាក់ពីដំណើរឡើងលើមេឃរបស់លោកយេស៊ូថា៖ *ក្រោយពីលោកម្ចាស់យេស៊ូបាន*

---

[14] បដិវាទភាព គឺភាពមិនចុះសម្រុងគ្នា ភាពខ្វែងគ្នា។ កំហុសជាច្រើនដែលមាននៅក្នុងព្រះគម្ពីរបាននាំឱ្យលោក Robert Kehl Zeller និយាយនៅក្នុងសៀវភៅ Authenticity of the Holy Bible ថាគ្មានគម្ពីរណាដែលទទួលរងនូវការផ្លាស់ប្តូរ,មានកំហុសនិងមានការរុករានជាច្រើនដូចជាគម្ពីរបរិសុទ្ធទេ។ នេះគឺផ្ទុយស្រឡះពីការលើកឡើងរបស់លោក William Muir និង Laura Vaglieri នៅពេលពួកគេនិយាយពីព្រះគម្ពីរគួរអានគឺគ្មានបដិវាទភាពឡើយ។ (សូមមើលកំណត់សម្គាល់លេខ ១៨និង ១៩)

*មានប្រសាសន៍ទៅកាន់ពួកគាត់ហើយ លោកក៏បានត្រូវលើកឡើងទៅស្ថានសួគ៌ ហើយបានអង្គុយនៅខាងស្ដាំព្រះ។*(ម៉ាកុស ១៦:១៩) *កាលដែលលោកកំពុងឱ្យពរលោកចាកចេញពីពួកគាត់ ហើយព្រះយកលោកឡើងទៅស្ថានសួគ៌។*(លូកា២៤:៥១) ខដែលបានរៀបរាប់ខាងលើពី ម៉ាកុស ១៦:១៩ ត្រូវបានលុបចេញរួមជាមួយនឹងខផ្សេងទៀតមួយចំនួន ដូចជាលូកា ២៤:៥១ ពាក្យថា *បានលើកឡើងទៅស្ថានសួគ៌* ត្រូវបានដកចេញ។

នៅក្នុងកណ្ឌគម្ពីរម៉ាថាយ ១៦:២៧-២៨ សរសេរថា៖ *ព្រោះកូនមនុស្សត្រូវមកជាមួយនឹងបណ្ដាទេវតារបស់លោក ដោយមានសិរីរុងរឿងពីបិតារបស់លោក ហើយនឹងសងដល់គ្រប់គ្នាតាមការប្រព្រឹត្តរបស់ពួកគេរៀងខ្លួន។ ខ្ញុំប្រាប់អ្នករាល់គ្នាការពិតថា អ្នកខ្លះដែលកំពុងឈរនៅទីនេះ នឹងមិនស្លាប់ឡើយ ទាល់តែបានឃើញកូនមនុស្សមកជាស្ដេចជាមុនសិន។* ក្នុងបទទំនាយនេះ វាមិនអាចក្លាយជាការពិតឡើយ[15] វាគឺជាការប្រតិដ្ឋឡើងលាបពណ៌ទៅលើលោកយេស៊ូដែលជាព្យាការីពិតរបស់ព្រះ ដែលបទទំនាយរបស់លោកមិនអាចខុសឆ្គងនោះឡើយ។

កណ្ឌគម្ពីរម៉ាថាយ សរសេរខ្វែងគ្នាដោយខ្លួនឯងនៅលើទំព័រតែមួយអំពីលោក **ពេត្រុស** រៀបរាប់ដោយសង្ខេប៖ *លោកយេស៊ូមានប្រសាសន៍តបទៅគាត់ថា៖ ស៊ីម៉ូន កូនយ៉ូណាស! អ្នកមានសុភមង្គលហើយ! ពីព្រោះនេះមិនមែនមនុស្សទេ ដែលបានបើកសម្ដែងឱ្យអ្នកដឹង... អ្នកគឺពេត្រុស... ខ្ញុំនឹងឱ្យកូនសោនៃរាជាណាចក្រស្ថានសួគ៌ដល់អ្នក ហើយអ្វីដែលអ្នកចងនៅផែនដី នោះជាអ្វីដែលត្រូវបានចងនៅស្ថានសួគ៌ ហើយអ្វីដែលអ្នកស្រាយនៅផែនដី នោះជាអ្វីដែលត្រូវបានស្រាយនៅស្ថានសួគ៌។* (ម៉ាថាយ ១៦:១៧-១៩) ចំណែកឯនៅក្នុង ម៉ាថាយ ១៦:២៣ វិញហាក់ដូចជាផ្ទុយស្រឡះពីអ្វីដែលលើកឡើងខាងលើ៖ *ប៉ុន្តែលោកបែរចេញ រួចប្រាប់ពេត្រុសថា៖ នែ!*

---

[15] ដ្បិតអ្នកដែលឈរជាមួយលោកយេស៊ូនៅពេលនោះពុំមាននរណាមានជីវិតដល់សព្វថ្ងៃទេ ធ្វើម្ដេចពួកគេអាចរស់រហូតដល់ថ្ងៃជំនុំជម្រះនោះ?

*សាតាំង ចូរទៅឆ្ងាយពីខ្ញុំទៅ! អ្នកកំពុងដាក់ឧបសគ្គដែលអាចនាំឱ្យខ្ញុំជំពប់ដួល ពីព្រោះអ្នកមិនគិតតាមគំនិតរបស់ព្រះទេ តែគិតតាមគំនិតរបស់មនុស្សវិញ។*

ទាក់ទងនឹងព្រឹត្តិការណ៍នៃការចងឆ្កាងលោកយេស៊ូវិញ កណ្ឌគម្ពីរម៉ាថាយ ២៧:៤៤ សរសេរថា៖ *សូម្បីតែចោរប្លន់ដែលបានត្រូវព្យួរជាមួយនឹងលោក ក៏ចាប់ផ្ដើមតិះដៀលលោកបែបដូច្នេះដែរ។* ត្រង់នេះនិយាយថាមានចោរ២នាក់បានតិះដៀលលោកជាមួយគ្នា។ យ៉ាងណាមិញ នៅក្នុងកណ្ឌគម្ពីរលូកា ២៣:៣៩-៤០ សរសេរថា៖ *ប៉ុន្តែអ្នកប្រព្រឹត្តអំពើអាក្រក់ម្នាក់ដែលបានត្រូវព្យួរ តាំងនិយាយប្រមាថលោកថា៖ ឯងជាគ្រិស្តមែនទេ? ចូរសង្គ្រោះខ្លួនឯងនិងយើងផង។ អ្នកប្រព្រឹត្តអំពើអាក្រក់ម្នាក់ទៀតបានស្តីបន្ទោសអ្នកនោះថា តើអ្នកមិនកោតខ្លាចព្រះសោះឬ? ឥឡូវនេះអ្នកបានទទួលទោសដូចគ្នាដែរ។* ឧទាហរណ៍នេះឱ្យយើងឃើញថា ចោរទាំង២នេះមិនបានរួមសកម្មភាពជាមួយគ្នាឡើយ ផ្ទុយទៅវិញគេទាំងពីរប្រឆាំងនឹងគ្នាផង។

ការផ្លាស់ប្ដូរ, ការកែប្រែ និងការខ្វែងគ្នា មិនមែនមានតែនៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មីនោះទេ តែក៏មានក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ដែរ[16]។ ជាឧទាហរណ៍អំពីការខ្វែងគ្នានេះ នៅក្នុងកណ្ឌគម្ពីរ ២ពង្សាវតារក្សត្រ ៨:២៦ គេប្រាប់ថា៖ *ព្រះបាទ **អ័ហាស៊ីយ៉ា** ឡើងសោយរាជ្យនៅពេលទ្រង់មានជន្មាយុ**ម្ភៃពីរ**វស្សា*។ ដែលខុសពីកណ្ឌគម្ពីរ ២របាក្សត្រ ២២:២ ដែលសរសេរថា៖ *កាលព្រះបាទអ័ហាស៊ីយ៉ាឡើងសោយរាជ្យ ទ្រង់មាន*

---

16 ក្រុមប្រឹក្សាចម្រុះនិកាយនៃបុរី**វ៉ាទីកង់**ទី២(ឆ្នាំ១៩៦២ដល់៦៥)បានទទួលស្គាល់នូវភាពមិនប្រក្រតីនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ បានលើកឡើងថា៖ *ឥឡូវគម្ពីរសម្ពន្ធមេត្រីចាស់ គឺស្របតាមស្ថានភាពរបស់មនុស្សជាតិជំនាន់មុននៃការសង្គ្រោះរបស់ព្រះគ្រិស្ត ដែលលោកបើកបង្ហាញដល់មនុស្សទាំងអស់នូវចំណេះដឹងអំពីព្រះនិងមនុស្ស រួមទាំងរបៀបដែលព្រះមានយុត្តិធម៌និងមេត្តាករុណាទាក់ទងនឹងមនុស្ស។ គម្ពីរទាំងនេះក៏មានផ្ទុកនូវរឿងរ៉ាវខ្លះដែលមិនពេញលេញនិងគ្រាន់តែប្រើជាបណ្ដោះអាសន្ន...។* ក្នុងសៀវភៅ *Providentissimus Deus* ដែលសិក្សាអំពីគម្ពីរបរិសុទ្ធចេញផ្សាយដោយសម្ដេច **ប៉ាប លីអូ ទី៨** កាលពីថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ១៨៩៣ សរសេរថា៖ *វាប្រាកដណាស់ថាអ្នកនិពន្ធចម្លងបានធ្វើឱ្យមានកំហុសនៅក្នុងអត្ថបទនៃគម្ពីរ។*

*ព្រះជន្ម**សែសិបពីរ**ព្រះវស្សា...*[17]។ យើងនៅតែឃើញមានចំនុចខ្វែងគ្នាបន្ថែមទៀត ដូចជា នៅក្នុងកណ្ឌគម្ពីរ ២ពង្សាវតារក្សត្រ ២៤:៨ សរសេរថា៖ *កាលព្រះបាទ **យ៉ូយ៉ាគីន** ឡើងសោយរាជ្យ ទ្រង់មានជន្មាយុ**ដប់ប្រាំបី**ព្រះវស្សា ហើយសោយរាជ្យបានបីខែនៅក្រុងយេរូសាឡឹម។* បើប្រៀបធៀបនឹងកណ្ឌគម្ពីរ២របាក្សត្រ ៣៦:៩ ដែលបានសរសេរថា៖ *កាលព្រះបាទយ៉ូយ៉ាគីនឡើងសោយរាជ្យ ស្តេចមានជន្មាយុ**ប្រាំបី**ព្រះវស្សា ហើយសោយរាជ្យបានបីខែនៅក្រុងយេរូសាឡឹម។*

ដោយឡែកកណ្ឌគម្ពីរ ២សាំយូអែល ៦:២៣ សរសេរថា៖ *ព្រះនាង**មិកាល់**ជាបុត្រីរបស់ព្រះបាទសូល**គ្មានបុត្រឡើយ** រហូតដល់ស្លាប់។* ត្រង់នេះបញ្ច្រាស់នឹងកណ្ឌគម្ពីរ ២សាំយូអែល ២១:៨ ដែលថា៖ ...*ព្រះរាជាក៏ឱ្យគេចាប់**កូនប្រុសទាំងប្រាំរបស់នាងមិកាល់** ជាបុត្រីរបស់ព្រះបាទ**សូល** គឺជាកូនដែលនាងបានបង្កើតជូនលោក **អទ្រីអែល** ជាកូនរបស់លោក **បាស៊ីឡៃ** ជាអ្នកស្រុក**មហូឡា**។* នៅក្នុងគម្ពីរបរិសុទ្ធជាភាសាអង់គ្លេស New Standard American Version ឆ្នាំ១៩៧៣ ឈ្មោះ **មិកាល់**(Michal) ដែលធ្លាប់មានទាំងនៅក្នុងគម្ពីរ KJV និងសេចក្តីបកប្រែពិភពលោកថ្មីរបស់ពួកសាក្សីព្រះយេហូវ៉ា ត្រូវបានគេជំនួសដោយឈ្មោះ **មិរ៉ាប**(Mirab) វិញដើម្បីចៀសវាងពីការខ្វែងគ្នា។ ចំពោះបញ្ហានៃការមើលឃើញព្រះវិញ គឺមានទាំងនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មី។ កណ្ឌគម្ពីរយ៉ូហាន ១:១៨ យើងឃើញថា៖ *គ្មានមនុស្សណាម្នាក់ធ្លាប់ឃើញព្រះម្តងណាឡើយ..។* ត្រង់នេះក៏មានលើកឡើងដូចគ្នាក្នុង ១យ៉ូហាន ៤:១២ ដែរ។ យ៉ាងណាមិញកណ្ឌគម្ពីរលោកុប្បត្តិ ៣២:៣០ និយាយរឿងខុសគ្នាពីនេះ៖ *លោកយ៉ាកុបដាក់ឈ្មោះកន្លែងនោះថា **ពេនីអែល** ដ្បិតលោកពោលថា ខ្ញុំបានឃើញព្រះភក្ត្ររបស់ព្រះជាម្ចាស់ផ្ទាល់នឹងភ្នែក តែខ្ញុំនៅមានជីវិតនៅឡើយ។* គួរឱ្យចម្លែកដែរ ក្នុងកណ្ឌគម្ពីរនិក្ខមនំ ៣៣:១១ ក៏និយាយដែរថា៖

---

[17] នេះជាការបកប្រែរបស់ព្រះគម្ពីរបរិសុទ្ធ(១៩៥៤)ជាភាសាខ្មែរ។ គម្ពីរបកប្រែមួយចំនួនបានរក្សាតួលេខ៨២ឆ្នាំ តែការប្រែសម្រួលខ្លះបានផ្លាស់ប្តូរជា ២០ឆ្នាំ តែទោះជាយ៉ាងណាក៏នៅតែខ្វែងគ្នាជាមួយនឹង ២ពង្សាវតារក្សត្រ ៨:២៦ ដដែល។

*ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោក**ម៉ូសេ**ទល់មុខគ្នា ហាក់ដូចជាមនុស្សម្នាក់សន្ទនាជាមួយមិត្តសម្លាញ់របស់ខ្លួន។* ហើយនៅក្នុងនិក្ខមនំ ២៤:៩-១១ សរសេរថា៖ *លោក**ម៉ូសេ**ឡើងទៅលើភ្នំជាមួយលោក**អើរ៉ុន**... អស់លោកទាំងនោះបានឃើញព្រះជាម្ចាស់ ហើយនាំគ្នាធ្វើពិធីជប់លៀង។*

ក្នុងកណ្ឌគម្ពីរយ៉ូហាន ៣:១៣ យើងឃើញថា៖ *ម្យ៉ាងទៀត គ្មានមនុស្សណាម្នាក់ធ្លាប់ឡើងទៅស្ថានសួគ៌ឡើយ មានតែលោកដែលបានចុះពីស្ថានសួគ៌ប៉ុណ្ណោះ គឺកូនមនុស្ស។* ដែលត្រង់នេះបញ្ច្រាស់នឹងកណ្ឌគម្ពីរលោកុប្បត្តិ ៥:២៤ ដែលថា៖ *លោក**ហេណុក**ដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ បន្ទាប់មកគេលែងឃើញគាត់នៅលើផែនដីទៀតហើយ ព្រោះព្រះជាម្ចាស់បានលើកគាត់ឡើងទៅ។* ក៏មាននៅក្នុង ២ពង្សាវតារក្សត្រ ២:១ ដែលថា៖ *នៅគ្រាដែលព្រះអម្ចាស់ឱ្យខ្យល់កួចលោក**អេលីយ៉ា**ឡើងទៅស្ថានបរមសុខនោះ...។* ដូច្នេះ តើមានតែលោកយេស៊ូទេដែលបានឡើងទៅស្ថានសួគ៌ ឬមួយក៏លោកហេណុក និងអេលីយ៉ាក៏បានឡើងទៅស្ថានសួគ៌ដែរ? លើសពីនេះទៅទៀត គម្ពីរសម្ពន្ធមេត្រីចាស់មានការកែប្រែជាច្រើនកំណែ ដែលអ្នកសរសេរមួយចំនួនធំមិនបានស្គាល់ អ្នកនិពន្ធគម្ពីរដើម។ ករណីដូចគ្នានេះដែរ បើយោងតាមគម្ពីរបកប្រែជាភាសាបារាំងបានសរសេរថា៖ *អ្នកសរសេរនិងអ្នកកែសម្រួលគម្ពីរភាគច្រើន ដែលពួកគេត្រូវបានគេសន្មតថាជាអ្នកតំណាងរបស់ព្រះ អ្នកសន្មតនោះគឺជាប្រជាជនរបស់ពួកគេ ហើយពួកគេក៏មិនត្រូវបានគេស្គាល់ថាជានរណាដែរ។*

ជំហររបស់សាសនាអ៊ីស្លាមទាក់ទងនឹងគម្ពីរបរិសុទ្ធ គឺប្រកាន់យកនូវភាពយុត្តិធម៌ និងអព្យាក្រឹត្យ។ យើងយល់ឃើញថា គម្ពីរបរិសុទ្ធ ពិតជាមានផ្ទុកនូវសេចក្ដីពិតមួយចំនួនដែរ ទន្ទឹមគ្នានេះ រឿងខុសឆ្គងក៏មានដាក់បញ្ចូលទៅក្នុងអត្ថបទដើមដ៏ពិសិដ្ឋដែរ។ ក្បួនខ្នាតដែលសាសនាអ៊ីស្លាមប្រើសម្រាប់បែងចែករវាង សេចក្ដីពិត និងការខុសឆ្គងនោះ គឺព្រះគម្ពីរ**គួរអាន** និងសេចក្ដីបង្រៀនរបស់ព្យាការី**មូហាំម៉ាត់**។ និយាយឱ្យងាយទៅគឺ ខ្លឹមសាររបស់គម្ពីរបរិសុទ្ធដែលមានភាពស្របគ្នានឹងព្រះគម្ពីរគួរអាន និងគម្ពីរ**ស៊ុណ្ណះ** គឺយើងទទួលយក ហើយត្រង់ណាដែលមិនមានភាពស្របគ្នា

គឺយើងបដិសេធ។ សេចក្ដីថ្លែងផ្សេងទៀតនៅក្នុងនោះ គឺយើងមិនទទួលជឿឬទុកចិត្តឡើយ។  មិនខុសពីព្រះគម្ពីរដើមទាំងឡាយដែលព្រះបានបើកបង្ហាញមកកាន់ព្យាការីរបស់ទ្រង់ដូចជា លោកអប្រាហាំ, លោកម៉ូសេ, ស្ដេចដាវីឌ, លោកយេស៊ូ និងបណ្ដាព្យាការីដទៃទៀត សេចក្ដីជំនឿរបស់ពួកលោក គឺស្ថិតក្នុងចំណោមសសរស្ដម្ភនៃគោលជំនឿ បើពុំដូច្នេះទេពុំមានលោកណាម្នាក់ជាអ្នកមូស្លីមឡើយ។

# សុក្រឹត្យភាពនៃ
# ព្រះគម្ពីរគួរអាន

ព្រះគម្ពីរចុងក្រោយបង្អស់ ដែលព្រះបានបើកបង្ហាញមកកាន់មនុស្សជាតិនោះគឺ ព្រះគម្ពីរ**គួរអាន** ដែលរក្សានូវភាពដើមផុតពីការកែប្រែរបស់មនុស្សអស់រយៈកាលជាង១៤០០ឆ្នាំ។ សារចុងក្រោយដែលព្រះបានបើកបង្ហាញមកព្យាការី **មូហាំម៉ាត់** ដែលការប្រទានចុះមកត្រូវចំណាយពេលអស់ជាង២៣ឆ្នាំ។ ព្រះគម្ពីរត្រូវបានបើកបង្ហាញមកជាផ្នែកៗ ប្រវែងអត្ថបទខុសៗគ្នា។ នៅពេលលោកទទួលបានព្រះរាជសារនោះមួយផ្នែកមក លោកសូត្រវាទៅកាន់សហការីរបស់លោក ហើយពួកគេក៏សរសេរទុករួចទន្ទេញ។ លើសពីនេះទៀតព្យាការីលោកបានចង្អុលបង្ហាញដល់អ្នកកត់ត្រារបស់លោក អំពីកន្លែងដែលផ្នែកនីមួយៗគួរតែត្រូវបានដាក់នៅក្នុងតួនៃអត្ថបទ។ តាមរបៀបនេះព្រះគម្ពីរគួរអានទាំងមូល ត្រូវបានសរសេរនិងទន្ទេញដោយមនុស្សរាប់រយនាក់ ដែលជាអ្នកដើរតាមព្យាការីមូហាំម៉ាត់អំឡុងពេលដែលលោកនៅមានជីវិត។ លោក **អាប៊ូ បាកើរ** មេដឹកនាំទី១នៃសាសនាអ៊ីស្លាម បានចាត់តាំងឱ្យលោក **ហ្សេដ ប៊ិន ដ្សាបិត** ទទួលខុសត្រូវខាងចងក្រងច្បាប់ចម្លងដំបូងបង្អស់នៃព្រះគម្ពីរគួរអាន ឱ្យទៅជាអត្ថបទរួមតែមួយ ក្រោយពេលព្យាការីមូហាំម៉ាត់ទទួលមរណភាព។ ក្រោយពីនោះ នៅក្រោមការដឹកនាំរបស់មេ

ដឹកនាំទី៣នៃសាសនាអ៊ីស្លាមគឺលោក **ឧស្មាន** លោកហ្វាអ៊ីត បានរៀបចំច្បាប់ចម្លងចំនួន៧ច្បាប់ទៀតដែលបានផ្ញើទៅមជ្ឈមណ្ឌលផ្សេងៗក្នុងពិភពអ៊ីស្លាម។

ព្រះគម្ពីរគួរអាននៅតែមានការរក្សាអត្ថបទដើមជាភាសា**អារ៉ាប់** ហើយក៏មានមនុស្សរាប់លាននាក់បានទន្ទេញចាំគ្រប់ព្យាង្គគ្រប់ពាក្យ នៅជុំវិញពិភពលោកពីមួយជំនាន់ទៅមួយជំនាន់ ហើយនិងមានភាពស្របគ្នាទាំងស្រុងរាល់ច្បាប់ថតចម្លង និងច្បាប់ចម្លងសរសេរដោយដៃទាំងអស់[18] ដែលផ្ទៀតផ្ទាត់ភាពត្រឹមត្រូវជាមួយនឹងការបើកបង្ហាញចុងក្រោយបង្អស់ និងជាការចង្អុលបង្ហាញមកកាន់មនុស្សជាតិ។ ព្រះគម្ពីរគួរអានទាំងមូលគឺជាព្រះបន្ទូលផ្ទាល់នៃព្រះជាអម្ចាស់ ដោយគ្មានការបន្ថែមបន្ថយឡើយ។ នៅពេលដែលព្រះមានព្រះបន្ទូលថា៖ *ចូរអ្នកពោលថា៖ ព្រះអល់ឡោះគឺជាព្រះអម្ចាស់តែមួយអង្គគត់។* ព្យាការីមូហាំម៉ាត់ ដែលអ្នកផ្សព្វផ្សាយព្រះរាជសារបន្តនោះលោកពុំអាចផ្លាស់ប្តូរមួយតួអក្សរ ឬមួយពាក្យណា ឱ្យខុសពីព្រះបន្ទូលព្រះឡើយ។ លោកត្រូវតែនិយាយដូចដែលព្រះបង្គាប់លោកថា៖ *ចូរអ្នកពោលថា ព្រះអល់ឡោះគឺជាព្រះអម្ចាស់តែមួយអង្គគត់។* ដោយមិនទាំងលុបបំបាត់ពាក្យ *ចូរអ្នកពោលថា* នោះទេ[19]។

---

[18] លោក William Muir បានសរសេរនៅក្នុងសៀវភៅរបស់លោកចំណងជើងថា *ជីវិតរបស់ព្យាការីមូហាំម៉ាត់* លោកបាននិយាយទាក់ទងនឹងព្រះគម្ពីរគួរអានថា៖ *វាពិតជាគ្មានសៀវភៅណាផ្សេងទេនៅលើលោកនេះដែលត្រូវបានថែរក្សាអស់ពេល១២សតវត្សរ៍ (មកដល់ពេលនេះគឺ១៤សតវត្សរ៍ហើយ) ជាមួយនឹងអត្ថបទដែលល្អវិសុទ្ធ(ដូចដើម)។*

[19] បណ្ឌិត Laura Veccia Vaglieri បានសរសេរនៅក្នុងសៀវភៅចំណងជើង *Apologia dell' Islamismo* ថា៖ *ប៉ុន្តែមានភស្តុតាងមួយទៀតដែលបញ្ជាក់ថាព្រះគម្ពីរគួរអានមកពីព្រះពិតមែននោះគឺព្រះគម្ពីរនេះត្រូវបានរក្សាការពារផុតពីការខូចខាតឆ្លងកាត់ច្រើនជំនាន់ ចាប់តាំងពីពេលបើកបង្ហាញដំបូងរហូតមកទល់សព្វថ្ងៃនេះ ហើយក៏ត្រូវថែរក្សារហូតទៅ ដោយព្រះបំណងរបស់ព្រះ ដរាបណាសកលលោកនៅតែមាន។*

ជាមួយគ្នានេះដែរ បទនិទាននៃព្យាការី (ឬហៅថា **ហាទីស**) ជាប្រភពសំខាន់ទី២របស់សាសនាអ៊ីស្លាម ក៏ជាការបើកបង្ហាញពីព្រះដែរប៉ុន្តែជាលក្ខណៈខ្លឹមសារ មិនមែនជាព្រះបន្ទូលផ្ទាល់នោះទេ។ បទនិទានទាំងនេះត្រូវបានរក្សាទុកដោយឡែកនៅក្នុងគម្ពីរ **ហាទីស** ។ ត្រឡប់ទៅមើលគម្ពីរបរិសុទ្ធវិញ មិនអាចអះអាងបានទេថាមានលក្ខណៈល្អវិសុទ្ធនោះ ដ្បិតក្នុងនោះមានការលាយឡំគ្នារវាង ពាក្យសម្ដីខ្លះដែលគេចោទថាជាបន្ទូលព្រះ, ពាក្យសម្ដីខ្លះទៀតជាប្រសាសន៍របស់បណ្ដាព្យាការី ហើយពាក្យខ្លះទៀតគ្រាន់តែជាសម្ដីរបស់មនុស្សធម្មតាប៉ុណ្ណោះ។

អ្នកណាហើយដែលបានអានព្រះគម្ពីរគួរអាន គឺច្បាស់ណាស់ថាព្រះគម្ពីរទាំងមូលផ្ដោតលើ ឯកអគ្គភាព[20]របស់ព្រះ ។ ព្រះគម្ពីរមិនបានដំណាលពីខ្សែរជីវិតរបស់ព្យាការីមូហាំម៉ាត់នោះទេ ហើយក៏មិនដំណាលពីភាពអស្ចារ្យរបស់លោក ដូចមនុស្សខ្លះធ្លាប់គិតនោះឡើយ។ អ្នកណាហើយដែលបានអានព្រះគម្ពីរគួរអានគឺឃើញច្បាស់ថា ព្រះគម្ពីរផ្ដោតតម្រង់ទៅលើការផ្សព្វផ្សាយពីជំនឿថា *ព្រះមានតែមួយអង្គគត់* , ទ្រង់មានតែមួយអង្គឯងគត់, ថ្វាយសិរីរុងរឿងចំពោះទ្រង់, បដិបត្តិតាមអ្វីដែលព្រះបានបង្គាប់ប្រើ និងចៀសវាងពីអ្វីដែលទ្រង់បានហាមឃាត់។ ព្រះគម្ពីរគួរអាន ចែងចំពោះព្យាការីមូហាំម៉ាត់ថាជា *អ្នកនាំសារនៃព្រះ* មិនខុសពីបណ្ដាអ្នកនាំសារដទៃទៀតដែលមកក្នុងជំនាន់មុនៗលោកនោះទេ។ ព្រះគម្ពីរគួរអាន ៣:១៤៤ ចែងថា៖ *មូហាំម៉ាត់គ្រាន់តែជាអ្នកនាំសារម្នាក់ ដែលអ្នកនាំសារជាច្រើនបានកន្លងផុតទៅមុនគាត់ប៉ុណ្ណោះ។ ប្រសិនបើគាត់ទទួលមរណភាព ឬត្រូវបានគេសម្លាប់ តើពួកអ្នកនឹងវិលត្រឡប់ទៅក្រោយ(សាសនាដើម)វិញឬ? បើអ្នកណាវិលត្រឡប់ទៅក្រោយវិញនោះ គឺវាមិនប៉ះពាល់អ្វីដល់ព្រះអល់ឡោះបន្តិចណាឡើយ។ ហើយព្រះអល់ឡោះទ្រង់នឹងតបស្នងដល់ពួកអ្នកដែលដឹងគុណ។*

---

[20] ភាពល្អឯក មានតែមួយ ខ្ពង់ខ្ពស់គ្មានអ្វីប្រៀបស្មើបាន។

ព្រះគម្ពីរក៏បានពិពណ៌នាអំពីព្យាការីថា លោកជាមនុស្សម្នាក់ដែលគ្មានលទ្ធភាពផ្តល់ជាប្រយោជន៍ដល់នរណាម្នាក់ឡើយ សូម្បីតែខ្លួនលោកផ្ទាល់ លើកលែងតែព្រះជាម្ចាស់អនុញ្ញាតប៉ុណ្ណោះ។ ព្រះគម្ពីរគួរអាន ៧:១៨៨ ប្រាប់យើងថា៖ *ចូរអ្នកពោលថា ខ្ញុំគ្មានអំណាចគ្រប់គ្រងលើប្រយោជន៍ និងគ្រោះថ្នាក់ចំពោះខ្លួនខ្ញុំបានឡើយ លើកលែងតែអ្វីដែលព្រះអល់ឡោះទ្រង់មានចេតនាប៉ុណ្ណោះ។ ប្រសិនបើខ្ញុំបានដឹងនូវអាថ៌កំបាំង ខ្ញុំពិតជានឹងបានផលចំណេញសម្បូណ៌ហូរហៀរ ហើយគ្មានអំពើអាក្រក់ណាមកបៀតបៀនរូបខ្ញុំបានឡើយ។ ខ្ញុំគ្មានអ្វីក្រៅពីជាអ្នកដាស់តឿនព្រមាន និងផ្តល់ដំណឹងរីករាយដល់ក្រុមអ្នកដែលមានជំនឿនោះឡើយ។*

មិនតែប៉ុណ្ណោះ ក្នុងព្រះគម្ពីរមានទាំងវាក្យខណ្ឌដែលស្តីបន្ទោសចំពោះសកម្មភាពរបស់ព្យាការីផង។ កាលគ្រានោះមានបុរសងងឹតភ្នែកម្នាក់ មកបង្អាក់ព្យាការីនៅពេលលោកកំពុងអំពាវនាវដល់អ្នកមានអំណាចមួយក្រុមនៅក្រុង**ម៉ាក្កះ** ឱ្យពួកគេមកកាន់សាសនាអ៊ីស្លាម។ បុរសងងឹតភ្នែកនោះសុំឱ្យព្យាការីលោកផ្តល់ចំណេះដឹងខាងសាសនាបន្ថែមទៀតដល់ខ្លួន។ ក្នុងពេលព្យាការីលោកកំពុងខ្នះខ្នែងព្យាយាមចង្អុលបង្ហាញមនុស្សមួយក្រុមនោះ លោកក៏មានការធុញទ្រាន់ និងព្រងើយកន្តើយចំពោះបុរសងងឹតភ្នែកនោះ ដ្បិតលោកបានដឹងថា បុរសងងឹតភ្នែកនោះមានជំនឿលើព្រះរឹងមាំណាស់ហើយ បើបុរសនោះរង់ចាំរហូតដល់លោកជំនុំគ្នាចប់ ក៏មិនមានអ្វីជាគ្រោះថ្នាក់ដែរ។ យ៉ាងណាមិញព្យាការីត្រូវបានព្រះស្តីបន្ទោសនៅក្នុងព្រះគម្ពីរគួរអាន ៨០:១-១១ ថា៖ *គាត់(មូហាំម៉ាត់)បានធ្វើមុខក្រញូវហើយងាកមុខចេញ។ ពីព្រោះមានជនងងឹតភ្នែកម្នាក់បានចូលមកជួបគាត់។ តើអ្នក(មូហាំម៉ាត់)អាចដឹងយ៉ាងដូចម្តេចបាន? ជួនកាលគេអាចមកសម្អាតចិត្តអំពីអំពើបាប ឬក៏គេមានការភ្ញាក់រលឹក ដូច្នេះការក្រើនរំឭកនោះអាចផ្តល់ផលប្រយោជន៍ដល់គេ។ រីឯអ្នកដែលមិនត្រូវការការចង្អុលបង្ហាញដោយអាងខ្លួនមានទ្រព្យនោះ អ្នកបែរជាយកចិត្តទុកដាក់ចំពោះគេទៅវិញ។ ហើយពុំមែនជាភារៈអ្នក(ទទួលខុសត្រូវ)ទេ ប្រសិនបើគេមិនមានជំនឿវិញនោះ? ចំណែកឯអ្នកដែលខំស្វាត់មកជួបអ្នកដើម្បីសុំការចង្អុលបង្ហាញផ្លូវល្អ ក្នុងសភាពកោត*

*ខ្លាចព្រះអល់ឡោះនោះ អ្នកបែរជាព្រងើយកន្តើយចំពោះគេទៅវិញ។ ចូរអ្នកកុំធ្វើបែប នេះ ពិតប្រាកដណាស់ វា(វាក្យខណ្ឌទាំងនេះ)គឺជាការក្រើនរំឭក។*

អ្នកអានព្រះគម្ពីរគួរអាន ក៏នឹងឃើញនូវវាក្យខណ្ឌដែលព្រមានយ៉ាងធ្ងន់ធ្ងរដល់ព្យាការីមូហាំម៉ាត់ ទាំងការគម្រាមលោកដល់ជីវិតផង បើលោកហ៊ានប្រតិដ្ឋពាក្យពេចន៍ណាមួយឡើង ហើយនិយាយថាវាជាបន្ទូលព្រះ។ ព្រះគម្ពីរគួរអាន ៦៩:៤៤-៤៧ ចែងថា៖ *ហើយប្រសិនបើគេ(មូហាំម៉ាត់) ប្រតិដ្ឋពាក្យសំដីខ្លះលើព្រះបន្ទូលរបស់យើងនោះ យើងនឹងដាក់ទោសគេដោយព្រះហស្តស្តាំរបស់យើង បន្ទាប់មកយើងពិតជានឹងកាត់សរសៃឈាមបេះដូងរបស់គេជាមិនខាន។ ហើយគ្មានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកអាចរារាំង (យើង) បានឡើយ។*

ពួកជនជាតិអារ៉ាប់ដែលមិនជឿសាសនានៅជំនាន់នោះ បានចោទប្រកាន់ព្យាការីថាលោកបានក្លែងព្រះគម្ពីរគួរអានឡើង។ កាលគ្រានោះព្រះបានបើកបង្ហាញវាក្យខណ្ឌមួយចំនួនដែលព្រះអង្គបបួលប្រកួតនឹងពួកគេ ឱ្យបង្កើតគម្ពីរណាមួយដែលប្រហាក់ប្រហែលនឹងព្រះគម្ពីរគួរអាន។ ព្រះគម្ពីរគួរអាន ១៧:៨៨ ចែងថា៖ *ចូរអ្នក(មូហាំម៉ាត់)ពោលថា ប្រសិនបើមនុស្សលោក និងជិន*[21] *បានរួមគ្នាដើម្បីចងក្រងឱ្យដូចនឹងព្រះគម្ពីរគួរអាននេះ គឺពួកគេមិនអាចចងក្រងឱ្យដូចនឹងវាបានឡើយ ទោះបីជាពួកគេបានជួយគ្នាទៅវិញទៅមកក៏ដោយ។* ហើយនៅក្នុងជំពូក ៥២:៣៣-៣៤ ចែងថា៖ *ឬមួយក៏ពួកគេនិយាយថា អ្នក(មូហាំម៉ាត់)បានប្រតិដ្ឋវា(ព្រះគម្ពីរគួរអាន)ដោយខ្លួនឯងឬ? ផ្ទុយទៅវិញពួកគេទេដែលគ្មានជំនឿនោះ។ ដូច្នេះចូរឱ្យពួកគេនាំយកពាក្យពេចន៍ណាមួយ ឱ្យដូចនឹងព្រះគម្ពីរនេះមក ប្រសិនបើពួកគេជាអ្នកដែលនិយាយពិតនោះ។* ប៉ុន្តែពួកអារ៉ាប់មិនជឿសាសនានោះមិនអាចធ្វើបានទេ។ ការបបួលប្រកួតនេះ ក្រោយមកបន្ថយនៅសល់ត្រឹមតែ១០ជំពូកប៉ុណ្ណោះដែលមានចែងក្នុង ១១:១៣ ថា៖ *ឬពួកគេនឹងនិយាយថា គាត់បានប្រតិដ្ឋវា (ព្រះគម្ពីរគួរអាន)។ ចូរអ្នកពោលថា ចូរពួកអ្នកនាំ*

---

[21] អមនុស្ស។

*យកដប់ជំពូកឱ្យដូចការប្រតិដ្ឋទាំងនេះមក ហើយចូរពួកអ្នកហៅអ្នកណាក៏ដោយដែលពួកអ្នកអាចហៅបានក្រៅពីព្រះអល់ឡោះ(ឱ្យជួយ) ប្រសិនបើពួកអ្នកជាពួកដែលស្មោះត្រង់ពិតមែននោះ។* ប៉ុន្តែពួកគេនៅតែមិនអាចធ្វើបាន ជាចុងក្រោយការបប្ចូលប្រកួតសល់តែ១ជំពូកប៉ុណ្ណោះ។ នៅក្នុងជំពូក ២:២៣-២៤ ប្រាប់យើងថា៖ *ប្រសិនបើពួកអ្នកមានការសង្ស័យ អំពីអ្វីដែលយើងបានប្រទានចុះមកឱ្យអ្នកបម្រើរបស់យើងនោះ ចូរពួកអ្នកនាំមកនូវជំពូកមួយណា ដែលដូចជំពូកនៃព្រះគម្ពីរគួរអាន ហើយចូរហៅសាក្សីរបស់ពួកអ្នកក្រៅពីព្រះអល់ឡោះមក ប្រសិនបើការអះអាងរបស់ពួកអ្នកពិតជាត្រឹមត្រូវមែននោះ។ តែប្រសិនបើពួកអ្នកមិនអាចធ្វើវាបានឥឡូវនេះទេ ហើយពួកអ្នកក៏នឹងមិនអាចធ្វើវាបានដែរនៅពេលអនាគតនោះ ដូច្នេះចូរពួកអ្នកខ្លាចភ្លើងនៃស្ថាននរកដែលឥន្ធនៈរបស់វាគឺមនុស្ស និងដុំថ្មដែលគេបានរៀបចំសម្រាប់ពួកដែលគ្មានជំនឿ។* ជំពូក ១០:៣៨ ក៏ចែងថា៖ *ឬមួយពួកគេនិយាយថា គេ(មូហាំម៉ាត់)បានបង្កើតវា(ព្រះគម្ពីរគួរអាន)ឡើង។ ចូរអ្នកតបវិញថា ដូច្នេះចូរពួកអ្នកនាំមកនូវជំពូកមួយណាដែលដូចនឹងវា ហើយចូរពួកអ្នកហៅអ្នកណាដែលពួកអ្នកអាចកោះហៅបានផ្សេងពីព្រះអល់ឡោះចុះ ប្រសិនបើពួកអ្នកជាអ្នកត្រឹមត្រូវមែននោះ។* ពួកគេនៅតែបរាជ័យក្នុងការបប្ចូលប្រកួតនេះ។ ការណ៍នេះសបញ្ជាក់ថា សត្រូវរបស់សាសនាអ៊ីស្លាម បើទោះជាពួកគេពូកែវោហាសាស្ត្រនិងភាសាអារ៉ាប់យ៉ាងណាក៏ដោយ ក៏នៅតែបរាជ័យក្នុងការតែងនិពន្ធជំពូកមួយ ឱ្យប្រហាក់ប្រហែលនឹងព្រះគម្ពីរគួរអានដែរ។ ការណ៍ដែលពួកគេទទួលការបប្ចូលប្រកួតនេះ ជួយឱ្យពួកគេចំណេញទាំងពេលទាំងកម្លាំងជាជាងការមកបញ្ឈប់សាសនាអ៊ីស្លាមដោយប្រើកម្លាំង។

មិនដូចគម្ពីរបរិសុទ្ធឡើយ ព្រះគម្ពីរគួរអានគ្មានជំពាក់ជំពិននឹង ភាពខុសប្រក្រតី , ការចុះមិនសម្រុងគ្នា និងបដិវាទភាពឡើយ ប៉ុន្តែប្រកបដោយហេតុផល និងលក្ខណៈវិទ្យាសាស្ត្រ។ ជំពូក ៤:៨២ ចែងថា៖ *តើពួកគេមិនត្រិះរិះពិចារណាអំពីព្រះគម្ពីរគួរអានទេឬ? ប្រសិនបើព្រះគម្ពីរនេះមិនមែនមកពីព្រះអល់ឡោះទេនោះ ពួកគេប្រាកដជាជួបប្រទះនូវបដិវាទភាពជាច្រើននៅក្នុងវា។*

ព្រះគម្ពីរគួរអានដែលបានបើកបង្ហាញតាំងពី១៤សតវត្សរ៍មុន បានលើកឡើងពីសេចក្តីពិតដែលថ្មីៗនេះទើបតែបានរកឃើញ និងបញ្ជាក់ថាត្រឹមត្រូវពីអ្នកវិទ្យាសាស្ត្រដោយមានជំនួយពីឧបករណ៍ទំនើបៗនិងវិទ្យាសាស្ត្រជឿនលឿនផង។ ជាឧទាហរណ៍ ព្រះមានព្រះបន្ទូលយ៉ាងច្បាស់អំពី ដំណាក់កាលនៃការវិវត្តន៍អំប្រ៊ីយ៉ុងរបស់មនុស្ស។ ព្រះមានព្រះបន្ទូលថា៖ *ហើយជាការពិតណាស់ យើងបានបង្កើតមនុស្សលោក(អាដាំ) អំពីដីឥដ្ឋ។ ក្រោយមកយើងបានបង្កើតមនុស្សពីទឹកកាមនៅក្នុងកន្លែងដែលមានសុវត្ថិភាព(នៅក្នុងស្បូន)។ បន្ទាប់មកយើងបានបំប្លែងទឹកកាមនោះឱ្យទៅជាឈាមមួយដុំ ហើយយើងបានបំប្លែងដុំឈាមនោះទៅជាសាច់មួយដុំ រួចយើងបានបំប្លែងដុំសាច់នោះឱ្យមានជាឆ្អឹង ហើយយើងបណ្តុះសាច់រុំព័ទ្ធលើឆ្អឹងនោះ ក្រោយមកទៀតយើងបានបំប្លែងវាទៅជារូបរាងមួយផ្សេងទៀត។ ហើយព្រះអល់ឡោះ ទ្រង់ដ៏ឧត្តុង្គឧត្តមដែលជាអ្នកបង្កើតដ៏ប្រសើរបំផុត។* (ព្រះគម្ពីរគួរអាន ២៣:១២-១៤)

ព្រះគម្ពីរគួរអានក៏លើកឡើងអំពីការកកើតឡើងនៃសាកលលោក ហើយនិងដំណាក់កាលដំបូងនៃការកកើតនោះគឺ បន្ទុះមហិមា។ ជំពូក ២១:៣០ ចែងថា៖ *តើពួកដែលគ្មានជំនឿមិនបានដឹងទេឬថា ពិតប្រាកដណាស់ មេឃជាច្រើនជាន់និងផែនដីដើមឡើយវាទាំង២នៅជាប់គ្នា តែយើងបានបំបែកវាទាំងពីរឱ្យឃ្លាតពីគ្នាវិញនោះ? ហើយយើងបានបង្កើតអ្វីៗទាំងអស់ឱ្យមានជីវិតដោយសារទឹក។ ដូច្នេះតើពួកគេនៅតែមិនជឿទៀតឬ?* ប្រធានបទនៃវាក្យខណ្ឌនេះ ត្រូវបានក្លាយជាប្រធានបទសម្រាប់ពានរង្វាន់ណូបែលក្នុងឆ្នាំ១៩៧៣។ វិទ្យាសាស្ត្រទំនើបក៏បានបញ្ជាក់ដែរថា ៨០ភាគរយរបស់ស៊ីតូប្លាសនៃកោសិកាមានជីវិតទាំងអស់គឺជាទឹក។ ចំណេះដឹងដ៏មានតម្លៃអស្ចារ្យបែបនេះ បានប្រទានចុះមកឱ្យព្យាការីមូហាំម៉ាត់ ដែលជាមនុស្សមិនចេះអក្សរផង តាំងពីជាង១៤សតវត្សរ៍មុន គឺជាភស្តុតាងដែលមិនអាចប្រកែកបានថា ព្រះគម្ពីរគួរអានគឺជាព្រះបន្ទូលរបស់ព្រះ ហើយមូហាំម៉ាត់គឺជាអ្នកនាំសាររបស់ព្រះអង្គ។

# ដំណើរជីវិត
# និងព័ន្ធកិច្ច
# របស់លោកយេស៊ូ

គេបានដឹងតិចតួចណាស់អំពីជីវិតកុមារភាពរបស់លោកយេស៊ូ។ នាងក្រមុំឈ្មោះ **ម៉ារី** បានប្រសូតលោកមកនៅឯទឹកដី**ប៉ាលេស្ទីន**។ អ្នកមូស្លីមទាំងអស់ទទួលជឿ និងផ្តល់ការគោរពចំពោះលោកយេស៊ូ ដោយសម្អាងលើព្រះគម្ពីរគួរអាន និងបទនិទាននៃព្យាការីថាលោកជា ព្យាការីមួយរូបដ៏ពិសិដ្ឋរបស់ព្រះ។

គោលសំខាន់បំផុតនៃការបង្រៀនរបស់លោកនោះគឺមានមូលដ្ឋាននៃ ជំនឿលើព្រះតែមួយអង្គ ហើយគោរពសក្ការៈចំពោះព្រះអង្គមួយអង្គគត់ដោយឥតលក្ខខណ្ឌ។ លោកក៏បានបង្រៀនពីសេចក្តីស្រឡាញ់ និងសន្តិភាព។ លោកបានសម្តែងការណ៍អស្ចារ្យជាច្រើន ហើយមិនផ្តល់កិត្តិនាមលើខ្លួនលោកទេ ប៉ុន្តែលោកតែងថ្លែងថា គ្រប់យ៉ាងគឺដោយព្រះបំណងរបស់ព្រះ[22]។ ក្នុងកណ្ឌគម្ពីរយ៉ូហាន ៥:៣០ លោកយេស៊ូ

---

[22] ទោះជាយ៉ាងនេះក្តីយើងឃើញថាគ្រូគង្វាលគ្រីស្ទានព្យាយាមប្រឆាំងនឹងការបង្រៀនរបស់គ្រីស្ទ ហើយចាត់ទុកការណ៍អស្ចារ្យរបស់លោកជាហេតុផលដើម្បីជឿថាលោកជាព្រះទៅវិញ។ បើយ៉ាងនេះគួរតែមានអ្នកទៅសួរគ្រូគង្វាលទាំងនោះថា៖ ចុះម្តេចបានមិនចាត់ទុកលោកម៉ូសេជាព្រះផងទៅ ដ្បិតលោកអាចយកដំបងវាយទឹកសមុទ្រឱ្យញែកពីគ្នាបានដែរនោះ?(និក្ខមនំ ១៤:១៦-២៩) លោកម៉ូសេថែមទាំងអាចធ្វើឱ្យដំបងលោកប្រែជាសត្វពស់បានផង។(និក្ខមនំ ៤:២-៥) ម្តេចមិនចាត់ទុក

មានប្រសាសន៍ថា៖ *ខ្ញុំមិនអាចធ្វើអ្វីដោយគំនិតរបស់ខ្ញុំផ្ទាល់បានឡើយ សូម្បីតែអ្វីមួយក៏ដោយ។*កណ្ឌគម្ពីរលូកា ១១:២០ សរសេរថា៖ *ក៏ប៉ុន្តែ ប្រសិនបើខ្ញុំបណ្តេញវិញ្ញាណកំណាចដោយម្រាមដៃរបស់ព្រះវិញនោះ។* លោកយេស៊ូធ្លាប់ទូលអង្វរព្រះ ជាព្រះដែលបង្កើតផែនដី និងមេឃា។ អំពីការណ៍ដែលលោកយេស៊ូប្រស់បុរសឈ្មោះ **ឡាសា** ឱ្យរស់ពីស្លាប់វិញនោះ កណ្ឌគម្ពីរយ៉ូហាន ១១:៤១-៤២ លើកឡើងថា៖ *ដូច្នេះពួកគេបានយកថ្មនោះចេញ។ បន្ទាប់មក លោកយេស៊ូងើយភ្នែកទៅលើ ក៏មានប្រសាសន៍ថា បិតាអើយ ខ្ញុំសូមអរគុណលោកដែលលោកបានស្តាប់ខ្ញុំ។ ពិតមែនតែខ្ញុំដឹងថាលោកតែងតែស្តាប់ខ្ញុំ ប៉ុន្តែខ្ញុំបាននិយាយដូច្នេះដោយសារមានបណ្តាជនកំពុងឈរនៅជុំវិញ ដើម្បីពួកគេអាចជឿថាលោកបានចាត់ខ្ញុំឱ្យមក។* អំពីលោក**ស៊ីម៉ូន**(ពេត្រុស) ជាសិស្សជំនិតរបស់លោកយេស៊ូវិញបាននិយាយថា៖ *ជនជាតិអ៊ីស្រាអែលអើយ ចូរស្តាប់ពាក្យនេះ លោកយេស៊ូពីស្រុកណាសារ៉ែត ជាបុរសម្នាក់ដែលព្រះបានសម្តែងឱ្យអ្នករាល់គ្នាឃើញជាចំហ ដោយការដែលប្រកបដោយឫទ្ធានុភាព សញ្ញាសម្គាល់ និងការណ៍ដ៏គួរឱ្យកោតស្ញើច ដែលព្រះបានធ្វើតាមរយៈលោកនៅកណ្តាលអ្នករាល់គ្នា ដូចអ្នករាល់គ្នាដឹងហើយ។*(កិច្ចការ ២:២២) សូម្បីតែអ្នកដែលបានឃើញការណ៍អស្ចារ្យទាំងនេះដោយផ្ទាល់ភ្នែកក៏ដោយ ក៏ជឿថាការណ៍អស្ចារ្យទាំងអស់នេះគឺមកពីព្រះជាម្ចាស់ ហើយលោកយេស៊ូជាព្យាការីរបស់ព្រះ។ ឯរឿងកូនប្រុសរបស់ស្រ្តីមេម៉ាយម្នាក់ដែលលោកយេស៊ូប្រស់ឱ្យរស់ពីស្លាប់ដែរនោះ អ្នកដែលបាននៅឃើញព្រឹត្តិការណ៍នោះបានអះអាងថា៖ *អ្នកប្រកាសទំនាយ(ព្យាការី)ម្នាក់ដ៏ឧត្តមបានត្រូវ*

---

លោកយ៉ូស្វេជាព្រះផងទៅ ដ្បិតលោកអាចបញ្ឈប់ព្រះអាទិត្យ និងព្រះចន្ទឱ្យឈប់ស្ងៀមបាន។(យ៉ូស្វេ ១០:១២-១៣) ចុះម្តេចមិនចាត់ទុកលោកអេលីយ៉ាជាព្រះផងទៅ ដ្បិតលោកប្រស់មនុស្សស្លាប់ឱ្យរស់បាន។(១ពង្សាវតារក្សត្រ ១៧:២០-២២) ឯលោកអេលីសេក៏បានប្រោសមនុស្សស្លាប់ឱ្យរស់ដូចគ្នា។(២ពង្សាវតារក្សត្រ ៤:៣២-៣៥) មិនត្រឹមតែប៉ុណ្ណោះលោកអេលីសេក៏រស់ឡើងវិញក្រោយពីស្លាប់ដែរ។(២ពង្សាវតារក្សត្រ ១៣:២០-២១ ) ក៏មានកងទ័ពរាប់ពាន់នាក់បានរស់ឡើងវិញក្រោយពីស្លាប់ដែរ ប៉ុន្តែពួកគេពុំមានអ្នកណាចាត់ទុកជាព្រះសោះឡើយ។(អេសេគាល ៣៧:៧-១០)

*តាំងឡើងក្នុងចំណោមយើង ហើយព្រះបានអាណិតរាស្ត្ររបស់លោក។*(លូកា ៧: ១៦)

នៅក្នុងព្រះគម្ពីរគួរអាន ព្យាការីដ៏ឧត្តមនោះសំដៅលើ **អ៊ីសា ប៊ីន ម៉ារីយ៉ាំ** (យេស៊ូ កូននាង ម៉ារី) ដែលនាមនេះត្រូវបានលើកឡើងក្នុងព្រះគម្ពីរគួរអានចំនួន ២៥ ដង ខណៈដែលនាមរបស់ព្យាការីមូហាំម៉ាត់ខ្លួនឯងមានលើកឡើងតែ ៥ ដងប៉ុណ្ណោះ។

ក្នុងជំពូកទី៣នៃព្រះគម្ពីរគួរអាន មានឈ្មោះថាជំពូក **អាលី អ៊ីមរ៉ាន** (គ្រួសារលោកអ៊ីមរ៉ាន) វាក្យខណ្ឌទី ៤២ ដល់ ៦២ មានចែងថា៖ *ហើយ(ចូរចងចាំ)នៅពេលដែលទេវតាបានពោលថា ម៉ារីអើយ! ព្រះអល់ឡោះបានជ្រើសរើសនាង និងបានសម្អាតនាង ហើយទ្រង់បានលើកតម្កើងនាងលើសពីស្ត្រីផ្សេងៗនៅលើលោក។ ម៉ារីអើយ! ចូរនាងគោរពទៅចំពោះព្រះអម្ចាស់របស់នាង ហើយចូរនាងឱនគោរពជាមួយពួកអ្នកឱនគោរពទាំងឡាយ(ថ្វាយបង្គំរួមគ្នា)។ ទាំងនោះគឺជាដំណឹងអាថ៌កំបាំងមួយចំនួនដែលយើងផ្តល់ឱ្យអ្នក(មូហាំម៉ាត់)។ ហើយអ្នកមិនបាននៅជាមួយពួកគេទេ នៅពេលដែលពួកគេបោះស្លាបប៉ាការបស់ពួកគេ(ទៅក្នុងទន្លេដើម្បីចាប់ឆ្នោត) តើអ្នកណាម្នាក់ក្នុងចំណោមពួកគេស័ក្តិសមនឹងថែរក្សាម៉ារីនោះ។ ហើយអ្នកក៏មិនបាននៅជាមួយពួកគេដែរ នៅពេលដែលពួកគេឈ្លោះប្រកែកគ្នា។ (ចូរចងចាំ)នៅពេលដែលទេវតាបានពោលថា ម៉ារីអើយ*[23]*! ពិតប្រាកដណាស់ ព្រះអល់ឡោះផ្តល់ដំណឹងរីករាយដល់*

---

[23] ម៉ារីយ៉ាំ(ម៉ារី) ជាម្តាយរបស់ព្យាការីយេស៊ូ និងជាស្ត្រីតែម្នាក់គត់ដែលមានឈ្មោះលើកឡើងក្នុងព្រះគម្ពីរគួរអាន។ ឈ្មោះរបស់នាងមានលើកឡើងចំនួន ៣៤ ដង។ លើសពីនេះទៀត គ្មានជំពូកណាមួយក្នុងគម្ពីរបរិសុទ្ធដាក់ឈ្មោះនាងឡើយ ខណៈមានជំពូកមួយក្នុងព្រះគម្ពីរគួរអានមានដាក់ឈ្មោះនាង។ ហើយជាការពិត គ្មានជំពូកណាមួយនៃព្រះគម្ពីរគួរអានលើកឡើងពីឈ្មោះម្តាយរបស់ព្យាការីមូហាំម៉ាត់ ឬកូនស្រី ឬភរិយារបស់លោកឡើយ។ នេះបង្ហាញពីក្តីស្រឡាញ់ដ៏អស្ចារ្យចំពោះនាងម៉ារី ហើយមានអ្នកមូស្លីមជាច្រើនបានដាក់ឈ្មោះកូនស្រីខ្លួនតាមឈ្មោះរបស់នាង។

*នាង នូវព្រះបន្ទូលពីទ្រង់[24] ឈ្មោះរបស់គេគឺគ្រិស្តយេស៊ូបុត្រនាងម៉ារី ដែលល្បីល្បាញទាំងក្នុងលោកិយនិងថ្ងៃបរលោក និងជាអ្នកជំនិតម្នាក់ក្នុងចំណោមអ្នកជំនិតទាំងឡាយរបស់ព្រះអល់ឡោះ។ ហើយយេស៊ូនិយាយជាមួយមនុស្សលោកតាំងពីនៅក្នុងអង្រឹង និងនៅពេលពេញវ័យ និងជាអ្នកសុចរិតម្នាក់ក្នុងចំណោមអ្នកសុចរិតទាំងឡាយ។ ម៉ារីបាននិយាយថា បពិត្រព្រះជាអម្ចាស់នៃខ្ញុំ! តើឱ្យខ្ញុំមានកូនដោយគ្មានបុរសណាមកប៉ះពាល់ខ្ញុំយ៉ាងដូចម្ដេច? ទេវតាបានឆ្លើយថា ដូច្នោះហើយព្រះអល់ឡោះទ្រង់បង្កើតអ្វីតាមតែទ្រង់មានព្រះបំណង។ នៅពេលដែលទ្រង់មានព្រះបំណងសម្រេចកិច្ចការអ្វីមួយ គឺទ្រង់គ្រាន់តែមានព្រះបន្ទូលទៅកាន់របស់នោះថា ចូរកើតចុះ វាក៏កើតឡើងភ្លាម។ ហើយទ្រង់នឹងបង្រៀនគេ(យេស៊ូ)នូវការសរសេរ និងសម្មាទិដ្ឋិ[25] និងព្រះគម្ពីរតាវរ៉ត[26] និងព្រះគម្ពីរដំណឹងល្អ[27] ។ ហើយតែងតាំងគេជាអ្នកនាំសារម្នាក់ទៅកាន់អំបូរអ៊ីស្រាអែល (ដោយឱ្យគេពោលថា) ពិតប្រាកដណាស់ ខ្ញុំបាននាំមកឱ្យពួកអ្នកនូវការណ៍អស្ចារ្យពីព្រះអម្ចាស់របស់ពួកអ្នក។ ពិតប្រាកដណាស់ ខ្ញុំអាចសូនដីឥដ្ឋសម្រាប់ពួកអ្នកជារូបបក្សី ហើយខ្ញុំក៏ផ្លុំជីវិតចូលទៅក្នុងវា ពេលនោះវាក៏*

---

[24] សំដៅលើព្យាការីយេស៊ូ ដែលចាប់កំណើតតាមរយៈព្រះបន្ទូលព្រះថា *ចូរកើតចុះ*។

[25] ការយល់ដឹងដោយភាពត្រឹមត្រូវ។

[26] ព្រះគម្ពីរ តាវរ៉ត*(Torah)* ជាព្រះគម្ពីរដែលព្រះបានប្រទានចុះមកឱ្យក្នុងជំនាន់ព្យាការី ម៉ូសេ ជាអ្នកដឹកនាំសាសន៍យូដា។ អ្នកសិក្សាភាគច្រើនកំណត់ថា ព្រះគម្ពីរតាវរ៉តគឺ គម្ពីរសម្ពន្ធមេត្រីចាស់ ប៉ុន្តែមិនមែនមានន័យថា គម្ពីរសម្ពន្ធមេត្រីចាស់ ជាព្រះគម្ពីរតាវរ៉តទេ តែគេជឿជាក់ថាផ្នែកខ្លះនៃព្រះគម្ពីរតាវរ៉តមានសេសសល់ខ្លះក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។

[27] ព្រះគម្ពីរដំណឹងល្អ*(Gospel)* ជាព្រះគម្ពីរដែលព្រះបានប្រទានចុះមកឱ្យក្នុងជំនាន់ព្យាការី យេស៊ូ។ អ្នកសិក្សាភាគច្រើនកំណត់ថា ព្រះគម្ពីរអ៊ីញជីលគឺ គម្ពីរសម្ពន្ធមេត្រីថ្មី។ សេចក្ដីពន្យល់បន្ថែមគឺដូចព្រះគម្ពីរតាវរ៉តខាងលើដែរ។

*ក្លាយជាសត្វបក្សីពិតប្រាកដភ្លាម[28] ដោយមានការអនុញ្ញាតពីព្រះអល់ឡោះ។ ហើយខ្ញុំអាចព្យាបាលជនងងឹតភ្នែកពីកំណើតនិងជម្ងឺឃ្លង់ ហើយខ្ញុំក៏អាចប្រស់សពឱ្យរស់ឡើងវិញបានដែរ ដោយការអនុញ្ញាតពីព្រះអល់ឡោះ។ ហើយខ្ញុំអាចប្រាប់ពួកអ្នកនូវអាហារដែលពួកអ្នកបរិភោគ និងអាហារដែលពួកអ្នកត្រូវបម្រុងទុកនៅក្នុងលំនៅដ្ឋានរបស់ពួកអ្នក។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះជាភស្តុតាងសម្រាប់ពួកអ្នក បើពួកអ្នកជាអ្នកមានជំនឿ។ ហើយ(ខ្ញុំមកនេះ)ដើម្បីបញ្ជាក់នូវអ្វីដែលមានពីមុនខ្ញុំ អំពីព្រះគម្ពីរតាវរ៉ត និងដើម្បីអនុញ្ញាតឱ្យពួកអ្នកនូវប្រការមួយចំនួន ដែលគេបានហាមប្រាមមកលើពួកអ្នក។ ហើយខ្ញុំបាននាំមកបង្ហាញពួកអ្នកនូវការណ៍អស្ចារ្យពីព្រះជាអម្ចាស់របស់ពួកអ្នក។ ដូច្នេះចូរពួកអ្នកកោតខ្លាចព្រះអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។ ពិតប្រាកដណាស់ព្រះអល់ឡោះគឺជាព្រះអម្ចាស់របស់ខ្ញុំ និងជាព្រះអម្ចាស់របស់ពួកអ្នក ដូច្នេះចូរពួកអ្នកគោរពសក្ការៈចំពោះទ្រង់។ នេះគឺជាមាគ៌ាដ៏ត្រឹមត្រូវ ។ ហើយនៅពេលយេស៊ូមានអារម្មណ៍ថាមានការប្រឆាំងពីពួកគេ គេក៏បានពោលថា តើអ្នកណាជាជំនួយរបស់ខ្ញុំដើម្បីព្រះអល់ឡោះ? បណ្តាពួកសាវ័កបានឆ្លើយថា ពួកយើងគឺជាជំនួយរបស់ព្រះអល់ឡោះ ពួកយើងមានជំនឿនឹងព្រះអល់ឡោះ ដូច្នេះសូមអ្នកធ្វើសាក្សីផងថា ពិតប្រាកដណាស់ ពួកយើងជាមូស្លីម។ បពិត្រព្រះអម្ចាស់នៃពួកយើង! ពួកយើងមានជំនឿលើអ្វីដែល ទ្រង់បានប្រទានចុះមក(ព្រះគម្ពីរអ៊ីញជីល) ហើយពួកយើងបានប្រតិបត្តិតាមអ្នកនាំសារ(យេស៊ូ) ដូច្នេះសូមទ្រង់មេត្តាកត់ត្រាពួកទូលបង្គំឱ្យនៅជាមួយបណ្តាអ្នកដែលធ្វើសាក្សីផង។ ហើយពួកគេបានប្រើឧបាយកល ហើយព្រះអល់ឡោះទ្រង់ក៏បានប្រើឧបាយកលតបវិញដែរ។ ហើយព្រះអល់ឡោះជាអ្នកដែលប្រសើរបំផុតក្នុងការតបតចំពោះអ្នកដែលប្រើឧបាយកលទាំងឡាយ។ (ចូរចងចាំ) នៅពេលដែលព្រះអល់ឡោះបានមានព្រះបន្ទូលថា ម្នាលយេស៊ូ! ពិតប្រាកដណាស់ យើងគឺជាអ្នក*

---

28 ការណ៍អស្ចារ្យនេះ រួមទាំងការណ៍អស្ចារ្យមួយទៀតដែរព្រះប្រទានតុអាហារពីលើមេឃមកសម្រាប់លោកយេស៊ូ (ក្នុងជំពូក៥:១៥៥) និងការណ៍អស្ចារ្យដទៃទៀតដែលបានលើកឡើងក្នុងព្រះគម្ពីរគួរអាន ប៉ុន្តែមិនមានលើកឡើងក្នុងគម្ពីរបរិសុទ្ធនោះទេ។

*ដកយកអ្នក(ពីផែនដី)និងជាអ្នកលើកអ្នកមកកាន់យើង[29] ព្រមទាំងរំដោះអ្នកឱ្យរួចផុតពីពួកប្រឆាំង ហើយយើងនឹងធ្វើឱ្យអស់អ្នកដែលប្រតិបត្តិតាមអ្នក ខ្ពង់ខ្ពស់ជាងពួកដែលប្រឆាំងរហូតដល់ថ្ងៃបរលោក។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកអ្នកគឺមកកាន់យើងវិញ។ ហើយយើងនឹងកាត់សេចក្ដីរវាងពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់ខ្វែងគំនិតគ្នាក្នុងរឿងនោះ។ រីឯពួកដែលប្រឆាំង យើងនឹងធ្វើទោសទណ្ឌពួកគេនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរទាំងក្នុងលោកិយ និងថ្ងៃបរលោក។ ហើយពួកគេគ្មានអ្នកជួយឡើយ។ ចំណែកឯអស់អ្នកដែលមានជំនឿ និងសាងអំពើល្អវិញ ព្រះអល់ឡោះនឹងបំពេញឱ្យពួកគេនូវផលបុណ្យរបស់ពួកគេ។ ហើយព្រះអល់ឡោះទ្រង់មិនសព្វព្រះទ័យនឹងពួកដែលបំពានឡើយ។ រឿងនោះហើយដែលយើងពណ៌នាប្រាប់អ្នក(មូហាំម៉ាត់)អំពីភស្តុតាងផ្សេងៗ និងអំពីព្រះគម្ពីរគួរអានដែលពោរពេញទៅដោយបញ្ញាញាណ។ ពិតប្រាកដណាស់ ការប្រៀបធៀប(ការបង្កើត)យេស៊ូ សម្រាប់ព្រះអល់ឡោះគឺដូចជា(ការបង្កើត)អាដាំដែរ គឺទ្រង់បានបង្កើតលោកពីដី បន្ទាប់មកទ្រង់បានមានបន្ទូលទៅកាន់លោកថា ចូរកើតចុះ លោកក៏កើតឡើងភ្លាម។ នេះជាការពិតមកពីព្រះអម្ចាស់របស់អ្នក ដូច្នេះចូរអ្នកកុំក្លាយជាអ្នកដែលស្ថិតនៅក្នុងចំណោមអ្នកដែលសង្ស័យឡើយ។ ហើយអ្នកណាដែលបានជជែកដេញដោលអ្នកអំពីរឿងនោះ(រឿងរបស់លោកយេស៊ូ) ក្រោយពីចំណេះដឹងបានមកដល់អ្នកហើយនោះ ចូរអ្នកពោលថា សូមពួកអ្នកមកទីនេះ! យើងនឹងហៅកូនចៅរបស់ពួកយើងនិងកូនចៅរបស់ពួកអ្នក និងភរិយារបស់ពួកយើង និងភរិយារបស់ពួកអ្នក និងខ្លួនពួកយើងនិងខ្លួនពួកអ្នក បន្ទាប់មកពួកយើងនឹងទូលអង្វរសុំ(ព្រះអល់ឡោះ)ឱ្យការដាក់បណ្ដាសារបស់ព្រះអល់ឡោះ ធ្លាក់ទៅលើពួកដែលភូតភរ។ ពិតប្រាកដណាស់ នេះគឺជារឿងពិត។ ហើយគ្មានព្រះអម្ចាស់ឯណាដែលត្រូវ*

[29] ព្រះបានសង្គ្រោះលោកយេស៊ូ និងលើកលោកឡើងទៅស្ថានសួគ៌ទាំងមានជីវិត ទាំងរូបកាយ ទាំងព្រលឹងវិញ្ញាណ ដោយគ្មានគ្រោះថ្នាក់ និងគ្មានការឈឺចាប់ឡើយ។

*គេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីព្រះអល់ឡោះឡើយ។ ហើយពិតប្រាកដណាស់ព្រះអល់ឡោះគឺជាព្រះអម្ចាស់មហាខ្លាំងពូកែ មហាបញ្ញាញាណ ។*

រីឯនៅក្នុងជំពូកទី១៩ ដែលមានឈ្មោះថាជំពូក **ម៉ារីយ៉ុំ**(ម៉ារី) ពីវាក្យខណ្ឌទី១៦ ដល់ទី៣៦ ព្រះមានព្រះបន្ទូលថា៖ *ហើយចូរអ្នក(មូហាំម៉ាត់)រំឭកពីរឿងម៉ារីនៅក្នុងព្រះគម្ពីរ(គួរអាន) ដែលនៅពេលនោះនាងបានចាកចេញឆ្ងាយពីក្រុមគ្រួសាររបស់នាងឆ្ពោះទៅកន្លែងមួយនៅទិសខាងកើត។ រួចមកនាងបានយករបាំងមួយមកបិទបាំងពីពួកគេ(អ្នកដទៃ)។ ក្រោយមកយើងបានបញ្ជូន**វិញ្ញាណ**(ទេវតាកាព្រីយ៉ែល)របស់យើងទៅកាន់នាង។ ហើយគេ(ទេវតាកាព្រីយ៉ែល)បាននិម្មិតខ្លួនជាមនុស្សម្នាក់ពេញលក្ខណៈទៅជួបនាង។ នាងបាននិយាយថា ពិតប្រាកដណាស់ ខ្ញុំទូលសុំពីព្រះអម្ចាស់ដ៏មហាសប្បុរសឱ្យបញ្ចៀសខ្ញុំ(ពីរឿងអាក្រក់) ពីអ្នកប្រសិនបើអ្នកគឺជាអ្នកកោតខ្លាចព្រះអល់ឡោះ។ គេ(ទេវតាកាព្រីយ៉ែល)បានតបវិញថា តាមពិតខ្ញុំគ្រាន់តែជាអ្នកនាំសារពីព្រះអម្ចាស់របស់នាង ដើម្បីឱ្យខ្ញុំប្រទានដល់នាងនូវកូនប្រុសម្នាក់ដែលស្អាតស្អំ។ នាងបាននិយាយ(ដោយភ្ញាក់ផ្អើល)ថា តើឱ្យខ្ញុំមានកូនប្រុសយ៉ាងដូចម្តេច បើគ្មាននរណាម្នាក់ធ្លាប់ប៉ះពាល់ខ្ញុំ ហើយខ្ញុំក៏មិនធ្លាប់ប្រព្រឹត្តអំពើផិតផងនោះ? គេ(ទេវតាកាព្រីយ៉ែល)បានពោលថា ដូច្នោះហើយបានជាព្រះអម្ចាស់របស់នាងបានមានព្រះបន្ទូលថា វាជាការងាយស្រួលបំផុតសម្រាប់យើង។ ហើយយើងយកគេ(ក្មេងប្រុស)ធ្វើជាសញ្ញាសម្គាល់សម្រាប់មនុស្សលោក និងជាក្តីមេត្តាករុណាពីយើង។ ហើយរឿងនេះព្រះអល់ឡោះទ្រង់បានកំណត់ទុករួចជាស្រេចមកហើយ។ ដូច្នេះ នាងក៏ចាប់ផ្តើមមានគភ៌ ហើយនាងបានចាកចេញទៅកន្លែងដែលឆ្ងាយ(ជ្រលងភ្នំ**ហ្គៃឡាហាំ**ទីក្រុងយេរ៉ូសាឡឹម)។ ហើយការឈឺចាប់នៅពេលមុនសម្រាលកូន បានជំរុញឱ្យនាងទៅកាន់ដើមលម៉ើមួយដើម ហើយនាងក៏និយាយថា ឱខ្លួនខ្ញុំអើយ! ប្រសិនបើខ្ញុំបានស្លាប់មុននេះ ប្រហែលជាខ្ញុំត្រូវបានគេបំភ្លេច ហើយគេមិននឹកនាខ្ញុំឡើយ។ ហើយគ្រានោះមានសំឡេងមួយ(សំឡេងទេវតាកាព្រីយ៉ែល) បានស្រែកប្រាប់នាងពីខាងក្រោមមកថា សូមនាងកុំព្រួយបារម្ភអ្វី ជាការពិតណាស់ព្រះអម្ចាស់របស់នាងបានធ្វើឱ្យមានប្រឡាយទឹកមួយនៅពីក្រោមនាង។ ហើយសូមនាងអង្រួនគល់ដើមលម៉ើនេះ វានឹងជ្រុះនូវផ្លែទុំស្រស់ៗឱ្យនាង។ ដូច្នេះចូរនាងទទួលទានផ្លែ*

*លមើ្មុ និងផឹកទឹកនេះ ហើយនិងរីករាយ(ដោយការប្រទានកូនពីព្រះអល់ឡោះចំពោះនាង)ចុះ។ ហើយប្រសិនបើនាងជួបមនុស្សណាម្នាក់(ហើយគេសួរនាងអំពីកូន) សូមនាងប្រាប់គេថា ពិតប្រាកដណាស់ខ្ញុំបានសច្ចាកាន់តំណមទៅចំពោះព្រះអម្ចាស់ដ៏មហាសប្បុរស។ ដូច្នេះខ្ញុំនឹងមិននិយាយរកអ្នកណាម្នាក់ឡើយនៅថ្ងៃនេះ។ បន្ទាប់មកនាងបាននាំទារកនោះ ឆ្ពោះទៅកាន់សាសន៍របស់នាងដោយបីទារកនោះ។ (ពេលឃើញម៉ារីបីទារកនោះ) ពួកគេបាននិយាយថា នែ ម៉ារី! ជាការពិតណាស់ អ្នកបាននាំមកនូវរឿងមួយដ៏ចម្លែកបំផុត។ នែ ប្អូនស្រីរបស់ហារូន! ឪពុករបស់នាងពុំមែនជាមនុស្សអាក្រក់ទេ ហើយម្តាយរបស់នាងក៏ពុំមែនជាអ្នកប្រព្រឹត្តអំពើផិតដែរ។ នាងបានចង្អុលទៅទារកនោះ(ដើម្បីឱ្យពួកគេសួរ)។ ពួកគេបាននិយាយថា តើឱ្យពួកយើងសួរទៅកាន់ទារកនៅក្នុងអង្រឹងយ៉ាងដូចម្តេច? ទារកនោះ(យេស៊ូ)បានពោលថា ពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកបម្រើរបស់ព្រះអល់ឡោះ ដែលទ្រង់បានប្រទានព្រះគម្ពីរមួយ(អ៊ីញជីល)ឱ្យខ្ញុំ ហើយទ្រង់បានចាត់ខ្ញុំជាព្យាការីម្នាក់។ ហើយទ្រង់បានប្រទានព្រះពរដល់ខ្ញុំគ្រប់ទីកន្លែងដែលខ្ញុំមានវត្តមាន ហើយទ្រង់បានផ្តែផ្តាំខ្ញុំឱ្យសឡាត(ថ្វាយបង្គំ) និងបង់ហ្សាកាត់[30]ដរាបណាខ្ញុំនៅមានជីវិត។ ហើយធ្វើឱ្យខ្ញុំក្លាយជាកូនកតញ្ញូចំពោះម្តាយរបស់ខ្ញុំ ហើយទ្រង់មិនបានធ្វើឱ្យខ្ញុំក្លាយជាអ្នកក្អេងក្អាងប្រឆាំង(នឹងទ្រង់)ឡើយ។ ហើយសូមសុខសន្តិភាពកើតមានដល់ខ្ញុំ នៅថ្ងៃដែលខ្ញុំបានប្រសូត និងនៅថ្ងៃដែលខ្ញុំស្លាប់ ហើយនិងនៅថ្ងៃដែលគេប្រស់ខ្ញុំឱ្យរស់ឡើងវិញ(ថ្ងៃបរលោក)។ ដំណើររឿងនោះគឺយេស៊ូកូនប្រុសរបស់ម៉ារី។ វាគឺជាពាក្យពិតដែលពួកគេ (ពួកយូដា និងពួកគ្រិស្តបរិស័ទ) មានការសង្ស័យ (ឬឈ្លោះប្រកែកគ្នា) ចំពោះវា។ វាមិនស័ក្តិសមទេសម្រាប់ព្រះអល់ឡោះដែលថា ទ្រង់មានបុត្រ។ ព្រះអង្គមហាស្អាតស្អំណាស់! នៅពេលដែលទ្រង់សម្រេចចង់ឱ្យអ្វីមួយកើតឡើង គឺទ្រង់គ្រាន់តែមានបន្ទូលទៅកាន់អ្វីនោះថា ចូរកើតចុះ វាក៏កើតឡើងភ្លាម។ (យេស៊ូបានពោលថា) ហើយពិតប្រាកដ*

[30] ហ្សាកាត់ ជាគោលគ្រឹះមួយក្នុងចំណោមគោលគ្រឹះទាំង៥របស់សាសនាអ៊ីស្លាម។ គឺជាកាតព្វកិច្ចរបស់អ្នកមូស្លីមគ្រប់ក្នុងការបង់ប្រាក់អប្បភាគនៃទ្រព្យសម្បត្តិសរុប រៀងរាល់ឆ្នាំ។

*ណាស់ ព្រះអល់ឡោះ គឺជាព្រះអម្ចាស់របស់ខ្ញុំ និងជាព្រះអម្ចាស់របស់ពួកអ្នក។ ដូច្នេះ ពួកអ្នកត្រូវគោរពសក្ការៈទៅចំពោះទ្រង់តែមួយអង្គគត់។ នេះគឺជាមាគ៌ាដ៏ត្រឹមត្រូវ។*

កាន់តែស៊ីជម្រៅទៀតនោះ ប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ក៏មានទាក់ទងនឹងលោកយេស៊ូដែរ។ នៅក្នុងបទនិទានមួយ ព្យាការីមូហាំម៉ាត់មានប្រសាសន៍ថា៖ *ទាំងនៅលើលោកិយនេះ និងថ្ងៃបរលោក ខ្ញុំគឺជាមនុស្សដែលនៅកៀកជិតនឹងលោកយេស៊ូកូននាងម៉ារីជាងគេ។ ព្យាការីទាំងអស់មានឪពុករួមគ្នា ឯម្ដាយទីទៃពីគ្នា ប៉ុន្ដែសាសនារបស់ពួកគេគឺតែមួយគត់*[31] ។

នៅក្នុងបទនិទានមួយទៀត ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា៖ *នៅពេលមនុស្សណាម្នាក់ប្រសូតមក អារក្សបិសាចប៉ះខ្លួនគេទាំងសងខាង ដោយម្រាមដៃពីររបស់វា។ លើកលែងតែយេស៊ូកូននាងម៉ារី ដែលអារក្សបិសាចព្យាយាមប៉ះក៏ប៉ុន្តែត្រូវបរាជ័យ។ នៅពេលវាប៉ះ ស្រោមសុកក្នុងស្បូនបានមកបិទបាំងរារាំង។*[32] នេះគឺជាការឆ្លើយតបនឹងការទូលអង្វររបស់ជីដូនលោកគឺ ភរិយាលោក**អ៊ីមរ៉ន** នៅពេលដែលលោកស្រីនិយាយថា៖ *...ខ្ញុំបានដាក់ឈ្មោះនាងថា ម៉ារី ហើយជាការពិតណាស់ ខ្ញុំសូមឱ្យព្រះអង្គការពារនាង និងកូនចៅរបស់នាង អំពីអារក្សបិសាចដែលត្រូវគេដាក់បណ្ដាសាផងចុះ*[33] ។(គួរអាន ៣:៣៦)

ព្រះគម្ពីរគួរអាន ថ្លឹងថ្លែងពីតួអង្គលោកយេស៊ូ និងមូហាំម៉ាត់ ថាមានលក្ខណៈវិសុទ្ធ និងឥតខ្ចោះស្មើគ្នា ហើយភាពឧត្ដុង្គឧត្ដមដូចគ្នា ដ្បិតលោកទាំងពីរជាព្យាការីរបស់ព្រះតែមួយអង្គ។

---

[31] និទានដោយ អាល់ប៊ូខរី ហាទីសលេខ ៣៣៧០។

[32] និទានដោយ អាល់ប៊ូខរី ហាទីសលេខ ៣២១៦។

[33] ទាំងក្នុងព្រះគម្ពីរគួរអាន និងព្យាការីមូហាំម៉ាត់ លើកកិត្តិយសរបស់លោកយេស៊ូ ដោយលើកឡើងពី ការណ៍ដែលលោកយេស៊ូត្រូវបានការពារពីអំពើអាក្រក់របស់អារក្សបិសាច។ ប៉ុន្តែគម្ពីរបរិសុទ្ធវិញ លើកឡើងថាលោកយេស៊ូត្រូវបានអារក្សបិសាចល្បួង។(លូកា ៤:២)

# ตาการี่มุบำม๊ด่

លោកយេស៊ូបានប្រាប់ទៅពួកសាសន៍យូដាថា បន្ទាប់ពីលោកទៅ គឺគ្មានព្យាការីចេញមកពីក្នុងចំណោមពួកគេឡើយ ហើយ រាជាណាចក្ររបស់ព្រះនឹងត្រូវដកហូតពីពួកគេ ហើយ ប្រគល់ដល់ប្រជាជាតិមួយដែលស័ក្តិសមវិញ។(ម៉ាថាយ ២១:៤៣) ប្រជាជាតិនេះ គឺជាពូជពង្សរបស់លោក**អ៊ីស្មាអែល** ដែលពួកសាសន៍យូដាបានបដិសេធគាត់[34]។ ព្រះគម្ពីរគួរអាន ៦១:៦ ចែងថា៖ *ហើយ(ចូរចងចាំ)នៅពេលដែលយេស៊ូកូនម៉ារីបានពោលថា ឱអំបូរអ៊ីស្រាអែល! ពិតប្រាកដណាស់ ខ្ញុំជាអ្នកនាំសាររបស់ព្រះអល់ឡោះមកកាន់ពួកអ្នក ដោយបញ្ជាក់អំពីអ្វីៗដែលមានមុនខ្ញុំនៅក្នុងព្រះគម្ពីរតាវរ៉ត និងផ្តល់ដំណឹងរីករាយដល់ពួកអ្នក អំពីអ្នកនាំសារម្នាក់ដែលនឹងមកដល់បន្ទាប់ពីខ្ញុំដែលគេមានឈ្មោះ*

[34] ទោះបីជាមានការបដិសេធយ៉ាងនេះក៏ដោយ ក៏អ្នកអានព្រះគម្ពីរគួរអានបានឃើញថាក្នុងរយៈពេលមួយ ព្រះអល់ឡោះក៏បានសព្វព្រះទ័យលើពូជពង្សអ៊ីស្រាអែលដែរ។(គួរអាន ២:៤៧) មានរឿងរ៉ាវជាច្រើននៅក្នុងព្រះគម្ពីរគួរអានដែលនិយាយអំពីពួកគេ ហើយនឹងព្យាការីរបស់ពួកគេ ជាពិសេសគឺលោក ម៉ូសេ ដែលព្រះគម្ពីរលើកឡើងពីឈ្មោះលោកចំនួន ១៣៦ ដង។ មិនត្រឹមតែប៉ុណ្ណោះ ព្យាការីមូហាំម៉ាត់លើកទឹកចិត្តឱ្យអ្នកមូស្លីមបួសតមអាហារជារៀងរាល់ឆ្នាំ នៅថ្ងៃ១០ ខែមូហារ៉ម(ខែទី១ក្នុងប្រតិទិនអ៊ីស្លាម)ហើយនឹងមុនថ្ងៃនោះមួយថ្ងៃ ដើម្បីជាការដឹងព្រះគុណចំពោះព្រះអល់ឡោះដែលបានសង្គ្រោះលោកម៉ូសេ និងពូជពង្សអ៊ីស្រាអែល ចេញពីកងទ័ពរបស់ស្តេចផារ៉ាអុងដោយព្រះអង្គធ្វើឱ្យសមុទ្រក្រហមញែកជាផ្លូវ។ អ្នកមូស្លីមបាននាំគ្នាបួសតមអាហារដើម្បីរំឭកពីព្រឹត្តិការណ៍នេះអស់រយៈកាល ១៤ សតវត្សរ៍មកហើយ។ ហើយអ្នកមូស្លីមក៏មានការគោរពយ៉ាងជ្រាលជ្រៅចំពោះព្យាការីទាំងអស់នៃពូជពង្សអ៊ីស្រាអែល ដូចមានគ្រួសារអ្នកមូស្លីមជាច្រើនបានដាក់ឈ្មោះកូនចៅពួកគេតាមឈ្មោះព្យាការីទាំងនោះ។

*ថា **អះម៉ាត់** (មូហាំម៉ាត់)។ ប៉ុន្តែនៅពេលដែលគាត់បានមកដល់ពួកគេ ជាមួយនឹងភស្តុតាងដ៏ច្បាស់លាស់ជាច្រើននោះ ពួកគេបែរជានិយាយថា នេះជាមន្តអាគមយ៉ាងច្បាស់លាស់។*

នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី លោកយេស៊ូបានធ្វើបទទំនាយអំពីការមកដល់របស់ព្យាការីមូហាំម៉ាត់ ដូចតទៅ៖ *ទោះជាយ៉ាងនោះក៏ដោយ ខ្ញុំប្រាប់អ្នករាល់គ្នាការពិតថា ខ្ញុំនឹងចេញទៅដើម្បីប្រយោជន៍អ្នករាល់គ្នា ព្រោះប្រសិនបើខ្ញុំមិនចេញទៅទេ នោះអ្នកជួយនឹងមិនមកឯអ្នករាល់គ្នាឡើយ។ ប៉ុន្តែប្រសិនបើខ្ញុំទៅ នោះខ្ញុំនឹងចាត់គាត់ឱ្យមកឯអ្នករាល់គ្នា។ កាលដែលអ្នកនោះមកដល់ គាត់នឹងផ្តល់ភស្តុតាងដែលនាំឱ្យជឿជាក់ដល់ពិភពលោកស្តីអំពីភាពខុសឆ្គង ស្តីអំពីសេចក្តីសុចរិត និងស្តីអំពីការវិនិច្ឆ័យ។ មុនបង្អស់ ស្តីអំពីភាពខុសឆ្គង ពីព្រោះពួកគេមិនបង្ហាញជំនឿលើខ្ញុំទេ។ បន្ទាប់មក ស្តីអំពីសេចក្តីសុចរិត ពីព្រោះខ្ញុំនឹងទៅឯបិតាដែលនៅស្ថានសួគ៌ ហើយអ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត។ រួចមក ស្តីអំពីការវិនិច្ឆ័យ ពីព្រោះអ្នកគ្រប់គ្រងពិភពលោកនេះបានត្រូវវិនិច្ឆ័យហើយ។ ខ្ញុំនៅមានរឿងជាច្រើនដែលចង់ប្រាប់អ្នករាល់គ្នា តែឥឡូវនេះអ្នករាល់គ្នាមិនអាចយល់បានឡើយ។ ក៏ប៉ុន្តែពេលដែលអ្នកជួយមកដល់ ពោលគឺសកម្មពលរបស់ព្រះ ដែលសម្តែងពីសេចក្តីពិត គាត់នឹងដឹកនាំអ្នករាល់គ្នា ដោយជួយឱ្យយល់សេចក្តីពិតយ៉ាងពេញលេញ ព្រោះគាត់នឹងមិននិយាយចេញពីខ្លួនគាត់ទេ ប៉ុន្តែអ្វីដែលគាត់ឮ គាត់នឹងនិយាយ ហើយគាត់នឹងប្រកាសប្រាប់អ្នករាល់គ្នាឱ្យដឹងអំពីការដែលនឹងមកដល់។ អ្នកនោះនឹងលើកតម្កើងខ្ញុំ ពីព្រោះគាត់នឹងប្រកាសប្រាប់អ្នករាល់គ្នានូវអ្វីដែលគាត់ទទួលពីខ្ញុំ។*(យ៉ូហាន ១៦:៧-១៤) ចាប់ពីពេលនោះមក តើមាននរណាលើកតម្កើងលោកយេស៊ូយ៉ាងច្រើនដូចព្យាការីមូហាំម៉ាត់នោះ?

នៅក្នុងដំណឹងល្អរបស់លោក**បាណាបាស** ជាដំណឹងល្អមួយដែលក្រុមជំនុំមិនទទួលស្គាល់នោះ លោកយេស៊ូមានប្រសាសន៍ថា៖ *នៅពេលដែលមនុស្សបានហៅខ្ញុំថា ព្រះ និង ព្រះរាជបុត្រានៃព្រះ ព្រះជាម្ចាស់ ដើម្បីកុំឱ្យខ្ញុំត្រូវពួកអារក្សចំអកឱ្យនៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោស។ ខ្ញុំត្រូវមនុស្សលោកចំអកមើលងាយ ដោយការស្លាប់*

*របស់យូដាស*[35] *ធ្វើឱ្យមនុស្សទាំងអស់ជឿថាខ្ញុំបានស្លាប់នៅលើឈើឆ្កាង។ ហើយការចំអកនេះនឹងបន្តរហូតដល់ការមកដល់របស់ មូហាំម៉ាត់ ដែលជាអ្នកនាំសាររបស់ព្រះ ដែលនៅពេលគាត់មក គាត់នឹងបើកបង្ហាញការភូតភរនេះដល់អ្នកដែលជឿលើច្បាប់របស់ព្រះ។*(បាណាបាស ជំពូកទី២២០)

គេលើកឡើងពីព្យាការីមូហាំម៉ាត់ ជាច្រើនដងដែរនៅកន្លែងផ្សេងៗគ្នាក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។ កន្លែងដែលសេសសល់ពីការកែប្រែនិងការបំផ្លាញនោះមានដូចជានៅក្នុងកណ្ឌគម្ពីរ ទុតិយកថា ១៨:១៨-១៩៖ *យើងនឹងធ្វើឱ្យមានព្យាការីម្នាក់ដូចអ្នកងើបឡើងពីក្នុងចំណោមបងប្អូនរបស់ខ្លួន យើងនឹងដាក់ព្រះបន្ទូលរបស់យើងក្នុងមាត់របស់ព្យាការីនោះលោកនឹងថ្លែងសេចក្តីទាំងប៉ុន្មានដែលយើងបង្គាប់។ អ្នកណាមិនស្តាប់ពាក្យដែលលោកថ្លែងក្នុងនាមយើងទេ យើងនឹងដាក់ទោសអ្នកនោះ។*

ក្រុង **ម៉ាក្កះ** ឬ **បាកា** ជាទីកន្លែងដែលព្យាការីមូហាំម៉ាត់បានទទួលការបើកបង្ហាញពីព្រះនោះ ត្រូវបានលើកមកនិយាយក្នុងកណ្ឌគម្ពីរទំនុកតម្កើង ៨៤:៦ ដែលថា

---

[35] បើយោងតាមគម្ពីរបរិសុទ្ធ លោកយូដាស ដែលមានឈ្មោះពេញថា យូដាស អ៊ីស្ការីយ៉ុត បានក្បត់លោកយេស៊ូដោយសារប្រាក់៣០កាក់។ យ៉ាងណាមិញលោក **អ៊ីបនូ ខទៀរ** សរសេរនៅក្នុងសៀវភៅ *សេចក្តីពន្យល់ព្រះគម្ពីរគួរអាន* របស់គាត់ នៅត្រង់ (៤:១៥៧) និងកន្លែងផ្សេងទៀតថា សិស្សនោះមិនបានក្បត់នឹងលោកយេស៊ូទេ។ ផ្ទុយទៅវិញលោកបានបូជាជីវិតជំនួសលោកយេស៊ូ។ នៅពេលដែលគាត់ឮលោកយេស៊ូមានប្រសាសន៍ថា៖ *នៅថ្ងៃគ្រោះថ្នាក់តើអ្នកណានឹងធ្វើឱ្យមើលទៅដូចខ្ញុំ អ្នកនោះនឹងធ្វើជាមិត្តរបស់ខ្ញុំនៅស្ថានសួគ៌?* សិស្សនោះបានបង្ហាញពីឆន្ទៈរបស់គាត់ក្នុងការធ្វើដូច្នេះ។ ការប្រព្រឹត្តដោយមិនគិតពីខ្លួនឯងបែបនេះទើបសមជាសិស្សរបស់លោកយេស៊ូគ្រិស្ត។ ម៉្យាងទៀតសកម្មភាពនៃការក្បត់ដែលបានប្រព្រឹត្តដោយយូដាស គឺផ្ទុយនឹងការនិទានក្នុងកណ្ឌគម្ពីរផ្សេងទៀត។ ដូចជាក្នុងម៉ាថាយ ១៩:២៨ លោកយេស៊ូមានប្រសាសន៍ថា៖ *ខ្ញុំប្រាប់អ្នករាល់គ្នាការពិតថា ក្នុងគ្រាបង្កើតសាជាថ្មី ពេលដែលកូនមនុស្សអង្គុយលើបល្ល័ង្ករុងរឿងរបស់លោក នោះអ្នករាល់គ្នាដែលបានកាន់តាមខ្ញុំ ក៏នឹងអង្គុយលើបល្ល័ង្កដប់ពីរ ហើយវិនិច្ឆ័យសេចក្តីកុលសម្ព័ន្ធអ៊ីស្រាអែលទាំងដប់ពីរ។* បើលោកយូដាស បានក្បត់ពិតមែន ម្តេចក៏លោកបានចូលស្ថានសួគ៌អង្គុយលើបល្ល័ង្ក ដែលលោកយេស៊ូប្រាប់ថាមាន១២សម្រាប់សិស្សទាំង១២ មិនមែនដកលោកយូដាសចេញសល់១១នោះទេ។

៖ *នៅពេលពួកគេដើរកាត់ជ្រលង**បាកា**[36]ព្រះអង្គបានធ្វើឱ្យទីនោះប្រែទៅជាប្រភពទឹក ហើយភ្លៀងនៅដើមរដូវក៏ធ្លាក់មក ជាព្រះពរលើកន្លែងនោះដែរ។*

ព្រះគម្ពីរគួរអានបានលើកឡើងនៅក្នុងជំពូកទី៣ វាក្យខណ្ឌទី៩៦ ថា៖ *ពិតប្រាកដណាស់ ដំណាក់(ទីកន្លែងគោរពសក្ការៈ)ដំបូងបង្អស់ ដែលគេបានដាក់សម្រាប់មនុស្សលោកនោះគឺនៅឯ **បាកា**[37] ដែលពោរពេញទៅដោយព្រះពរនិងជាការចង្អុលបង្ហាញសម្រាប់មនុស្សលោកទាំងអស់។* ព្យាការី **អប្រាហាំ** ក៏បានលើកឡើងពីទីតាំងដដែលនេះដែលលោកបានសាងសង់គ្រឹះនៃដំណាក់ដ៏ពិសិដ្ឋនេះ(**កាក់ហ្ពះ**[38]) ដោយបញ្ជាក់ដែរថាទីនេះជាកន្លែងរឹងស្ងួត។ ព្រះគម្ពីរគួរអាន ១៤:៣៧ ចែងថា៖ *បពិត្រព្រះអម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ ខ្ញុំបានឱ្យកូនចៅរបស់ខ្ញុំមួយចំនួនរស់នៅទីជ្រលងភ្នំដែលគ្មានដំណាំទាល់តែសោះ នៅក្បែរបូជនីយដ្ឋានរបស់ទ្រង់។*បន្ថែមពីនេះទៀត ក្នុងកណ្ឌគម្ពីរអេសាយ ២១:១៣ ក៏បាននិយាយផងដែរថានឹងមានការបើកបង្ហាញចេញពីស្រុកអារ៉ាប់។

ជាការពិតណាស់ ព្យាការីមូហាំម៉ាត់ ជាមនុស្សមិនចេះអក្សរ ហើយក៏មិនអាចអានបានដែរ ដូចមានលើកឡើងក្នុងកណ្ឌគម្ពីរអេសាយ ២៩:១២ ថា៖ *គេក៏យកសៀវភៅនោះទៅឱ្យមនុស្សម្នាក់ដែលមិនចេះអក្សរទាំងពោលថា ចូរអានទៅ! តែអ្នកនោះតបមកវិញថា ខ្ញុំមិនចេះអក្សរទេ!។*

---

[36] ការបកប្រែជាភាសាខ្មែរ គម្ពីរបរិសុទ្ធ(កែសម្រួលថ្មីឆ្នាំ២០១៦) បានរក្សាទុកឈ្មោះ បាកា នៅដដែល រីឯការបកប្រែខ្លះបានប្តូរឈ្មោះនេះទៅជា *ច្រកនៃសេចក្តីយំសោក* ឬ *ជ្រោះរីងស្ងួត*វិញ។

[37] ដោយឈ្មោះ ពក្កាហ៍ ឬ បាកា នេះជាឈ្មោះបុរាណរបស់ក្រុង ម៉ាក្កះ ដែលពុំសូវមានអ្នកស្គាល់ឈ្មោះនេះ អ្នកបកប្រែព្រះគម្ពីរគួរអានខ្លះ បានជំនួសឈ្មោះនេះដោយ ម៉ាក្កះ តែម្តងដើម្បីងាយយល់។ រីឯព្រះគម្ពីរដើមជាភាសាអារ៉ាប់នៅតែប្រើឈ្មោះ ពក្កាហ៍ ឬ បាកា ដដែល។ នេះពុំមានបញ្ហាឡើយ ដ្បិតអ្នកកាន់សាសនាអ៊ីស្លាមឱ្យតម្លៃលើព្រះគម្ពីរដើមជាភាសាអារ៉ាប់តែមួយគត់ គ្មានការបកប្រែណាអាចមកជំនួស ឬប្រៀបស្មើបានឡើយ។

[38] សំណង់រាងជាគូប មានទីតាំងនៅក្រុងម៉ាក្កះ ដែលអ្នកមូស្លីមប្រើប្រាស់ជាគោលសម្រាប់កំណត់ទិសក្នុងការថ្វាយបង្គំ។

នៅក្នុងគម្ពីរ **សហេស អាល់ប៊ូខរី** ហាទីសលេខ ៣ យើងក៏ឃើញរឿងរ៉ាវស្តីពីការបើកបង្ហាញដំបូងមកកាន់ព្យាការីមូហាំម៉ាត់៖ *គាត់(មូហាំម៉ាត់) បាននៅក្នុងរូងភ្នំនៅគ្រាដែលទេវតាបានមករកគាត់។ ទេវតាបានមករកគាត់ហើយនិយាយថា ចូរអានចុះ ។ គាត់និយាយថា ខ្ញុំមិនចេះអានទេ។ ព្យាការីលោកបានពន្យល់បន្ថែមទៀតថា ដូច្នេះហើយទេវតាក៏បានឱបរឹតខ្ញុំយ៉ាងណែន រហូតដល់ខ្ញុំថប់ដង្ហើម បន្ទាប់មកក៏លែងខ្ញុំហើយនិយាយថា ចូរអានចុះ ខ្ញុំក៏បាននិយាយថា ខ្ញុំមិនចេះអានទេ! គាត់ឱបរឹតខ្ញុំយ៉ាងណែន ធ្វើឱ្យខ្ញុំថប់ដង្ហើមទៀត។ បន្ទាប់មកក៏លែងខ្ញុំហើយនិយាយទៀតថា ចូរអានចុះ ខ្ញុំបាននិយាយទៀតថា ខ្ញុំមិនចេះអានទេ។ ដូច្នេះហើយគាត់(ទេវតា)បានឱបរឹតខ្ញុំយ៉ាងណែនជាលើកទីបីបន្ទាប់មកក៏លែងខ្ញុំហើយនិយាយថា ចូរអានចុះ ក្នុងព្រះនាមព្រះអម្ចាស់របស់អ្នកដែលបានបង្កើតមនុស្សពីដុំឈាម។ ចូរអានចុះ ហើយព្រះអម្ចាស់របស់អ្នកគឺមហាសប្បុរសបំផុត។*

នៅក្នុងព្រះគម្ពីរគួរអាន ជំពូកទី៧ វាក្យខណ្ឌទី១៥៧ ព្រះមានព្រះបន្ទូលថា៖ *អស់អ្នកណាហើយដែលប្រតិបត្តិតាមអ្នកនាំសារ(មូហាំម៉ាត់) ដែលជាព្យាការីមិនចេះអាននិង មិនចេះសរសេរ ដែលពួកគេដឹងពីលក្ខណៈរបស់គាត់ ដែលត្រូវបានសរសេរក្នុងព្រះគម្ពីរតាវរ៉ាត និងព្រះគម្ពីរដំណឹងល្អ[39] ដែលមាន(នៅជាមួយពួកគេ)។*

បទទំនាយរបស់ព្យាការីយេស៊ូ និងព្យាការីជំនាន់មុន បានក្លាយជាការពិតនៅក្នុងឆ្នាំ ៥៧១ នៃគ្រិស្តសករាជនៅឯស្រុកអារ៉ាប់។ **អ្នកជួយ**នោះបានប្រសូតចេញពីក្នុងចំណោមកូនចៅនៃលោក**អ៊ីស្មាអែល**[40]ដែលជាកុលសម្ព័ន្ធគោរពពហុទេព និង

---

[39] សូមមើលកំណត់សម្គាល់លេខ ២៥ និង ២៦។

[40] លោក អ៊ីស្មាអែល (ឈ្មោះក្នុងព្រះគម្ពីរគួរអានហៅថា **អ៊ីស្មាអ៊ីល**) ជាកូនប្រុសច្បងរបស់លោកអប្រាហាំ (ឈ្មោះដើមថា **អាប់រ៉ាម**) ដូចមានបញ្ជាក់ក្នុងកណ្ឌគម្ពីរលោកកុប្បត្តិ ១៦:១៦ ថា៖ *នៅពេលដែលនាង**ហាកា**បង្កើតអ៊ីស្មាអែលជូនលោកនោះ លោក**អាប់រ៉ាម**មានអាយុប៉ែតសិបប្រាំមួយឆ្នាំហើយ។* ហើយនៅក្នុងលោកកុប្បត្តិ ២១:៥ សរសេរថា៖ *ពេល**អ៊ីសាក**ជាកូនកើតមកនោះ លោកអប្រាហាំមានអាយុមួយរយឆ្នាំហើយ។* ប៉ុន្តែគម្ពីរបរិសុទ្ធនេះសរសេរបញ្ជ្រាស់នឹងខ្លួនឯង ដោយ

ថ្វាយបង្គំរូបចម្លាក់។ ព្យាការីមូហាំម៉ាត់ បានក្រោកឈរឡើងក្នុងចំណោមប្រជាជនទាំងអស់ ដោយផ្អែកលើគុណធម៌នៃភាពទៀងត្រង់, ក្តីស្រឡាញ់របស់លោកចំពោះសេចក្តីពិត និងក្តីមេត្តារបស់លោកទៅចំពោះអ្នកក្រខ្សត់និងអ្នកទន់ខ្សោយ។ លោកត្រូវបានប្រជាជន ហៅថា **អាល់ អាមីន** ដែលមានន័យថា អ្នកដ៏ជាទីទុកចិត្ត។ នៅពេលលោកមានអាយុ៤០ឆ្នាំ លោកត្រូវបានព្រះជាអម្ចាស់ជ្រើសរើសជាអ្នកនាំសារ និងជាព្យាការីមកកាន់មនុស្សជាតិទាំងអស់។ លោកបង្រៀនពីសេចក្តីជំនឿលើភាពតែមួយអង្គគត់របស់ព្រះអល់ឡោះ ជាព្រះដែលបង្កើតរាល់អ្វីៗ, ជាព្រះដ៏ស័ក្តិសមនឹងយើងគោរពថ្វាយបង្គំ និងជាព្រះដែលទ្រទ្រង់សកលលោកនិងសព្វសារពើទាំងអស់។

ព្រះទ្រង់ជួយគាំទ្រដល់ព្យាការីមូហាំម៉ាត់ ដោយការណ៍អស្ចារ្យជាច្រើន ដែលមនុស្សសន្និកសន្ទាប់បានឃើញផ្ទាល់ភ្នែក។ ដូចជាព្រឹត្តកាណ៍ដួងចន្ទជាពីរ(ជំពូក ៥៤:១) ខ្យល់ក្ងួចដែលព្រះអង្គបញ្ជូនមកដើម្បីទប់ទល់នឹងការវាយប្រហារពីសត្រូវនៅឯក្រុង**ម៉ាឌីណះ** (ជំពូក ៣៣:៩) ការណ៍អស្ចារ្យទាំងនេះត្រូវបានលើកឡើងក្នុងព្រះគម្ពីរគួរអាន ក្រោយពេលវាបានកើតឡើងជាក់ស្តែង ហើយអ្នកដែលប្រឆាំងនឹងព្រះគម្ពីរគួរអានក្នុងជំនាន់នោះដែលខំប្រឹងស្វែងរកកំហុសឆ្គងក្នុងព្រះគម្ពីរគួរអាន ក៏មិនអាចរកភាពខុសគ្នាអ្វីដែលមានលើកឡើងក្នុងព្រះគម្ពីរ និងអ្វីដែលបានកើតឡើងជាក់ស្តែងដែរ។ ជាលទ្ធផល មានមនុស្សជាច្រើនបានសម្រេចចិត្តទទួលយកសាសនាអ៊ីស្លាម ហើយក្នុងនាមជាអ្នកជឿព្រះ ការណ៍អស្ចារ្យទាំងនេះបានជួយពង្រឹងជំនឿរបស់ពួកគេលើព្រះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ឱ្យកាន់តែរឹងមាំថែមទៀត។ មានការណ៍អស្ចារ្យជាច្រើនក៏បានត្រូវលើកមកបង្ហាញក្នុងគម្ពីរ **ហាទីស** ដូចជាមានទឹកហូរចេញពីចន្លោះម្រាមដៃរបស់ព្យាការីមូហាំម៉ាត់, ការបង្កើនម្ហូបអាហារក្នុងអំឡុងពេលជីកព្រែកនៅក្រុង**ម៉ាឌីណះ** និងការដែលលោកអាចដឹងរឿងទុកជាមុន និងរឿងអាថ៌កំបាំងដែលព្រះអល់ឡោះបើកបង្ហាញឱ្យលោកដឹង។ យ៉ាងណាមិញ ការណ៍

---

អះអាងនៅក្នុងលោកុប្បត្តិ ២២:២ ថា៖ *ចូរយកអ៊ីសាកកូនរបស់អ្នកមក គឺកូនប្រុស**តែមួយ**ដ៏ជាទីស្រឡាញ់របស់អ្នក...។*

អស្ចារ្យមួយដែលបន្សល់ទុកមកដល់សព្វថ្ងៃនេះគឺ ព្រះគម្ពីរគួរអាន។ ព្រះគម្ពីរចែងអំពី ភាសាសាស្ត្រ, វិទ្យាសាស្ត្រ និងបញ្ញត្តិដែលទាក់ទងនឹងអព្ភូតហេតុក្នុងធម្មជាតិ។

ព្យាការីមូហាំម៉ាត់រស់នៅក្នុងចំណោមសហការី, គ្រួសារ និងប្រជាជនរបស់លោក។ គ្មានអ្វីលាក់កំបាំងឡើយក្នុងជីវិតរបស់លោក។ ជីវិតរបស់លោកប្រៀបដូចជាប្រៀបដូចជាសៀវភៅដែលបើកចំហ សូម្បីតែរឿងតូចតាចនិងរឿងលម្អិតក្នុងការរស់នៅរបស់លោកពេញមួយជីវិតត្រូវបានអ្នកជឿព្រះបានដឹងយ៉ាងសព្វគ្រប់ ទាំងដែលព្យាការីលោកពុំមានអ្វីសម្រាប់ផ្តល់ឱ្យពួកគេឡើយ ក្រៅពីអ្វីដែលលោកបានទទួលពីការបើកបង្ហាញពីព្រះនៃគ្រប់ភាវៈទាំងអស់។

សេចក្តីបង្រៀនរបស់លោកដែលនិយាយអំពី ភាតរភាព នៅក្នុងសាសនាអ៊ីស្លាមគឺគ្មានភាពខុសគ្នាឡើយ ហើយក៏គ្មានបែងចែករើសអើងដោយផ្អែកលើ អម្បូរ, ពណ៌សម្បុរ, ភាសា, ទ្រព្យធន ឬភេទនោះដែរ។ សេចក្តីបង្រៀនបែបនេះគឺបញ្ជាក់ដោយព្រះបន្ទូលរបស់ព្រះក្នុងព្រះគម្ពីរគួរអានក្នុងជំពូក ៤៩:១៣ ៖ *ម្នាលមនុស្សលោក! ពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកពីបុរស និងស្ត្រី(អាដាំ និងហាវ៉ា) ហើយយើងធ្វើឱ្យពួកអ្នកមានជនជាតិ និងកុលសម្ព័ន្ធជាច្រើន ដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ ពិតប្រាកដណាស់ អ្នកដែលថ្កុំថ្កើងជាងគេចំពោះព្រះអល់ឡោះក្នុងចំណោមពួកអ្នក គឺអ្នកដែលកោតខ្លាចព្រះអល់ឡោះជាងគេក្នុងចំណោមពួកអ្នក។ ពិតប្រាកដណាស់ ព្រះអល់ឡោះទ្រង់មហាដឹង មហាជ្រួតជ្រាបបំផុត។*

ព្យាការីលោកក៏បានសង្កត់ធ្ងន់ផងដែរថា ពូជអម្បូរពុំមានតម្លៃអ្វីឡើយចំពោះព្រះជាម្ចាស់[41]។ លោកបានមានប្រសាសន៍ថា៖ *ព្រះអម្ចាស់របស់អ្នកគឺតែមួយអង្គគត់ ហើយឪពុករបស់អ្នក(អាដាំ)ក៏តែម្នាក់ដែរ។ ជនជាតិអារ៉ាប់គ្មានអ្វីខ្ពង់ខ្ពស់ជាងអ្នកដែលមិនមែនជាជនជាតិអារ៉ាប់ទេ ហើយអ្នកដែលមិនមែនជាជនជាតិអារ៉ាប់ក៏គ្មានអ្វី*

---

[41] លោក **អាប៊ូ ឡាហាប** ត្រូវជាឪពុកមាររបស់ព្យាការីមូហាំម៉ាត់ បានបដិសេធចំពោះសាររបស់ព្រះ។ ជាលទ្ធផល វាក្យខណ្ឌមួយត្រូវបានបើកបង្ហាញដោយនិយាយពីការដាក់ទោសគាត់ នឹងស្បថថាគាត់ពិតជានឹងចូលស្ថាននរក។ យើងឃើញថា ការណ៍ដែលមានសែស្រឡាយជាប់ជាមួយនឹងព្យាការីមូហាំម៉ាត់ ពុំអាចការពារគាត់ឱ្យផុតពីការធ្វើទោសអស់កល្បបានទេ។

*ខ្ពង់ខ្ពស់ជាងជនជាតិអារ៉ាប់ដែរ។ មនុស្សស្បែកសគ្មានអ្វីខ្ពង់ខ្ពស់ជាងមនុស្សស្បែកខ្មៅទេ ហើយមនុស្សស្បែកខ្មៅក៏គ្មានអ្វីខ្ពង់ខ្ពស់ជាងមនុស្សស្បែកសដែរ លើកលែងតែអ្នកណាហើយដែលមានចិត្តអាណិតអាសូរ និងប្រព្រឹត្តសុចរិត។*[42]នេះមានន័យថា ចិត្តអាណិតអាសូរ និងការប្រព្រឹត្តសុចរិត គឺជាគោលការណ៍ដែលព្រះវិនិច្ឆ័យមនុស្សដោយមិនគិតពីពណ៌សម្បុរ និងជាតិសាសន៍ឡើយ។

ទាសភាព ត្រូវបានរីករាលដាលជុំវិញពិភពលោក ហើយទាសករទាំងនោះក៏ត្រូវបានដាក់ទោសដោយសាសនាដែលមនុស្សជាអ្នកបង្កើតនៅសម័យនោះ ដោយរួមទាំងគម្ពីរបរិសុទ្ធផងដូចមានក្នុង លោកុប្បត្តិ ៩:២៥-២៧, និក្ខមនំ ២១:២-១២ និង អេភេសូ ៦:៥។ នៅពេលដែលព្រះបានបញ្ជូនព្យាការីមូហាំម៉ាត់ជាមួយនឹងសារចុងក្រោយរបស់ទ្រង់មក ការដោះលែងទាសករបានក្លាយជាកិច្ចការមួយដ៏ល្អប្រសើរបំផុត និងអាចនាំឱ្យមនុស្សណាម្នាក់បានចូលទៅកៀកនឹងព្រះផង។ ជាមួយគ្នានេះដែរ សកម្មភាពនេះបានក្លាយជាមធ្យោបាយមួយដើម្បីឱ្យព្រះទ្រង់ទទួលយក, ដើម្បីបានការរីករាយក្នុងចិត្ត និងដើម្បីជាការសារភាពទោសនិងអំពើបាបនានា។ ព្រះបានមានព្រះបន្ទូលថា៖ *ហេតុម្តេចគេមិនឆ្លងឱ្យផុតផ្លូវលំបាកនោះទៅ។ តើអ្នកដឹងទេអ្វីទៅជាផ្លូវលំបាកនោះ? គឺការដោះលែងខ្ញុំបម្រើឱ្យមានសិទ្ធិសេរីភាព។*(គួរអាន ៩០:១១-១៣)

ព្យាការីមូហាំម៉ាត់ ត្រូវបានព្រះបញ្ជូនមកដើម្បីជា **ក្តីមេត្តាករុណាមកកាន់ពិភពលោក** ដូចមានចែងនៅក្នុងព្រះគម្ពីរគួរអានជំពូក ២១:១០៧ ។ ហើយព្យាការីមូហាំម៉ាត់មានប្រសាសន៍ថា៖ *អ្នកដែលមានចិត្តមេត្តាករុណា នោះព្រះអល់ឡោះនឹងមានមេត្តាករុណាចំពោះគេវិញ។ យ៉ាងនេះហើយ ចូរមានមេត្តាករុណានៅលើផែនដីនេះ ដូច្នេះព្រះដែលគង់នៅឯមេឃ នឹងមានមេត្តាករុណាចំពោះអ្នក។*[43] ហាទីសមួយ

[42] និទានដោយ អះម៉ាត់ ហាទីសលេខ ២៣១០៥។

[43] និទានដោយ អាត់ ទៀរមីហ្ស៊ី, ១៩២៨។

ទៀតលើកឡើងថា៖ *អ្នកណាហើយ ដែលគ្មានក្តីមេត្តាករុណាចំពោះមនុស្ស គេក៏នឹងមិនទទួលបានក្តីមេត្តាករុណាពីព្រះអល់ឡោះដែរ។*[44]

ការរស់នៅប្រចាំថ្ងៃរបស់ព្យាការីមូហាំម៉ាត់ គឺជាឧទាហរណ៍នៃក្តីមេត្តាករុណា។ ព្រះអល់ឡោះទ្រង់មានបន្ទូលក្នុងព្រះគម្ពីរគួរអានជំពូក ៣:១៥៩ ៖ *ដោយសារមានក្តីមេត្តាករុណាពីព្រះអល់ឡោះ អ្នក(មូហាំម៉ាត់)មានភាពទន់ភ្លន់ចំពោះពួកគេ។ តែបើអ្នកមានអាកប្បកិរិយាកោងកាចនិងរឹងរូសវិញនោះ គឺពួកគេនឹងចាកចេញពីអ្នកជាមិនខាន។ ដូច្នេះចូរអ្នកអធ្យាស្រ័យដល់ពួកគេនិងសុំការប្រោសប្រណី(ពីព្រះ)ឱ្យពួកគេ ហើយចូរអ្នកពិភាក្សាជាមួយពួកគេរាល់កិច្ចការ។*

ព្យាការីលោកមានចិត្តអាណិតអាសូរ សូម្បីតែចំពោះសត្រូវរបស់លោកក៏ដោយ។ ឧទាហរណ៍ដ៏ជាក់ច្បាស់មួយអំពីទឹកចិត្តអាណិតអាសូររបស់លោកនោះគឺនៅពេលដែលលោកច្បាំងបានក្រុងម៉ាក្កះ(ជាចម្បាំងមិនបង្ហូរឈាម)។ ពួកអ្នកមិនជឿសាសនាដែលរស់នៅក្រុងម៉ាក្កះជឿថាលោកនឹងគុំកួនហើយសងសឹកចំពោះពួកគេជាមិនខាន។ យ៉ាងណាមិញ នៅពេលដែលលោកឡើងឈរនៅមាត់ទ្វារ**កាក់ហ្ពះ** ហើយលោកមានប្រសាសន៍ទៅកាន់ពួកគេថា៖ *តើពួកអ្នកគិតថាខ្ញុំគួរប្រព្រឹត្តដាក់ពួកអ្នកយ៉ាងណាដែរ? ពួកគេតបវិញថា ត្រូវប្រព្រឹត្តល្អ សប្បុរស និងមេត្តាករុណាក្នុងភាពជាបងប្អូន។ ព្យាការីបានប្រកាសថា ចូរធ្វើយ៉ាងហ្នឹងចុះ។ ខ្ញុំនិយាយទៅកាន់អ្នកដូចព្យាការី* ***យ៉ូសែប*** *និយាយទៅកាន់បងប្អូនរបស់លោកដែរ។ គ្មានឡើយការស្តីបន្ទោសចំពោះពួកអ្នកនាថ្ងៃនេះ! ព្រះអល់ឡោះទ្រង់នឹងអភ័យទោសដល់ពួកអ្នក ហើយទ្រង់ជាអង្គដ៏មេត្តាករុណាបំផុត។*[45] *បន្ទាប់មកលោក(មូហាំម៉ាត់)មានប្រសាសន៍ទៅកាន់ពួកគេថា ចូរទៅចុះ ចំពោះពួកអ្នកគឺមានសេរីភាពហើយ។*[46] វាជាការងាយស្រួលណាស់ចំពោះលោក បើសិនជាលោកចង់សងសឹកឱ្យអ្នកដែលត្រូវគេធ្វើទារុណកម្ម និងអ្នកដែលត្រូវគេសម្លាប់ ហើយមានអ្នកតាមលោកជាច្រើនដែលត្រូវរងការធ្វើទុក្ខ

---

[44] និទានដោយ មូស្លីម, ៥៩៨៣។

[45] ប្រយោគនេះស្រង់ចេញពីព្រះគម្ពីរគួរអានជំពូក ១២:៩២។

[46] និទានដោយ អាល់ ហៃ្ពហាគី, ១៨៦៤៧ និង ១៨៦៤៧។

បុកម្ទេញក្រោមជើងពួកអ្នកក្រុងម៉ាក្កះ ប៉ុន្តែលោកបានលើកទោសឱ្យពួកគេទាំងអស់។ នេះជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា លោកពិតជាក្តីមេត្តាករុណាចំពោះមនុស្សជាតិពិតមែន។ ការធ្វើដូចនេះ គឺលោកធ្វើតាមការទូន្មានពីក្នុងព្រះគម្ពីរគួរអានដែលថា៖ *... អស់អ្នកដែលមានភាពអត់ធ្មត់ចំពោះកំហឹង ហើយនិងបណ្តាអ្នកដែលមានការអធ្យាស្រ័យដល់មនុស្សលោក។ ហើយព្រះអល់ឡោះសព្វព្រះទ័យអស់អ្នកដែលប្រព្រឹត្តសុចរិត។*(គួរអាន ៣:១៣៤) ព្រះអល់ឡោះក៏មានព្រះបន្ទូលទៀតដែរថា៖ *ប្រការល្អនិងប្រការអាក្រក់មិនអាចស្មើគ្នាបានឡើយ។ ចូរអ្នកតបតវិញចុះនូវអ្វីដែលល្អបំផុត ពេលនោះអ្នកដែលជាសត្រូវរបស់អ្នកនឹងក្លាយជាមិត្តជិតស្និទ្ធរបស់អ្នកជាមិនខានឡើយ។ ហើយគ្មានអ្នកណាម្នាក់ត្រូវបានគេផ្តល់នូវប្រការល្អនេះឡើយ លើកលែងតែអស់អ្នកដែលអត់ធ្មត់ ហើយក៏គ្មានអ្នកណាម្នាក់ត្រូវបានគេផ្តល់នូវប្រការល្អនេះដែរ លើកលែងតែអ្នកដែលមានភ័ព្វសំណាងដ៏ធំប៉ុណ្ណោះ។*(គួរអាន ៤១:៣៤-៣៥)

នៅពេលដែលសហាការីរបស់ព្យាការីបានសុំឱ្យលោក ទូលដល់ព្រះឱ្យទ្រង់ក្រោធពិរោធចំពោះសត្រូវដែលបានធ្វើឱ្យលោករងរបួសក្បាល និងបាក់ធ្មេញផងនោះ លោកបានបដិសេធនឹងសំណើរនេះហើយមានប្រសាសន៍ថា៖ *បពិត្រព្រះអម្ចាស់! សូមទ្រង់មានមេត្តាករុណាចំពោះប្រជាជនខ្ញុំផងចុះ ដ្បិតពួកគេមិនដឹងថាពួកគេកំពុងធ្វើអ្វីឡើយ។*[47]

ព្យាការីលោកមិនដែលខឹងសម្បារនឹងបញ្ហាផ្ទាល់ខ្លួននោះទេ។ រាល់ការខឹងសម្បារលោកទាំងអស់គឺដោយហេតុដើម្បីព្រះប៉ុណ្ណោះ។ លោកធ្លាប់មានប្រសាសន៍ថា៖ *មនុស្សដែលខ្លាំងពិតប្រាកដ មិនមែនជាអ្នកដែលវាយគេហើយបានឈ្នះគេនោះទេ។ ប៉ុន្តែគឺជាអ្នកដែលអាចរម្ងាប់កំហឹងគេបាន នៅពេលគេខឹងសម្បារ។*[48] លោកក៏ជាគំរូដ៏ល្អបំផុតចំពោះការបន្ទាបខ្លួន។ កាលនោះមានបុរសម្នាក់មកជួបនឹងព្យាការី

---

[47] និទានដោយ អ៊ីបនូ ហ៊ីបបាន, ៩៤៩។

[48] និទានដោយ មូស្លីម, ៦៥៩៥។

ទាំងភ័យញ័រខ្លួនព្រោះគេគិតថា គេនឹងត្រូវជួបស្តេចមួយអង្គ។ ព្យាការីបានជួបគាត់ដោយការបន្ទាបខ្លួនបំផុត ហើយលោកក៏មានប្រសាសន៍ទៅគាត់ថា៖ *ចូរត្រជាក់ចិត្តចុះ! ខ្ញុំពុំមែនជាស្តេចអ្វីឡើយ ខ្ញុំគឺជាកូនរបស់ស្ត្រីដែលធ្លាប់ទទួលទានសាច់ក្រៀមក្នុងក្រុងម៉ាក្កះ។*[49] ក៏មានហាទីស្សមួយទៀតដែលព្យាការីលោកបានមានប្រសាសន៍ថា៖ *អ្នកណាហើយដែលមានភាពក្រអឺតក្រទម ប៉ុនទម្ងន់សត្វស្រមោចនៅក្នុងបេះដូងគេនឹងមិនបានចូលស្ថានសួគ៌ឡើយ។*[50]

នៅដែលមានសូរ្យគ្រាសកើតឡើង ចំពេលនៃមរណភាពកូនប្រុសរបស់ព្យាការីដែលមានឈ្មោះថា **អ៊ីប្រហ៊ីម** ។ មនុស្សម្នានាំគ្នានិយាយឡើងថា សូរ្យគ្រាសនេះគឺកើតឡើងដោយសារមរណភាពនេះឯង។ យ៉ាងណាមិញ ព្យាការីបានហៅពួកគេមកហើយមានប្រសាសន៍ថា៖ *ព្រះអាទិត្យ និងព្រះចន្ទ ទាំងពីរនេះគឺជាទីសម្គាល់របស់ព្រះអល់ឡោះ។ បាតុភូតនៃសូរ្យគ្រាស ឬចន្ទគ្រាស មិនមែនជាដើមហេតុនៃការស្លាប់ ឬការកើតរបស់នរណាឡើយ។*[51]

នៅក្នុងហាទីស្សដោយឡែកមួយទៀត ព្យាការីមូហាំម៉ាត់បានណែនាំដល់អ្នកកាន់តាមទាំងអស់ថា៖ *ចូរកុំលើកតម្កើងខ្ញុំ ដូចពួកគ្រិស្តបរិស័ទលើកតម្កើងកូននាងម៉ារីឱ្យសោះ។ ខ្ញុំជាអ្នកបម្រើរបស់ព្រះអល់ឡោះ ដូច្នេះចូរហៅខ្ញុំថា អ្នកបម្រើរបស់ព្រះអល់ឡោះនិងជាអ្នកនាំសាររបស់ទ្រង់។*[52]

កាលគ្រាមួយ សហការីរបស់លោកម្នាក់បាននិយាយទៅកាន់លោកថា៖ *លោកគឺជាចៅហ្វាយនៃពួកយើង ហើយលោកមានអំណាច និងចិត្តប្រណីជាងយើងទាំងអស់គ្នា។* ព្យាការីលោកមានការខឹងសម្បារនឹងគំនិតបែបនេះ ហើយការខឹងនេះគឺក្នុងបុព្វហេតុព្រះប៉ុណ្ណោះ។ លោកមានប្រសាសន៍ឆ្លើយថា៖ *មានតែព្រះអល់ឡោះតែមួយ*

---

[49] និទានដោយ អ៊ីបនូ ម៉ាចាស់, ៣៣៩១។

[50] និទានដោយ មូស្លីម, ២២៥។

[51] និទានដោយ អាល់ ប៊ូខរី, ១០៤៤។

[52] និទានដោយ អាល់ ប៊ូខរី, ៣៣៧២។

*អង្គគត់ជាចៅហ្វាយ! ខ្ញុំពុំមែនជាចៅហ្វាយរបស់នរណាម្នាក់ទេ។ ចូរកុំឱ្យអារក្សបិសាចបោកប្រាស់អ្នក។ ខ្ញុំមិនចង់ឱ្យអ្នកលើកតម្កើងខ្ញុំទៅដល់ឋានៈខ្ពស់ជាងអ្វីដែលព្រះអល់ឡោះបានផ្តល់ឱ្យខ្ញុំឡើយ។ ខ្ញុំគ្រាន់តែជាអ្នកបម្រើរបស់ព្រះអល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់។*[53]

ច្បាប់ **សារីអា** (ច្បាប់របស់ព្រះ) ដែលព្យាការីមូហាំម៉ាត់បាននាំយកមកនោះ គឺបង្កើតឱ្យមានការយកចិត្តទុកដាក់ចំពោះអ្នកទន់ខ្សោយ, ជនខ្វះខាត, ជនទ័លក្រ ហើយនិងក្មេងកំព្រា ដែលជាផ្នែកដ៏ធំមួយក្នុងសាសនាអ៊ីស្លាម។ ព្រះអល់ឡោះមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *តើអ្នកបានឃើញបុគ្គលដែលបដិសេធនឹងថ្ងៃជំនុំជម្រះដែរឬទេ? នោះហើយគឺជាបុគ្គលដែលបោះបង់ក្មេងកំព្រា។ ហើយមិនជម្រុញគ្នាឱ្យផ្តល់ចំណីអាហារដល់អ្នកក្រីក្រ។*(គួរអាន ១០៧:១-៣) ការធ្វេសប្រហែសមិនយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រក៏អាចឱ្យមនុស្សម្នាក់ចូលក្នុងស្ថាននរកដែរ។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ពិតប្រាកដណាស់ គេមិនធ្លាប់មានជំនឿលើព្រះអល់ឡោះ ដ៏មហាធំធេងឡើយ។ ហើយគេក៏មិនដែលជំរុញគ្នាលើការផ្តល់ចំណីអាហារដល់អ្នកក្រីក្រដែរ។*(គួរអាន ៦៩:៣៣-៣៤)

សាសនាអ៊ីស្លាមថ្កោលទោសចំពោះរាល់អំពើអយុត្តិធម៌, ការរំលោភបំពាន, ភេរវកម្មប្រឆាំងនឹងជនស្លូតត្រង់។ ព្រះមានព្រះបន្ទូលថា៖ *...ហើយចូរពួកអ្នកកុំរំលោភបំពាន។ ពិតប្រាកដណាស់ព្រះអល់ឡោះ មិនសព្វព្រះទ័យនឹងពួកដែលរំលោភបំពានឡើយ។*(គួរអាន ២:១៩០)

ព្រះគម្ពីរគួរអានក៏បានចែងដែរថា៖ *ដោយមូលហេតុនេះហើយ ទើបយើងបានដាក់បញ្ញត្តិទៅលើអំបូរអ៊ីស្រាអែលថា ជាការពិតណាស់ អ្នកណាហើយបានសម្លាប់បុគ្គលណាម្នាក់ដោយគ្មានមូលហេតុ ឬបង្កវិនាសកម្មនៅលើផែនដី គឺហាក់បីដូចជាគេបានសម្លាប់មនុស្សលោកទាំងអស់។ ហើយអ្នកណាបានសង្គ្រោះជីវិតបុគ្គលណាម្នាក់ គឺហាក់បីដូចជាគេបានជួយសង្គ្រោះជីវិតមនុស្សលោកទាំងអស់។*(គួរអាន ៥:៣២)

---

[53] និទានដោយ អះម៉ាត់, ១២២៩៥។

អំពីការណ៍ដែលថា នៅក្នុងសាសនាអ៊ីស្លាមមានការសម្លាប់សាហាវឃោរឃៅនោះ ផ្ទុយទៅវិញអ្នកមូស្លីមថែមទាំងត្រូវបានគេលើកទឹកចិត្តឱ្យធ្វើល្អចំពោះសត្វ ហើយហាមប្រាមក្នុងការបង្កគ្រោះថ្នាក់ដល់ពួកវា។ នៅគ្រាមួយ ព្យាការីមូហាំម៉ាត់មានប្រសាសន៍ថា៖ *មានស្ត្រីម្នាក់ត្រូវបានគេធ្វើទោស(ក្នុងស្ថាននរក) ដោយសារតែនាងបានចងសត្វឆ្មាមួយក្បាលរហូតដល់វាងាប់។ ដោយសាររឿងនេះនាងត្រូវបានធ្លាក់ទៅក្នុងស្ថាននរក។ នាងបានឃុំឃាំងវា(ឆ្មា) មិនផ្តល់ចំណី និងទឹកដល់វា ហើយក៏មិនដោះលែងវាឱ្យមានសេរីភាពដើម្បីនឹងបានស៊ីសត្វល្អិតនៅលើដីផង។*[54]

លោកក៏បាននិទានផងដែរអំពីករណី ស្ត្រីពេស្យាម្នាក់បានឱ្យទឹកទៅសត្វសុនខមួយដែលកំពុងស្រេកទឹកស្ទើរតែងាប់ ហើយព្រះអល់ឡោះបានអភ័យទោសដល់បាបរបស់នាង។[55] *មានគេសួរព្យាការីថា៖ ឱ អ្នកនាំសារនៃព្រះ! តើពួកយើងនឹងទទួលបានការប្រោសប្រទានឬទេ ចំពោះការធ្វើល្អដាក់សត្វ? លោកមានប្រសាសន៍ថា នឹងមានការប្រោសប្រទាន ចំពោះរាល់អំពើល្អទៅកាន់សត្វមានជីវិតទាំងអស់ ឬជាមនុស្សក៏ដោយ។*[56]

សេចក្តីបង្រៀនរបស់សាសនាអ៊ីស្លាមផ្សព្វផ្សាយពីការសណ្តោសប្រណី និងការគោរពចំពោះអ្នកដែលមិនមែនជាមូស្លីមផងដែរ។ ព្យាការីមូហាំម៉ាត់មានប្រសាសន៍ថា៖ *អ្នកណាហើយដែលប្រព្រឹត្តអយុត្តិធម៌ ទៅលើអ្នកដទៃដែលមានកិច្ចព្រមព្រៀងគាំពារ(អាចនិយាយបានថា អ្នកមិនមែនជាមូស្លីម)ឬមិនបានផ្តល់សិទ្ធិគ្រប់គ្រាន់ដល់គេ ឬដាក់បន្ទុកលើសពីអ្វីដែលគេអាចទទួលយកបាន ឬយកអ្វីមួយពីគេប្រឆាំងនឹងឆន្ទៈគេ ខ្ញុំនឹងជាសត្រូវរបស់អ្នកនោះនៅថ្ងៃជំនុំជម្រះ។*[57]

---

[54] និទានដោយ មូស្លីម, ៥៨០៤។

[55] និទានដោយ អាល់ ប៊ូខរី, ៣៣៩២។

[56] និទានដោយ អាល់ ប៊ូខរី, ២៣២៣។

[57] និទានដោយ អាប៊ូ ដាវូត, ៣០៥៤។

សាសនាអ៊ីស្លាមប្រឆាំងដាច់ខាតចំពោះភាពអាត្មានិយម ហើយអំពាវនាវឱ្យមនុស្សស្រឡាញ់អ្នកដទៃឱ្យដូចស្រឡាញ់ខ្លួនឯងដែរ។ ព្យាការីលោកមានប្រសាសន៍ថា៖ *គេមិនរាប់ថាជាអ្នកមានជំនឿនោះទេ រហូតដល់អ្នកនោះស្រឡាញ់អ្នកដទៃឱ្យដូចស្រឡាញ់ខ្លួនឯង។*[58] សីលធម៌ល្អ និងការគោរពចំពោះស្ត្រីភេទ ក៏ជាផ្នែកមួយនៃសេចក្តីបង្រៀនរបស់សាសនាអ៊ីស្លាមដែរ។ ព្យាការីលោកមានប្រសាសន៍ថា៖ *អ្នកមានជំនឿដែលជំនឿរបស់គេពេញលេញបំផុតនោះ គឺនរណាហើយដែលមានអាកប្បកិរិយាល្អប្រសើរ។ ហើយអ្នកដែលល្អប្រសើរបំផុតក្នុងចំណោមអ្នកមានជំនឿនោះ គឺជានរណាហើយដែលបានប្រព្រឹត្តល្អបំផុតចំពោះស្ត្រី។*[59] ក៏មានហាទីសមួយទៀតដែរដែលថា៖ *មានបុរសម្នាក់បានមករកព្យាការី ហើយនិយាយថា ឱអ្នកនាំសារនៃព្រះ! តើនរណាដែលខ្ញុំត្រូវធ្វើល្អជាចម្បង? ព្យាការីឆ្លើយតបថា ម្តាយរបស់អ្នក។ បុរសនោះសួរថា បន្ទាប់មកនរណាទៀត? ព្យាការីឆ្លើយតបថា ម្តាយរបស់អ្នក។ បុរសនោះសួរម្តងទៀតថា បន្ទាប់មកនរណាទៀត? ព្យាការីឆ្លើយតបទៀតថា ម្តាយរបស់អ្នក។ នៅពេលបុរសនោះសួរជាលើកទីបួន ព្យាការីឆ្លើយតបថា ឪពុករបស់អ្នក។*[60] បើយោងតាមសេចក្តីបង្រៀនរបស់សាសនាអ៊ីស្លាម ផលបុណ្យដែលទទួលបានពីការបម្រើ និងមើលថែម្តាយម្នាក់ គឺនឹងទទួលបានស្ថានសួគ៌។ មានបុរសម្នាក់ដែលមកពិគ្រោះនឹងព្យាការី ដោយគេមានបំណងទៅធ្វើ**ជីហាត**(ចម្បាំងក្នុងផ្លូវព្រះ) ទាំងដែលគេមានម្តាយចាស់ជរាត្រូវមើលថែ។ ព្យាការីបានណែនាំគេថា៖ *ចូរនៅជាមួយគាត់ចុះ ដ្បិតស្ថានសួគ៌គឺនៅក្រោមបាតជើងរបស់គាត់។*[61]

ព្យាការីក៏មានប្រសាសន៍ដែរថា៖ *នរណាហើយដែលមានកូនស្រី ហើយមិនបង្អាប់នាង ឬមិនស្រឡាញ់កូនប្រុសជាងនាង គេនឹងបានចូលស្ថានសួគ៌។*[62] ព្យាការីក៏

---

[58] និទានដោយ អាត់ ទៀរមីហ្ស៊ី, ១២៦១។

[59] និទានដោយ អះម៉ាត់, ៧៣៧៤។

[60] និទានដោយ មូស្លីម, ៦៤៥២។

[61] និទានដោយ អាន់ ណាសាអ៊ី, ៣១០៦។

[62] និទានដោយ អះម៉ាត់, ៣១០៦។

បានលើកឡើងដែរថា៖ *នរណាហើយមានកូនស្រីពីរនាក់ ឬបងប្អូនស្រីពីរនាក់ ហើយប្រព្រឹត្តចំពោះពួកនាងបានល្អនោះ គេនឹងក្លាយជាមិត្តសំឡាញ់ជិតស្និទ្ធរបស់ខ្ញុំនៅឯស្ថានសួគ៌។*[63] ទាំងនេះហើយ ដែលសបញ្ជាក់យ៉ាងច្បាស់ថា ការប្រព្រឹត្តល្អចំពោះស្ត្រីគឺជាផ្នែកដ៏សំខាន់មួយក្នុងសេចក្ដីបង្រៀនរបស់សាសនាអ៊ីស្លាម ហើយនេះក៏ជាកិច្ចការមួយដែលអាចនាំមនុស្សឱ្យចូលស្ថានសួគ៌បានដែរ។

យោងតាមច្បាប់សារីអា បុរសគឺត្រូវមានការទទួលខុសត្រូវចំពោះសុខមាលភាពរបស់ស្ត្រី បើទោះជាបុរសនោះជាឪពុកនាង, ជាប្ដី, ជាកូន, ជាបងប្អូន ឬជាអាណាព្យាបាលនាងក៏ដោយ។ នាងមានសិទ្ធិក្នុងការទទួលចំណែកមរតករបស់នាង និងមានសិទ្ធិទទួលទ្រព្យបណ្ណាការរបស់នាងនៅពេលនាងរៀបការដែរ។ ហើយនាងក៏មានសិទ្ធិជ្រើសរើសរៀបការជាមួយបុរសណាដែលនាងស្រឡាញ់ពេញចិត្ត ហើយក៏មានសិទ្ធិរៀបការម្ដងទៀតក្រោយពីនាងលែងលះ និងមានរឿងជាច្រើនទៀត។[64] ព្រះ

---

[63] និទានដោយ អ៊ីបនូ អាប៊ី ស្ហៃបាស, ២១១៧៩។

[64] នៅក្នុងកណ្ឌគម្ពីរ លេវីវិន័យ ១៥:១៩-៣០ យើងឃើញថា៖ កាលណាស្ត្រីម្នាក់ធ្លាក់ឈាម ដោយមានរដូវ នាងត្រូវនៅក្នុងភាពមិនបរិសុទ្ធ អស់រយៈពេលប្រាំពីរថ្ងៃ។ អ្នកដែលប៉ះនាងនឹងទៅជាមិនបរិសុទ្ធ រហូតដល់ល្ងាច។ ពេលមានរដូវនោះគ្រែដែលនាងដេក ឬកៅអីដែលនាងអង្គុយ ក៏ទៅជាមិនបរិសុទ្ធដែរ។ អ្នកដែលប៉ះនឹងគ្រែនោះត្រូវតែបោកសម្លៀកបំពាក់ ព្រមទាំងលាងសម្អាតខ្លួនប្រាណ ហើយស្ថិតនៅក្នុងភាពមិនបរិសុទ្ធ រហូតដល់ល្ងាច។ អ្នកប៉ះនឹងកៅអីដែលនាងបានអង្គុយត្រូវតែបោក សម្លៀកបំពាក់ ព្រមទាំងលាងសម្អាតខ្លួនប្រាណ ហើយត្រូវស្ថិតនៅក្នុងភាពមិនបរិសុទ្ធ រហូតដល់ល្ងាច។ ប្រសិនបើមាននរណាម្នាក់ប៉ះនឹងវត្ថុអ្វីមួយនៅលើគ្រែ ឬកៅអីដែលនាងអង្គុយ អ្នកនោះត្រូវស្ថិតនៅក្នុងភាពមិនបរិសុទ្ធ រហូតដល់ល្ងាច។ ប្រសិនបើមានបុរសម្នាក់រួមដំណេកជាមួយនាងក្នុងអំឡុងពេលនាងមានរដូវ បុរសនោះក៏ទៅជាមិនបរិសុទ្ធ អស់រយៈប្រាំពីរថ្ងៃ ហើយគ្រែដែលគេដេកនោះក៏មិនបរិសុទ្ធដែរ។ កាលណាស្ត្រីម្នាក់ធ្លាក់ឈាមខុសពីធម្មតា ឬធ្លាក់ឈាមច្រើនថ្ងៃជាងពេលមានរដូវ នាងត្រូវស្ថិតនៅក្នុងភាពមិនបរិសុទ្ធ ក្នុងអំឡុងពេលធ្លាក់ឈាមនោះ ដូចគ្រានាងមានរដូវដែរ។ ពេលនោះ គ្រែដែលនាងដេក ឬកៅអីដែលនាងអង្គុយ នឹងទៅជាមិនបរិសុទ្ធដូចពេលនាងមានរដូវដែរ។ អ្នកដែលប៉ះនឹងគ្រែនោះត្រូវតែបោកសម្លៀកបំពាក់ ព្រមទាំងលាងសម្អាតខ្លួនប្រាណ ហើយស្ថិតនៅក្នុងភាពមិនបរិសុទ្ធ រហូតដល់ល្ងាច។ កាលណានាងឈប់ធ្លាក់ឈាមហើយ នាងត្រូវ

អល់ឡោះមានព្រះបន្ទូលថា៖ *ហើយប្រពន្ធមានសិទ្ធិ(ចំពោះប្ដី) ដូចដែលពួកនាងមានភារកិច្ច(ប្រតិបត្តិចំពោះប្ដី)ដោយអំពើល្អ។* (គួរអាន ២:២២៨)

សាសនាអ៊ីស្លាម លើកទឹកចិត្តឱ្យមនុស្សម្នាប្រព្រឹត្តល្អចំពោះឪពុកម្ដាយ ហើយប្រព្រឹត្តដោយទឹកចិត្តមេត្តាចំពោះពួកគាត់ បើទោះជាពួកគាត់ប្រឆាំងនឹងសាសនាអ៊ីស្លាមក៏ដោយ។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ហើយយើងបានបង្គាប់ដល់មនុស្សលោក(ឱ្យកតញ្ញូ) ចំពោះឪពុកម្ដាយរបស់គេ។ ម្ដាយរបស់គេបានពរពោះរូបគេដោយសុខភាពចុះខ្សោយជាលំដាប់។ ហើយផ្ដាច់បំបៅគេក្នុងអាយុពេលពីរខួប។ ដូច្នេះ ចូរអ្នកដឹងគុណចំពោះយើង និងឪពុកម្ដាយរបស់អ្នកចុះ។ ចំពោះយើងគឺជាទីវិលត្រឡប់(ក្រោយពេលស្លាប់)។ ហើយប្រសិនបើគាត់ទាំងពីរ(ឪពុកម្ដាយ)ព្យាយាមជម្រុញ ឱ្យអ្នកធ្វើស្ហ៊ីរិក(គោរពព្រះដទៃ)រួមជាមួយយើង(ព្រះអល់ឡោះ) នូវអ្វីដែលអ្នក*

---

រង់ចាំអស់រយៈពេលប្រាំពីរថ្ងៃទៀត ទើបនាងអាចធ្វើពិធីជម្រះកាយឱ្យបរិសុទ្ធ។ នៅថ្ងៃទីប្រាំបី នាងត្រូវយកលលកពីរ ឬព្រាបជំទើរពីរ ទៅជូនបូជាចារ្យនៅត្រង់មាត់ទ្វារពន្លាជួបព្រះអម្ចាស់។ បូជាចារ្យយកសត្វមួយ ថ្វាយជាយញ្ញបូជារំដោះបាប និងសត្វមួយទៀតថ្វាយជាតង្វាយដុតទាំងមូល។ បន្ទាប់មក បូជាចារ្យធ្វើពិធីជម្រះបាបឱ្យស្ត្រីធ្លាក់ឈាម ដែលបណ្ដាលឱ្យនាងទៅជាមិនបរិសុទ្ធនោះ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់។

គម្ពីរបរិសុទ្ធមិនត្រឹមតែចាត់ទុកស្ត្រីភេទថា មិនមានភាពជ្រះស្អាតពេញមួយជីវិតនាង ហើយចាត់ទុកនាងថាជាប្រភពនៃភាពមិនបរិសុទ្ធប៉ុណ្ណោះទេ ហើយថែមទាំងប្រព្រឹត្តចំពោះនាងដូចជាជនល្មើសដែលបានប្រព្រឹត្តទោសកំហុស ដែលត្រូវការតង្វាយ ទាំងដែលវាមិនមែនជាជម្រើសរបស់នាងផងនោះ។ មិនតែប៉ុណ្ណោះគម្ពីរបរិសុទ្ធពិពណ៌នាអំពីស្ត្រីភេទតាមរបៀបស្អប់ខ្ពើម និងបន្ទុះបង្អាប់ ដូចមានក្នុង ១ធីម៉ូថេ ៥:១០ និយាយថា កិច្ចការល្អ ដែលគេទទួលស្គាល់នោះគឺ ដោយស្ត្រីមេម៉ាយទៅលាងជើងជូនពួកបរិសុទ្ធ។ រីឯស្រីដែលប្ដីស្លាប់ចោលមិនអាចរៀបការនឹងនរណាផ្សេងបានឡើយក្រៅពីបងប្អូនបង្កើតរបស់ប្ដីនោះ។(ទុតិយកថា ២៥:៥) នាងមិនមានសិទ្ធិទទួលមរតកទេបើសិនជាមានសាច់ញាតិជាបុរស។(ទុតិយកថា ២១:១៥-១៧ និង ជនគណនា ២៧:១-១១) ហើយបុរសអាចមានសិទ្ធិគ្រប់គ្រាន់ក្នុងការលក់កូនស្រីរបស់ខ្លួន។(និក្ខមនំ ២១:៧) ជាងនេះទៅទៀត ស្ត្រីដែលលែងលះរួចគឺមិនអនុញ្ញាតឱ្យរៀបការម្ដងទៀតនោះទេ។(ម៉ាថាយ ៥:៣២)

*មិនបានដឹងទេនោះ ចូរអ្នកកុំធ្វើតាមពួកគាត់ទាំងពីរ។ តែអ្នកត្រូវកតញ្ញូចំពោះគាត់ទាំងពីរនៅក្នុងលោកិយនេះដោយអំពើល្អ។* (គួរអាន ៣១:១៤-១៥)

សាសនាអ៊ីស្លាមក៏អំពាវនាវឱ្យមានការប្រព្រឹត្តដោយក្តីមេត្តា និងក្តីអាណិតអាសូរដល់អ្នកដទៃ។ ព្យាការីមានប្រសាសន៍ថា៖ *ភ្លើងនរកគឺត្រូវបានហាមឃាត់ចំពោះនរណាហើយ ដែលប្រព្រឹត្តដាក់មនុស្សម្នាដោយសេចក្តីល្អ, ដោយការយល់ពីគ្នា, ហើយនិងក្តីមេត្តា និងងាយទំនាក់ទំនង។*[65] ចំពោះអ្នកដែលឃោរឃៅ,ក្រអឺតក្រទម និងមិនចេះគិតពិចារណា ព្យាការីបានរាប់ពួកគេនៅក្នុងចំណោមអ្នករស់នៅក្នុងស្ថាននរក។[66]

សាសនាអ៊ីស្លាមផ្តល់តម្លៃ និងការគោរពចំពោះសិទ្ធិមនុស្សហើយការអនុវត្តច្បាប់សារីអាដោយធានាបាននូវការរស់នៅប្រកបដោយសន្តិភាព និងភាពសុខដុមរមនារវាងគ្នានឹងគ្នា។ ព្យាការីមានប្រសាសន៍ថា៖ *ការខាតបង់ក្នុងចំណោមប្រជាជនខ្ញុំនោះគឺ អ្នកដែលមកដល់ថ្ងៃជំនុំជម្រះ ជាមួយនឹងការសឡាត(ថ្វាយបង្គំ), ការបួសតមអាហារ និងការបរិច្ចាគទាន ប៉ុន្តែគេក៏នាំមកជាមួយគេដែរ(នូវអំពើអាក្រក់) ដូចជា គេបានជេរប្រមាថ, រំលោភបំពាន, លួច, ប្រើហិង្សា ឬសម្លាប់អ្នកដទៃ។ ដូច្នេះហើយ អ្នកដែលគេធ្វើខុសចំពោះនោះ(អ្នករងគ្រោះ) នឹងយកផលបុណ្យពីគេ(អ្នកប្រព្រឹត្ត) ដើម្បីជាថ្នូរនឹងអ្វីដែលអ្នក(ប្រព្រឹត្ត)ធ្វើខុសចំពោះគេ។ នៅពេលផលបុណ្យរបស់គេ(អ្នករងគ្រោះ)នោះពេញលេញហើយ អ្នកនោះ(អ្នកប្រព្រឹត្ត)នៅតែជំពាក់ពួកគេទៀត។ នោះអំពើអាក្រក់របស់ពួកគេ(អ្នករងគ្រោះ) នឹងត្រូវបន្ថែមទៅលើគេ(អ្នកប្រព្រឹត្ត) រហូតដល់គេ(អ្នកប្រព្រឹត្ត)ត្រូវបានបោះចូលទៅក្នុងភ្លើង(នរក)។*[67]

សាសនាអ៊ីស្លាមអំពាវនាវឱ្យប្រព្រឹត្តយុត្តិធម៌ និងមានការអត់ឱនសូម្បីតែចំពោះសត្រូវរបស់ខ្លួន។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ម្នាលអស់អ្នកមានជំនឿ! ចូរពួក*

---

[65] និទានដោយ អះម៉ាត់, ៣៩៣៧។

[66] និទានដោយ មូស្លីម, ៧១៣៦។

[67] និទានដោយ មូស្លីម, ៦៥៣១។

*អ្នកតាំងខ្លួនជាអ្នកដែលប្រកាន់ខ្ជាប់នូវការពិតដើម្បីព្រះអល់ឡោះ ជាអ្នកដែលធ្វើសាក្សីដោយយុត្តិធម៌។ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ធ្វើជាសាក្សីដើម្បីព្រះអល់ឡោះ។ ហើយចូរកុំបណ្តោយឱ្យចិត្តស្អប់ចំពោះក្រុមមួយ នាំឱ្យពួកអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ឱ្យសោះ។ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ព្រោះវាជិតបំផុតក្នុងការកោតខ្លាចព្រះអល់ឡោះ។ ហើយចូរពួកអ្នកកោតខ្លាចព្រះអល់ឡោះ។ ពិតប្រាកដណាស់ព្រះអល់ឡោះទ្រង់ជ្រាបបំផុតនូវអ្វីដែលពួកអ្នប្រព្រឹត្ត។*(គួរអាន ៥:៨)

សាសនាអ៊ីស្លាមក៏ជាសាសនាមួយដែលបំពេញតម្រូវការទាំងខាងរូបកាយ និងព្រលឹងវិញ្ញាណ ហើយសមស្របសម្រាប់មនុស្សគ្រប់រូប និងគ្រប់សម័យកាលទាំងអស់។ សាសនាអ៊ីស្លាមបានបង្គាប់ឱ្យមនុស្សប្រព្រឹត្តល្អ និងហាមប្រាមមនុស្សពីការប្រព្រឹត្តទង្វើអាក្រក់។[68] មុនពេលលោកក្លាយជាព្យាការី លោកបានរៀបការជាមួយស្ត្រី

[68] ដោយមានភស្តុតាងជាច្រើនសម្អាងថា ព្យាការីមូហាំម៉ាត់ពិតជាមនុស្សមិនចេះអក្សរយ៉ាងប្រាកដ ហើយលោករស់នៅក្នុងតំបន់ដែលមានកង្វះខាតខាងការអប់រំ។ ថ្វីបើយ៉ាងនេះក្តី លោកបាននាំមកនូវ ច្បាប់ដ៏ពេញលេញ ដែលគ្របដណ្តប់លើបញ្ហាជាច្រើននៃជីវិតមនុស្សគ្រប់សម័យកាល ទាំងក្នុងសេចក្តីជំនឿ, កិច្ចការគោរពសក្ការៈ, កិច្ចព្រមព្រៀង, ក្រមសីលធម៌ ។ល។ លោកក៏បង្ហាញពីប្រព័ន្ធអនុវត្តន៍ដ៏ល្អឥតខ្ចោះដូចជា អាពាហ៍ពិពាហ៍, ការលែងលះ, ការពរពោះ, ការចិញ្ចឹមបីបាច់កូន, អាហារកិច្ចចំពោះកូន(ក្រោយការលែងលះ), ការបែងចែកមរតក, ទំនាក់ទំនងក្នុងក្រុមគ្រួសារ និងអ្នកជិតខាង, ទោសទណ្ឌចំពោះបទល្មើស, សិទ្ធិមនុស្ស, នយោបាយ, សេដ្ឋកិច្ច, ជីវិតសង្គម, ហើយនិងឥរិយាបថចំពោះខ្លួនឯងទាំងការបរិភោគ, ការផឹក, ការស្លៀកពាក់, ការធ្វើដំណើរ, ការគេង, ការភ្ញាក់ពីគេង, ការស្វាប, ការកណ្តាស់, ការសុំការអនុញ្ញាត, ការសួរសុខទុក្ខអ្នកជម្ងឺ, អនាម័យផ្ទាល់ខ្លួន ។ល។ ព្យាការីលោកមិនបាននាំយករឿងរ៉ាវទាំងនេះចេញពីខ្លួនលោកមកទេ ហើយក៏មិនដែលអះអាងថាចំណេះដឹងដ៏មហោស្ចារ្យនេះជារបស់លោកដែរ។

ប្រសិនបើព្យាការីមូហាំម៉ាត់លោកមានគោលបំណង ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ឬដើម្បីឱ្យគេលើកតម្កើងលោកនោះ វាគឺផ្ទុយស្រឡះនឹងអ្វីដែលលោកបានបង្គាប់អ្នកដើរតាមលោកឱ្យប្រព្រឹត្តការណ៍មួយចំនួនដូចជា ការយកទឹកជម្រះកាយ និងការថ្វាយបង្គំ៥ដងក្នុងមួយថ្ងៃ, ការជម្រះកាយក្រោយរួមមេត្រីនឹងដៃគូ, ការបួសតមអាហារ ដែលសូម្បីតែទឹកក៏មិនអាចផឹកបាន ក្នុងរយៈពេលពេញមួយខែតាំងពីថ្ងៃរះរហូតដល់ថ្ងៃលិច នៅរៀងរាល់ឆ្នាំ(ជាពិសេសនៅស្រុកអារ៉ាប់ដែលជាតំបន់វាលខ្សាច់ ហើយកម្តៅស្ទើរទ្រាំមិនបាន) ហើយថែមទាំងហាមឃាត់ពីអ្វីដែលមនុស្ស

ម្នាក់ឈ្មោះ **ខឌីចះ** ជាស្ត្រីម្នាក់ដែលមានទ្រព្យស្តុកស្តម្ភនៅក្រុងម៉ាក្កះ។ នៅពេលដំណឹងដែលលោកក្លាយជាព្យាការីត្រូវបានមហាជនដឹងសុសសាយនោះ មនុស្សម្នាបានផ្តល់ឱ្យលោកមុខតំណែង ទ្រព្យសម្បត្តិ រហូតដល់ផ្តល់រាជ្យជូនលោកក្លាយជាស្តេចរបស់ពួកគេទៀត ធ្វើយ៉ាងណាឱ្យតែលោកព្រមបោះបង់ការអំពាវនាវឱ្យមនុស្សជឿលើព្រះអល់ឡោះ។ លោកបានបដិសេធការផ្តល់ឱ្យទាំងអស់នេះ ហើយបន្តនៅលើផ្លូវដែលព្រះបានជ្រើសរើសសម្រាប់លោក, ជាផ្លូវដែលរងទុក្ខនិងការឈឺចាប់សព្វគ្រប់បែបយ៉ាង តែជាប្រយោជន៍ដើម្បីចែកចាយព្រះបន្ទូលនៃព្រះ។ ថ្វីបើមានអ្នកមានអំណាច និងពួកអាជ្ញាធរជាច្រើនស្ថិតក្រោមដៃរបស់លោក ក្រោយពេលលោកបានចែកចាយព្រះបន្ទូលហើយនោះ លោកនៅតែរស់នៅក្នុងជីវភាពសាមញ្ញបំផុត រស់នៅដោយគ្មានភាពស្តុកស្តម្ភ ទាំងដែលលោកអាចទទួលបាន បើលោកចង់។ លោកសម្រាន្តនៅលើកន្ទេលត្បាញគគ្រាតមួយ ហើយរស់នៅក្នុងផ្ទះដែលសាងឡើងពីដីភក់។ ភរិយារបស់លោកបានឱ្យដឹងថា៖ *ច្រើនលើកច្រើនសាណាស់ដែលព្យាការី ហើយនិងគ្រួសាររបស់លោក គ្មានអាហារទទួលទាន ប៉ុន្មានយប់ជាប់ៗគ្នា។ ហើយភាគច្រើននំប៉ុងដែលពួកគាត់យកមកចម្អែតពោះនោះគឺធ្វើពីស្រូវសាលី។*[69] នៅគ្រាដែលលោកទទួលមរណភាព ខែលរបស់លោកគឺនៅនឹងតួបបញ្ចាំរបស់ជនជាតិយូដាម្នាក់ ដើម្បីដូរនឹងស្រូវសាលីយកមកធ្វើនំប៉ុងសម្រាប់ក្រុមគ្រួសាររបស់លោក។

---

ភាគច្រើនប្រព្រឹត្តជាទូទៅដូចជា ការផឹកទឹក, ការប្រព្រឹត្តខុសសីលធម៌ខាងកាម, ការចងការប្រាក់, ការលេងល្បែងស៊ីសង ។ល។ ការណ៍នេះក៏បានលើកឡើងផងដែរនៅក្នុងកណ្ឌគម្ពីរ ទុតិយកថា ១៨:២០ និង យេរេមា ១៤:១៥ ដែលថាព្រះបានដាក់ទោសចំពោះអ្នកណាហើយ ដែលតាំងខ្លួនជាព្យាការីក្លែងក្លាយ ហើយព្រះបានដាក់ទោសព្យាការីនោះ ដោយប្រហារជីវិតមិនដល់មួយឆ្នាំផង។ (យេរេមា ២៨:១៥-១៧) ព័ន្ធកិច្ចរបស់ព្យាការីមូហាំម៉ាត់ឯណោះវិញ មានរយៈពេលដល់ទៅ២៣ឆ្នាំ ហើយមកដល់សព្វថ្ងៃនេះសាសនាអ៊ីស្លាម ក្លាយជាសាសនាដែលរីកចម្រើនលឿនជាងគេបំផុតក្នុងពិភពលោក។ មិនតែប៉ុណ្ណោះក្នុងអំឡុងពេលលោកមានជីវិត លោកត្រូវបានព្រះជាម្ចាស់គាំពារនឹងគាំទ្រវាល់ពេលទាំងអស់។

[69] និទានដោយ អាត់ ទៀរមីហ្ស៊ី, ២៤០០។

លោកបានលះបង់សព្វគ្រប់នៃជីវិតរបស់លោក ដើម្បីជាប្រយោជន៍ដល់មនុស្ស ឱ្យបានទទួលជឿលើព្រះអល់ឡោះថាជាព្រះពិតតែមួយអង្គគត់។ ព្រះទ្រង់មានព្រះបន្ទូលថា៖ *ហើយយើងមិនបានបង្កើតជិន(អមនុស្ស) និងមនុស្សលោកក្រៅពីឱ្យពួកគេគោរពសក្ការៈមកចំពោះយើងឡើយ។* (គួរអាន ៥១:៥៦) ទាំងនេះគឺក្នុងបំណងចង្អុលបង្ហាញជិននិងមនុស្សទាំងអស់ឱ្យមកកាន់សុភមង្គលដ៏ពិតប្រាកដ ហើយនឹងសង្គ្រោះពួកគេចេញពីមហន្តរាយនានាទាំងលោកិយនេះ និងលោកខាងមុខ។

ព្យាការីមូហាំម៉ាត់ ដែលជាព្យាការី និងជាអ្នកនាំសារចុងក្រោយបង្អស់របស់ព្រះបានទទួលមរណភាពក្នុងឆ្នាំ៦៣២នៃគ្រិស្តសករាជ ដោយបន្សល់ទុកឱ្យយើងរាល់គ្នានូវព្រះគម្ពីរគួរអាន ជាព្រះរាជសារចុងក្រោយរបស់ព្រះ ហើយនិងបន្សល់ទុកនូវសេចក្តីបង្រៀនរបស់លោកផ្ទាល់ដែលជាការចង្អុលបង្ហាញដល់មនុស្សជាតិ រហូតដល់ថ្ងៃដែលព្រះប្រស់មនុស្សទាំងអស់ឱ្យរស់ឡើងវិញ។

អ្នកនិពន្ធជនជាតិអាមេរិកម្នាក់ឈ្មោះ **ម៉ៃឃើល ហាត** (Michael Hart) បានលើកឡើងនៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា **បុគ្គល១០០រូប ៖ ចំណាត់ថ្នាក់បុគ្គលដែលមានឥទ្ធិពលក្នុងប្រវត្តិសាស្ត្រ។** លោកបានដាក់ព្យាការីស្ថិតក្នុងចំណាត់ថ្នាក់លេខ១ ដោយមានឃ្លាថា *ជាបុរសម្នាក់នៅក្នុងប្រវត្តិសាស្ត្រ ដែលជាបុគ្គលជោគជ័យបំផុតទាំងផ្នែក អាណាចក្រ និង សាសនាចក្រ។* លក្ខណៈពិសេសប្លែកគេនេះ បានធ្វើឱ្យលោកក្លាយជាមនុស្សដែលជោគជ័យបំផុត និងជាតួអង្គដែលមានឥទ្ធិពលបំផុតនៅលើពិភពលោក។ លោក **វីលៀម មួរ** (William Mur) ជាប្រវត្តិវិទូជនជាតិស្កុតឡេន បានលើកឡើងពីការលើកតម្កើង និងភាពច្បាស់លាស់នៃប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ និងបានលើកឡើងថាសាសនារបស់ព្យាការីគឺមានភាពងាយស្រួល។ លោកក៏បានគូសបញ្ជាក់ផងដែរថា ព្យាការីបានបំពេញនូវកិច្ចការដ៏ល្អអស្ចារ្យ ហើយពុំមានមនុស្សណាម្នាក់នៅក្នុងប្រវត្តិសាស្ត្រធ្លាប់ជោគជ័យលើការដាស់ស្មារតី និងព្រលឹងវិញ្ញាណ និងធ្វើឱ្យអំពើល្អនិងអំពើប្រកបដោយគុណធម៌បានរស់រានឡើង ក្នុងរយៈពេលដ៏ខ្លីដូចដែលព្យាការីធ្លាប់ធ្វើនោះទេ។

ប្រវត្តិវិទូដ៏ល្បីល្បាញមួយរូបទៀតគឺលោក **ចច ប៊ឺណាត ស្ហ** (George Bernard Shaw) បានសរសេរនៅក្នុងសៀវភៅចំណងជើង The Genuine Islam ភាគទី១ ល.៨ ចេញផ្សាយឆ្នាំ១៩៣៦ ថា ពិភពលោកពិតជាត្រូវការយ៉ាងចាំបាច់ នូវមនុស្សដែលមានបញ្ញាញាណដូចព្យាការីមូហាំម៉ាត់។ ក្នុងនាមលោកជាព្យាការី លោកតែងតែទុកសេចក្តីជំនឿរបស់លោកក្នុងការគោរព និងកិត្តិយស។ ប្រវត្តិវិទូរូបនេះបានបន្ថែមថា សាសនាអ៊ីស្លាមជាសាសនាមួយដែលអាចចុះសម្រុងជាមួយនឹងគ្រប់អារ្យធម៌ គ្រប់សម័យកាល ហើយអះអាងថានឹងជ្រាបដល់ទ្វីបអឺរ៉ុប ទោះបីជាមានការយល់ខុសច្រើនពីព្យាការីមូហាំម៉ាត់ ហើយយល់ច្រឡំថាលោកជាសត្រូវនឹងសាសនាគ្រិស្តក៏ដោយចុះ។ លោក ចច បានសរសេរបន្ថែមទៀតថា៖ *ខ្ញុំបានសិក្សាពីព្យាការី លោកជាមនុស្សដ៏អស្ចារ្យមួយរូប ហើយក្នុងការយល់ឃើញរបស់ខ្ញុំ លោកប្រាកដជាមិនមែនជាអ្នកប្រឆាំងនឹងលោកយេស៊ូឡើយ។ លោកគួរតែត្រូវបានគេហៅថា អ្នកសង្គ្រោះមនុស្សជាតិ។ ខ្ញុំជឿជាក់ថា ប្រសិនបើមនុស្សដូចលោកមានអំណាចពេញដៃនៅសម័យទំនើបនេះ លោកនឹងដោះស្រាយបញ្ហាបានជោគជ័យ ក្នុងផ្លូវដែលនាំឱ្យមានសន្តិភាព និងសុភមង្គលច្រើនបំផុត..។*

លោក **អាល់ហ្វុង ដឺ ឡាម៉ាតាំង** (*Alphonse de Lamartine*) ជាកវីនិពន្ធជនជាតិបារាំងដ៏ល្បីល្បាញម្នាក់ បាននិយាយនៅក្នុងសៀវភៅរបស់លោកចំណងជើងថា *Histoire de la Turquie (1854)* ថា៖ មិនដែលមានមនុស្សណាចាត់ខ្លួនឯងដោយស្ម័គ្រចិត្ត ក្នុងគោលបំណងដ៏វិសេសវិសាលមួយ ហើយគោលបំណងនេះគឺហួសពីអ្វីដែលមនុស្សធម្មតាអាចយល់បាន គឺការបំផ្លាញជំនឿខុសឆ្គង រវាងមនុស្សហើយនិងព្រះ ...។ ក៏មិនដែលមានមនុស្សណាអាចធ្វើឱ្យសម្រេចជោគជ័យក្នុងរយៈពេលដ៏ខ្លី ដោយបន្សល់ទុកនូវការផ្លាស់ប្តូរដ៏ធំមហិមាសម្រាប់ពិភពលោក..។ បើសិនជា គោលបំណងរបស់លោកមានភាពខ្ពង់ខ្ពស់ ហើយមធ្យោបាយដែលប្រើមានភាពសន្សំសំចៃនោះ លទ្ធផលដែលធ្វើឱ្យបានសម្រេចយ៉ាងឆាប់រហ័សនោះ គឺផ្សំដោយបុគ្គលិកលក្ខណៈទាំង៣របស់គាត់។ តើមាននរណាអាចយកមនុស្សណាម្នាក់ក្នុងប្រវត្តិសាស្ត្រទំនើបទៅប្រៀបនឹងមូហាំម៉ាត់នោះ? លោកបានពាល់ដល់ព្រលឹងវិញ្ញាណ, លោកបានរកឃើញព្រះគម្ពីរ ដែលតួអក្សរនីមួយៗក្លាយជាច្បាប់បញ្ញត្តិ, ស្មារតីរួបរួមមនុស្សគ្រប់

ភាសាគ្រប់ពូជសាសន៍... ការអត់ធ្មត់ដើម្បីទទួលបានជោគជ័យ, លោកបានពលីដើម្បីដើរតាមគំនិតមួយ.. សរុបជារួមមក ទាំងនេះជាស្តង់ដាររបស់មនុស្ស ដែលគួរយកមកសម្រាប់ជាសូចនាករចំពោះមនុស្សគ្រប់គ្នា។ ហើយយើងក៏គួរតែសួរថា៖ តើមានមនុស្សណាល្អអស្ចារ្យជាងលោកទៀតនោះ?

បណ្ឌិត **វ៉ាកលីរី** *(Vaglieri)* បានសរសេរនៅក្នុងសៀវភៅ *Apologia dell' Islamismo* ថា៖ មូហាំម៉ាត់ ជាអ្នកបង្រៀននៃសាសនារបស់ព្រះ ជាសុភាពបុរស និងមានក្តីមេត្តា សូម្បីតែចំពោះសត្រូវផ្ទាល់ខ្លួនរបស់លោកក៏ដោយ។ ក្នុងខ្លួនលោកគឺរួមបញ្ចូលដោយ យុត្តិធម៌ និងក្តីមេត្តា ជាគុណធម៌ខ្ពស់បំផុតដែលចិត្តគំនិតមនុស្សដែលអាចគិតដល់។ មិនពិបាករកអ្វីមកសម្អាងពីការលើកឡើងបែបនេះទេ ពីព្រោះមានឧទាហរណ៍ជាក់ស្តែងជាច្រើនដែលយើងអាចរកឃើញក្នុងជីវប្រវត្តិរបស់លោក។

បណ្ឌិត **ហ្កូតលីប វីលហែម លីថនឺ** (*Gottlieb Wilhelm Leitner*) បាននិយាយថា៖ ខ្ញុំគ្មានអ្វីសន្និដ្ឋានឱ្យល្អជាងនេះទេ ក្រៅពីការបង្ហាញក្តីសង្ឃឹមថានឹងមានថ្ងៃមួយដែលគ្រិស្តបរិស័ទ នឹងគោរពចំពោះលោកយេស៊ូ ហើយបន្ថែមទៅដោយការគោរពចំពោះមូហាំម៉ាត់។ មានលក្ខណៈដូចគ្នាសាមញ្ញច្រើនរវាងសាសនាអ៊ីស្លាម និងសាសនាគ្រិស្ត។ ហើយគេនឹងក្លាយជាគ្រិស្តបរិស័ទល្អប្រសើរម្នាក់ ប្រសិនបើគេគោរពសេចក្តីពិតដែលព្យាការីមូហាំម៉ាត់បាននាំមក។ (ស្រង់ចេញពីសៀវភៅ *The Islamic Review* ចេញផ្សាយខែ ឧសភា ឆ្នាំ ១៩៦១ ទំព័រទី៦ ដល់ទី១១)

# គោលជំនឿនៃ
# សាសនាអ៊ីស្លាម
# និង សាសនាគ្រិស្ត

ជាទូទៅនិកាយជាច្រើននៃសាសនាគ្រិស្ត ជឿតាមគោលជំនឿទាំង ៥ មានដូចជា៖ ព្រះត្រៃឯក[70], ភាពជាព្រះរបស់លោកយេស៊ូ, ភាពជាព្រះបុត្រារបស់លោកយេស៊ូ, បាបពីកំណើត, ដង្វាយធួន[71]។

នៅក្នុងសាសនាអ៊ីស្លាម ភាពមានតែមួយអង្គគត់ នៃព្រះអល់ឡោះ ជាព្រះតែមួយអង្គគត់ដែលត្រូវគោរពសក្ការៈ និងទូលអង្វរសុំជំនួយ គឺជាជំនឿជាមូលដ្ឋាននៃអ្នកមូស្លីមគ្រប់រូប។ នេះផ្ទុយពីលក្ខណៈរបស់ព្រះត្រៃឯកក្នុងនិកាយជាច្រើនរបស់សាសនាគ្រិស្ត។ សាសនាអ៊ីស្លាមមើលឃើញថា ការគោរពសក្ការៈចំពោះលោកយេស៊ូគឺជាការក្លាយជាអ្នកមិនជឿព្រះវិញ។[72] ដូចដែលមានលើក

---

[70] *Trinity* ព្រះបីអង្គរួមតែមួយ។ ក្រុមជំនុំខ្លះបកប្រែថា ព្រះត្រីឯក, ព្រះត្រៃឯក ឬ ព្រះឯកត្រីអង្គ ជាដើម។

[71] *Atonement* ការបកប្រែខ្លះប្រែថា ថ្លៃលោះ ឬ យញ្ញបូជាលោះបាប ជាដើម។ ក្នុងសៀវភៅនេះភាគច្រើនប្រើពាក្យ ថ្លៃលោះ ឬ ដង្វាយធួន ដែលមានន័យដូចគ្នា។

[72] លោក **វីល ឌូរ៉េន** សរសេរក្នុងសៀវភៅ *Story of Civilization* ភាគ១១ ទំព័រ២៧៦ ថា៖ សាសនាគ្រិស្តមិនបានមកបញ្ចប់លទ្ធិមិនជឿព្រះនោះទេ ផ្ទុយមកវិញគឺបន្តអនុវត្តលក្ខណៈនោះថែមទៀត។

ឡើងក្នុងព្រះគម្ពីរគួរអានថាការចាប់កំណើតរបស់លោកយេស៊ូ មិនមែនជាការចាប់កំណើតរបស់ព្រះជាអម្ចាស់នោះទេ ប៉ុន្តែលោកគឺជាព្យាការី និងជាអ្នកនាំសារ មិនខុសពីព្យាការីដទៃទៀតឡើយ លោកជាមនុស្សធម្មតានៅគ្រប់លក្ខខណ្ឌទាំងអស់។ សាសនាអ៊ីស្លាមក៏បដិសេធពីការណ៍ដែលលើកឡើងថាលោកយេស៊ូជាបុត្ររបស់ព្រះ ហើយក៏បដិសេធចំពោះ បាបពីកំណើត, យញ្ញបូជា និងដង្វាយធួនដែរ។

គោលលទ្ធិនៃសេចក្តីជំនឿរបស់សាសនាអ៊ីស្លាមមាន៦គឺ៖

1. ជឿលើព្រះអម្ចាស់តែមួយអង្គគត់
2. ជឿលើវត្តមាននៃបណ្តាទេវតា
3. ជឿលើព្រះគម្ពីរដែលបើកបង្ហាញមក
4. ជឿលើអ្នកនាំសាររបស់ព្រះ
5. ជឿលើថ្ងៃដែលព្រះប្រស់ឱ្យរស់ឡើងវិញ
6. ជឿលើព្រះលិខិត ទាំងល្អទាំងអាក្រក់ដែលព្រះបានកំណត់មក។

# ព្រះត្រៃឯក

គោលជំនឿនេះ ជាគោលជំនឿដែលគ្រិស្តបរិស័ទទូទាំងពិភពលោកប្រកាន់ខ្ជាប់។ ដោយការលើកឡើងពីវត្តមាននៃព្រះ៣អង្គ មានលក្ខណៈជាបុគ្គល ៣ ចែកដាច់ពីគ្នា រួមមាន៖ ព្រះបិតា, ព្រះបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។ យ៉ាងណាមិញ គួរឱ្យភ្ញាក់ផ្អើលដែរថាលោកយេស៊ូពុំដែលប្រសាសន៍សោះឡើយទាក់ទងនឹងព្រះ ៣ អង្គរួមគ្នាជាព្រះត្រៃឯក។ ហើយជាការពិតណាស់ពាក្យថា **ព្រះត្រៃឯក** គឺមិនមានក្នុងគម្ពីរបរិសុទ្ធសោះឡើយ។ លក្ខណៈយល់ដឹងរបស់លោកយេស៊ូទៅចំពោះព្រះនោះ គឺមិន

---

នេះគឺនិយាយចំពោះគ្រិស្តបរិស័ទដែលដើរតាមការបង្រៀនរបស់សាវ័កប៉ូល មិននិយាយពីគ្រិស្តបរិស័ទដែលដើរតាមលោកយេស៊ូដែលអំពាវនាវឱ្យគោរពសក្ការៈចំពោះព្រះតែមួយអង្គនោះទេ។

ខុសពីលក្ខណៈយល់ដឹងរបស់បណ្តាព្យាការីជំនាន់មុនឡើយ។ បណ្តាព្យាការីទាំងអស់បង្រៀនពី ភាពតែមួយអង្គគត់របស់ព្រះ ហើយមិនមែនជាព្រះត្រៃឯកឡើយ។[73]

លោកយេស៊ូក៏បានបញ្ជាក់ដូចនឹងអ្វីៗដែលព្រះបានបើកបង្ហាញមកដល់ព្យាការីមុនៗ។ ក្នុងកណ្ឌគម្ពីរម៉ាកុស ១២:២៨-៣០ សរសេរថា៖ *ពេលនោះមានអ្នកជំនាញខាងច្បាប់ម្នាក់មកដល់ហើយស្តាប់ពួកគេជជែកជាមួយនឹងលោក។ គាត់ឃើញថាលោកបានឆ្លើយសំណួររបស់ពួកគេយ៉ាងល្អប្រសើរ។ ដូច្នេះ គាត់សួរលោកថា តើបញ្ញត្តិមួយណាជាបញ្ញត្តិទីមួយ? លោកយេស៊ូមានប្រសាសន៍ឆ្លើយថា បញ្ញត្តិទីមួយគឺ ឱអ៊ីស្រាអែលអើយ! ចូរស្តាប់! ព្រះអម្ចាស់ជាព្រះរបស់យើង។ ព្រះមានតែមួយ*

---

[73] យោងតាមកណ្ឌគម្ពីរអេសាយ ៤៤:២៤ ៖ *យើងជាព្រះអម្ចាស់ដែលបានបង្កើតអ្វីៗទាំងអស់..។* និងអេសាយ ៤៥:៥ ដែលថា៖ *យើងនេះហើយជាព្រះអម្ចាស់ គ្មានព្រះអម្ចាស់ណាផ្សេងទៀតឡើយក្រៅពីយើង គ្មានព្រះជាម្ចាស់ណាទេ។* ហើយនៅក្នុងអេសាយ ៤៥:១៨ ៖ *ព្រះអម្ចាស់បានបង្កើតផ្ទៃមេឃ ព្រមទាំងបានសូនផែនដី ព្រះអង្គបានពង្រឹងផែនដីឱ្យរឹងមាំ ព្រះអង្គមិនបានបង្កើតផែនដីមកដើម្បីឱ្យនៅទទេឡើយ គឺព្រះអង្គបានបង្កើតផែនដី ឱ្យសត្វលោកស្នាក់អាស្រ័យនៅ។ ព្រះអង្គមានព្រះបន្ទូលថា គឺយើងនេះហើយជាព្រះអម្ចាស់ ក្រៅពីយើងគ្មានព្រះអម្ចាស់ឯណាទៀតទេ។* ក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៦:១៦ បានលើកឡើងពីព្រះថា៖ *មានតែព្រះអង្គមួយគត់ដែលមានព្រះជន្មអមតៈ។* អេសាយ ៤៦:៩ បញ្ជាក់ថា៖ *យើងជាព្រះជាម្ចាស់ ក្រៅពីយើងគ្មានព្រះណាទៀតទេ យើងជាព្រះជាម្ចាស់ គ្មានអ្វីផ្សេងទៀតអាចផ្ទឹមស្មើ នឹងយើងបានឡើយ។* ព្រះគម្ពីរគួរអាន ៣៩:៦២ចែងថា៖ *ព្រះអល់ឡោះគឺជាអ្នកដែលបានបង្កើតរាល់អ្វីៗទាំងអស់។ ហើយទ្រង់គឺជាអ្នកថែរក្សារាល់អ្វីៗទាំងអស់។* និងជំពូកទី ៦:១០២៖ *នោះហើយគឺព្រះអល់ឡោះជាព្រះអម្ចាស់នៃពួកអ្នក។ គ្មានព្រះអម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដ មានតែទ្រង់មួយអង្គគត់។ ទ្រង់ជាអ្នកបង្កើតសព្វអ្វីៗទាំងអស់ ដូច្នេះចូរពួកអ្នកគោរពសក្ការៈទៅចំពោះទ្រង់ចុះ។ ហើយទ្រង់ជាអ្នកគ្រប់គ្រងសព្វអ្វីៗទាំងអស់។* ជំពូកទី ២៥:៥៨ ៖ *ហើយចូរអ្នកប្រគល់ការទុកចិត្តចុះ លើព្រះអម្ចាស់ដែលគង់នៅហើយដែលមិនសុគត។* ជំពូកទី ៤២:១១ ៖ *គ្មានអ្វីមកប្រដូចនឹងទ្រង់បានឡើយ។ ហើយទ្រង់មហាឮ មហាទតឃើញ។* ដូច្នេះហើយសមហេតុផលបំផុតនោះគឺទ្រង់ស័ក្តិសមបំផុតជាព្រះដែលត្រូវគេគោរពសក្ការៈតែមួយអង្គគត់។

*ទេ ហើយអ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ឱ្យអស់ពីដួងចិត្ត អស់ពីព្រលឹង ឱ្យអស់ពីសមត្ថភាពរិះគិត និងឱ្យអស់ពីកម្លាំងកាយ។*

ភស្តុតាងមួយទៀតនៅក្នុងគម្ពីរបរិសុទ្ធ ឱ្យយើងដឹងថាលោកយេស៊ូជឿលើព្រះតែមួយអង្គគត់ ពុំមែនព្រះបីរួមតែមួយនោះឡើយ ដូចប្រសាសន៍របស់លោកថា៖ *អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គប៉ុណ្ណោះ។*(ម៉ាថាយ ៤:១០)

គោលជំនឿលើព្រះត្រៃឯក មានភាពមិនចុះសម្រុងនឹងសេចក្តីបង្រៀនរបស់លោកយេស៊ូ ហើយគោលជំនឿនេះកើតឡើងនៅប្រមាណ៣០០ឆ្នាំ ក្រោយពេលលោកយេស៊ូចាកចេញពីផែនដី។ កណ្ឌគម្ពីរម៉ាកុស, ម៉ាថាយ, លូកា និងយ៉ូហាន គ្មានផ្ទុកនូវទីសម្អាងណាមួយអំពីព្រះត្រៃឯកដែរ។ មិនថាលោកយេស៊ូក៏ដោយ ពួកសាវ័កក៏ដោយ ក៏ពុំមាននរណាធ្លាប់បង្រៀនពីគោលជំនឿនេះទេ។ ដូចគ្នានេះដែរ ពុំមានបញ្ញាវន្តជំនាន់ដើម ឬអ្នកដើរតាមលោកយេស៊ូណាម្នាក់បង្រៀនពីគោលជំនឿនេះដែរ។ គោលជំនឿនេះគឺត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាក្រុង **នីសៀរ** បន្ទាប់ពីមានការបែកបាក់និងជម្លោះយ៉ាងខ្លាំង។ ប៉ុន្តែក្រុមប្រឹក្សានេះបែរជាទទួលគំនិតពីខាងក្រុមសម្លេងភាគតិច ជាជាងក្រុមសម្លេងភាគច្រើនដែលជឿលើគោលជំនឿព្រះតែមួយអង្គ។

យ៉ាងណាមិញ បើគេយកគំនិតនៃព្រះត្រៃឯកមកពិចារណាតាមហេតុនិងផលនោះ គំនិតនេះមិនមាននិរន្តរភាពនោះទេ។ វាជំរុញឱ្យមនុស្សជឿលើព្រះ៣អង្គ ដែលមានលក្ខណៈមានដែនកំណត់ផង និងឥតដែនកំណត់ផង។ បើយើងគិតថាព្រះទាំង៣ឥតមានដែនកំណត់នោះ នឹងមានន័យថាមានលក្ខណៈឥតដែនកំណត់៣យ៉ាងដែរ នាំឱ្យមានន័យថា មានភាវៈដែលមានអំណាចឥតដែនកំណត់៣ផ្សេងគ្នា ឬនិយាយឱ្យងាយគឺមានព្រះ៣អង្គដាច់ដោយឡែកពីគ្នា។ ផ្ទុយមកវិញបើយើងគិតថាព្រះទាំង៣មានដែនកំណត់នោះ ទាំងតួអង្គព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធសុទ្ធតែមិនអាចជាព្រះបានទេ។ លក្ខណៈនៃព្រះត្រៃឯកគឺមានផ្ទុកតួអង្គ២ដែលជាភាវៈខុសគ្នា មួយគឺលោកយេស៊ូមានភាវៈជាមនុស្ស មួយទៀតគឺវិញ្ញាណបរិសុទ្ធមានភាវៈជា

ព្រលឹង។ ដោយសារតែភាពមិនសមហេតុផលនៃគោលជំនឿលើព្រះត្រៃឯកនេះ ហើយ ក្រុមជំនុំតែងតែឆ្លើយតបថាវាហួសពីអ្វីដែលមនុស្សធម្មតាអាចយល់បាន ហើយ គ្រាន់តែទទួលជឿទៅបានហើយ។

សាសនាអ៊ីស្លាមបង្រៀនពីលក្ខណៈសាមញ្ញងាយយល់ ចំពោះជំនឿលើព្រះតែមួយអង្គ។ លក្ខណៈជំនឿនេះបញ្ជាក់ពីឯកអគ្គភាពរបស់ព្រះអល់ឡោះ ហើយនិងលក្ខណៈដែលទ្រង់ខ្ពង់ខ្ពស់បំផុត គ្មានអ្វីជាដៃគូប្រៀបស្មើឡើយ។ ព្រះអង្គពឹងអាស្រ័យលើអង្គឯងផ្ទាល់ និងជាទីពឹងអាស្រ័យនៃសព្វអ្វីៗទាំងអស់ ដែលគ្មានអ្វីផ្សេងអាចពឹងអាស្រ័យបានឡើយ។ ព្រះអង្គមិនប្រសូតបុត្រណាមួយឡើយ ហើយទ្រង់ក៏មិនបានប្រសូតចេញពីនរណាដែរ។ គ្មានអ្វីមួយដែលកើតចេញពីទ្រង់ហើយមានភាពស្មើនឹងទ្រង់ ឬជាដៃគូទ្រង់ឡើយ។

លោកយេស៊ូបង្រៀនពីលក្ខណៈតែមួយអង្គគត់របស់ព្រះ ដូចមានបង្ហាញយ៉ាងច្បាស់នៅក្នុងគម្ពីរបរិសុទ្ធថា៖ *ខ្ញុំនិយាយអំពីអ្វីៗដែលខ្ញុំបានឃើញកាលដែលនៅជាមួយនឹងបិតារបស់ខ្ញុំ ហើយអ្នករាល់គ្នាក៏ធ្វើអ្វីៗដែលអ្នករាល់គ្នាបានឮពីឪពុករបស់អ្នករាល់គ្នាដែរ។ ពួកគេតបទៅលោកថា អប្រាហាំជាឪពុករបស់យើង។ លោកយេស៊ូមានប្រសាសន៍ទៅពួកគេថា ប្រសិនបើអ្នករាល់គ្នាជាកូនចៅរបស់អប្រាហាំ ចូរធ្វើអ្វីដែលអប្រាហាំបានធ្វើ។ ប៉ុន្តែឥឡូវនេះអ្នករាល់គ្នាកំពុងរកវិធីសម្លាប់ខ្ញុំ ដែលជាមនុស្ស*[74] *ម្នាក់បានប្រាប់អ្នករាល់គ្នានូវសេចក្តីពិតដែលខ្ញុំបានឮពីព្រះ។ អប្រាហាំមិនបានធ្វើដូច្នេះទេ។* (យ៉ូហាន ៨:៣៨-៤០)

---

[74] ក្នុងគម្ពីរភាសាខ្មែរខ្លះគេបកប្រែថា *ជាអ្នក* ដោយបំបាត់ចោលពាក្យថា *ជាមនុស្ស* ។ លោកយេស៊ូទទួលថាលោកជាមនុស្ស ឯព្រះវិញមានព្រះបន្ទូលថា៖ *ព្រោះយើងជាព្រះជាម្ចាស់មិនមែនជាមនុស្សទេ។* (ហូសេ ១១:៩) *ព្រះជាម្ចាស់មិនមែនមនុស្សលោកទេ... ក៏មិនមែនជាកូនមនុស្សដែរ។* (ជនគណនា ២៣:១៩) *វិញ្ញាណយើងនឹងមិននៅក្នុងមនុស្សជារៀងរហូតឡើយ ពីព្រោះគេជាសាច់ឈាមប៉ុណ្ណោះ។* (លោកុប្បត្តិ ៦:៣)

ដូចគ្នានេះដែរលោកយេស៊ូមានប្រសាសន៍ថា៖ *ដើម្បីបានជីវិតដែលគ្មានទីបញ្ចប់ ពួកគាត់ត្រូវស្គាល់ទ្រង់ដែលជាព្រះពិតតែមួយឱ្យបានច្បាស់ ព្រមទាំងយេស៊ូគ្រិស្ត ដែលលោកបានចាត់ឱ្យមក។ ខ្ញុំបានតម្កើងទ្រង់នៅផែនដី ដោយបានបង្ហើយកិច្ចការដែលទ្រង់បានផ្តល់ឱ្យខ្ញុំធ្វើ។* (យ៉ូហាន ១៧:៣-៤)

ព្រះគម្ពីរគួរអានបញ្ជាក់អំពីលក្ខណៈតែមួយអង្គរបស់ព្រះនៅក្នុងជំពូកទី១១២៖ *ចូរអ្នកពោលថា ព្រះអល់ឡោះទ្រង់តែមួយអង្គគត់។ ទ្រង់ជាទីពឹងអាស្រ័យ។ ទ្រង់មិនបានប្រសូតបុត្រឡើយ ហើយទ្រង់មិនត្រូវបានគេប្រសូតដែរ។ ហើយគ្មានអ្វីអាចប្រៀបប្រដូចនឹងទ្រង់បានឡើយ។*

ព្រះអល់ឡោះទ្រង់មានព្រះបន្ទូលថា៖ *ម្នាលបណ្តាជននៃគម្ពីរ! ចូរពួកអ្នកកុំបំផ្លើសក្នុងសាសនារបស់ពួកអ្នក ហើយចូរពួកអ្នកកុំនិយាយពីព្រះអល់ឡោះក្រៅពីការពិតឱ្យសោះ។ តាមពិតគ្រិស្តយេស៊ូកូននាងម៉ារីនោះ គឺជាអ្នកនាំសាររបស់ព្រះអល់ឡោះ ហើយ(ទ្រង់បានបង្កើតគេពី)ព្រះបន្ទូលរបស់ទ្រង់ ដែលទ្រង់បានបញ្ជូនទៅកាន់នាងម៉ារីនិងវិញ្ញាណមួយមកពីទ្រង់ប៉ុណ្ណោះ។ ដូច្នេះចូរពួកអ្នកមានជំនឿលើព្រះអល់ឡោះ និង បណ្តាអ្នកនាំសាររបស់ទ្រង់ចុះ ហើយកុំនិយាយថា បី (ព្រះបីអង្គ)។ ចូរពួក អ្នកឈប់(និយាយពាក្យនេះ)វាជាការប្រសើរសម្រាប់ពួកអ្នក។ ពិតប្រាកដណាស់ព្រះអល់ឡោះជាព្រះអម្ចាស់តែមួយអង្គគត់ ទ្រង់មានភាពស្អាតស្អំអំពីការមានបុត្រ។ អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់ និង អ្វីៗដែលមាននៅលើផែនដីគឺជាកម្មសិទ្ធិរបស់ទ្រង់។ គ្រប់គ្រាន់ហើយដែលព្រះអល់ឡោះជាព្រះអភិបាល។*(គួរអាន ៤:១៧១)
នៅជំពូកមួយផ្សេងទៀតទ្រង់មានព្រះបន្ទូលថា៖ *ជាការពិតណាស់ ពួកអ្នកដែលបាននិយាយថា ពិតប្រាកដណាស់ ព្រះអល់ឡោះគឺជាព្រះទីបីក្នុងចំណោមព្រះទាំងបីអង្គនោះ ពិតជាបានក្លាយជាពួកដែលគ្មានជំនឿ។ ហើយគ្មានព្រះអម្ចាស់ណាផ្សេងដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដឡើយ គឺមានតែព្រះអម្ចាស់តែមួយអង្គគត់។ ហើយប្រសិនបើពួកគេមិនព្រមបញ្ឈប់នូវអ្វីដែលពួកគេនិយាយទេនោះ ទណ្ឌកម្មដ៏សែនឈឺចាប់ពិតជានឹងធ្លាក់ទៅលើពួកដែលប្រឆាំងក្នុងចំណោមពួកគេជាមិនខាន។ តើពួកគេនៅតែមិនព្រមសារភាពទោសកំហុសចំពោះព្រះអល់ឡោះ និងមិនទូលសុំការអភ័យ*

*ទោសអំពីទ្រង់ទៀតទេឬ? ព្រះអល់ឡោះមហាអភ័យទោស មហាអាណិតស្រឡាញ់។* (គួរអាន ៥:៧៣-៧៤)

មានអត្ថបទមួយគត់ក្នុងគម្ពីរបរិសុទ្ធទាំងមូល ដែលជាទីសម្អាងនៃគោលជំនឿលើព្រះត្រៃឯក គឺនៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ជំពូក៥ ខ៧៖ *មានសាក្សី៣អង្គដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺព្រះវរបិតា ព្រះបន្ទូល និងព្រះវិញ្ញាណបរិសុទ្ធ តែទាំង៣អង្គនេះរួមមកតែមួយទេ។*[75] យ៉ាងណាមិញពាក្យទាំងនេះត្រូវបានគេដកចេញ និងកែសម្រួលនៅក្នុងការបោះពុម្ពផ្សាយគម្ពីរលើកក្រោយៗ[76] ក្រោយពីក្រុមបញ្ញវន្តគ្រិស្ទានបានរកឃើញថានេះគ្រាន់តែជាការបកស្រាយនៅក្នុងគម្ពីរ *KJV* និងការបោះពុម្ពមួយចំនួនទៀតប៉ុណ្ណោះ។

# ភាពជាព្រះរបស់លោកយេស៊ូ

គ្រិស្តបរិស័ទខ្លះជឿថាលោកយេស៊ូគឺជាព្រះដែលគង់នៅអស់កល្ប ឬថាជាព្រះទី២ក្នុងព្រះត្រៃឯក ហើយប្រហែលពីរពាន់ឆ្នាំមុនបានមកយកកំណើតជាមនុស្ស ហើយបានប្រសូតចេញពីនាងក្រមុំម៉ារី។ មានការកត់ត្រាក្នុងគម្ពីរបរិសុទ្ធដែរ គោលជំនឿនេះមានការខ្វែងគំនិតគ្នា និងមានលក្ខណៈផ្ទុយពីការបង្រៀនរបស់លោកយេស៊ូ។ ជាការពិតណាស់ លោកយេស៊ូមិនដែលបានអះអាងថាលោកជាព្រះឡើយ ហើយលោកថែមទាំងបញ្ជាក់ពីភាពតែមួយអង្គគត់របស់ព្រះ។ លោកមានប្រសាសន៍ថា៖ *ហេតុអ្វីអ្នកថាខ្ញុំល្អដូច្នេះ? ក្រៅពីព្រះ គ្មានអ្នកណាល្អឡើយ។*(ម៉ាកុស ១០:១៨) បើសិនជាលោកយេស៊ូបដិសេធពីភាពល្អរបស់លោកហើយ តើលោកទទួលទេថាលោកជាព្រះ?

---

[75] ការបកប្រែនេះស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ ចេញផ្សាយឆ្នាំ១៩៥៤។

[76] ក្នុងគម្ពីរបរិសុទ្ធជាភាសាខ្មែរ ១យ៉ូហាន ៥:៧ មានត្រឹមឃ្លាថា៖ *មានបន្ទាល់បីគឺ*។

នៅពេលលោកយេស៊ូមានប្រសាសន៍ទាក់ទងនឹងព្រះ លោកតែងប្រើពាក្យថា៖ *...បិតារបស់ខ្ញុំនិងបិតារបស់អ្នករាល់គ្នា ហើយទោះព្រះរបស់ខ្ញុំនិងព្រះរបស់អ្នករាល់គ្នា។*(យ៉ូហាន ២០:១៧)

លោកយេស៊ូក៏បានបដិសេធចំពោះការណ៍ដែលយល់ឃើញថា លោកអាចធ្វើអ្វីៗសព្វគ្រប់បែបយ៉ាងបានដោយខ្លួនលោកផ្ទាល់។ លោកបានបញ្ជាក់ច្បាស់ណាស់ថា គ្រប់យ៉ាងគឺទៅតាមព្រះបំណងរបស់ព្រះ ជាព្រះដែលចាត់លោកមកផែនដីនេះ។ លោកមានប្រសាសន៍ថា៖ *ខ្ញុំមិនអាចធ្វើអ្វីដោយគំនិតរបស់ខ្ញុំផ្ទាល់បានឡើយ សូម្បីតែអ្វីមួយក៏ដោយ*[77]*។ ខ្ញុំវិនិច្ឆ័យតាមអ្វីដែលខ្ញុំឮ ហើយការវិនិច្ឆ័យរបស់ខ្ញុំគឺសុចរិត ពីព្រោះខ្ញុំមិនរកបំពេញតាមបំណងប្រាថ្នារបស់ខ្ញុំទេ តែខ្ញុំរកបំពេញតាមបំណងប្រាថ្នារបស់លោក(ព្រះ)ដែលបានចាត់ខ្ញុំឱ្យមក។*(យ៉ូហាន ៥:៣០) បន្ថែមពីនោះទៀត លោកបានប្រាប់ថាអ្វីដែលលោកថ្លែងមិនមែនជាសម្ដីរបស់លោកទេ តែជាការបើកបង្ហាញពីព្រះមកកាន់លោកដែលជាព្យាការី៖ *ព្រោះខ្ញុំមិនបាននិយាយចេញពីចិត្តរបស់ខ្ញុំទេ ប៉ុន្តែបិតានៅស្ថានសួគ៌ដែលបានចាត់ខ្ញុំឱ្យមក បានឱ្យបញ្ញត្តិមួយមកខ្ញុំដោយផ្ទាល់ ស្ដីអំពីអ្វីដែលខ្ញុំត្រូវប្រាប់ និងអ្វីដែលខ្ញុំត្រូវនិយាយ។*(យ៉ូហាន ១២:៤៩) នៅក្នុងកណ្ឌគម្ពីរយ៉ូហាន ៧:១៧-១៨ លោកយេស៊ូមានប្រសាសន៍ថា៖ *ប្រសិនបើអ្នកណាចង់ធ្វើតាមបំណងប្រាថ្នារបស់លោក(ព្រះ) អ្នកនោះនឹងដឹងថានេះជាសេចក្ដីបង្រៀនមកពីព្រះ ឬក៏ជាសេចក្ដីបង្រៀនដែលខ្ញុំនិយាយចេញពីខ្លួនខ្ញុំ។ អ្នកណាដែលនិយាយចេញពីខ្លួនឯង អ្នកនោះចង់ឱ្យគេលើកតម្កើងខ្លួន ប៉ុន្តែអ្នកណាដែលចង់ឱ្យគេលើកតម្កើងអ្នកដែលបានចាត់ខ្លួនឱ្យមក គឺអ្នកនោះហើយដែលពិតត្រង់ ហើយគ្មានភាពមិនសុចរិតក្នុងខ្លួនគាត់ឡើយ។* លោកយេស៊ូក៏មានប្រសាសន៍ដែរថា ព្រះមានលក្ខណៈ

[77] លោកយេស៊ូក៏មានប្រសាសន៍ថែមទៀតថា៖ *មនុស្សមិនអាចសម្រេចការនេះបានឡើយ តែចំណែកព្រះវិញ លោកអាចសម្រេចការនេះបាន ពីព្រោះព្រះអាចសម្រេចគ្រប់ការទាំងអស់បាន។* (ម៉ាកុស ១០:២៧)

ល្អវិសេសអស្ចារ្យជាងលោក នេះបើយោងតាមកណ្ឌគម្ពីរយ៉ូហាន ១៤:២៨ ដែលសរសេរថា៖ *ខ្ញុំទៅឯបិតាដែលនៅស្ថានសួគ៌ ពីព្រោះបិតានៅស្ថានសួគ៌គឺធំជាងខ្ញុំ។* លោកយេស៊ូបំពេញកិច្ចការនានាដើម្បីបំពេញព្រះទ័យរបស់ព្រះ៖ *លោក(ព្រះ)ដែលបានចាត់ខ្ញុំឱ្យមកក៏នៅជាមួយនឹងខ្ញុំ។ លោកមិនបានចោលខ្ញុំឱ្យនៅតែម្នាក់ឯងទេ ពីព្រោះខ្ញុំតែងតែធ្វើអ្វីដែលលោកពេញចិត្ត។*(យ៉ូហាន ៨:២៩) បើយោងតាមកណ្ឌគម្ពីរលូកា ៤:៤៣ លោកយេស៊ូបានមកបង្រៀនអំពីព្រះរាជាណាចក្ររបស់ព្រះ៖ *ខ្ញុំត្រូវប្រកាសដំណឹងល្អអំពីរាជាណាចក្ររបស់ព្រះនៅក្រុងផ្សេងទៀតដែរ ពីព្រោះនេះជាមូលហេតុដែលខ្ញុំបានត្រូវចាត់ឱ្យមក។*

មិនតែប៉ុណ្ណោះ លោកយេស៊ូប្រាប់យើងថា ដើម្បីបានចូលទៅព្រះរាជាណាចក្ររបស់ព្រះគឺពឹងផ្អែកលើការធ្វើអ្វីទៅតាមព្រះទ័យរបស់ព្រះ៖ *មិនមែនអស់អ្នកដែលនិយាយមកខ្ញុំថា លោកម្ចាស់! លោកម្ចាស់!*[78] *នឹងចូលក្នុងរាជាណាចក្រស្ថានសួគ៌ឡើយ តែគឺអ្នកណាដែលធ្វើតាមបំណងប្រាថ្នានៃបិតារបស់ខ្ញុំដែលស្ថិតនៅស្ថានសួគ៌វិញ។*(ម៉ាថាយ ៧:២១) លោកក៏មានប្រសាសន៍ទៀតដែរថា៖ *អ្នកណាដែលធ្វើតាមបំណងប្រាថ្នារបស់ព្រះ អ្នកនោះហើយជាប្អូនប្រុស ប្អូនស្រី និងម្ដាយរបស់ខ្ញុំ*[79]*។* (ម៉ាកុស ៣:៣៥)

---

[78] ពាក្យភាសាក្រិកថា ῥαββί (រ៉ាប៊ី) ដែលគេតែងបកប្រែថា *ព្រះអម្ចាស់* តែអត្ថន័យដើមគឺមានន័យថា *លោកម្ចាស់* ឬ *លោកគ្រូ។* កណ្ឌគម្ពីរយ៉ូហាន ១:១៣ សរសេរថា៖ *រួចលោកយេស៊ូបែរទៅឃើញពួកគាត់កំពុងដើរតាម ក៏មានប្រសាសន៍ទៅពួកគាត់ថា តើអ្នករាល់គ្នាកំពុងរកអ្វី? ពួកគាត់ឆ្លើយថា រ៉ាប៊ី (ដែលមានន័យថា លោកគ្រូ) តើលោកស្នាក់នៅឯណា?។*

[79] ក្នុងកណ្ឌគម្ពីរម៉ាថាយ ១២:៥០ សរសេរថា៖ *ព្រោះអ្នកណាដែលធ្វើតាមបំណងប្រាថ្នាបិតារបស់ខ្ញុំដែលស្ថិតនៅស្ថានសួគ៌ អ្នកនោះហើយជាប្អូនប្រុស ប្អូនស្រី និងម្ដាយរបស់ខ្ញុំ។* លោកម៉ាថាយបានប្ដូរពីពាក្យថា *ព្រះ* ទៅជា *បិតា* វិញដើម្បីតម្រូវនឹងគោលជំនឿរបស់ខ្លួន។

បើយោងតាមកណ្ឌគម្ពីរម៉ាកុស ១៣:៣២ លោកយេស៊ូត្រូវបានគេកត់ត្រាថា លោកបានលើកឡើងថា ខ្លួនលោកមិនបានដឹងពីពេលកំណត់ចុងក្រោយនៃផែនដីនេះឡើយ៖ *គ្មានអ្នកណាដឹងថ្ងៃនិងម៉ោងនោះឡើយ។ សូម្បីតែបណ្ដាទេវតានៅស្ថានសួគ៌ និងបុត្ររបស់ព្រះក៏មិនជ្រាបដែរ។ មានតែបិតានៅស្ថានសួគ៌ប៉ុណ្ណោះដែលជ្រាប។*

ក្នុងកណ្ឌគម្ពីរលូកា ១៣:៣៣-៣៤ លោកយេស៊ូបានទទួលស្គាល់ខ្លួនលោកថាជាព្យាការីមួយរូប៖ *ទោះជាយ៉ាងនោះក៏ដោយ ខ្ញុំត្រូវធ្វើដំណើរនៅថ្ងៃនេះ ថ្ងៃស្អែក និងខានស្អែក ពីព្រោះអ្នកប្រកាសទំនាយ(ព្យាការី) ពុំអាចត្រូវបំផ្លាញនៅខាងក្រៅក្រុងយេរូសាឡិមបានឡើយ។ ក្រុងយេរូសាឡិម ក្រុងយេរូសាឡិមអើយ! គឺនាងហើយដែលបានសម្លាប់ពួកអ្នកប្រកាសទំនាយ(ព្យាការី) ហើយបានគប់ដុំថ្មសម្លាប់អ្នកដែលបានត្រូវចាត់មកឯនាង!*

ប្រសាសន៍របស់លោកយេស៊ូទាំងអស់នេះហើយ ដែលត្រូវបានគេកត់ត្រាទុកក្នុងគម្ពីរបរិសុទ្ធ បង្ហាញឱ្យយើងឃើញថា ទំនាក់ទំនងរវាងលោកយេស៊ូនឹងព្រះ មានជំហរដូចមនុស្សទូទៅដែរ។ លោកយេស៊ូមិនមែនជាអ្នកបង្កើតរាល់អ្វីៗនោះទេ តែលោកក៏ត្រូវបានព្រះបង្កើតមកដូចលោកអាដាំដែរ។ លោកអធិដ្ឋានបួងសួងទៅកាន់ព្រះ(ម៉ាកុស ១:៣៥, ម៉ាកុស ១៤:៣៥, លូកា ៥:១៦) ដែលសរុបមកមានន័យថា លោកជាព្យាការីរបស់ព្រះ ដ្បិតព្រះមិនអធិដ្ឋានបួងសួងទៅកាន់នរណាឡើយ។ លោកយេស៊ូតែងតែសរសើរតម្កើងព្រះ ដូចមានសរសេរយ៉ាងច្បាស់ក្នុងកណ្ឌគម្ពីរម៉ាថាយ ១១:២៥ ថា៖ *ឱបិតា ជាម្ចាស់ស្ថានសួគ៌និងផែនដី ខ្ញុំសូមសរសើរលោកនៅមុខមនុស្ស ..។*

គោលជំនឿដែលថាលោកយេស៊ូមានភាពជាព្រះនោះ គឺមិនមានប្រសាសន៍របស់លោកយេស៊ូមួយណា យកមកធ្វើជាសម្អាងបានឡើយ។ មិនខុសពីគោលជំនឿលើព្រះត្រៃឯកនោះទេ គោលជំនឿលើការចាប់កំណើតជាថ្មី ក៏ត្រូវបានគេរៀបចំក្រោយពេលលោកយេស៊ូចាកចេញពីផែនដីដែរ។ ជំនឿនេះបានហូរចូលមកក្នុង

សាសនាគ្រិស្តពីពួកដែលមិនជឿសាសនា។ ក្នុងនិទានកថារបស់សាសនាបុរាណៗ ដែលមានមុនសាសនាគ្រិស្ត គេឃើញថា មនុស្សអស្ចារ្យខ្លះក៏ត្រូវបានគេចាត់ទុកថាជាព្រះដែរ។ ហើយរឿងដែលគេស្គាល់ច្រើននោះរួមមានដូចជា **ព្រះក្រឹស្ណា** នៅក្នុងសាសនាហិណ្ឌូ, **ព្រះសិទ្ធត្ថ** ក្នុងសាសនាព្រះពុទ្ធ, **ព្រះមិស្រា** ក្នុងសាសនាពែរ្ស, ព្រះ **អូស៊ីរីស** នៃសាសនាអេស៊ីបបូរាណ, **ព្រះបាក់ឈូស** នៃសាសនាក្រិកបូរាណ, **ព្រះបាអាល់** នៃពួកសាសន៍បាប៊ីឡូន, **ព្រះអាដូនីស** នៃពួកសាសន៍ស៊ីរី ហើយនិង **លោកយេស៊ូ** នៃពួកគ្រិស្តបរិស័ទ។ ក្នុងសាសនាអ៊ីស្លាមឯណោះវិញ បានរំដោះបរិស័ទរបស់ខ្លួនឱ្យផុតពីជំនឿខុសឆ្គងទាំងឡាយ ដោយបដិសេធនូវជំនឿដែលថាព្រះមានការចាប់កំណើត ឬរួមបញ្ចូលអ្វីមួយដែលព្រះបានបង្កើតថាជាព្រះដែរ។

សាសនាអ៊ីស្លាមបញ្ជាក់យ៉ាងច្បាស់ថា ទាំងលោកយេស៊ូក៏ដោយ អ្នកណាផ្សេងទៀតក៏ដោយ មិនអាចជាព្រះនោះទេ។ សាសនាអ៊ីស្លាមក៏បដិសេធនូវទស្សនៈដែលថា ព្រះជាម្ចាស់អាចនឹងចាប់កំណើត ឬមករួបរួមជាមួយនឹងអ្វីដែលទ្រង់បានបង្កើតដែរ។ នៅក្នុងជំពូកទី៥ វាក្យខណ្ឌទី៧៥ ព្រះគម្ពីរគួរអានបានប្រាប់យើងថា លោកយេស៊ូ គឺជាអ្នកនាំសាររបស់ព្រះ មិនខុសពីអ្នកនាំសារមុនៗដែលមកមុនលោកឡើយ។ ហើយលោកនិងម្តាយរបស់លោក ធ្លាប់បរិភោគអាហារ ជាធម្មតា។ គំនិតនេះគឺថា នរណាហើយដែលត្រូវការបរិភោគអាហារ មិនអាចជាព្រះឡើយ នេះក៏ដូចជាលោកយេស៊ូ, មូហាំម៉ាត់ ឬក៏បណ្តាព្យាការី និងអ្នកនាំសារដទៃៗទៀតដែរ។ ដោយសារការបរិភោគអាហារ បង្ហាញពីតម្រូវការ និងការពឹងផ្អែកលើរបស់ក្រៅខ្លួន រីឯព្រះជាអម្ចាស់ទ្រង់ពុំមានតម្រូវការអ្វី ហើយក៏ពុំត្រូវពឹងផ្អែកលើអ្វីដែរ។ ដូចគ្នានេះដែរ ការបរិភោគអាហារ គឺជាដំណើរការនៃការបញ្ចូលអាហារចូលក្នុងរាងកាយ ដើម្បីឱ្យរាងកាយទទួលយកសារធាតុចិញ្ចឹម ក្រោយមកត្រូវបញ្ចេញមកវិញតាមរយៈការបន្ទោរបង់។ កិច្ចការយ៉ាងនេះពិតជាមិនស័ក្តិសមសោះឡើយចំពោះសិរីរុងរឿងរបស់ព្រះ។

ប្រជាជាតិជាច្រើន ទោះបីពួកគេរស់នៅទីដាច់ស្រយាល មានអារ្យធម៌ទាបយ៉ាងណាក៏ដោយ ក៏ពួកគេភាគច្រើនមិនទទួលយកគំនិតថា បណ្ដាអ្នកនាំសាររបស់ព្រះអាចជាមនុស្សធម្មតា ចេះបរិភោគអាហារ ដូចពួកគេដែរ។ មានព្យាការីជាច្រើនរូបត្រូវបានប្រជាជនស្អប់ខ្ពើមដោយសារហេតុផលនេះ។ ព្រះគម្ពីរគួរអាន បានលើកឡើងពីប្រជាជនរបស់ព្យាការី **ហ៊ូទ** បាននិយាយអំពីលោកថា៖ *គេនេះគ្មានអ្វីក្រៅពីជាមនុស្សធម្មតាដូចពួកអ្នកដែរ គេបរិភោគនូវអ្វីដែលពួកអ្នកបរិភោគ និងផឹកនូវអ្វីដែលពួកអ្នកផឹក។* (គួរអាន ២៣:៣៣) ព្រះគម្ពីរគួរអាន ក៏បានលើកឡើងពីពួកជនជាតិអារ៉ាប់ដែលជាប្រជាជនរបស់ព្យាការីមូហាំម៉ាត់៖ *ហើយពួកគេបាននិយាយទៀតថាហេតុអ្វីបានជាអ្នកនាំសារនេះចេះទទួលទានចំណីអាហារ និងដើរតាមផ្សារ(ដូចយើងដែរ)?* (គួរអាន ២៥:៧) ចំពោះពួកអ្នកដែលនិយាយពីភាពជាព្រះរបស់លោកយេស៊ូវិញ យើងឃើញថា ពួកគេបានបន្ទុះបង្អាប់ព្រះដ៏មានព្រះចេស្ដា ហើយចាត់ទុកទ្រង់ដូចជាមនុស្សដែលទទួលទានអាហារជាធម្មតា។

ភាពជាព្រះរបស់លោកយេស៊ូត្រូវបានព្រះគម្ពីរគួរអានបដិសេធ ដោយព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ពួកអ្នកដែលបាននិយាយថា ជាការពិតណាស់ព្រះអល់ឡោះគឺជា គ្រិស្ដកូនរបស់ម៉ារីនោះ ពិតជាក្លាយជាពួកដែលគ្មានជំនឿ។ ហើយគ្រិស្ដបានពោលថា ឱពូជពង្សអ៊ីស្រាអែល! ចូរពួកអ្នកគោរពសក្ការៈចំពោះព្រះអល់ឡោះជាព្រះអម្ចាស់របស់ខ្ញុំ និងជាព្រះអម្ចាស់របស់ពួកអ្នក។ ពិតប្រាកដណាស់អ្នកណាប្រព្រឹត្តពហុទេពនឹងព្រះអល់ឡោះ ព្រះអល់ឡោះពិតជាបានហាមឃាត់គេអំពីស្ថានសួគ៌ ហើយកន្លែងស្នាក់នៅរបស់គេគឺស្ថាននរក។ ហើយចំពោះពួកដែលបំពានគឺពុំមានអ្នកជួយឡើយ។* (គួរអាន ៥:៧២)

ព្រះអល់ឡោះក៏បានបើកបង្ហាញថា៖ *ពិតប្រាកដណាស់ ការប្រៀបធៀប(ការបង្កើត)យេស៊ូ សម្រាប់ព្រះអល់ឡោះដូចជា(ការបង្កើត) អាដាំដែរ គឺទ្រង់បានបង្កើតលោកពីដី បន្ទាប់មកទ្រង់បានមានព្រះបន្ទូលទៅកាន់លោកថា ចូរកើតចុះ! លោកក៏*

*កើតឡើងភ្លាម។*[80](គួរអាន ៣:៥៩) នៅក្នុងព្រះគម្ពីរគួរអាន ព្រះអល់ឡោះបានពិពណ៌នាអំពីលោកយេស៊ូថាជាព្យាការីរបស់ទ្រង់ លោកមានលក្ខណៈវិសុទ្ធ, មានការគោរពស្រឡាញ់ដូចព្យាការីឯទៀតរបស់ព្រះដែរ ហើយលោកមានលក្ខណៈជាមនុស្សជានិច្ច។ លោកមានប្រសាសន៍ថា៖ *ពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកបម្រើរបស់ព្រះអល់ឡោះ ដែលទ្រង់បានប្រទានព្រះគម្ពីរមួយឱ្យខ្ញុំ ហើយទ្រង់បានចាត់តាំងខ្ញុំជាព្យាការីម្នាក់។*(គួរអាន ១៩:៣០)

នៅក្នុងកណ្ឌគម្ពីរកិច្ចការ ជំពូកទី៣ ខទី១៣ លើកឡើងថា៖ *ព្រះរបស់អប្រាហាំ អ៊ីសាក និងយ៉ាកុប ជាព្រះនៃពួកបុព្វបុរសរបស់យើង បានតម្កើងអ្នកបម្រើរបស់លោក គឺលោកយេស៊ូ...។*

តាមការលើកឡើងជាក់ស្តែងខាងលើនេះ បានបង្ហាញដល់លោកអ្នកអានថា ពុំមែនមានតែសាសនាអ៊ីស្លាមមួយទេ ដែលបដិសេធពីភាពជាព្រះរបស់លោកយេស៊ូ សូម្បីតែអត្ថបទក្នុងគម្ពីរបរិសុទ្ធក៏បដិសេធដូចគ្នាដែរ។

តាមរយៈការស្ទង់មតិ ដែលរៀបចំដោយស្ថានីយទូរទស្សន៍មួយនៅចក្រភពអង់គ្លេស ក្នុងកម្មវិធីមួយឈ្មោះថា *Credo* បានបង្ហាញថា ក្នុងចំណោមពួកចាស់ទុំ ៣១ នាក់នៃក្រុមជំនុំ**អង់គ្លីកង់** មាន១៩នាក់បញ្ជាក់ថាគ្រិស្តបរិស័ទមិនមានកាតព្វកិច្ចត្រូវតែជឿលោកយេស៊ូថាជាព្រះនោះទេ។[81]

---

[80] ក្នុងគម្ពីរបរិសុទ្ធបានលើកឡើងពីព្រះបាទ**ម៉េលគីសេដិក** ថា៖ *ស្តេចនោះគ្មានឪពុក គ្មានម្តាយ គ្មានពង្សាវតារ ហើយក៏គ្មានថ្ងៃកើតឬថ្ងៃស្លាប់...*។(ហេប្រឺ ៧:៣) ទោះជាយ៉ាងនេះក្តី គ្មាននរណាអះអាងថាលោកជាព្រះឡើយ។

[81] ដកស្រង់ពីកាសែត Daily News ចេញផ្សាយថ្ងៃទី ២៥ មិថុនា ១៩៨៤។

# ភាពជាបុត្ររបស់ព្រះ

គោលជំនឿនេះក៏មិនខុសពីគោលជំនឿមុនៗ ដែលយើងបានពិភាក្សារួចមកហើយ។ គោលជំនឿនេះគ្មានការបញ្ជាក់ពីសេចក្ដីបង្រៀន ឬប្រសាសន៍ណាមួយរបស់លោកយេស៊ូឡើយ។ ក្នុងគម្ពីរបរិសុទ្ធបានប្រើពាក្យ **បុត្រ ឬកូនរបស់ព្រះ** គឺប្រើសំដៅទៅលើលោកអាដាំ (លូកា ៣:៣៨) ហើយក៏សំដៅដល់ព្យាការីជំនាន់មុនជាច្រើនដែលមកមុនលោកយេស៊ូ។ ឧទាហរណ៍ **អ៊ីស្រាអែល** ត្រូវបានហៅថាជាកូនរបស់ព្រះដែរនៅក្នុងកណ្ឌគម្ពីរមួយ៖ *ត្រូវប្រាប់ស្ដេចផារ៉ាអុងថា ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ ប្រជាជនអ៊ីស្រាអែលជាកូនច្បងរបស់យើង។*(និក្ខមនំ ៤:២២)

ក្នុងកណ្ឌគម្ពីរទំនុកតម្កើង ងារជាកូនរបស់ព្រះនេះក៏ត្រូវបានផ្ដល់ទៅព្រះបាទ**ដាវីឌ** ផងដែរ៖ *ខ្ញុំនឹងប្រកាសក្រឹត្យរបស់ព្រះអម្ចាស់ ព្រះអង្គមានព្រះបន្ទូលមកកាន់ខ្ញុំថា ព្រះអង្គជាបុត្ររបស់យើង! គឺយើងដែលបានបង្កើតព្រះអង្គនៅថ្ងៃនេះ។*(ទំនុកតម្កើង ២:៧) ដូចគ្នានេះដែរនៅក្នុងកណ្ឌគម្ពីរ ១របាក្សត្រ ២២:១០ ព្រះបាទ**សាឡូម៉ុន** ក៏ត្រូវបានហៅថា បុត្ររបស់ព្រះដែរ *៖ គឺបុត្រនោះហើយ ដែលនឹងសង់ដំណាក់មួយសម្រាប់នាមយើង។ គេនឹងធ្វើជាកូនរបស់យើង ហើយយើងធ្វើជាឪពុករបស់គេដែរ។ យើងនឹងពង្រឹងរាជបល្ល័ង្ករបស់គេឱ្យនៅស្ថិតស្ថេរលើស្រុកអ៊ីស្រាអែលរហូតតទៅ!។*

តាមរយៈការលើកឡើងខាងលើនេះ ហើយក៏មានខផ្សេងៗជាច្រើនទៀតក្នុងគម្ពីរបរិសុទ្ធបានបង្ហាញថាពាក្យ **បុត្ររបស់ព្រះ** មានអត្ថន័យជាក់ស្ដែងថា ជាអ្នកដែលនៅជិតកៀកបំផុតនឹងក្ដីស្រឡាញ់របស់ព្រះ។ សូម្បីតែលោកយេស៊ូក៏បានមានប្រសាសន៍ថា៖ *ក៏ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរបន្តស្រឡាញ់សត្រូវរបស់អ្នក ហើយអធិដ្ឋានដើម្បីអ្នកដែលបៀតបៀនអ្នក ដើម្បីបង្ហាញថាអ្នកជាកូននៃបិតារបស់អ្នកដែលនៅស្ថានសួគ៌...។*(ម៉ាថាយ ៥:៤៤-៤៥) *អស់អ្នកដែលធ្វើឱ្យមានសន្តិភាព នោះមានសុភមង្គលហើយ! ពីព្រោះមនុស្សនឹងហៅអ្នកទាំងនោះថា កូនព្រះ ។*(ម៉ាថាយ ៥:៩)

ក្រោយពីវិភាគលើប្រសាសន៍ទាំងនេះហើយ យើងគ្មានការសង្ស័យសោះឡើយចំពោះអ្វីដែលលោកយេស៊ូ បានពន្យល់ចំពោះអត្ថន័យនៃពាក្យថា **បុត្រ ឬកូន** នោះ។ ដូច្នេះបើយើងគិតឱ្យមែនទែនទៅ គ្មានអ្វីដែលអាចនាំឱ្យយើងចាត់ទុកលោកយេស៊ូថាជាបុត្ររបស់ព្រះ ដែលមានលក្ខណៈពិសេសខុសប្លែកពីអ្នកដទៃនោះទេ។ រាល់ពេលដែលលោកយេស៊ូ លើកឡើងពីពាក្យថា បុត្ររបស់ព្រះ គឺវាមានអត្ថន័យដូចគ្នានឹងការហៅចំពោះលោក អាដាំ, អ៊ីស្រាអែល, ដាវីឌ, សាឡូម៉ូន ដែរ។ លោកយេស៊ូត្រូវបានពិពណ៌នាដោយប្រើពាក្យ **បុត្ររបស់ព្រះ** ចំនួន១៣ដងគត់ក្នុងគម្ពីរបរិសុទ្ធ ហើយការពិពណ៌នាចំពោះលោកថាជា **កូនមនុស្ស** មានរហូតដល់ទៅ៨៣ដងឯណោះ។

ព្រះគម្ពីរគួរអានបានបដិសេធយ៉ាងដាច់អហង្ការ ចំពោះជំនឿលើបុត្ររបស់ព្រះដូចមានលើកឡើងក្នុងជំពូកទី២ វាក្យខណ្ឌ ១១៦ ថា៖ *ហើយពួកគេបាននិយាយថាព្រះអល់ឡោះមានបុត្រ។ ព្រះអង្គមហាបរិសុទ្ធបំផុត! ផ្ទុយទៅវិញសព្វសារពើដែលមាននៅលើមេឃជាច្រើនជាន់ និងផែនដីជាកម្មសិទ្ធិរបស់ទ្រង់។ អ្វីសព្វសារពើទាំងអស់នេះគឺគោរពប្រតិបត្តិចំពោះទ្រង់។*

លើសពីនេះទៅទៀត ការបង្កើតរឿងថាព្រះមានបុត្រ គឺជាការប្រមាថ និងបដិសេធពីភាពល្អឥតខ្ចោះរបស់ព្រះ ហើយជាការបង្ហាញថាព្រះមានតម្រូវការ ពោលគឺត្រូវការមនុស្សម្នាក់ទៀតនៅជាមួយទ្រង់ គឺមិនស័ក្តិសមសោះឡើយ ដ្បិតព្រះគ្មានតម្រូវការអ្វីឡើយ។

# បាបពីកំណើត

បើយោងតាមការពន្យល់របស់គ្រិស្តបរិស័ទអំពីគោលជំនឿនេះគឺថា លោក **អាដាំ**បានប្រព្រឹត្តទង្វើបាប នៅពេលដែលលោកមិនស្តាប់បង្គាប់ព្រះហើយបរិភោគផ្លែឈើពីដើមឈើដែលព្រះបានហាមឃាត់ (ដើមឈើនៃការដឹងខុសត្រូវ មានសរសេរ

ក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ២:១៧)។[82] ជាលទ្ធផល បើតាមទ្រឹស្តីសាសនារបស់គ្រិស្តបរិស័ទ កូនចៅជំនាន់ក្រោយរបស់លោកអាដាំទាំងអស់ ត្រូវទទួលបាបបន្តមកពីលោកអាដាំ ដែលមានន័យថាមនុស្សគ្រប់រូប សុទ្ធតែកើតមកដោយមានបាបពីកំណើត ហើយគ្រិស្តបរិស័ទក៏លើកឡើងដែរថា នេះជាការធ្វើឱ្យមានភាពយុត្តិធម៌ចំពោះព្រះ ដែលបាបទាំងអស់ត្រូវសងទៅតាមអ្វីដែលបានប្រព្រឹត្ត។

និយាយដោយឡែកវិញ ព្រះនឹងមិនលើកទោសចំពោះបាបណាមួយឡើយបើមិនមានការទូលសុំ ហើយព្រះមិនអាចលើកទោសសូម្បីតែទង្វើបាបធម្មតាមួយ។ គ្រិស្តបរិស័ទលើកឡើងទៀតថា វិធីតែម្យ៉ាងគត់ដើម្បីលុបលាងបាបបាននោះគឺការបង្ហូរឈាម។ សាវ័ក**ប៉ូល**និយាយថា៖ *ហើយបើគ្មានការបង្ហូរឈាមទេ នោះគ្មានការអភ័យទោសចំពោះការខុសឆ្គងឡើយ។*[83](ហេប្រឺ ៩:២២) ប៉ុន្តែឈាមនេះត្រូវតែជាឈាមដែលល្អឥតខ្ចោះ គ្មានបាប និងមិនចេះស្អុយរលួយ។ ដូច្នេះហើយលោកយេស៊ូដែលត្រូវគេចោទប្រកាន់ថាជាបុត្ររបស់ព្រះ ត្រូវបានគេបង្ហូរឈាមរបស់លោកដែលគ្មានបាប លោកបានរងទុក្ខឈឺចាប់ដែលមិនអាចពិពណ៌នាបាន ហើយបានស្លាប់ដើម្បីសងថ្លៃលោះបាបរបស់មនុស្ស។ ដោយសារលោកជាព្រះដែលឥតដែនខណ្ឌ មានតែលោកទេដែលអាចលោះថ្លៃបាបដែលឥតដែនខណ្ឌបាន។ ដូច្នេះគ្មាននរណាម្នាក់អាចទទួលការសង្គ្រោះបានឡើយ លើកលែងតែអ្នកនោះព្រមទទួលលោកយេស៊ូជាអ្នក

---

[82] មានសំណួរដែលគួរចោទសួរនោះគឺ តើព្រះដាក់ទោសយ៉ាងដូចម្តេចទៅ បើអាដាំប្រព្រឹត្តដោយមិនដឹងខុសត្រូវផងនោះ។

[83] ការលើកឡើងរបស់សាវ័កប៉ូលគឺមានភាពខ្វែងគ្នានឹងអត្ថបទគម្ពីរផ្សេងទៀតដែលថាដង្វាយធួនអាចធ្វើឡើងតាមរយៈការថ្វាយម្សៅម៉ដ្ឋ(លេវីវិន័យ ៥:១១) ឬ ថ្វាយជាប្រាក់(និក្ខមនំ ៣០:១៥) ឬ *គ្រឿងអលង្ការធ្វើពីមាស គឺមានខ្សែក ខ្សែដៃ ចិញ្ចៀន ក្រវិល និងបន្តោងខ្សែក។*(ជនគណនា ៣១:៥០)

សង្គ្រោះខ្លួនគេ។[84] លើសពីនេះទៅទៀត មនុស្សគ្រប់រូបនឹងត្រូវរងទុក្ខវេទនានៅក្នុងស្ថាននរកដោយសារតែបាបពីកំណើតនោះ លើកលែងតែអ្នកណាហើយដែលព្រមទទួលយកដង្វាយធួនមកលោះនឹងបាបរបស់គេ ដែលធ្វើដោយលោកយេស៊ូនិងឈាមរបស់លោក។

គោលជំនឿនេះអាចបែងចែកជា៣ផ្នែកសំខាន់ៗបាន៖ ផ្នែកទី១ បាបមានពីកំណើតមកស្រាប់។ ផ្នែកទី២ ត្រូវជឿថាព្រះធ្វើឱ្យមានភាពយុត្តិធម៌តាមរយៈការលោះបាប ហើយថ្លៃលោះនោះគឺជាឈាម។ ផ្នែកទី៣ ជឿថាលោកយេស៊ូបានលោះបាបសម្រាប់មនុស្សគ្រប់គ្នា ដោយការស្លាប់របស់លោកនៅលើឈើឆ្កាង ហើយការសង្គ្រោះនេះគឺសម្រាប់តែអ្នកណាដែលជឿលើការលះបង់ជីវិតរបស់លោកប៉ុណ្ណោះ។[85] ផ្នែកទាំង៣នេះមានបកស្រាយដូចខាងក្រោម។

**ផ្នែកទី១** លោកបូជាចារ្យ *De Groot* បានសរសេរថា៖ *គម្ពីរបានបង្រៀនយើងថា បាបរបស់លោកអាដាំ បានបន្តមកកាន់មនុស្សគ្រប់គ្នា។* (ស្រង់ពីសៀវភៅ Our Blessed lady exempted) ចំណែកឯបណ្ឌិត Paul វិញសរសេរថា៖ *ដោយហេតុថាមនុស្សទាំងអស់បានទទួលបាបដោយសារលោកអាដាំតែម្នាក់។ ហើយមនុស្សជាច្រើនបានប្រព្រឹត្តដោយយុត្តិធម៌ដោយសារគ្រិស្តតែម្នាក់ដូចគ្នា។*[86] សម្តីទាំងនេះបង្ហាញយ៉ាងច្បាស់ថា មនុស្សគ្រប់រូបសុទ្ធតែទទួលបាបបន្តពីលោកអាដាំ។ មិនខុសពី

---

[84] កណ្ឌគម្ពីរអេសាយ ៤៣:១១ សរសេរថា៖ *មានតែយើងទេជាព្រះអម្ចាស់ ក្រៅពីយើងគ្មានព្រះសង្គ្រោះណាទៀតឡើយ។*

[85] បើជំនឿលើការចងឆ្កាងលោកយេស៊ូជាវិធីតែមួយគត់ដើម្បីទទួលបានការសង្គ្រោះ សម្រាប់អ្នកដែលរស់នៅជំនាន់ជាមួយលោក និងអ្នកជឿលោកជំនាន់ក្រោយៗមកទៀតនោះ។ ចុះអ្នកដែលមានបាបហើយស្លាប់ក្នុងជំនាន់មុនៗលោកយេស៊ូវិញនោះ គេគ្មានឱកាសនិងស្គាល់លោក ហើយក៏មិនបានជឿលើការចងឆ្កាងដែរ តើយុត្តិធម៌ចំពោះពួកគេដែរឬទេ?

[86] ស្រង់ចេញពីសៀវភៅ *Catholic Teaching* ទំព័រ១៤០។ មានយោងពីគម្ពីរបរិសុទ្ធត្រង់ រ៉ូម ៥: ១៨-១៩។

ជំនឿរបស់គ្រិស្តបរិស័ទជាច្រើនឡើយ គោលជំនឿនៃ*ការទទួលបាបបន្ត* គឺគ្មានអ្វីជាសម្អាងឡើយ ទាំងប្រសាសន៍របស់លោកយេស៊ូ ឬព្យាការីមុនៗដែលមកពីមុនលោក។ ពួកលោកទាំងអស់គ្នា(ព្យាការី) បង្រៀនថា មនុស្សគ្រប់រូបត្រូវទទួលខុសត្រូវលើអ្វីដែលខ្លួនបានប្រព្រឹត្ត។ ឯកូនក៏មិនត្រូវទទួលទោសដោយសារតែបាបដែលឪពុកម្តាយខ្លួនប្រព្រឹត្តដែរ។

គ្មានមនុស្សណាម្នាក់ដែលកើតមកពេញដោយបាបនោះទេ។ លោកយេស៊ូបានមានប្រសាសន៍ទាក់ទងនិងកូនចៅថា ជាអ្នកស្លូតត្រង់ហើយវិសុទ្ធ។ លោកមានប្រសាសន៍យ៉ាងជាក់ច្បាស់ថា៖ *ឱ្យកូនក្មេងទាំងនោះមកឯខ្ញុំ កុំឃាត់ពួកគេឡើយ ពីព្រោះរាជាណាចក្ររបស់ព្រះជារបស់អ្នកដែលមានលក្ខណៈដូចក្មេងទាំងនេះ។ ខ្ញុំប្រាប់អ្នករាល់គ្នាការពិតថា អ្នកណាដែលមិនព្រមទទួលរាជាណាចក្ររបស់ព្រះ ដូចក្មេងតូចម្នាក់ទេ អ្នកនោះនឹងមិនបានចូលក្នុងរាជាណាចក្ររបស់ព្រះសោះឡើយ។* (ម៉ាកុស ១០:១៤-១៥)

បើយើងគិតប្រកបដោយហេតុផលវិញ វាគឺជារឿងដែលអយុត្តិធម៌ខ្លាំងបំផុតដែលគ្រប់មនុស្សទាំងអស់ត្រូវទទួលបាប ដែលបាបនោះប្រព្រឹត្តតាំងពីរាប់ពាន់ឆ្នាំមុនដោយឪពុកម្តាយដើមរបស់យើង។ អំពើបាបគឺជាការប្រព្រឹត្តបំពានដោយចេតនាលើច្បាប់របស់ព្រះ ឬច្បាប់នៃអ្វីត្រូវនិងអ្វីខុស។ ហេតុដូច្នេះការទទួលខុសត្រូវឬការស្តីបន្ទោសចំពោះបាបនេះ ត្រូវតែធ្លាក់ទៅលើបុគ្គលដែលបានប្រព្រឹត្ត មិនមែនធ្លាក់មកលើកូនរបស់គេទេ។ វាជារឿងដ៏អយុត្តិធម៌យ៉ាងធ្ងន់ធ្ងរដែលចាត់ទុកថាមនុស្សកើតមកមានបាបមកស្រាប់។ វាជារឿងដ៏មិនសមហេតុផលសោះ ដែលមនុស្សមានចិត្តគំនិតរឹងមាំបែរជាជឿលើជំនឿនៃបាបពីកំណើត ដូចបានបង្ហាញដោយទ្រឹស្តីសាសនារបស់បព្វជិត *Augustine* ថា សូម្បីតែទារកតូចដែលមិនទាន់ប្រែចិត្តជឿ ក៏ត្រូវវិនាសទៅឆេះអស់កល្បជានិច្ចក្នុងភ្លើងនរកដែរ?! ទើបតែរយៈពេលក្រោយនេះទេ ដែលក្នុងពិភពគ្រិស្តបរិស័ទឈប់យកទារកតូចៗដែលមិនទាន់បានទទួលពិធីជ្រមុជទឹក ទៅកប់ក្នុងដី

ដោយសារតែគេជឿថា ទារកទាំងនេះសមនឹងស្លាប់ដោយសារតែបាបពីកំណើតរបស់ពួកគេ។

សាសនាអ៊ីស្លាមបានបដិសេធនិងប្រឆាំងនឹងគោលជំនឿបាបពីកំណើត ដោយលើកឡើងថា ទារកគឺមានលក្ខណៈវិសុទ្ធ និងឥតមានបាបសោះឡើយនៅពេលកើត។ ឯបាបវិញមិនមែនជារឿងដែលអាចទទួលបន្តគ្នាបានឡើយ ប៉ុន្តែគឺជាអ្វីដែលមនុស្សទទួលបាន នៅពេលដែលគេប្រព្រឹត្តអ្វីដែលគេមិនគួរប្រព្រឹត្ត ឬមិនប្រព្រឹត្តអ្វីដែលគេគួរប្រព្រឹត្ត។

**ផ្នែកទី២** នៃគោលជំនឿលើដង្វាយធួនរបស់គ្រិស្តបរិស័ទ គឺគេជឿថាភាពយុត្តិធម៌របស់ព្រះគឺទាល់តែមានដង្វាយធួន ដើម្បីជាថ្លៃលោះចំពោះបាបពីកំណើតនិងបាបដទៃទៀតរបស់មនុស្ស។ ប្រសិនបើព្រះលើកលែងទោសឱ្យមនុស្សមានបាបដោយពុំដាក់ទណ្ឌកម្មនោះ វាជាការខុសឆ្គងទៅនឹងភាពយុត្តិធម៌របស់ទ្រង់។ លោកបូជាចារ្យ W. Goldsake បានសរសេរទាក់ទងនឹងរឿងនេះថា៖ *គ្រប់គ្នាបានដឹងច្បាស់ដូចថ្ងៃអ៊ីចឹង ថាព្រះមិនបំពានច្បាប់របស់ទ្រង់ឡើយ។ ទ្រង់មិនលើកលែងទោសចំពោះមនុស្សមានបាប ដោយមិនដាក់ទណ្ឌកម្មគេឱ្យសមរម្យឡើយ បើទ្រង់ធ្វើយ៉ាងនោះមែន តើមាននរណាចាត់ទុកថាទ្រង់យុត្តិធម៌ និងសមធម៌នោះ?*[87] ការយល់ឃើញយ៉ាងនេះបង្ហាញពីការមិនយល់អ្វីសោះទៅលើយុត្តិធម៌របស់ព្រះ។ ព្រះអង្គមិនមែនគ្រាន់តែជាចៅក្រម ឬជាស្តេចនោះទេ តែទ្រង់គឺមានលក្ខណៈដូចនឹងអ្វីដែលព្រះគម្ពីរគួរអានបានពិពណ៌នាថា៖ *ទ្រង់ដ៏មហាសប្បុរស មហាមេត្តាករុណា។ ទ្រង់ជាអធិបតីនាថ្ងៃជំនុំជម្រះ។* ព្រះអង្គមិនត្រឹមតែយុត្តិធម៌ប៉ុណ្ណោះទេ តែទ្រង់ថែមទាំងប្រកបដោយក្តីមេត្តាករុណា និងការលើកលែងទោសផង៖ *...ព្រះអល់ឡោះទ្រង់នឹងអភ័យទោសដល់ពួកអ្នក ហើយទ្រង់ជាអង្គដ៏មេត្តាករុណាក្រៃលែង។*(គួរអាន ១២:៩២) ប្រសិនបើព្រះទ្រង់ជ្រាបដឹងថា មនុស្សលោកបានសារភាពទោសដោយស្មោះអស់ពីចិត្តហើយនោះ

[87] ស្រង់ចេញពីសៀវភៅ *The Atonement* ទំព័រទី៥។

ហើយគេកម្លាចិត្តខ្លួនគេឱ្យយកឈ្នះលើសេចក្ដីអាក្រក់ដែលមានក្នុងខ្លួនគេ នោះព្រះដ៏ពេញចេស្ដានឹងលើកលែងនូវទោសកំហុស និងបាបរបស់គេផង។ ក្រោយពីនោះ មានមូលហេតុមួយដែលស័ក្តិសមបំផុតនឹងការដាក់ទោសនោះគឺ ទ្រង់ទតមើលការផ្លាស់ប្រែសេចក្ដីអាក្រក់ក្នុងខ្លួនអ្នកធ្លាប់ល្មើសនោះ។ ការដាក់ទោសនរណាម្នាក់ដោយសារបាបដែលគេធ្លាប់ប្រព្រឹត្តពីមុន ទោះបីគេបានសារភាពទោស និងបានផ្លាស់ប្រែខ្លួនគេហើយនោះ វាគឺជាការសងសឹកទៅវិញទេ ហើយក៏មិនយុត្តិធម៌ផង ហើយការលើកលែងទោសក្រោយពេលដាក់ទោសជននោះរួច ឬក៏ដាក់ទោសអ្នកណាផ្សេងជំនួសជននោះ វាមិនមែនជាការលើកលែងទោសអ្វីនោះទេ។

ព្រះដែលយើងគោរពថ្វាយបង្គំជាព្រះនៃក្ដីមេត្តា។ ចំពោះច្បាប់វិន័យនានាដែលទ្រង់បានបញ្ញត្តិមក ហើយនិងបង្គាប់ឱ្យយើងប្រតិបត្តិតាមនោះ មិនមែនកើតជាប្រយោជន៍សម្រាប់ទ្រង់នោះឡើយ តែវាគឺជាប្រយោជន៍សម្រាប់មនុស្សជាតិសុទ្ធសាធ។ ហើយប្រសិនបើទ្រង់ដាក់ទោសមនុស្សណាម្នាក់ដោយសារតែកំហុស និងបាបរបស់គេនោះ គឺមិនមែនដើម្បីបំពេញព្រះទ័យទ្រង់ ឬដើម្បីទូទាត់នឹងអ្វីមួយដូចជំនឿគ្រិស្ដបរិស័ទឡើយ ប៉ុន្តែគឺដើម្បីទប់ស្កាត់អំពើអាក្រក់ និងដើម្បីជម្រះសម្អាតដល់អ្នកប្រព្រឹត្តបាបនោះផង។ ព្រះទ្រង់លើកលែងនូវទោសកំហុស និងបាប ដល់នរណាហើយដែលងាកចេញពីអំពើបាបរបស់គេ និងបានផ្លាស់ប្រែខ្លួនគេ ដោយទ្រង់មិនដាក់ទោសពួកគេ ឬអ្នកណាផ្សេងជំនួសពួកគេឡើយ ហើយការណ៍នេះក៏ខុសឆ្គងនឹងភាពយុត្តិធម៌របស់ព្រះដែរ។

ព្រះអល់ឡោះទ្រង់មានព្រះបន្ទូលថា៖ *ព្រះអម្ចាស់នៃអ្នករាល់គ្នាបានកំណត់សេចក្ដីមេត្តាករុណាលើអង្គទ្រង់ផ្ទាល់។ ជាការប្រាកដណាស់ អ្នកណាក្នុងចំណោមពួកអ្នកបានប្រព្រឹត្តអំពើអាក្រក់ដោយល្ងង់ខ្លៅ ក្រោយមកគេបានសារភាពកំហុស និងបានផ្លាស់ប្រែខ្លួនវិញបន្ទាប់ពីនោះ ពិតប្រាកដណាស់ព្រះអល់ឡោះទ្រង់មហាអភ័យទោស មហាមេត្តាករុណា។* (គួរអាន ៦:៥៤)

**ផ្នែកទី៣** នៃគោលជំនឿរបស់គ្រិស្តបរិស័ទអំពីដង្វាយធួននោះគឺ លោកយេស៊ូបានចេញថ្លៃលោះដល់បាបពីកំណើត និងបាបដទៃទៀតរបស់មនុស្សលោក តាមរយៈការស្លាប់របស់លោកលើឈើឆ្កាងនៅឯភ្នំ**លលាដ៍ក្បាល**[88]ហើយការសង្គ្រោះនេះទៀតសោត គឺមិនអាចធ្វើបានឡើយ បើគ្មានជំនឿលើអំណាចនៃការសង្គ្រោះតាមរយៈលោហិតរបស់លោក។ លោកបូជាចារ្យ *De Groot* បានសរសេរថា៖ *ចាប់តាំងពីពេលគ្រិស្ត ដែលជាព្រះមកយកកំណើតជាមនុស្ស បានយកបាបពីពួកយើងរាល់គ្នា ទៅលើខ្លួនលោកទាំងអស់ ដើម្បីជាថ្លៃលោះសម្រាប់មនុស្សទាំងអស់ ដោយការធ្វើនេះគឺដើម្បីបំពេញព្រះទ័យព្រះ និងដើម្បីឱ្យមានយុត្តិធម៌ផង។ លោក(យេស៊ូ)គឺជាអ្នកសម្របសម្រួលរវាងព្រះនិងមនុស្សលោក។*[89]

គោលជំនឿយ៉ាងនេះមិនត្រឹមតែប្រឆាំងនឹងក្ដីមេត្តាករុណារបស់ព្រះប៉ុណ្ណោះទេ ថែមទាំងប្រឆាំងនឹងសេចក្ដីយុត្តិធម៌របស់ព្រះអង្គផង។[90]

ការទាមទារនូវឈាមដើម្បីជាថ្នូរនឹងការលើកលែងទោសចំពោះមនុស្សលោកនោះ គឺជាការបង្ហាញពីភាពខ្វះក្ដីមេត្តាករុណា ហើយដាក់ទោសចំពោះមនុស្សម្នាក់ដែលគ្មានទោសសោះ ជំនួសបាបរបស់អ្នកដទៃវិញ។ មិនថាតាំងពីដើមមកវាជាការស្ម័គ្រចិត្តឬក៏អត់ ក៏នៅតែជារឿងដ៏អយុត្តិធម៌បំផុត។

---

[88] ភ្នំកាល់វ៉ារី, ភាសាកូណេក្រិក ៖ Γολγοθᾶ[ς] , ភាសាហេប្រឺ ៖ גולגלת ,
ភាសាស៊ីរីអាក់ ៖ ܓܓܘܠܬܐ ។

[89] ស្រង់ចេញពីសៀវភៅ *Catholic Teaching* ទំព័រទី ១៦២។

[90] ក្នុងចំណុចនេះយើងគួរឆ្ងល់ថា៖ តើការណ៍ដែលលោកអាដាំបានសារភាពទោស និងការកែប្រែចិត្តទៅចំពោះព្រះក្តី, ការទម្លាក់លោកអាដាំចេញពីស្ថានសួគ៌ក្តី រួមទាំងទឹកជំនន់មកលើកូនចៅលោកក្តី និងការលះបង់ជាច្រើនទៀត នៅមិនគ្រប់គ្រាន់ដើម្បីឱ្យគាត់អាចទទួលការសង្គ្រោះទេឬ? ចុះអ្នកឯទៀតដែលប្រព្រឹត្តបាបធ្ងន់ធ្ងរជាងអាដាំផងនោះយ៉ាងណាវិញ? ហើយហេតុយ៉ាងដូចម្តេចបានជាមិនមានអ្នកណាបានដឹងសោះអំពីការសង្គ្រោះ សូម្បីតែព្យាការីទាំងឡាយ ប៉ុន្តែវិធីនៃការសង្គ្រោះត្រូវបានរកឃើញដោយក្រុមជំនុំ និងវិហារទៅវិញ?

មានការបដិសេធជាច្រើនដែលបញ្ជាក់ពីភាពខុសឆ្គងនៃជំនឿដង្វាយធួន និង ការចងឆ្កាង។ ខាងក្រោមនេះជាចំណុចមួយចំនួនដែលយើងនឹងលើកមក៖

**ទីមួយ៖** គោលជំនឿទាក់ទងនឹងការចងឆ្កាងលោកយេស៊ូដើម្បីជាថ្លៃលោះបាបពីកំណើតនោះ គឺយោងទៅតាមមូលដ្ឋានគ្រឹះដែលខុសឆ្គង ដូចនេះរាល់អ្វីដែលយោងទៅតាមមូលដ្ឋានគ្រឹះខុសឆ្គង គឺវាប្រាកដជាខុសឆ្គងដែរហើយ។ ទស្សនៈដែលថា បាបរបស់លោក អាដាំ ត្រូវធ្លាក់បន្តមកដល់កូនចៅរបស់លោកនោះ គឺមានភាពមិនត្រឹមត្រូវឡើយជាមួយនឹងខគម្ពីរនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ ហើយបើយោងតាមគម្ពីរសម្ពន្ធមេត្រីថ្មីទៀតនោះ គម្ពីរសម្ពន្ធមេត្រីចាស់ត្រូវបានលោកយេស៊ូមកធ្វើឱ្យពេញលេញ មិនមែនមកលុបបំបាត់ចោលនោះទេ។ ជាមួយគ្នានេះផងដែរ យើងឃើញថានៅក្នុងកណ្ឌគម្ពីរទុតិយកថា ២៤:១៦ បានសរសេរថា៖ *មិនត្រូវសម្លាប់ឪពុកដោយសារតែទោសរបស់កូនទេ ហើយក៏មិនត្រូវសម្លាប់កូនដោយសារតែទោសរបស់ឪពុកដែរ។ បុគ្គលម្នាក់ៗត្រូវស្លាប់ដោយសារតែទោសរបស់ខ្លួនប៉ុណ្ណោះ។* ក្នុងកណ្ឌគម្ពីរអេសេគាល ១៨:២០ សរសេរថា៖ *បុគ្គលណាដែលធ្វើអំពើខុសឆ្គងគឺបុគ្គលនោះហើយដែលត្រូវស្លាប់។ កូនមិនទទួលទោសចំពោះកំហុសឆ្គងរបស់ឪពុកទេ ហើយឪពុកក៏មិនទទួលទោសចំពោះកំហុសឆ្គងរបស់កូនដែរ។* បើយើងមើលទៅកណ្ឌគម្ពីរម៉ាថាយ ១៦:២៧ លោកយេស៊ូមានប្រសាសន៍ថា៖ *ព្រោះកូនមនុស្សនឹងត្រូវមកជាមួយនឹងបណ្ដាទេវតារបស់លោក ដោយមានសិរីរុងរឿងពីបិតារបស់លោក ហើយលោកនឹងសងដល់គ្រប់គ្នាតាមការប្រព្រឹត្តរបស់ពួកគេរៀងៗខ្លួន។* នេះជាការស្របគ្នាទៅនឹងការលើកឡើងនៃព្រះគម្ពីរគួរអាន ដែលចែងថា៖ *មិនត្រូវឱ្យជីវិតមួយទទួលបាបពីជីវិតដទៃឡើយ។ ហើយសម្រាប់មនុស្សលោកមិនទទួលបានក្រៅពីអ្វីដែល ខ្លួនគេបានប្រឹងប្រែងធ្វើនោះឡើយ។ ហើយពិតប្រាកដណាស់ ការប្រឹងប្រែងរបស់គេនឹងត្រូវគេបង្ហាញឱ្យឃើញ(នៅថ្ងៃជំនុំជម្រះ)។* (គួរអាន ៥៣:៣៨-៤០)

**ទីពីរ៖** យោងទៅតាមកណ្ឌគម្ពីរលោកុប្បត្តិ ៥:៥ សរសេរថា ឳពុករបស់យើងរាល់គ្នាគឺលោកអាដាំ បានរស់នៅជាមួយភរិយាអស់រយៈពេល៩៣០ឆ្នាំ បន្ទាប់ពីពួកគាត់បានទទួលទានផ្លែនៃដើមឈើហាមឃាត់។ នេះជាការបញ្ជាក់ពីភាពខុសឆ្គងនៃកណ្ឌគម្ពីរលោកុប្បត្តិ ២:១៧ ដែលថា៖ *ប៉ុន្តែអ្នកមិនត្រូវបរិភោគផ្លែពីដើមដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់ឡើយ ព្រោះនៅថ្ងៃណាដែលអ្នកបរិភោគ អ្នកនឹងស្លាប់ជាមិនខាន។* យើងឃើញថាការស្លាប់នោះមិនបានកើតឡើងចំពោះលោកអាដាំនោះទេ នេះក៏ដោយសារតែលោកបានសារភាពទោសកំហុសចំពោះបាបរបស់លោក និងសូមឱ្យទ្រង់លើកទោស ហើយព្រះក៏បានលើកទោសដល់គាត់។ នៅក្នុងកណ្ឌគម្ពីរអេសេគាល ១៨:២១-២២ សរសេរថា៖ *ប៉ុន្តែបើជនទុច្ចរិត*[91] *កែខ្លួនឈប់ប្រព្រឹត្តអំពើខុសឆ្គងទៀត ហើយកាន់តាមបញ្ញត្តិរបស់ខ្ញុំ(ព្រះ) ព្រមទាំងប្រព្រឹត្តអ្វីដែលសុចរិតនិងយុត្តិធម៌ នោះគាត់នឹងរស់រានមានជីវិតតទៅទៀត។ គាត់នឹងមិនស្លាប់ទេ។ អំពើខុសឆ្គងដែលគាត់បានធ្វើទាំងប៉ុន្មាន នឹងមិនត្រូវលើកមកទាស់នឹងគាត់ទេ។ គាត់នឹងរស់រានមានជីវិតតទៅទៀតដោយសារគាត់ប្រព្រឹត្តអ្វីដែលសុចរិត។* ប៉ុន្តែយើងឃើញថាលោកអាដាំនិងភរិយាគាត់**អាចនៅរស់**បាន នោះមានន័យថាគាត់បានងាកចេញពីអំពើបាបទាំងឡាយដែលពួកគាត់បានប្រព្រឹត្ត។ នេះមានន័យថា បាប ពុំត្រូវបានបន្សល់ទុកនិងធ្លាក់មកលើពួកយើង ហើយក៏គ្មានហេតុផលអ្វីដែលលោកយេស៊ូត្រូវមកស្លាប់ដើម្បីលោះបាបនរណាដែរ។ នេះក៏ដូចទៅនឹងការលើកឡើងរបស់ព្រះគម្ពីរគួរអានដែលបានចែងថា៖ *ហើយលោកអាដាំបានធ្វើខុសនឹងបទបញ្ជានៃព្រះអម្ចាស់របស់គាត់ ហើយនិងបានវង្វេង(ពីការពិត)។ ក្រោយមក ព្រះអម្ចាស់របស់គាត់បានជ្រើសរើសគាត់ ហើយទ្រង់បានអភ័យទោសឱ្យគាត់ និងបានចង្អុលបង្ហាញគាត់(ទៅរកមាគ៌ាដ៏ត្រឹមត្រូវ)វិញ។* (គួរអាន ២០:១២១-១២២)

---

[91] ការលើកឡើងនេះគឺក្នុងករណីមនុស្សនោះជាមនុស្សទុច្ចរិត។ តើយ៉ាងណាទៅវិញប្រសិនបើអ្នកប្រព្រឹត្តបាបនោះជាមនុស្សសុចរិតដូចយ៉ាងលោកអាដាំវិញនោះ? ពិតណាស់ គាត់មុខជាទទួលបានការលើកទោស តាមដែលគាត់បានសារភាពទោសមិនខាន។

**ទីបី៖** ហើយវាមិនត្រឹមត្រូវនោះទេ បើយោងទៅតាមគម្ពីរបរិសុទ្ធនោះ លើកឡើងថា លោកយេស៊ូមិនមានបំណង ឬចង់មកស្លាប់ដើម្បីលោះបាបមនុស្សលោកឡើយ ហើយលោកក៏មិនចង់ស្លាប់នៅលើឈើឆ្កាងដែរ។ នៅពេលលោកដឹងថាសត្រូវរបស់លោកប៉ុនប៉ងយកជីវិតលោក លោកបានប្រកាសថា៖ *ខ្ញុំកំពុងកើតទុក្ខស្ទើរស្លាប់។*(ម៉ាកុស ១៤:៣៤) ក្រោយមកលោកបានបួងសួងទៅកាន់ព្រះថា៖ *អប្បា បិតាអើយ! លោកអាចសម្រេចគ្រប់ការទាំងអស់បាន។ សូមដកពែងនេះចេញពីខ្ញុំ។ ប៉ុន្តែសូមឱ្យបំណងរបស់លោកបានសម្រេច មិនមែនបំណងរបស់ខ្ញុំទេ។*(ម៉ាកុស ១៤:៣៦) មិនតែប៉ុណ្ណោះលោកក៏បានប្រាប់ឱ្យសិស្សរបស់លោក ទិញដាវទុក(លូកា ២២:៣៦) ហើយនៅចាំយាមការពារលោកនៅពេលយប់ពីសត្រូវរបស់លោកផង។

**ទីបួន៖** គម្ពីរបរិសុទ្ធបានឱ្យដឹងនៅក្នុងកណ្ឌគម្ពីរម៉ាកុស ១៥:៣៤ ថាបុរសដែលត្រូវបានគេចងឆ្កាង បានស្រែកដោយសម្លេងយ៉ាងខ្លាំង ដោយនិយាយ៖ **អេលីអេលី ឡាម៉ាសាបាក់ថានី?** ដែលមានន័យថា៖ *ព្រះខ្ញុំអើយ ព្រះខ្ញុំអើយ ហេតុអ្វីបានជាលោកបោះបង់ចោលខ្ញុំ?* ការស្រែកដោយសេចក្តីអស់សង្ឃឹមយ៉ាងនេះដូចជាមិនសមឡើយ បើសិនជាយើងព្រមធ្វើវាដើម្បីជាប្រយោជន៍សម្រាប់មនុស្សលោក នេះក៏បង្ហាញថាអ្នកដែលត្រូវគេចងឆ្កាងនោះ មិនមានបំណង ហើយក៏មិនចង់ស្លាប់នៅលើឈើឆ្កាងដែរ។ អ្វីដែលសំខាន់ទៀតនោះ រឿងរ៉ាវនេះបានសបញ្ជាក់យ៉ាងច្បាស់ថាមនុស្សដែលត្រូវគេចងឆ្កាងនោះមិនមែនជាលោកយេស៊ូទេ ពីព្រោះថាការស្រែក និងការភ័យស្លន់ស្លោមិនស័ក្តិសមជាទង្វើរបស់ព្យាការីរបស់ព្រះឡើយ ហើយកាន់តែមិនសមថាជាព្រះផងដែរ។

**ទីប្រាំ៖** យោងទៅតាមកណ្ឌគម្ពីរម៉ាកុស ១៤:៥០ បានលើកឡើងថាគ្មានសិស្សរបស់លោកយេស៊ូណាម្នាក់បានឃើញការចងឆ្កាងនោះដោយផ្ទាល់ភ្នែកឡើយ

គឺពួកគេទាំងអស់គ្នាបានបោះបង់ចោលលោកហើយរត់គៀសខ្លួនអស់ទៅ[92]។ មិនតែប៉ុណ្ណោះ ក៏គ្មានអ្នកសរសេរគម្ពីរ ឬអ្នកសរសេរសំបុត្រណាម្នាក់ បានឃើញហេតុការណ៍ចងឆ្កាងផ្ទាល់ភ្នែកដែរ។ ដូច្នេះប្រភពនៃសាច់រឿងការចងឆ្កាងហាក់នៅមានភាពមន្ទិលសង្ស័យ ជាពិសេសនៅពេលយើងពិនិត្យមើលព័ត៌មានលម្អិតពីកណ្ឌគម្ពីរខ្លះ ឃើញថានៅមានភាពមិនស្របគ្នាទាក់ទងនឹងព្រឹត្តិការណ៍នេះតាំងពីដើមរហូតដល់ចប់។

**ទីប្រាំមួយ៖** គំនិតដែលថា ត្រូវមានការបង្ហូរឈាមដើម្បីជាថ្លៃលោះហើយដើម្បីបំពេញព្រះទ័យរបស់ព្រះនោះ មើលទៅហាក់ដូចជាព្រះជាអារក្សបិសាចដ៏ខ្លាំងក្លាមួយទៅវិញ។ វាមិនមានហេតុផលណាដែលថា ឈាម ហើយនិង បាប មានទំនាក់ទំនងគ្នាសោះឡើយ។ អ្វីដែលអាចជម្រះបាបបាននោះគឺមានដូចជា ការនឹកស្តាយក្រោយ, ការសារភាពទោសដោយស្មោះស, ការតស៊ូព្យាយាមប្រឆាំងនឹងសេចក្តីអាក្រក់ និងការតស៊ូព្យាយាមប្រតិបត្តិតាមអ្វីដែលព្រះបានបើកបង្ហាញមកកាន់យើងតាមរយៈបណ្តាព្យាការីរបស់ព្រះអង្គ។ កាន់តែស៊ីជម្រៅទៅទៀត នៅពេលដែលមានគេសួរលោកយេស៊ូអំពីជីវិតអស់កល្ប(ជីវិតនៅស្ថានសួគ៌) លោកបានតបថា មិនមែនជាការជឿចំពោះលោកថាជាអ្នកសង្គ្រោះតាមការបង្ហូរឈាមអ្វីឡើយ តែលោកតបថា៖ *ប៉ុន្តែ ប្រសិនបើអ្នកចង់ទទួលជីវិត ចូរប្រព្រឹត្តតាមបញ្ញត្តិទាំងប៉ុន្មានជាដរាបចុះ។* (ម៉ាថាយ ១៩:១៧)

របៀបនៃការសង្គ្រោះដែលគ្រិស្តបរិស័ទសព្វថ្ងៃបានជឿនេះ មិនត្រឹមតែមិនសមហេតុផល និងមិនសមខាងសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងខុសឆ្គងពីសេចក្តី

---

[92] បើយើងគិតវិជ្ជមានចំពោះសិស្សលោកយេស៊ូនោះ មានរឿង២យ៉ាងដែលអាចកើតឡើងនោះគឺ៖ ទី១ ប្រហែលការលើកឡើងថាសិស្សទាំងអស់បានបោះបង់នឹងរត់ចោល ជាខ្លឹមសារដែលខុសពីអត្ថបទដើម(មានការកែប្រែឬក្លែងដូចបានលើកឡើងកាលពីជំពូកមុនៗ)។ ទី២ ប្រហែលជាសិស្សទាំងអស់បានបោះបង់នឹងរត់ចោលមែន ដ្បិតពួកគេដឹងថា អ្នកដែលកំពុងចងឆ្កាងមិនមែនជាលោកយេស៊ូឡើយ។

បង្រៀនរបស់លោកយេស៊ូ ដែលលោកមកផែនដីនេះដើម្បីសង្គ្រោះមនុស្សតាមរយៈការបង្រៀនរបស់លោក ក៏ដូចជាផ្តល់ភាពជាគំរូនៃជីវិតដែលរស់នៅតាមបែបផែនដែលព្រះរៀបចំ មិនមែនមកសង្គ្រោះដោយស្លាប់នៅលើឈើឆ្កាង ហើយបង្ហូរឈាមខ្លួនឯងមកលាងបាបអ្នកដទៃនោះទេ។ ព័ន្ធកិច្ចរបស់លោកគឺដើម្បីមកអំពាវនាវមនុស្សដែលប្រព្រឹត្តបាបទាំងឡាយ ឱ្យសារភាពទោសកំហុស ដែលព័ន្ធកិច្ចនេះក៏ដូចជាអ្វីដែលព្យាការីដែលមកជំនាន់មុនៗលោកបានធ្វើដែរ។ លោកមិនដែលមានប្រសាសន៍ថា លោកមកដើម្បីជាថ្លៃលោះបាបមនុស្សដែរ។ រឿងនេះត្រូវបានបញ្ជាក់នៅក្នុងកណ្ឌគម្ពីរម៉ាថាយ ៤:១៧ ថា៖ *ចាប់ពីពេលនោះមក លោកយេស៊ូបានផ្សព្វផ្សាយថា ចូរប្រែចិត្ត ព្រោះរាជាណាចក្រស្ថានសួគ៌គឺជិតដល់ហើយ។* វាកាន់តែពិបាកយល់ នៅពេលដែលគម្ពីរបរិសុទ្ធលើកឡើងយ៉ាងបំពានទៅចំពោះលោកយេស៊ូដោយថាលោកជាមនុស្សត្រូវបណ្តាសា។ លោកប៉ូលនិយាយថា៖ *ដោយសារគ្រិស្តបានទិញយើង នោះលោកបានរំដោះយើងឱ្យរួចពីបណ្តាសានៃច្បាប់ ដោយធ្វើជាអ្នកត្រូវបណ្តាសាជំនួសយើង ពីព្រោះបទគម្ពីរចែងថា អ្នកណាដែលត្រូវព្យួរលើបង្គោលឈើ អ្នកនោះត្រូវបណ្តាសាហើយ។* (កាឡាទី ៣:១៣)

ជំនឿនៃដង្វាយធួន ឬថ្លៃលោះនេះ ក៏មានផងដែរនៅក្នុងសាសនាខុសឆ្គង។ យោងតាមសៀវភៅ Rock of Truth និពន្ធដោយលោក Arthur Findley បានសរសេរថា មានអង្គចំនួន១៦ ដែលមនុស្សលោកបានជឿថា បានមកកាន់ផែនដីនេះដើម្បីសង្គ្រោះមនុស្ស និងជាថ្លៃលោះបាប។ អង្គទាំង១៦នោះមានដូចជា៖ ព្រះអូរីស៊ីសរបស់ពួកអេស៊ីប (១៧០០ឆ្នាំមុនគ.ស.), ព្រះបាអាល់របស់ពួកបាប៊ីឡូន(១២០០ឆ្នាំមុនគ.ស.), ព្រះក្រឹស្នារបស់ពួកឥណ្ឌា(១០០០ឆ្នាំមុនគ.ស.), ព្រះអាន់ជ្រារបស់ពួកទីបេ(៧២៥ឆ្នាំមុនគ.ស.), ព្រះពុទ្ធតាមបែបចិន(៥៦០ឆ្នាំមុនគ.ស.) និងព្រះមិស្រារបស់ពួកពែរ្ស(៤០០ឆ្នាំមុនគ.ស.) ជាដើម។

គោលជំនឿលើដង្វាយធួននេះ មិនត្រឹមតែមិនសមស្រមនឹងហេតុផលនោះទេ វាថែមទាំងជំរុញមនុស្សឱ្យបោះបង់ការប្រព្រឹត្តអំពើល្អ ហើយស្រវាំចាប់អំពើខុសឆ្គង

ដូចជា កាប់សម្លាប់, លួចប្លន់, រំលោភបំពានជាដើម។ លោកប៉ូលបានមើលស្រាលបទបញ្ញត្តិនានាដែលលោកយេស៊ូបានបង្រៀន ហើយបែរជានិយាយថា៖ *ព្រោះយើងយល់ឃើញថាមនុស្សម្នាក់នឹងត្រូវប្រកាសថាសុចរិតដោយសារជំនឿ មិនមែនដោយអាងលើច្បាប់ទេ។*(រ៉ូម ៣:២៨) លោកប៉ូលក៏និយាយទៀតថា លោកអប្រាហាំមិនអាចរាប់ថាជាមនុស្សសុចរិតនោះទេបើតាមការប្រព្រឹត្តរបស់លោកនោះ។(រ៉ូម ៤:២) តាមពិតគឺលោកប៉ូលនេះហើយដែលបង្កើតគំនិតថា មានតែការជឿលើការចងឆ្កាងរបស់លោកយេស៊ូប៉ុណ្ណោះ ទើបទទួលបានសេចក្ដីសង្គ្រោះ។ តើស្ថានភាពមនុស្សជាតិនឹងក្លាយទៅជាយ៉ាងណាបើមនុស្សនាំគ្នាជឿបែបនេះទាំងអស់គ្នានោះ?

ដើម្បីឆ្លើយតបនឹងការលើកឡើងរបស់លោកប៉ូល ចម្លើយគឺមាននៅក្នុងប្រសាសន៍របស់លោកយេស៊ូ៖ *ហេតុនេះ សូម្បីតែបញ្ញត្តិដែលមនុស្សចាត់ទុកថាមិនសូវសំខាន់ តែបើអ្នកណាល្មើសបញ្ញត្តិនោះ ហើយបង្រៀនអ្នកឯទៀតឱ្យធ្វើដូច្នោះ អ្នកនោះមិនសមនឹងចូលរាជាណាចក្រស្ថានសួគ៌ឡើយ។ ផ្ទុយទៅវិញ អ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិទាំងនោះ ហើយបង្រៀនអ្នកឯទៀតឱ្យប្រព្រឹត្តតាមដែរ អ្នកនោះសមនឹងចូលរាជាណាចក្រស្ថានសួគ៌។*(ម៉ាថាយ ៥:១៩)

សាសនាអ៊ីស្លាមបដិសេធចំពោះគោលជំនឿលើដង្វាយធួន ហើយបញ្ជាក់យ៉ាងច្បាស់ថា ការលើកទោសមិនអាចធ្វើឡើងតាមរយៈយញ្ញបូជា ឬការធ្វើទុក្ខទោសមនុស្សណាម្នាក់ឡើយ ផ្ទុយទៅវិញ ការលើកទោស គឺតាមរយៈក្ដីប្រោសមេត្តារបស់ព្រះជាម្ចាស់ ទៅកាន់មនុស្សណាហើយដែលបានសារភាពទោសកំហុសដោយស្មោះស និងដោយប្រឹងប្រែងចៀសវាងពីការប្រព្រឹត្តអាក្រក់ ហើយត្រឡប់មកប្រព្រឹត្តល្អវិញ។ កាន់តែស៊ីជម្រៅទៀតនោះ ប្រសិនបើការប្រព្រឹត្តបាបនោះ ប៉ះពាល់ឬធ្វើឱ្យមានភាពអយុត្តិធម៌ដល់សិទ្ធិអ្នកដទៃផងនោះ អ្នកដែលត្រូវគេបំពាននឹងត្រូវទទួលបានសិទ្ធិនោះមកវិញយ៉ាងពេញលេញ ហើយអ្នកប្រព្រឹត្តខុសក៏ត្រូវសុំការអភ័យទោសពីអ្នកដែលខ្លួនបំពានផង។

ព្រះគម្ពីរគួរអានបានសន្យាថា មនុស្សទាំងអស់នឹងទទួលបានការសង្គ្រោះ តាមរយៈការទទួលជឿលើព្រះតែមួយអង្គគត់ នឹងប្រព្រឹត្តសុចរិតផងៈ *ការពិតមិនមែនដូច្នោះទេ (អ្នកដែលនឹងបានចូលស្ថានសួគ៌នោះ) គឺអ្នកដែលបានថ្វាយខ្លួនរបស់គេចំពោះព្រះអល់ឡោះ ហើយជាអ្នកប្រព្រឹត្តសុចរិតផង។ ដូច្នេះ សម្រាប់អ្នកនោះនឹងទទួលបានផលបុណ្យពីព្រះអម្ចាស់របស់គេ ហើយពួកគេគ្មានការភ័យខ្លាចនិងទុក្ខព្រួយអ្វីឡើយ។* (គួរអាន ២:១១២) ព្រះអល់ឡោះក៏មានព្រះបន្ទូលទៀតដែរថាៈ *ដូច្នេះ អ្នកណាហើយដែលមានសេចក្ដីសង្ឃឹមថា គេនឹងបានជួបព្រះអម្ចាស់របស់គេ ចូរឱ្យគេប្រព្រឹត្តអំពើណាដែលសុចរិត ហើយកុំឱ្យគេគោរពសក្ការៈអ្វីមួយ រួមស្មើនឹងព្រះឡើយ។*(គួរអាន ១៨:១១០)

កណ្ឌគម្ពីរយ៉ាកុប ២:១៤ បានលើកឡើងត្រឹមត្រូវស្របនឹងសាសនាអ៊ីស្លាម ដូចមានចែងថាៈ *បងប្អូនខ្ញុំអើយ ប្រសិនបើអ្នកណាម្នាក់និយាយថាខ្លួនមានជំនឿ តែអ្នកនោះគ្មានការប្រព្រឹត្ត តើមានប្រយោជន៍អ្វី? ជំនឿរបស់អ្នកនោះមិនអាចសង្គ្រោះអ្នកនោះបានឡើយ មែនទេ?* កណ្ឌគម្ពីរដដែលជំពូក ២ ខ ១៧ ចែងផងដែរថាៈ *ដូចគ្នាដែរ ប្រសិនបើមានជំនឿ តែគ្មានការប្រព្រឹត្ត ជំនឿនោះគឺស្លាប់ហើយ។*

# សាសនាអ៊ីស្លាម គឺជាសាសនាឯកទេពនិយមរបស់បណ្ដាព្យាការីទាំងឡាយ

តាមរយៈការវិភាគយ៉ាងស៊ីជម្រៅអំពីគោលជំនឿរបស់សាសនាគ្រិស្ដ ដូចដែលបានរៀបរាប់ខាងលើ នាំឱ្យយើងអាចសន្និដ្ឋានបានពីរយ៉ាងគឺ គោលជំនឿមានលក្ខណៈមិនសមហេតុផល និងមិនត្រឹមត្រូវតាមសេចក្ដីបង្រៀនរបស់លោកយេស៊ូ។ ពីព្រោះយើងដឹងច្បាស់ហើយថា នៅពេលដែលលោកចេញពីផែនដីប៉ុន្មានឆ្នាំដំបូង គ្មានអ្នកកាន់តាមណាម្នាក់ជឿថាលោកជាព្រះឡើយ គឺទទួលជឿត្រឹមថាលោកជាព្យាការីរបស់ព្រះប៉ុណ្ណោះ។ រីឯគោលជំនឿរបស់គ្រិស្ដបរិស័ទសព្វថ្ងៃ គឺទើបតែកើត

ឡើងច្រើនឆ្នាំក្រោយមក ដែលមានន័យថាគោលគ្រឹះនៃជំនឿនៅតាមក្រុមជំនុំ គឺឃ្លាតចេញឆ្ងាយពីសេចក្តីបង្រៀនពិតប្រាកដរបស់លោកយេស៊ូ និងខុសពីសេចក្តីបង្រៀនរបស់ព្យាការីជំនាន់មុនផងដែរ។

ការទទួលជឿថា ព្រះគឺមានតែមួយអង្គគត់ ហើយការគោរពសក្ការៈទៅចំពោះទ្រង់តែមួយអង្គគត់គឺជាបញ្ញត្តិដែលត្រូវតែធ្វើតាមដាច់ខាត។ ការទុកអ្វីមួយជាព្រះ ឬស្មើនឹងព្រះ គឺជាជំនឿដែលកើតឡើងនៅសម័យក្រោយៗនេះទេនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ក្នុងរយៈកាលប្រមាណជា១០សតវត្សរ៍បន្ទាប់ពីវត្តមានរបស់លោកអាដាំ មនុស្សលោកគឺគោរពសក្ការៈតែចំពោះព្រះជាអម្ចាស់តែមួយអង្គគត់។ ជំនឿខុសឆ្គងទើបតែកើតឡើងនៅមុនសម័យកាលរបស់ព្យាការី**ណូអេ** ដែលមនុស្សលោកចាប់ផ្តើមគោរពសក្ការៈទៅចំពោះរូបបដិមា។ រឿងនេះវាកើតឡើងដោយសារតែមនុស្សបានព្យាយាមលើកតម្កើងហួសប្រមាណ ទៅចំពោះសន្តបុគ្គលមួយចំនួនក្រោយពេលពួកគេបានស្លាប់ទៅ។ ព្យាការីណូអេ ត្រូវបានព្រះចាត់បញ្ជូនមកដើម្បីចង្អុលបង្ហាញមនុស្សលោកឱ្យត្រឡប់មករកផ្លូវដែលត្រឹមត្រូវ និងអំពាវនាវឱ្យពួកគេគោរពសក្ការៈទៅចំពោះព្រះអល់ឡោះតែមួយអង្គគត់។ បន្ទាប់ពីនោះព្រះក៏បានចាត់បញ្ជូនព្យាការីម្នាក់ហើយម្នាក់ទៀតបន្តបន្ទាប់គ្នា ទៅកាន់ប្រជាជាតិជាច្រើន ដើម្បីផ្សព្វផ្សាយនូវព្រះរាជសារដ៏សាមញ្ញមួយគឺ **គ្មានព្រះឯណាឡើយដែលត្រូវគោរពសក្ការៈក្រៅពីព្រះអល់ឡោះ។**

ព័ន្ធកិច្ចរួមរបស់បណ្តាព្យាការីទាំងអស់ គឺដើម្បីអំពាវនាវមនុស្សលោកឱ្យមានជំនឿលើព្រះ ដែលជាអង្គអាទិទេពដ៏ខ្ពង់ខ្ពស់ក្រៃលែងបំផុត ហើយទទួលស្គាល់ព្រះអង្គថាជាព្រះអាទិករបង្កើតរាល់សព្វសារពើទាំងអស់ ក៏ដូចជាអង្គដែលផ្គត់ផ្គង់និងរក្សាទ្រទ្រង់ពិភពលោកនេះផងដែរ។ សូម្បីតែមនុស្សដែលគោរពព្រះដទៃៗនោះក៏បានដឹងដោយធម្មជាតិថា ព្រះពិតជាមានពិតមែន ហើយពួកគេក៏មិនមានមន្ទិលសង្ស័យ

ដែរ។[93] មានតែពួកគេមួយចំនួនតូចប៉ុណ្ណោះដែលធ្វើជាប្រឆាំងថាលើលោកនេះគ្មានព្រះនោះទេ។ ក៏មានដែរពួកមួយចំនួនដែលគេគោរពសក្ការៈចំពោះព្រះតាមរយៈការធ្វើអំពើល្អ ហើយក៏មានការអធិស្ឋានបួងសួងដល់ព្រះខ្លះដែរនៅពេលគេជួបទុក្ខលំបាក។ ប៉ុន្តែនៅពេលដែលជីវិតមានភាពសុខស្រួល ពួកគេក៏បួងសួងដែរ តែបួងសួងតាមរយៈពួកអាចារ្យ។ ព្យាការីរបស់ព្រះបានអំពាវនាវពួកគេ ឱ្យបែរទៅរកព្រះជាអម្ចាស់ ហើយទូលអង្វរទៅចំពោះព្រះអង្គផ្ទាល់នៅគ្រប់ពេលទាំងអស់ ដោយមិនចាំបាច់ទូលអង្វរតាមរយៈពួកអាចារ្យឡើយ។ ដោយសារតែជំនឿលើព្រះតែមួយអង្គ គឺជារឿងចម្បង ក៏ជាកាតព្វកិច្ច និងជាគោលគ្រឹះដែលធ្វើឱ្យរាល់សកម្មភាពរបស់យើងមានភាពត្រឹមត្រូវ និងត្រូវបានទទួលស្គាល់ ទើបយើងឃើញថា រាល់ព្យាការីទាំងអស់ចាប់ផ្តើមអំពាវនាវទៅកាន់មនុស្សលោកដោយពោលថា៖ *ចូរពួកអ្នកគោរពសក្ការៈចំពោះព្រះអល់ឡោះចុះ ពួកអ្នកគ្មានម្ចាស់ឯណាផ្សេងក្រៅពីទ្រង់ឡើយ។*(គួរអាន ៧:៦១) ព្រះអល់ឡោះក៏បានមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ១៦:៣៦ ថា៖ *ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ ដោយគេបង្គាប់ពួកគេឱ្យគោរពសក្ការៈចំពោះព្រះអល់ឡោះ និងចៀសវាងពី**តហ្គូត**(ព្រះក្លែងក្លាយ)។* បន្ថែមពីនោះព្រះអល់ឡោះក៏បានមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ២១:២៥ ថា៖ *ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាម្នាក់មុនអ្នក លើកលែងតែ*

[93] លទ្ធិមិនជឿព្រះ(Atheism) បានចាប់ផ្តើមរីកដុះដាលយ៉ាងធំចេញពីសហគមន៍គ្រិស្តបរិស័ទក្នុងអំឡុងសតវត្សរ៍ទី១៨ និង១៩។ ហេតុផលចម្បងដែលនាំឱ្យមានរឿងនេះកើតឡើងគឺដោយសារតែក្រុមជំនុំ ឬវិហារសាសនា បានប្រព្រឹត្តអំពើអយុត្តិធម៌ដូចជា ទាសភាព, ការមើលងាយមើលថោក និងរំលោភបំពានទៅចំពោះមនុស្សដោយប្រើពាក្យថា «ក្នុងព្រះនាមនៃព្រះ»។ បន្ថែមពីនោះ សាសនាគ្រិស្តក៏តែងតែមិនស្របគ្នាជាមួយនឹងហេតុផល និងតម្រូវការរបស់មនុស្សផង។ មិនតែប៉ុណ្ណោះ ក្រុមជំនុំមួយក៏បានប្រឆាំងនិងការរីកចម្រើនឡើងខាងវិទ្យាសាស្ត្រហើយថែមទាំងធ្វើទុក្ខបុកម្នេញដល់ពួកអ្នកវិទ្យាសាស្ត្រ ដែលនាំឱ្យមានការបែកចេញរវាងមនុស្ស និងជំនឿ។ ដូច្នេះហើយបានជាមនុស្សដែលមានទំនោរលើសម្ភារនិយមខាងលោកិយនេះ ដោយសារតែអវត្តមាននៃភាពសមហេតុផល ឯជំនឿក៏មានការបែកបាក់ ធ្វើឱ្យសាសនាក៏គ្មានតួនាទីអ្វីសោះក្នុងជីវិតមនុស្ស។

*យើងបានបើកបង្ហាញទៅកាន់អ្នកនាំសារនោះថា ពិតប្រាកដណាស់ គ្មានព្រះអម្ចាស់ណាផ្សេងដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីយើងនោះឡើយ។ ដូច្នេះ ចូរពួកអ្នកគោរពសក្ការៈមកចំពោះយើងចុះ។* ដូច្នេះហើយទើបយើងអាចសន្និដ្ឋានយ៉ាងជាក់ច្បាស់ថា សាសនាអ៊ីស្លាមគឺជាសាសនារបស់ព្យាការីនិងអ្នកនាំសារទាំងអស់របស់ព្រះរាប់តាំងពីព្យាការីអាដាំ មកដល់ព្យាការីមូហាំម៉ាត់។ ជាការពិតណាស់អ៊ីស្លាមគឺជាសាសនារបស់ព្យាការី ណូអេ, អប្រាំហាំ, ម៉ូសេ និង យេស៊ូ។ បើតាមសេចក្ដីបង្រៀនរបស់សាសនាអ៊ីស្លាម ព្យាការីទាំងអស់គឺជាបងប្អូននឹងគ្នា ហើយពុំមានការបែងចែករវាងពួកលោកឡើយ។ នរណាហើយដែលបានប្រតិបត្តិតាមការចង្អុលបង្ហាញពីព្យាការីរបស់គេ នៅក្នុងជំនាន់របស់គេ ហើយគោរពសក្ការៈចំពោះព្រះជាអម្ចាស់នោះ អ្នកនោះត្រូវចាត់ទុកថាជាអ្នកមូស្លីម(អ្នកថ្វាយខ្លួន) ហើយនិងបានចូលស្ថានសួគ៌។

សាសនាអ៊ីស្លាមបានមកស្តារឡើងវិញនូវសភាពដើមនៃព្រះរាជសារ ដែលព្រះបានប្រទានមកបណ្ដាព្យាការីទាំងឡាយរបស់ទ្រង់។ សាសនាអ៊ីស្លាមគ្រាន់តែមកបន្តផ្សព្វផ្សាយព្រះរាជសារនោះ ដែលដើមឡើយព្រះអល់ឡោះបានបញ្ញត្តិដល់កុលសម្ព័ន្ធឬប្រជាជាតិជាក់លាក់ណាមួយ ក្នុងសម័យកាលជាក់លាក់ណាមួយ តាមរយៈព្យាការីដែលទ្រង់បានចាត់បញ្ជូនទៅកាន់ពួកគេ។ ប៉ុន្ដែពេលវេលាកន្លងផុតទៅ ព្រះរាជសារនោះត្រូវបានមនុស្សបកស្រាយឱ្យមានភាពខុសឆ្គង ឬយកទៅលាយឡំជាមួយអប្បិយជំនឿខុសឆ្គង ឬកិច្ចពិធីផ្សេងៗដែលមនុស្សបានបង្កើតឡើង ដែលនាំឱ្យបាត់បង់នូវជំនឿត្រឹមត្រូវ ហើយក្លាយជាកិច្ចប្រតិបត្តិដែលឥតប្រយោជន៍។

សាសនាអ៊ីស្លាមដែលព្រះបានបើកបង្ហាញមកកាន់ព្យាការីមូហាំម៉ាត់ គឺជាការធ្វើឱ្យមានឡើងវិញនូវគោលជំនឿអំពីព្រះតែមួយអង្គ ដែលលោកយេស៊ូ និង បណ្ដាព្យាការីទាំងអស់របស់ព្រះអល់ឡោះបានបង្រៀនមកកាន់មនុស្សលោក។ សាសនាអ៊ីស្លាមគឺជាព្រះរាជសារមកកាន់មនុស្សជាតិទាំងឡាយ រហូតដល់គ្រាចុងក្រោយនៃផែនដី ហើយក៏នឹងមិនធ្វើឱ្យមានការបែកបាក់គ្នាជាក្រុមៗដូចសម័យព្យាការីមុនៗឡើយ។

សាសនាអ៊ីស្លាមបដិសេធនូវរាល់ជំនឿទាំងឡាយណា ដែលជាការប្រមាថចំពោះព្រះ ហើយធ្វើឱ្យមនុស្សបានយល់ដឹងពីលក្ខណៈពិតរបស់ព្រះជាម្ចាស់ឡើងវិញ ថាទ្រង់ជាព្រះតែមួយអង្គគត់ដែលជាព្រះអាទិករបង្កើតនូវសព្វសារពើ ព្រមទាំងជាអង្គដែលផ្គត់ផ្គង់ និងអភិបាលនូវរាល់អ្វីៗទាំងអស់ក្នុងចក្រវាឡ ហើយទ្រង់ក៏ជាព្រះតែមួយអង្គគត់ដែលអាចចាត់ថាល្អវិសេសឥតខ្ចោះ។ នេះក៏ជាការបង្ហាញថាព្រះអង្គជាព្រះដែលយើងចាំបាច់ត្រូវតែគោរពសក្ការៈ។ កាន់តែស៊ីជម្រៅទៀតនោះ យើងត្រូវតែគោរពសក្ការៈចំពោះព្រះអង្គតាមរបៀបដែលទ្រង់បង្គាប់យើង មិនមែនតាមរបៀបដែលយើងបង្កើតឡើងតាមចិត្តចង់ឡើយ។ ព្រះអង្គជាព្រះដែលស័ក្តិសមឱ្យយើងទូលបួងសួង។ ហើយការទទួលជំនឿថា ព្រះគឺមានតែមួយអង្គគត់ គឺជាគុណតម្លៃដ៏វិសេសលើសលប់ ហើយការទុកអ្វីមួយផ្សេងថាជាព្រះ ឬស្មើនឹងព្រះគឺជាបាបដ៏ក្រៃលែងបំផុតដូចគ្នា។ វាគឺជាបាបតែមួយគត់ដែលព្រះនឹងមិនលើកលែងទោសនោះឡើយ លើកលែងតែយើងបានផ្លាស់ប្រែខ្លួនទៅរកទ្រង់វិញមុននឹងអស់ជីវិត។ ព្រះបានមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *ពិតប្រាកដណាស់ ព្រះអល់ឡោះមិនអភ័យទោសឱ្យអ្នកដែលគោរពអ្វីមួយស្មើនឹងទ្រង់នោះឡើយ តែទ្រង់នឹងអភ័យទោសឱ្យចំពោះបាបផ្សេងពីនោះចំពោះអ្នកណាដែលទ្រង់មានចេតនា។*(គួរអាន ៤:៤៨) មិនត្រឹមតែប៉ុណ្ណោះ ការទុកអ្វីមួយផ្សេងថាជាព្រះ ឬស្មើនឹងព្រះ គឺជាហេតុដែលឱ្យព្រះរារាំងយើងមិនឱ្យចូលស្ថានសួគ៌ និងទាញទម្លាក់យើងចូលក្នុងស្ថាននរក។ ព្យាការីយេស៊ូ ក៏បានមានប្រសាសន៍ក្នុងព្រះគម្ពីរគួរអាន ៥:៧២ ថា៖ *ពិតប្រាកដណាស់ អ្នកណាទុកអ្វីមួយជាព្រះស្មើនឹងព្រះអល់ឡោះ នោះព្រះអល់ឡោះពិតជាបានហាមឃាត់គេអំពីស្ថានសួគ៌ ហើយកន្លែងរស់នៅរបស់គេគឺស្ថាននរក។ ហើយចំពោះពួកអ្នកដែលល្មើស គឺពុំមានអ្នកជួយគេឡើយ។* ការគោរពសក្ការៈអ្វីផ្សេងក្រៅពីព្រះពិតនោះ គឺជាបាបធំដែលអាចលុបបំបាត់នូវអំពើល្អទាំងអម្បាលម៉ានដែលយើងបានប្រព្រឹត្ត ដូចជាមានបញ្ជាក់ក្នុងព្រះគម្ពីរគួរអាន ៦:៨៨ ថា៖ *ប្រសិនបើពួកគេបានទុកអ្វីមួយជាព្រះស្មើនឹងព្រះអល់ឡោះនោះ អ្វីដែលពួកគេធ្លាប់បានសាងពិតជាអាសារបង់មិនខាន។*

ពិតណាស់ព្រះគឺជាអង្គដែលសត្វលោកទាំងអស់ត្រូវការ ដោយមិនត្រូវការអ្នកណាមកទូលអង្វរជំនួសឡើយ។ ព្រះជាអង្គដែលភាវៈមានជីវិតទាំងឡាយពឹងអាស្រ័យ ជាព្រះអាទិករបង្កើត និងទ្រទ្រង់នូវរាល់សព្វសារពើនៅលើលោកនេះ។ ទ្រង់ជាព្រះដ៏មហាអភ័យទោស មានក្ដីមេត្តាករុណា និងពេញដោយព្រះចេស្ដា។

បើយើងងាកមកមើលពាក្យសម្ដីរបស់បូព៌សិក្ខាវិទូ (Orientalist) ជនជាតិអ៊ីតាលីដ៏ល្បីល្បាញមួយរូបគឺ បណ្ឌិត Laura Veccia Vaglieri[94] បានសរសេរថា៖ *គួរអរគុណដល់សាសនាអ៊ីស្លាម ដែលបានមកកម្ចាត់ជំនឿខុសឆ្គង។ ការយល់ឃើញអំពីសាកលលោកក្ដី របៀបនៃការបដិបត្តិសាសនាក្ដី ហើយរបៀបនៃការរស់នៅក្នុងសង្គមក៏ត្រូវបានរំដោះចេញពីនឹមនៃជំនឿខុសឆ្គងដែលចងរឹតពួកគេ ឯចិត្តគំនិតរបស់ពួកគេក៏បានរំដោះចេញពីការរើសអើងពូជសាសន៍។ មនុស្សជាតិក៏បានស្គាល់នូវសេចក្ដីថ្លៃថ្នូរ ហើយក៏ចេះបន្ទាបខ្លួនទៅចំពោះព្រះ ដែលជាព្រះអាទិករបង្កើតរាល់សព្វសារពើផងដែរ។ រាល់ចិត្តគំនិតទាំងអស់ត្រូវបានរំដោះឱ្យផុតពីការប្រកាន់ពូជសាសន៍ មនុស្សក៏ត្រូវបានដោះលែងឱ្យរួចពីចំណង ដែលចងគេឱ្យជាប់ក្រោមអំណាចនៃមនុស្សដទៃផ្សេងទៀត។ ពួកអាចារ្យខ្លះការពារនូវរឿងខុសឆ្គង ជាអ្នកបំផ្លាញសេចក្ដីសង្គ្រោះ ហើយពួកមនុស្សខ្លះដែលតាំងខ្លួនជាអ្នកកណ្ដាលរវាងព្រះនិងមនុស្ស ក៏គិតថាខ្លួនមានសិទ្ធិអំណាចត្រួតត្រាលើចិត្តគំនិតមនុស្សដទៃ។ ក្រោយមកមនុស្សក្លាយជាអ្នកបម្រើចំពោះព្រះអល់ឡោះតែមួយអង្គគត់ ហើយចំពោះមនុស្សធម្មតាវិញគេគឺជាមនុស្សដែលមានសេរីភាពម្នាក់ ដែលមានកាតព្វកិច្ចត្រូវបំពេញចំពោះមនុស្សមានសេរីភាពដូចគ្នា។ ក្នុងពេលនោះផងដែរ មនុស្សលោកបានរងទុក្ខដោយសារតែភាពអយុត្តិធម៌ដែលកើតឡើងដោយសារតែគម្លាតនៃសង្គម ខណៈពេលដែលសាសនាអ៊ីស្លាមមកប្រកាសផ្សាយអំពីសមភាពរវាងមនុស្សជាតិ។ អ្នកមូស្លីមម្នាក់មិនមែន*

[94] ដកស្រង់ពីសៀវភៅ *Apologia dell’ Islamismo* បកប្រែដោយបណ្ឌិត Caselli ដាក់ចំណងជើងថ្មីថា Interpretation of Islam ទំព័រ ៣៣-៣៤។

*ខ្ពង់ខ្ពស់ជាងអ្នកមូស្លីមម្នាក់ទៀត ដោយសារតែពូជពង្សវង្សត្រកូល ឬដោយសារហេតុផលអ្វីដែរ តែអ្នកមូស្លីមម្នាក់ល្អប្រសើរជាងអ្នកមូស្លីមដទៃទៀតគឺដោយសារ ទំហំនៃការកោតខ្លាចទៅចំពោះព្រះរបស់គេ, អំពើល្អរបស់គេ, សុជីវធម៌របស់គេ និង កម្រិតចំណេះដឹងរបស់គេ។* លោកស្រីបណ្ឌិតក៏បានលើកឡើងនៅក្នុងសៀវភៅរបស់លោកស្រីដែរថា៖ *ការរីកសាយភាយរបស់សាសនាអ៊ីស្លាមយ៉ាងទូលំទូលាយនេះ គឺមិនមែនដោយសារការប្រើហិង្សា, ប្រើអាវុធ ឬដោយសារការគម្រាមកំហែងពីសំណាក់អ្នកផ្សាយសាសនាដែរ ប៉ុន្តែគឺដោយសារតែសេចក្តីពិតដែលអ្នកមូស្លីមនាំមក ហើយគេមានសេរីភាពពេញលេញដោយអាចទទួលស្គាល់ក៏បាន ឬបដិសេធក៏បាន ដ្បិតថាវាជាព្រះគម្ពីរមកពីព្រះ, ជាព្រះបន្ទូលនៃសេចក្តីពិត ហើយវាក៏ជាការណ៍អស្ចារ្យមួយដែលព្យាការីមូហាំម៉ាត់បាននាំមកបង្ហាញដល់ពួកមនុស្សដែលមានមន្ទិលសង្ស័យ និងពួកមនុស្សដែលចចេសរឹងរូស។* លោកស្រីបន្តទៀតថា៖ *ភាពខ្លាំងរបស់ព្រះគម្ពីរគឺភាពជាក់ច្បាស់, ភាពសាមញ្ញ និងភាពងាយស្រួល អំណោយផលដល់សាសនាអ៊ីស្លាមក្នុងការជ្រាបចូលដល់ដួងចិត្តមនុស្សគ្រប់គ្នាដោយមិនចាំបាច់ត្រូវការពន្យល់វែងឆ្ងាយ ឬអធិប្បាយទេសនាអ្វីឡើយ។*

ប្រវត្តិវិទូដ៏លេចធ្លោម្នាក់ទៀតគឺលោក Arnold J. Toynbee បានលើកឡើងថា៖ ជាការពិតណាស់ ខ្ញុំបានអំពាវនាវឱ្យពិភពលោកទទួលយកគោលការណ៍ភាតរភាព និងសមភាព របស់សាសនាអ៊ីស្លាមមកអនុវត្តន៍។ គោលជំនឿអំពីឯកអគ្គភាពនៃព្រះបានធ្វើឱ្យសាសនាអ៊ីស្លាម ក្លាយជាគម្រូដ៏ល្អវិសេសអំពីការរួបរួមគ្នាជាធ្លុងមួយ។ ហើយការណ៍ដែលសាសនាអ៊ីស្លាមនៅតែបន្តមានវត្តមាន គឺផ្តល់ជាក្តីសង្ឃឹមទៅកាន់ពិភពលោកទាំងមូល។[95]

---

[95] ស្រង់ចេញពីអត្ថបទ Civilization on Trial ផ្សាយចេញពីក្រុងញូយ៉ក ក្នុងព្រឹត្តប័ត្រនៃសាកលវិទ្យាល័យ Oxford ឆ្នាំ១៩៤៨។

# ជំហានចុងក្រោយ
# របស់ខ្ញុំមកកាន់
# សាសនាអ៊ីស្លាម

ត្រឹមតែរឿងរ៉ាវខ្លះៗដែលបានរៀបរាប់ក្នុងជំពូកមុននេះ គឺវាគ្រប់គ្រាន់ណាស់ហើយ សម្រាប់លោកអ្នកដែលស្វះស្វែងចង់រកនូវសេចក្តីពិត និងចង់បញ្ជាក់ពីភាពសុក្រឹត្យរបស់សាសនាអ៊ីស្លាម ក៏ដូចជាអ្នកដែលចង់ដឹងថា តើគ្រិស្តសាសនិកបានងាកចេញ និងប្រាសចាកពីសេចក្តីបង្រៀនដ៏ពិតប្រាកដរបស់ព្យាការីយេស៊ូកម្រិតណា។ ទោះជាយ៉ាងនេះក្តី ក៏ខ្ញុំមិនទាន់បានសម្រេចចិត្តឱ្យដាច់ស្រេច ក្នុងការដកខ្លួនចេញពីមាគ៌ាដែលខាងព្រះវិហារកាតូលិកបានគូសវាសឱ្យខ្ញុំដើរនោះដែរ។ បណ្តោងស័ក្តិសិទ្ធិរបស់ខ្ញុំតែងតែនៅជាមួយខ្ញុំមិនថាខ្ញុំទៅទីណាក៏ដោយ។ ក្នុងថង់តូចមួយដែលខ្ញុំដាក់តាមខ្លួនជាប់រហូត មានរូបឈើឆ្កាងចំនួនប្រាំពីរដែលធ្វើពីប្រាក់ ព្រមទាំងរូបថតនិងរូបចម្លាក់ដែលគេសន្មតថាជាលោកយេស៊ូ។ ខ្ញុំចេះតែមានអារម្មណ៍ថាបើខ្ញុំដកវាចេញពីខ្លួន នឹងមានរឿងអាក្រក់កើតឡើងចំពោះខ្ញុំជាមិនខាន។ យ៉ាងនេះហើយ ធ្វើឱ្យខ្ញុំមិនដែលច្រឡំដៃដាក់កន្លែងផ្សេងឡើយ វាតែងតែនៅក្នុងហោប៉ៅខ្ញុំជានិច្ច។

ថ្ងៃមួយ ពេលដែលខ្ញុំកំពុងអានសៀវភៅដែលខាងព្រះវិហារអ៊ីស្លាមបានឱ្យខ្ញុំ។ ខ្ញុំបានអានប៉ះប្រយោគពីរ ដែលនាំយកសេចក្តីអំណររីករាយជាពន់ពេកចូលទៅក្នុងបេះដូងរបស់ខ្ញុំ។ ខ្ញុំពោលបណ្តើរស្របពេលដែលទឹកភ្នែកចាប់ផ្តើមហូរចេញពីភ្នែក

ទាំងទ្វេររបស់ខ្ញុំថា៖ *ព្រះជាម្ចាស់! នេះហើយជាសេចក្តីពិត! នេះហើយជាចម្លើយដែលខ្ញុំមិនធ្លាប់បានរកឃើញពីមុនមក!*

ខ្ញុំជម្រាបដោយត្រង់ចុះ តាំងពីដើមមកខ្ញុំមិនដែលប៉ះឬអានព្រះគម្ពីរគួរអានសោះឡើយ។ មិនថាព្រះគម្ពីរគួរអានថតចម្លងភាសាអីក៏ដោយខ្ញុំមិនធ្លាប់បានឃើញឬប៉ះ សូម្បីតែបន្តិច ហើយពាក្យ**ព្រះគម្ពីរគួរអាន**នេះមិនដែលមាននៅក្នុងវចនានុក្រមនៃខួរក្បាលខ្ញុំឡើយ។ ខ្ញុំអានសៀវភៅមគ្គុទ្ទេសក៍ដែលខ្ញុំទទួលបានពីព្រះវិហារអ៊ីស្លាមអានវាមួយៗយ៉ាងយកចិត្តទុកដាក់៖ *ដោយពាក្យរបស់ពួកគេថា ពិតប្រាកដណាស់ពួកយើងបានសម្លាប់យេស៊ូគ្រិស្ត បុត្រនាងម៉ារី ដែលជាអ្នកនាំសារនៃព្រះអល់ឡោះ។ តាមពិតពួកគេមិនបានសម្លាប់យេស៊ូ និង មិនបានចងភ្ជាប់គេឡើយ។*(គួរអាន ៤: ១៥៧)

ខ្ញុំឈប់ត្រង់វាក្យខណ្ឌនេះ ហើយអានឡើងវិញជាច្រើនលើកត្រង់ឃ្លា *តាមពិតពួកគេមិនបានសម្លាប់យេស៊ូ និង មិនបានចងភ្ជាប់គេឡើយ។* នៅពេលដែលខ្ញុំកំពុងអានឃ្លាទាំងនោះ ខ្ញុំមានអារម្មណ៍ថាព្រះកំពុងតែឆ្លើយតបនឹងសំណួរដែលធ្វើឱ្យខ្ញុំធ្លាប់មន្ទិលសង្ស័យពីឫទ្ធានុភាពរបស់ព្រះអង្គ ព្រោះតែពីមុនគ្មានចម្លើយដែលសមហេតុផលដែលអាចទទួលយកបាន។

វាមិនមែនជារឿងងាយទេក្នុងការស្វែងរកចម្លើយមួយនេះ។ គិតបកទៅក្រោយវិញ ខ្ញុំត្រូវប្រកួតប្រជែងជាមួយសិស្សជាច្រើនដើម្បីទទួលបានអាហារូបករណ៍មួយនេះផង, ខ្ញុំត្រូវធ្វើដំណើររាប់ពាន់គីឡូម៉ែត្រមកកាន់រដ្ឋធានី**វ៉ាស៊ីនតោន**នៃសហរដ្ឋអាមេរិកផង, ខ្ញុំត្រូវរៀននិយាយនិងអានភាសាអង់គ្លេសផង ហើយទាំងដែលខ្ញុំមកពីអាមេរិកឡាទីនឯណោះ។ ខ្ញុំត្រូវរៀនធ្វើអាកប្បកិរិយា ដែលអ្នកមូស្លីមនៅក្រុង**ស៊ីអេថល**ទាំងអស់អាចទទួលយកបាន ដើម្បីអាចស្វែងរកឃ្លាទាំងពីរខាងលើនេះឃើញ។ ការណ៍ដែលចម្លើយទាំងនេះ អាចទៅដល់មនុស្សម្នាក់នៅប្រទេសវេណេហ្ស៊ុយអេឡាក្នុងឆ្នាំ ១៩៧៨ ពិតជាមិនងាយនោះទេ។ ទោះជាយ៉ាងនេះក្តី អ្វីដែលព្រះអល់ឡោះទ្រង់បាន

រៀបចំរមែងត្រូវបានសម្រេចយ៉ាងពេញលេញ។ នៅខណៈដែលខ្ញុំកំពុងត្រេកអរចំពោះចម្លើយដែលខ្ញុំរកឃើញនេះ ខ្ញុំក៏បានទូលទៅកាន់ព្រះអង្គ ហើយសុំការលើកទោសពីទ្រង់។ ខ្ញុំពិតជាចង់ហោះហើរដោយនាំយកដំណឹងនេះទៅវេណេហ្សុយអេឡាដើម្បីជម្រាបទៅក្រុមគ្រួសាររបស់ខ្ញុំ និងពិភពលោកទាំងមូលតែម្តង។

គ្រប់យ៉ាងបានកើតឡើងដូចជានៅក្នុងរឿងកុនអ៊ីចឹង។ វីរបុរសដ៏អស្ចារ្យរបស់ខ្ញុំអើយ! ព្យាការីជាទីស្រឡាញ់របស់ខ្ញុំអើយ! លោកយ៉ស៊ូអ្នកស្រុកណាសារ៉ែតអើយ! លោកនេះហើយ ជាអ្នកដែលខ្ញុំធ្លាប់ថ្វាយបង្គំមួយថ្ងៃ២ដងនៅអាសនៈដ៏តូចក្នុងផ្ទះរបស់ខ្ញុំ បើគិតនៅក្នុងរឿងកុន លោកគឺជាតួអង្គចិត្តល្អម្នាក់ ហើយតាមពិតលោកមិនត្រូវបានគេចងឆ្កាងឡើយ!!!

សម្រាប់ខ្ញុំ ពេលនោះវាហាក់ដូចជាទម្ងន់របស់ឈើឆ្កាងដែលគេនិយាយថាលោកយេស៊ូលីសែងទៅកាន់ភ្នំកាល់វ៉ារី បានបែកជាបំណែកតូចៗប្រៀបប្រដូចនឹងអគារដ៏ស្កឹមស្កៃ ឬភ្នំដ៏រឹងមាំត្រូវបានផ្ទុះបាក់បែកខ្ទេចខ្ទីអស់។

បន្ទាប់ពីនោះក៏មានរឿងរ៉ាវសំខាន់ៗជាច្រើនទៀតផងដែរ។ ខ្ញុំចេះតែគិតពិចារណា បើវាជាការពិតមែននោះ សាសនានេះហើយដែលត្រឹមត្រូវ។ ក្នុងរយៈពេល២០ឆ្នាំមកនេះ គេតែងប្រាប់ខ្ញុំថាលោកយេស៊ូត្រូវបានគេសម្លាប់។ ខ្ញុំត្រូវបានគេដឹកនាំឱ្យធ្វើដំណើររួមជាមួយគេដោយឥតបានរកផ្លូវជំនួសណាឡើយ។ ឥឡូវវិថីផ្សេងមួយទៀតត្រូវបានបើកត្រដាង ដោយភ្ជាប់ជាមួយនឹងចម្លើយដែលសមហេតុផលជាងមុន អ្វីៗក៏បានរំលេចឡើងកាន់តែច្បាស់ ហើយចម្លើយចុងក្រោយនៃប្រស្នាក៏អាចស្រាយបាន។ ការរួចផុតពីការសម្លាប់នេះ ជាការណ៏អស្ចារ្យចុងក្រោយ ក្នុងចំណោមការណ៍អស្ចារ្យជាច្រើន ដែលលោកយេស៊ូបានសម្តែងដោយឫទ្ធានុភាពពីព្រះអល់ឡោះជាម្ចាស់។ ដោយព្រះទ្រង់ចេតនា បុរសម្នាក់អាចធ្វើឱ្យមនុស្សខ្វាក់មើលឃើញម្តងទៀត, អាចដើរលើទឹក, អាចព្យាបាលអ្នកកើតឃ្លង់, អាចធ្វើឱ្យមនុស្សខ្វិនជើងដើរវិញបាន ហើយអាចប្រស់មនុស្សស្លាប់ឱ្យរស់ឡើងវិញទៀតនោះ ខ្ញុំគ្មានការសង្ស័យឡើយថា

គាត់មិនត្រូវបានគេចាប់ឆ្កាង។ ខ្ញុំគិតម្តងទៀត ខ្ញុំពិចារណាជាថ្មី ហើយក៏សម្រេចចិត្តថា ខ្ញុំចង់នៅក្នុងសាសនាមួយនេះ ខ្ញុំចង់ក្លាយជាមូស្លីម!

មិនខុសពីការណ៍ដែលទម្ងន់របស់ឈើឆ្កាងត្រូវបែកជាបំណែកតូចៗ ដែលខ្ញុំបានលើកឡើងមុននេះឡើយ។ ការរស់ឡើងវិញរបស់លោកយេស៊ូនៅថ្ងៃអាទិត្យ, សប្តាហ៍បរិសុទ្ធ[96], អភិបូជាថ្ងៃសុក្រពិសិដ្ឋ, ការទៅក្រុមជំនុំទាំងប្រាំពីរ (Stations of the Cross), ការបួសតមសាច់នៅថ្ងៃសុក្រដោយបរិភោគតែត្រីជាដើម ដែលសុទ្ធសឹងជាថ្ងៃដែលគេប្រាប់ថា ជាថ្ងៃពិសិដ្ឋទាំងនោះ ក៏បានរលាយបាត់អស់ក្នុងពេលតែមួយដោយខ្ញុំដឹងថាការណ៍ទាំងអស់នោះសុទ្ធតែជាការភូតកុហក។ ចិត្តគំនិតដែលចេះពិចារណារកខុសត្រូវរបស់កម្លោះវ័យក្មេងម្នាក់ដែលខំសិក្សាដើម្បីក្លាយជាវិស្វករ នៅពេលនេះមានសិទ្ធសេរីភាពក្នុងការបដិសេធចំពោះបណ្តាប្រពៃណីទាំងអស់នេះ ដែលគ្មានមូលដ្ឋានគ្រឹះច្បាស់លាស់ ផ្អែកលើគំនិតមិនសមហេតុផលដែលថា ព្រះក្លាយជាមនុស្សហើយស្លាប់ដើម្បីលាងបាបរបស់មនុស្ស។ ក្នុងនាមខ្ញុំក៏ធ្លាប់ជាអ្នកពន្លត់អគ្គិភ័យ ធ្លាប់ជួយជីវិតមនុស្ស ហើយជាអ្នកមិនដែលប៉ះពាល់បារីស្រាទាល់តែសោះ ទោះបីវាជារឿងធម្មតាក្នុងសង្គមក៏ដោយ ខ្ញុំពិតជាមិនអាចទទួលយកការកុហកបោកប្រាស់ទាំងនេះបានឡើយ។

នានិទាឃរដូវក្នុងអំឡុងឆ្នាំ១៩៧៩ ខ្ញុំបានសិក្សានូវវគ្គខ្លីមួយនៅសកលវិទ្យាល័យក្នុងរដ្ឋ**អូក្លាហូម៉ា** ហើយវគ្គសិក្សានោះរឹតតែបំភ្លឺនូវមាគ៌ាថ្មីដែលខ្ញុំបានចាប់ផ្តើមធ្វើដំណើរលើវា។ វគ្គសិក្សាខ្លីនោះឈ្មោះថា **វប្បធម៌អ៊ីស្លាម**។ នៅចុងបញ្ចប់នៃនិទាឃរដូវនេះ ខ្ញុំបានត្រលប់ទៅរដ្ឋ**ស៊ីអេថល**វិញ ហើយបានទទួលយកសាសនាអ៊ីស្លាមជាផ្លូវការជាមួយនឹងអ៊ីមុាំដែលបង្រៀនខ្ញុំកាលពីលើកមុន ដោយការពោលពាក្យសច្ចា (ស្ហាហាដះ)។

[96] សប្តាហ៍នៃថ្ងៃបុណ្យព្រះយេស៊ូមានព្រះជន្មឡើងវិញ។

ខ្ញុំនៅចាំបានពេលដែលអ៊ីម៉ាំបានសួរខ្ញុំថា៖ *តើប្អូនប្រាកដចិត្តឬទេថានឹងចូលកាន់សាសនាអ៊ីស្លាម?* ខ្ញុំតបវិញថា *បាទ* ។ គាត់នៅតែសួរបញ្ជាក់៖ *ច្បាស់ហើយឬ? ទោះបីជាប្អូនត្រូវសរសេរថាប្អូនជាមូស្លីមលើលិខិតឆ្លងដែនក៏ដោយ?* ខ្ញុំតបវិញ៖ *បាទ ទោះបីជាយ៉ាងហ្នឹងក៏ដោយ។* គាត់ក៏បាននិយាយថា៖ *បើប្អូនប្រាកដថាវាជាអ្វីដែលប្អូនចង់ធ្វើហើយ សូមប្អូនថាតាមខ្ញុំ៖* ***ខ្ញុំសូមសច្ចាថាគ្មានព្រះឯណាដែលស័ក្តិសមនឹងទទួលបានការគោរពសក្ការៈក្រៅពីព្រះអល់ឡោះជាម្ចាស់ ហើយខ្ញុំសូមសច្ចាថាមូហាំម៉ាត់គឺជាអ្នកនាំសាររបស់ទ្រង់។*** ខ្ញុំបានពោលពាក្យសច្ចាជាភាសាអង់គ្លេស បន្ទាប់មកពោលជាភាសាអារ៉ាប់តាមអ៊ីម៉ាំ ដែលវាបានធ្វើឱ្យខ្ញុំឈានជំហានចុងក្រោយចូលមកកាន់សាសនាអ៊ីស្លាម។

# ឥទ្ធិពលនៃ
# សាសនាអ៊ីស្លាម
# មកលើជីវិតខ្ញុំ

ជាការប្រាកដណាស់ ដើម្បីអាចផ្លាស់ប្ដូរបានគឺត្រូវតែមានការកែប្រែខុសពីមុន ជាពិសេសគឺរឿងខ្ញុំនេះតែម្ដង។ នៅពេលដែលខ្ញុំកាន់សាសនាអ៊ីស្លាម ខ្ញុំសច្ចានឹងព្រះអល់ឡោះថា ខ្ញុំនឹងធ្វើគ្រប់យ៉ាងដើម្បីខិតខំប្រឹងប្រែងសិក្សាអំពីសាសនាមួយនេះ។ កាលនោះខ្ញុំទើបតែរៀនចប់ឆ្នាំទី១នៅសាកលវិទ្យាល័យរដ្ឋអូក្លាហូម៉ា ខ្ញុំក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនារីមូស្លីមម្នាក់ដែលរស់នៅក្រុង**ស្ទិលវ៉តធឺ** រដ្ឋអូក្លាហូម៉ា។ ពេលនោះមានមជ្ឈមណ្ឌលអ៊ីស្លាមមួយបានចាត់តាំងគ្រូអ៊ីស្លាមម្នាក់ឱ្យមកបង្រៀនខ្ញុំជាលើកដំបូង។ លោកគ្រូនោះឈ្មោះ **ហ្វៃស៍** មកពីប្រទេសប៉ាឡេស្ទីន ដែលលោកបានលះបង់ពេលវេលាជាច្រើនរបស់លោកដើម្បីបង្រៀនខ្ញុំអំពីរបៀបថ្វាយបង្គំ ក៏ដូចជាសសរស្ដម្ភផ្សេងទៀតរបស់សាសនាអ៊ីស្លាម និងគោលជំនឿទាំង៦។ បន្ថែមពីនោះខ្ញុំក៏បានរៀនអំពីជីវិតក្រោយពេលស្លាប់, អំពីថ្ងៃដែលព្រះនឹងប្រស់មនុស្សគ្រប់គ្នាឱ្យរស់ឡើងវិញ និងរឿងរ៉ាវជាច្រើនទៀត។ ខ្ញុំនៅចាំថា រឿងមួយដែលពាល់ដល់ដួងចិត្តខ្ញុំខ្លាំងជាងគេនោះគឺ ជីវិតក្រោយពេលស្លាប់។ ក្នុងមួយជីវិតរបស់ខ្ញុំដែលជាគ្រិស្ដបរិស័ទ មិនដែលមាននរណាធ្លាប់មកបង្រៀនខ្ញុំពីរឿងបែបនេះ ហើយល្អិតល្អន់យ៉ាងនេះទេ។ ខ្ញុំមិនដែលបានយល់ច្បាស់ពីសេចក្ដីស្លាប់សោះឡើយ។

ខ្ញុំមិនដឹងសោះថា តើនឹងមានអ្វីកើតឡើងចំពោះខ្ញុំ នៅពេលគេបញ្ចុះសពខ្ញុំទៅក្នុងផ្នូរ។ ក្នុងសាសនាអ៊ីស្លាម ខ្ញុំបានរកឃើញនូវចម្លើយយ៉ាងលម្អិត។ នៅពេលមនុស្សម្នាក់ស្លាប់ទៅ សពរបស់គេនឹងបញ្ចុះទៅក្នុងដី ដូចដែលព្យាការីមូហាំម៉ាត់បានបង្គាប់យើង។ សពនោះនឹងត្រូវបានងូតទឹកសម្អាត(ចំអាស)ឱ្យបានស្អាតល្អ និងលាបប្រេងក្រអូបផង។ បន្ទាប់មកគេរុំសពនោះនឹងសំពត់ពណ៌សយ៉ាងតិច៣ផ្ទាំង[97] ហើយគេក៏បញ្ចុះសពនោះទៅក្នុងដីដោយមិនដាក់ក្តារមឈូសឡើយ ហើយបែរមុខរបស់សពទៅទិសតម្រង់ទៅក្រុងម៉ាក្កះ[98]។ អ្នកស្លាប់នោះនឹងឮសម្លេងសម្រឹបជើងរបស់អ្នកដែលនៅរស់ដើរចាកចេញពីទីបញ្ចុះសព ហើយសពនឹងដឹងខ្លួនថាគេទុកខ្លួនចោលតែម្នាក់ឯងហើយ។ ក្រោយពីនោះ ក៏នឹងមានទេវតាពីររូបបានមកកាន់ទីផ្នូរហើយសួរសពនោះនូវសំណួរ ៣ រួមមាន៖

1. តើព្រះជាម្ចាស់របស់អ្នកជានរណា?
2. តើសាសនារបស់អ្នកជាអ្វី?
3. តើព្យាការីរបស់អ្នកជានរណា?

ព្យាការីមូហាំម៉ាត់លោកបានប្រាប់យើងថា ចំពោះអ្នកមានជំនឿ គេនឹងឆ្លើយសំណួរនេះបានត្រឹមត្រូវយ៉ាងងាយស្រួល រីឯអ្នកគ្មានជំនឿវិញពួកគេមិនអាចឆ្លើយបានឡើយ។ បន្ថែមពីនោះទៀត បើអ្នកនោះជាអ្នកប្រព្រឹត្តសុចរិតកាលពីនៅមានជីវិតគេនឹងទទួលដឹងនូវចំហាយក្រអូបនិងត្រជាក់ពីស្ថានសួគ៌។ រីឯមនុស្សប្រព្រឹត្តទុច្ចរិត

---

[97] សម្រាប់សពបុរសត្រូវប្រើសំពត់ពណ៌សយ៉ាងតិច ៣ ផ្ទាំង សម្រាប់សពស្ត្រីប្រើសំពត់ពណ៌សដូចគ្នាយ៉ាងតិច ៥ ផ្ទាំង។

[98] សម្រាប់នៅប្រទេសកម្ពុជា ទិសតម្រង់ទៅក្រុងម៉ាក្កះគឺទិសខាងលិច។ ឥរិយាបថនៃការដាក់សពគឺក្បាលសពទៅទិសខាងជើង ជើងសពទៅទិសខាងត្បូង ដាក់សពឱ្យដេកផ្អៀង បែរមុខទៅទិសខាងលិច។

វិញនឹងទទួលដឹងនូវចំហាយក្តៅពីស្ថាននរក។ អ្នកនោះនឹងនៅជាសពរហូតដល់ថ្ងៃដែលព្រះនឹងប្រស់ពួកគេឱ្យរស់ឡើងវិញ។

លោកគ្រូ ហ្វែស៍ បាននិយាយប្រាប់ខ្ញុំពីរឿងរ៉ាវទាំងនេះ ហើយវាបានជម្រះមន្ទិលសង្ស័យរបស់ខ្ញុំដែលធ្លាប់តែឆ្ងល់ពីរឿងមនុស្សខ្លះដែលប្រព្រឹត្តអំពើអាក្រក់ តែកាលដែលនៅរស់មិនបានទទួលទោសទណ្ឌអ្វីសោះ។ ហើយខ្ញុំក៏បានយល់ផងដែរថាហេតុអ្វីបានជាព្រះអល់ឡោះប្រោសប្រទានឱកាសជាច្រើនដល់មនុស្សគ្រប់គ្នា ដើម្បីសារភាពទោសកំហុសនិងផ្លាស់ប្រែខ្លួន ហើយចាប់ផ្តើមជីវិតជាថ្មី។ នេះជាការបង្ហាញយ៉ាងច្បាស់ពីភាពយុត្តិធម៌ដែលព្រះមានចំពោះយើងរាល់គ្នា។ កាលពីខ្ញុំនៅជាកាតូលិក ខ្ញុំធ្លាប់គិតថាខ្ញុំបានយល់ច្បាស់ហើយពី ជីវិតលោកិយ និងជីវិតអស់កល្ប។ គេថែមទាំងបង្រៀនខ្ញុំថា លោកយេស៊ូស្លាប់ដើម្បីសង្គ្រោះយើង ប៉ុន្តែនៅក្នុងសាសនាអ៊ីស្លាមវិញខ្ញុំបានដឹងថា មនុស្សរាល់គ្នាត្រូវទទួលខុសត្រូវនូវអ្វីដែលខ្លួនបានប្រព្រឹត្តរៀងៗខ្លួន ហើយគេនឹងទទួលផលបុណ្យ ឬការធ្វើទោសទៅតាមនោះដែរ។ មើលទៅមានភាពសមហេតុផល ហើយការយល់ដឹងពីរឿងនេះក៏ធ្វើឱ្យចិត្តគំនិតខ្ញុំត្រូវបានប្រស់ឱ្យមានជីវិតឡើងវិញដែរ។

ចំណេះដឹងថ្មីទាំងនេះបានចូលមកកម្ចាត់អស់ការយល់ខុសពីមុនមក ហើយក៏ធ្វើឱ្យខ្ញុំបានដឹងថាត្រូវទុករឿងណាជារឿងសំខាន់សម្រាប់ជីវិត។ ខ្ញុំចាប់ផ្តើមចំណាយពេលវេលាយ៉ាងច្រើនបន្ថែមទៀតដើម្បីសិក្សាពីសាសនា។ ជាធម្មតាខ្ញុំតែងងើបពីព្រឹកដើម្បីហាត់ប្រាណ ប៉ុន្តែនៅពេលចូលអ៊ីស្លាមខ្ញុំត្រូវថ្វាយបង្គំជាន់ម៉ោងជាមួយការហាត់ប្រាណ ខ្ញុំពន្យាម៉ោងហាត់ប្រាណដោយគិតពីការថ្វាយបង្គំជាធំ។

ប៉ុន្មានឆ្នាំមុនខ្ញុំទទួលសាសនាអ៊ីស្លាម ខ្ញុំជាតន្ត្រីករដ៏ផុលផុសម្នាក់ ហើយក៏ធ្លាប់បានចូលរួមការប្រគុំតន្ត្រីជាច្រើនដង ដ្បិតអីខ្ញុំជាអ្នកលេងហ្គីតាផងនិងជាអ្នកចម្រៀងផង។ ប៉ុន្តែនៅពេលដែលខ្ញុំបានចូលសាសនាអ៊ីស្លាម ខ្ញុំបានបោះបង់ទាំងការលេងហ្គីតាទាំងការច្រៀង ហើយយកពេលមករៀនសូត្រព្រះគម្ពីរគួរអានជាភាសា

អារ៉ាប់ ដែលជាភាសាដើមដែលព្រះបើកបង្ហាញមក។ ដោយការទទួលខុសត្រូវក្នុងនាមជាស្វាមីម្នាក់ផង ជានិស្សិតវិស្វកម្មផង ពេលនោះខ្ញុំទើបតែមានអាយុ២១ឆ្នាំ ខ្ញុំពិតជាមមាញឹកខ្លាំងរហូតគ្មានពេលទៅធ្វើអ្វីផ្សេងទៀតសោះ។ ប៉ុន្តែដោយការចង្អុលបង្ហាញពីព្រះអល់ឡោះ ខ្ញុំចាប់ផ្តើមនឹកចង់បង្រៀនបន្តនូវចំណេះដឹងសាសនាដែលខ្ញុំមានបន្តិចបន្តួចនោះ។

នៅពេលខ្ញុំត្រឡប់ទៅប្រទេសវេណេហ្សុយអេឡាវិញ ក្រុមគ្រួសារខ្ញុំមិនមាននរណាម្នាក់ដឹងពីសាសនាអ៊ីស្លាមសោះឡើយ។ ពួកគាត់តែងតែមើលខ្ញុំថ្វាយបង្គំដោយមិនថាអី ឬបន្តុះបង្អាប់ខ្ញុំឡើយ។ ខ្ញុំបានចេញពីប្រទេសកំណើតទៅសហរដ្ឋអាមេរិកអស់ជាង៤ឆ្នាំ ដូច្នេះហើយឪពុកម្តាយខ្ញុំនិងបងប្អូនប្រុសស្រីទាំងអស់ គិតតែពីរីករាយចំពោះការវិលត្រឡប់មកជួបជុំគ្នាវិញ ហើយពួកគាត់នៅតែទទួលយកខ្ញុំដូចមុនដែរ។

ចំពោះការងារខ្ញុំនៅវេណេហ្សុយអេឡាវិញ ខ្ញុំបានសុំការអនុញ្ញាតពីអ្នកចាត់ការទូទៅរបស់ខ្ញុំ ដើម្បីថ្វាយបង្គំប្រហែលជា៥នាទីនៅក្នុងបន្ទប់ធ្វើការ។ កាលនោះខ្ញុំគិតថាមានតែខ្ញុំម្នាក់ទេដែលជាអ្នកមូស្លីមជនជាតិវេណេហ្សុយអេឡា ហើយធ្វើការក្នុងឧស្សាហកម្មប្រេងនៅក្នុងឆ្នាំ១៩៨២។ ខ្ញុំអធិដ្ឋានដល់ព្រះអល់ឡោះជាអម្ចាស់ សូមទ្រង់ពង្រឹងខ្ញុំឱ្យមានភាពខ្ជាប់ខ្ជួនក្នុងការបដិបត្តិ ដោយពេលនោះមានការល្បួងអូសទាញជាច្រើនបានកើតឡើងមកលើខ្ញុំជាញឹកញាប់។ ដោយព្រះគុណនិងសេចក្តីប្រោសមេត្តារបស់ព្រះអង្គ ខ្ញុំនៅតែរក្សាបានដោយមិនឱ្យមានអ្វីមកបៀតបៀនឡើយ។

មកទល់ពេលនេះ ជាង៣០ឆ្នាំហើយដែលខ្ញុំបានមកកាន់សាសនាអ៊ីស្លាម ខ្ញុំនៅតែមានសេចក្តីអំណរជាពន់ពេកណាស់ ដែលខ្ញុំបានសម្រេចចិត្តកាន់សាសនាអ៊ីស្លាម។ ខ្ញុំកាន់តែមានអារម្មណ៍កក់ក្តៅថែមទៀត នៅពេលខ្ញុំឃើញមនុស្សនៅជុំវិញខ្លួនខ្ញុំចូលសាសនាអ៊ីស្លាមស្ទើររៀងរាល់ថ្ងៃ។ រាល់ការសរសើរតម្កើងទាំងអស់សូមថ្វាយដល់ព្រះអល់ឡោះ! ជាព្រះអម្ចាស់នៃរាល់សព្វសារពើ! សាសនាអ៊ីស្លាមបាន

ក្លាយជាសាសនាដែលរីកដុះដាលលឿនជាងគេបំផុតលើលោកនេះ! មកទល់ពេលនេះមានតួលេខកំណើនអ្នកចូលសាសនាច្រើនបំផុត[99]បើទោះជាសាសនាអ៊ីស្លាមមានអ្នកផ្សព្វផ្សាយសាសនា និងមធ្យោបាយក្នុងការផ្សព្វផ្សាយតិចតួចបើប្រៀបធៀបនឹងសាសនាដទៃជាពិសេសសាសនាគ្រិស្ត។ ខណៈពេលដែលសាសនាអ៊ីស្លាមកំពុងរីកសាយភាយយ៉ាងខ្លាំងដោយងាយនោះ សាសនាគ្រិស្តហាក់មិនមែនជាគូប្រជែងឡើយ បើទោះជាពួកគេមានធនធាននិងសកម្មភាពផ្សព្វផ្សាយក្លៀវក្លាយ៉ាងណាក្តី។ ខ្ញុំសូមលើកយករឿងមួយជាការប្រៀបធៀបរវាងការចូលសាសនាអ៊ីស្លាម និងការចូលសាសនាគ្រិស្ត ដែលសាសនាទាំងពីរនេះមានអ្នកបដិបត្តិនៅជុំវិញពិភពលោក ឃើញថា សាសនាគ្រិស្តភាគច្រើនទាក់ទាញបានអ្នកដែលមានកម្រិតជីវភាព។ ពួកគេត្រូវគេអូសទាញឱ្យចូលវិហារដោយសារតែភាពក្រីក្រហើយគេផ្តល់ឱ្យនូវជំនួយនានា ហើយគេតែងតែលើកឡើងពីភាពល្អរបស់គេ ដោយសារតែគេសុខចិត្តចាកចេញពីផ្ទះសម្បែងឯប្រទេសអ្នកមាន ហើយមកធ្វើការនៅប្រទេសក្រីក្រវិញ។ បើយើងងាកមកមើលសាសនាអ៊ីស្លាមវិញ អ្នកដែលចូលសាសនាអ៊ីស្លាមគឺមានគ្រប់ឋានៈសង្គម ទាំងអ្នកក្រ អ្នកមាន អ្នកល្បីល្បាញ អ្នកវិទ្យាសាស្ត្រ បញ្ញាវន្ត សូម្បីតែមនុស្សខ្លះដែលលះបង់អស់សម្បត្តិលោកិយ ដូចជាបព្វជិតសាសនាគ្រិស្តខ្លះក៏បានចូលសាសនាអ៊ីស្លាមដែរ។

យ៉ាងនេះហើយសេចក្តីជំនឿរបស់ខ្ញុំកាន់រឹងមាំខ្លាំងឡើងៗ ដោយខ្ញុំបានឃើញថា ព្រះអល់ឡោះទ្រង់កំពុងបំពេញសេចក្តីសន្យារបស់ទ្រង់ដូចមានចែងថា៖ *ពួកគេនោះចង់ពន្លត់ពន្លឺនៃព្រះអល់ឡោះ ដោយសម្តីរបស់ពួកគេ។ ប៉ុន្តែព្រះអល់ឡោះទ្រង់នៅតែបំភ្លឺពន្លឺនៃទ្រង់ឱ្យពេញបរិបូណ៌ ទោះជាពួកអ្នកដែលមិនជឿមិនពេញចិត្តក៏ដោ*

---

[99] ចំនួននៃកំណើនអ្នកកាន់សាសនាអ៊ីស្លាម គឺស្មើនឹងចំនួនកំណើនអ្នកកាន់សាសនាផ្សេងៗទៀតបូកសរុបចូលគ្នា។ យោងតាមកាសែត *Sunday Times* ចំនួនអ្នកទៅព្រះវិហារអ៊ីស្លាមនៅចក្រភពអង់គ្លេសមានប្រមាណ ៩៣០ ០០០ នាក់ បើប្រៀបនឹងចំនួនអ្នកទៅវិហារសាសនាគ្រិស្តដែលមានប្រមាណ ៩១៦ ០០០ នាក់ ទាំងដែលចក្រភពអង់គ្លេសជាប្រទេសដែលភាគច្រើនជាគ្រិស្តបរិស័ទ។

*យ។ ហើយព្រះអង្គជាអ្នកដែលចាត់បញ្ជូនអ្នកនាំសាររបស់ទ្រង់ (ដោយនាំយកមក) ជាមួយនឹងការចង្អុលបង្ហាញ និងសាសនាដ៏ពិតប្រាកដ ដើម្បីឱ្យសាសនានេះលេចត្រដែតឡើងលើសាសនានានា ទោះជាអ្នកដែលគោរពពហុទេពមិនពេញក៏ដោយ។* (គួរអាន ៦១:៨-៩)

អ្នកដែលសិក្សាពីគម្ពីរបរិសុទ្ធ ប្រាកដជានឹងបានឃើញហើយ សេចក្តីបង្រៀនមួយចំនួននៅក្នុងគម្ពីរបរិសុទ្ធគឺមានតែអ្នកមូស្លីមទេដែលអនុវត្តន៍ខ្ជាប់ខ្ជួន។ នៅក្នុងគម្ពីរបរិសុទ្ធ លោកយេស៊ូ ក៏ដូចជាព្យាការីជំនាន់មុនៗដែរ ពួកលោកតែងតែក្រាបកាយចុះនៅពេលថ្វាយបង្គំព្រះ(លោកុប្បត្តិ ១៧:៣ និង ម៉ាថាយ ២៦:៣៦) អ្នកមូស្លីមនៅតែថ្វាយបង្គំរបៀបនេះមកដល់សព្វថ្ងៃ។ ដូចគ្នាដែរ មានតែស្ត្រីមូស្លីមទេដែលនៅទទូរក្រណាត់បិទបាំងក្បាលរបស់នាង ដែលមានចែងក្នុងគម្ពីរបរិសុទ្ធ ខណៈដែលស្ត្រីជាគ្រិស្តបរិស័ទភាគច្រើនមិនចាប់អារម្មណ៍បដិបត្តិ ទាំងដែលនាងម៉ារីជាស្ត្រីវិសេសលើសគេនាងតែងទទូរក្រណាត់បាំងជានិច្ច។(បទចម្រៀង ៤:៩ និង ១កូរិនថូស ១១:៥)

សូម្បីតែឃ្លាថា *សូមឱ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត* ជាពាក្យដែលលោកយេស៊ូប្រើដើម្បីគោរវកិច្ចនោះ(លូកា ២៤:៣៦) ក៏អ្នកមូស្លីមនៅតែប្រើ រីឯគ្រិស្តបរិស័ទវិញតែងតែស្វាគមន៍គ្នាដោយពាក្យ សួស្តី ឬ ជម្រាបសួរ វិញ។ ហើយក៏នៅមានកិច្ចសាសនាមួយចំនួនដែលអ្នកមូស្លីមនៅបដិបត្តិដល់សព្វថ្ងៃដូចជា ការយកទឹក **វូឌូ** (ជាការយកទឹកសម្អាតខ្លួនមុនថ្វាយបង្គំ), ការកាត់ស្បែកចុងអង្គជាតិបុរស, ចៀសវាងទទួលទានសាច់ជ្រូក និងសត្វដែលមិនបានសម្លាប់ត្រឹមត្រូវ ។ល។ គ្មានអីគួរឱ្យសង្ស័យសោះឡើយថា អ្នកដែលបដិបត្តិពិតប្រាកដតាមព្យាការីយេស៊ូ និងព្យាការីជំនាន់មុនផ្សេងៗទៀត គឺអ្នកមូស្លីមនេះហើយ។

# ការផ្លាស់ប្ដូរជីវិត
# របស់ខ្ញុំបានជះឥទ្ធិពល
# ដល់អ្នកដទៃទៀត

ដោយទទួលបានការប្រោសប្រទានដ៏ក្រៃលែង អំពីព្រះអល់ឡោះជាអម្ចាស់ ខ្ញុំមានកម្លាំងចិត្តជាខ្លាំងក្នុងការផ្សព្វផ្សាយព្រះរាជសារចុងក្រោយរបស់ព្រះអង្គ ទៅកាន់អស់អ្នកដែលមិនធ្លាប់បានឮពីមុនមក។ កាលពីខ្ញុំចេញមកផ្សព្វផ្សាយដំបូងនោះ ខ្ញុំមិនជោគជ័យប៉ុន្មានទេ មានអ្នកនិយាយចំអកលេងសើចមកខ្ញុំ ហើយអ្នកខ្លះទៀតប្រាប់ខ្ញុំឱ្យទៅផ្សព្វផ្សាយឱ្យក្មេងៗស្តាប់ទៅ ដ្បិតអីមនុស្សចាស់មានផ្លូវរបស់គាត់ហើយ។ មួយរយៈនោះ អ្នកដែលគាំទ្រនិងផ្តល់កម្លាំងចិត្តខ្ញុំគឺមានតែភរិយាខ្ញុំម្នាក់គត់ ដែលរួមជំនឿលើសាសនាអ៊ីស្លាមជាមួយខ្ញុំ។

នៅក្នុងឆ្នាំ១៩៩០ ខ្ញុំក៏ត្រឡប់មកសហរដ្ឋអាមេរិកវិញដើម្បីបន្តថ្នាក់អនុបណ្ឌិតផ្នែកវិស្វកម្មនៅសាកលវិទ្យាល័យ A&M ក្នុងរដ្ឋ**តិចសាស់**។ ការមកវិញលើកនេះ ខ្ញុំតាំងចិត្តថានឹងខំប្រឹងឱ្យអស់ពីលទ្ធភាពក្នុងការបង្កើនចំណេះដឹងអ៊ីស្លាម។ ខ្ញុំបានអនុវត្តន៍តាមកម្មវិធីហ្វឹកហ្វឺនចំណេះដឹងអ៊ីស្លាម ដែលខ្ញុំបង្កើតឡើងដោយខ្លួនឯងដោយមានឯកសារជំនួយពីបណ្ណាល័យអ៊ីស្លាមនៃវិទ្យាស្ថាន**ប្រ៊ីយ៉ាន**។ ខ្ញុំក៏តែងតែសរសេរសំបុត្រផ្ញើទៅក្រុមគ្រួសាររបស់ខ្ញុំនៅវេណេហ្សុយអេឡាអំពីអ្វីដែលខ្ញុំបានរៀន

ថ្មីៗទាក់ទងនឹងសាសនាអ៊ីស្លាម។ ជាក្តីអំណរណាស់ នៅពេលខ្ញុំត្រឡប់ទៅស្រុកកំណើតវិញក្នុងឆ្នាំ១៩៩២ ឪពុកម្តាយ និងបងប្រុសរបស់ខ្ញុំបានទទួលយកសាសនាអ៊ីស្លាម ក្រោយមកទៀតប្អូនស្រីខ្ញុំ២នាក់ ប្អូនប្រុសម្នាក់ហើយមានក្មួយប្រុសរបស់ខ្ញុំម្នាក់ទៀតក៏បានទទួលយកសាសនាអ៊ីស្លាមផងដែរ។

កាលនោះមានព្រះវិហារអ៊ីស្លាមថ្មីមួយទើបសាងសង់រួចរាល់ នៅឯក្រុង **ការ៉ាកាស់**ប្រទេសវេណេហ្ស៊ុយអេឡា ដែលជាព្រះវិហារអ៊ីស្លាមធំជាងគេបំផុតនៅអាមេរិកឡាទីន។ ខ្ញុំបានដាក់សំណើរមួយទៅលោកអភិបាលព្រះវិហារនោះ ដើម្បីសុំអនុញ្ញាតអញ្ជើញអ្នកមិនមែនមូស្លីមចូលទៅទស្សនាក្នុងព្រះវិហារ និងស្វែងយល់ពីសាសនាអ៊ីស្លាមផង។ លោកអភិបាលក៏យល់ព្រមនឹងសំណើរនេះ ហើយខ្ញុំក៏បានចាត់ចែងរៀបចំកម្មវិធីដោយមានការសហការពី**អ៊ីម៉ាំ**ប្រចាំព្រះវិហារ។ ការខិតខំប្រឹងប្រែងរៀបចំកម្មវិធីរបស់ពួកយើងពិតជាជោគជ័យមែន ដោយមានអ្នកចូលរួមប្រមាណ ២៥០នាក់ ហើយខ្ញុំក៏បានធ្វើការអធិប្បាយជាលើកដំបូង ក្នុងការផ្សព្វផ្សាយសាសនាអ៊ីស្លាមទៅកាន់ជនជាតិវេណេហ្ស៊ុយអេឡា។ ខ្ញុំគិតថានេះជាលើកទីមួយក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសវេណេហ្ស៊ុយអេឡាហើយ ដែលមានទាំងអ្នកកាន់សាសនាយូដា, សាសនាគ្រិស្ត, អ្នកគ្មានសាសនា និងអ្នកផ្សេងៗទៀតមកអង្គុយជាមួយគ្នាស្តាប់ការអធិប្បាយអំពីសាសនាអ៊ីស្លាម។ ដោយព្រះគុណនៃព្រះ កម្មវិធីនេះជោគជ័យមិននឹកស្មានដល់ ដ្បិតមានជនជាតិវេណេហ្ស៊ុយអេឡាជាច្រើនបានទទួលយកសាសនាអ៊ីស្លាម។ កម្មវិធីនេះនៅបន្តរហូតដល់សព្វថ្ងៃ នរណាហើយដែលចង់សិក្សាអំពីសាសនាអ៊ីស្លាមនៅតែអាចទៅចូលរួមបាន។

នៅពេលដែលខ្ញុំទៅធ្វើការអធិប្បាយនៅកន្លែងផ្សេងៗ ខ្ញុំកត់សម្គាល់ឃើញថាមានមនុស្សច្រើនណាស់ដែលចាប់អារម្មណ៍មកលើសាសនាអ៊ីស្លាម ហើយមនុស្សជាច្រើនបានទទួលយកសាសនាមួយនេះ។ អ្នកខ្លះទៀតព្យាយាមយកឯកសារនានាទៅសិក្សាឱ្យបានកាន់តែច្បាស់ ដូចខ្ញុំកាលពី៣០ឆ្នាំមុនដែរ។ យ៉ាងណាក៏នៅមានអ្នកខ្លះ

ទៀតដែលមិនទាន់អាចទទួលយកសាសនាអ៊ីស្លាមបាន ដោយពួកគេនិយាយថាពួកគេនៅមានរឿងច្រើនណាស់ដែលពួកគេមិនអាចបោះបង់ ឬឈប់ប្រព្រឹត្តបាន។ មកដល់ចំណុចនេះខ្ញុំចង់ជម្រាបដល់អស់លោកអ្នកអានថា នៅពេលមនុស្សណាម្នាក់ទទួលយកសាសនាអ៊ីស្លាម ជីវិតរបស់គេនឹងមិនផ្លាស់ប្តូរគ្រប់យ៉ាងភ្លាមៗនោះទេ វាមានខ្លះដែរ តែភាគច្រើនមិនបែបហ្នឹងទេ។ ជារឿយៗ នៅពេលយើងបង្រៀនមនុស្សណាម្នាក់ ហើយដឹកនាំគេឱ្យទៅកៀកជិតនឹងព្រះ ឬទៅកៀកជិតនឹងអ្នកមានជំនឿដូចគ្នា ឬបង្រៀនពីមូលដ្ឋានគ្រឹះនៃសេចក្តីជំនឿក្តី ភាគច្រើនអ្នកដែលមកស្តាប់ការអធិប្បាយរបស់ខ្ញុំ តែងតែសួរសំណួរដូចជា៖ *តើដើម្បីឱ្យខ្ញុំក្លាយជាអ្នកមូស្លីមបានទាល់តែខ្ញុំចេះនិយាយភាសាអារ៉ាប់មែនទេ? តើនៅពេលខ្ញុំក្លាយជាអ្នកមូស្លីមហើយខ្ញុំត្រូវក្លាយជាជនជាតិអារ៉ាប់មែនទេ? តើនៅពេលខ្ញុំក្លាយជាអ្នកមូស្លីមហើយខ្ញុំត្រូវតែឈប់ជឿលើលោកយេស៊ូ និងអ្នកម្តាយម៉ារីមែនទេ?*

ចម្លើយមួយម៉ាត់ដែលអាចឆ្លើយសំណួរទាំង៣ខាងលើនេះបានគឺ *អត់ទេ!* ។ សាសនាអ៊ីស្លាមជាសាសនាសាកល អ្នកមូស្លីមមាននៅគ្រប់ប្រទេសទាំងអស់ជុំវិញពិភពលោក ហើយរឿងភាសាវិញមិនជាបញ្ហានោះទេ។ ក្នុងនាមជាអ្នកមូស្លីម គឺចាំបាច់ត្រូវតែជឿលើលោកយេស៊ូ ដោយជឿថាលោកជាព្យាការីដ៏ពិសិដ្ឋម្នាក់ក្នុងចំណោមព្យាការីទាំងអស់របស់ព្រះអល់ឡោះ រីឯអ្នកម្តាយម៉ារីវិញ គឺជាម្តាយរបស់លោកយេស៊ូ ជានារីម្នាក់ដែលព្រះអល់ឡោះជាអម្ចាស់លើកតម្កើងនាងលើសនារីទាំងឡាយ។

ជំហានទី១ដើម្បីក្លាយជាអ្នកមូស្លីមគឺសាមញ្ញនិងងាយស្រួលណាស់។ គ្មានអ្វីដែលពិបាកស្មុគស្មាញច្រើន គ្មានកិច្ចពិធី ហើយក៏មិនចាំបាច់តាំងសមាធិ ឬធ្វើអ្វីខុសពីធន្ទះខ្លួនដែរ។ រឿងដែលត្រូវការចាំបាច់បំផុតដើម្បីទទួលយកសាសនាអ៊ីស្លាមនោះគឺការមានជំនឿដោយសុទ្ធចិត្ត និងស្តាប់បង្គាប់ទៅចំពោះព្រះពិតតែមួយអង្គគត់។ ហើយក៏ទទួលស្គាល់ថាព្រះជាព្រះអាទិករបង្កើតរាល់សព្វសារពើ, ជាព្រះដែលទ្រទ្រង់

ចក្រវាឡនេះទាំងមូល, ជាព្រះដែលជីវិតទាំងឡាយស្ថិតក្រោមព្រះហស្តទ្រង់, ជាព្រះអភិបាលលើសព្វសារពើ, ជាព្រះដែលស័ក្តិសមនឹងយើងគោរពសក្ការៈ, ជាព្រះដែលមានព្រះនាមដែលប្រសើរក្រៃលែង, ព្រះអង្គមានព្រះចេស្តារុងរឿងជាអនេកប្បការ, ព្រះអង្គគ្មានដៃគូណាប្រៀបស្មើ, គ្មានបុត្រ គ្មានមាតាបិតា ហើយក៏គ្មានអ្វីអាចប្រៀបនឹងទ្រង់បានឡើយ។ ហើយក៏ត្រូវតែបោះបង់ចោលឱ្យអស់នូវសេចក្តីជំនឿខុសឆ្គងទាំងឡាយ។

ក្រោយពេលដែលបានសច្ចាថា *គ្មានព្រះឯណាស័ក្តិសមនឹងគោរពសក្ការៈក្រៅពីព្រះអល់ឡោះ ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់ព្រះអល់ឡោះ* ហើយអ្វីៗផ្សេងទៀតគឺអាចសិក្សាបានដោយការអត់ធ្មត់និងការព្យាយាម។ បើនរណាហើយបាត់បង់ជីវិតក្រោយពីបានទទួលយកសេចក្តីជំនឿទាំងនេះហើយ អ្នកនោះរាប់ថាជាអ្នកមូស្លីមហើយ ហើយសង្ឃឹមថាគេនឹងចូលស្ថានសួគ៌បរមសុខ ដោយសេចក្តីប្រោសមេត្តានៃព្រះអល់ឡោះជាអម្ចាស់។

នៅពេលគេសច្ចាថា *មូហាំម៉ាត់ជាអ្នកនាំសាររបស់ព្រះអល់ឡោះ* មិនមែនមានន័យថាលោកជាព្យាការីតែម្នាក់គត់របស់ព្រះអល់ឡោះឡើយ ប៉ុន្តែលោកគឺជាព្យាការីចុងក្រោយបង្អស់ដែលព្រះបានចាត់មក បន្តពីព្យាការីជំនាន់មុនៗជាច្រើនរូបរាប់តាំងពីជំនាន់ព្យាការីអាដាំមក។

# សាសនាដែលអាច
# ឈរជើងបានដោយ
# ប្រើការបង្ខិតបង្ខំ

ព្រះអល់ឡោះដ៏ពេញព្រះចេស្តា បានមានព្រះបន្ទូលថា គ្មាននរណាម្នាក់ត្រូវបានគេបង្ខិតបង្ខំឱ្យទទួលយកសាសនាអ៊ីស្លាមនោះឡើយ ដូចមានសេចក្តីបង្គាប់របស់ព្រះអង្គថា៖ *គ្មានការបង្ខិតបង្ខំឡើយនៅក្នុងសាសនា។ ពិតប្រាកដណាស់ ភាពត្រឹមត្រូវបានលេចច្បាស់ជាងភាពខុសឆ្គង។*(គួរអាន ២:២៥៦)

ព្រះអល់ឡោះក៏មានព្រះបន្ទូលថា៖ *ចូរអ្នកពោលថា សេចក្តីពិតគឺមកពីព្រះអម្ចាស់នៃពួកអ្នក។ ហើយបើអ្នកណាចង់(ជឿ)ចូរឱ្យគេជឿចុះ។ តែបើអ្នកណាមិនចង់(ជឿ)វិញ ចូរឱ្យគេមិនជឿចុះ។*(គួរអាន ១៨:២៩) សាសនាអ៊ីស្លាមក៏តែងតែជំរុញឱ្យមានការជជែកពិភាក្សា ដើម្បីផ្តល់ជាចំណេះដឹងមុននឹងទទួលយកសាសនានេះដូចដែលព្រះមានបន្ទូលថា៖ *ចូរអ្នកអំពាវនាវ(មនុស្សលោក)ទៅកាន់ មាគ៌ានៃម្ចាស់របស់អ្នកដោយបញ្ញាញាណ និងការបង្រៀនតាមវិធីសាស្រ្តដ៏ល្អចុះ។ ហើយចូរអ្នកជជែកជាមួយពួកគេតាមរបៀបណាដែលប្រសើរបំផុត។*(គួរអាន ១៦:១២៥)

វិហារកាតូលិកមួយចំនួនដែលអាចឈរជើងមកដល់សព្វថ្ងៃនេះ ដោយសារតែធ្លាប់មានការកាប់សម្លាប់បង្ហូរឈាមជនស្លូតត្រង់រាប់ម៉ឺននាក់។ គួរឱ្យចម្លែកចិត្តណាស់ គ្រាន់តែនៅប្រទេស**ហូឡង់**មួយ មានមនុស្សជាង៣លាននាក់ត្រូវបានសម្លាប់ ដោយសារតែពួកគេមិនទទួលយកគោលជំនឿនៃវិហារកាតូលិក។

*នៅក្នុងថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ១៥៦៨ គណៈដឹកនាំសាសនា(កាតូលិក)បានសម្រេចចោទប្រកាន់ និងកាត់ទោសប្រហារជីវិតប្រជាជនហូឡង់ទាំងអស់ ដោយចោទពីបទល្មើសភូតកុហក។ អ្នកដែលរួចផុតពីការកាត់ទោសនេះគឺមានតិចតួចប៉ុណ្ណោះ ជាពិសេសអ្នកដែលមានឈ្មោះល្បីល្បាញ ត្រូវបានគេលើកលែង។ ១០ថ្ងៃក្រោយមក ក៏មានចេញព្រះរាជក្រឹត្យអនុម័តឱ្យអនុវត្តន៍ជាបន្ទាន់តាមការកាត់ទោសខាងលើ ដោយមិនខ្វល់ពីអាយុ, ភេទ ឬលក្ខខណ្ឌយ៉ាងណានោះទេ។ នេះជាការសម្លាប់រង្គាលដ៏ធំសម្បើមបំផុតមិនធ្លាប់មាន មនុស្សក្មេងចាស់ប្រុសស្រីជាង៣លាននាក់ ត្រូវបានគេប្រកាសទោសដោយសាលក្រមមួយដែលមានអក្សរតែ៣បន្ទាត់ប៉ុណ្ណោះ ហើយក្រោយពេលដែលចេញព្រះរាជក្រឹត្យ ការកាប់សម្លាប់ធ្វើឡើងកាន់តែលឿនរហ័ស។ មិនថាមនុស្សឋានៈខ្ពស់ឬឋានៈតូចទាប ត្រូវបានគេអូសយកទៅសម្លាប់បន្តបន្ទាប់ជារៀងរាល់ថ្ងៃ។ ក្នុងសេចក្តីសំបុត្រដែលលោក**អាល់វ៉ា** សរសេរទៅលើលោក**ភីលីព** បានប៉ាន់ប្រមាណថា ក្រោយអំឡុងពេលសប្តាហ៍បរិសុទ្ធ ដែលមានរយៈពេល៧ថ្ងៃ មានមនុស្ស៨០០នាក់ត្រូវបានគេសម្លាប់។*[100]

ក្រោយការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាក្រុង**នីសៀរ** គេបានសម្រេចថា នរណាដែលកាន់កាប់និងប្រើប្រាស់កណ្ឌគម្ពីរដែលក្រុមប្រឹក្សាមិនទទួលស្គាល់ នឹងត្រូវមានទោស។ មួយឆ្នាំក្រោយការសម្រេចនេះ មានគ្រិស្តបរិស័ទជាងមួយលាននាក់ត្រូវបានសម្លាប់។ នេះគឺជាយុទ្ធសាស្ត្រដែលសន្ត **អាតាណាសឺស**[101]យកមកប្រើដើម្បីបង្រួប

---

[100] ដកស្រង់ពីសៀវភៅ *The Rise of the Ducth Republic*, *by* John Lothrop Motley។

[101] Saint *Athanasius of Alexandria* ជាអ្នកដឹកនាំសាសនាកាតូលិក (ឆ្នាំ ២៩៣-៤៧៣ គ.ស.)។

បង្រួមគ្រិស្តបរិស័ទកុំឱ្យបែកបាក់គ្នា។ បើយើងមើលទៅភាគច្រើននៃពួកឧក្រិដ្ឋជនប្រល័យពូជសាសន៍ ពួកគេមិនមានការជំរុញពីសាសនានោះឡើយ ប៉ុន្តែខ្ញុំរន្ធត់ចិត្តជាខ្លាំងនៅពេលដែលខ្ញុំរកឃើញថាឧក្រិដ្ឋកម្ម និងអំពើសាហាវយង់ឃ្នង គឺមានរូបភាពចេញពីគម្ពីរបរិសុទ្ធ ដូចមានសរសេរថា៖ *ឥឡូវនេះ ចូរសម្លាប់ក្មេងប្រុសទាំងអស់ ក្នុងចំណោមក្មេងតូចៗ ហើយសម្លាប់ស្ត្រីទាំងប៉ុន្មានដែលធ្លាប់បានរួមរស់ជាមួយប្រុសៗ ប៉ុន្តែ ត្រូវទុកជីវិតឱ្យស្ត្រីក្រមុំ សម្រាប់អ្នករាល់គ្នា គឺស្ត្រីដែលពុំបានរួមរស់ជាមួយបុរសណានៅឡើយ។*(ជនគណនា ៣១:១៧-១៨) ហើយព្រះមានបន្ទូលទៀតថា៖ *ចូរដើរតាមក្រោយគាត់ ហើយប្រហារអ្នកក្រុងនេះទៅកុំអាណិតមេត្តា និងត្រាប្រណីពួកគេឡើយ! ចូរសម្លាប់ពួកគេទាំងអស់គ្នាឱ្យផុតពូជ គឺទាំងចាស់ ទាំងកំលោះ ទាំងក្រមុំ ទាំងក្មេង ទាំងស្ត្រី តែកុំប៉ះពាល់អស់អ្នកដែលមានសញ្ញាជើងក្អែកឡើយ។ ចូរចាប់ផ្ដើមពីទីសក្ការៈរបស់យើងទៅ!។ អ្នកទាំងនោះក៏ចាប់ផ្ដើមសម្លាប់ពួកព្រឹទ្ធាចារ្យដែលនៅខាងមុខព្រះដំណាក់។*(អេសេគាស ៩:៥-៦) លោកយ៉ូស្វេនិយាយទៅកាន់បណ្ដាជនអ៊ីស្រាអែលថា៖ *...ចូរស្រែកជ័យឃោសឡើង!ដ្បិតព្រះអម្ចាស់បានប្រគល់ទីក្រុងឱ្យអ្នករាល់គ្នាហើយ។ ...រីឯមាស ប្រាក់ និងវត្ថុធ្វើពីលង្ហិន ឬពីដែកទាំងអស់ត្រូវទុកជាចំណែកថ្វាយព្រះអម្ចាស់ ហើយបញ្ចូលទៅក្នុងសម្បត្តិរបស់ព្រះអង្គ។... ពួកគេបំផ្លាញអ្វីៗទាំងប៉ុន្មានដែលមាននៅក្នុងទីក្រុង ថ្វាយផ្ដាច់ដល់ព្រះអម្ចាស់ គឺប្រហារមនុស្សទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ ទាំងគោ ចៀម និងលាដោយមុខដាវ។*[102](យ៉ូស្វេ ៦:១៦-២១)

បន្ទូលព្រះក្នុងគម្ពីរបរិសុទ្ធមានចែងទៀតថា៖ *ឥឡូវនេះ ចូរទៅវាយប្រហារជនជាតិ**អាម៉ាឡេក**ចុះ។ ត្រូវបំផ្លាញអ្វីៗទាំងប៉ុន្មានរបស់ពួកគេថ្វាយផ្ដាច់ដល់ព្រះអម្ចាស់ ឥតត្រាប្រណីឡើយ គឺត្រូវសម្លាប់ចោលទាំងអស់ ទាំងប្រុស ទាំងស្រី ទាំងកូនក្មេង*

[102] មានអ្នកខ្លះលើកឡើងជាការវាយប្រហារថា សាសនាអ៊ីស្លាមរីកសាយភាយដោយប្រើមុខដាវ។ គួរចាប់អារម្មណ៍ផងដែរថា ក្នុងគម្ពីរបរិសុទ្ធមានសរសេរពាក្យថា *ដាវ* ចំនួន ៤០៦ ដង រីឯក្នុងព្រះគម្ពីរគួរអានគ្មានសរសេរពាក្យ *ដាវ* សូម្បីតែម្ដង។

*ទាំងទារក ទាំងគោ ទាំងចៀម ទាំងអូដ្ឋ និងលាផង។*(១សាំយ៉ូអែល ១៥:៣) *ទារករបស់គេនឹងត្រូវចាប់បោកខ្ទេចខ្ទីនៅចំពោះមុខគេ ផ្ទះរបស់គេត្រូវរឹបអូសយកអ្វីៗទាំងអស់ ហើយប្រពន្ធរបស់គេក៏ត្រូវរំលោភដែរ។*(អេសាយ ១៣:១៦) *អ្នកក្រុងសាម៉ារីនឹងទទួលទោស ព្រោះគេបានបះបោរប្រឆាំងនឹងព្រះរបស់ខ្លួន។ ពួកគេនឹងដួលស្លាប់ដោយមុខដាវ កូនក្មេងនឹងត្រូវគេជាន់ខ្ទេចខ្ទី ហើយវះពោះស្ត្រីមានគភ៌។*[103](ហូសេ ១៣:១៦)

ជាក់ស្តែង គម្ពីរបរិសុទ្ធ គឺជាគម្ពីរសាសនាតែមួយគត់លើលោកនេះដែលលើកឡើងពីការសម្លាប់កុមារ, បោកកម្ទេចទារក និងវះពោះស្ត្រីមានគភ៌។ ដោយមានខគម្ពីរទាំងនេះក្នុងគម្ពីរបរិសុទ្ធ វាជាភស្តុតាងមួយយ៉ាងច្បាស់ថា គម្ពីរបរិសុទ្ធត្រូវបានមនុស្ស

---

[103] សាសនាអ៊ីស្លាមអនុញ្ញាតឱ្យធ្វើ **ជីហាត** (ចម្បាំងក្នុងផ្លូវព្រះ) ដើម្បីទប់ទល់និងការពារអ្នកទន់ខ្សោយ ដូចជាស្ត្រី និងកុមារជាដើម មិនមែនទៅសម្លាប់ ឬជាន់កម្ទេចពួកគេឡើយ។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *តើហេតុអ្វីបានជាពួកអ្នកធ្វើចម្បាំងក្នុងផ្លូវព្រះ និង(ជួយសង្គ្រោះ)ពួកដែលទន់ខ្សោយ ក្នុងចំណោមបុរសនិងស្ត្រី ហើយនិងក្មេងៗ(ដែលត្រូវគេបំពាន)។*(គួរអាន ៤:១៦) ការធ្វើជីហាត ជាសកម្មភាពនៃការការពារខ្លួនមិនមែនជាការរំលោភបំពាននោះឡើយ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ហើយចូរពួកអ្នកធ្វើចម្បាំងក្នុងផ្លូវព្រះ ច្បាំងទល់នឹងពួកដែលមកច្បាំងនឹងពួកអ្នក ហើយចូរពួកអ្នកកុំល្មើសបំពាន ពិតប្រាកដណាស់ ព្រះអល់ឡោះ មិនសព្វព្រះទ័យពួកដែលល្មើសបំពានឡើយ។*(គួរអាន ២:១៩០) ជីហាត ក៏ជាកិច្ចការមួយដែលធ្វើឡើងដើម្បីធានាបាននូវសេរីភាពយ៉ាងពេញលេញ ក្នុងការអំពាវនាវបណ្តាជនទាំងឡាយទៅកាន់ផ្លូវព្រះ ហើយផ្តល់ឱ្យពួកគេនូវជម្រើសក្នុងការទទួលយកជំនឿដោយគ្មានការបង្ខិតបង្ខំឡើយ។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *គ្មានការបង្ខិតបង្ខំឡើយនៅក្នុងសាសនា។ ពិតប្រាកដណាស់ ភាពត្រឹមត្រូវបានលេចច្បាស់ជាងភាពខុសឆ្គង។*(គួរអាន ២:២៥៦) *ចូរអ្នកពោលថា សេចក្តីពិតគឺមកពីព្រះអម្ចាស់នៃពួកអ្នក។ ហើយបើអ្នកណាចង់(ជឿ)ចូរឱ្យគេជឿចុះ។ តែបើអ្នកណាមិនចង់(ជឿ)វិញ ចូរឱ្យគេមិនជឿចុះ។*(គួរអាន ១៨:២៩)

កែប្រែបំភ្លៃ និងភូតកុហកថាជាបន្ទូលព្រះ។[104] ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ដូច្នេះ ក្តីវិនាសអន្តរាយគឺដល់ពួកដែលសរសេរគម្ពីរដោយដៃពួកគេផ្ទាល់ រួចនិយាយថា គម្ពីរនេះមកពីព្រះដើម្បីប្តូរវានឹងកម្រៃបន្តិចបន្តួច។ ហើយភាពវិនាសអន្តរាយនោះកើតមានដល់ពួកគេ គឺដោយសារតែអ្វីដែលពួកគេបានសរសេរដោយផ្ទាល់ដៃ។ ហើយការវិនាសនោះកើតមានដល់ពួកគេ ក៏ដោយសារតែកម្រៃដែលពួកគេទទួលបានដែរ។*(គួរអាន ២:៧៩)

ការបង្ខិតបង្ខំមិនត្រូវមានក្នុងសាសនាឡើយ ដ្បិតសាសនាគឺអាស្រ័យលើសេចក្តីជំនឿនិងសេរីភាពនៃការសម្រេចចិត្ត បើសាសនាត្រូវគេទទួលយកដោយការបង្ខិតបង្ខំនោះវាគ្មានន័យអ្វីសោះឡើយ។ មនុស្សគ្រប់គ្នាត្រូវតែទទួលបានឱកាសក្នុងការជ្រើសរើសសាសនាណាមួយដែលគេមានជំនឿ ហើយជម្រើសទាំងនោះគឺត្រូវផ្តល់ឱ្យពួកគេដោយគ្មានភាពលម្អៀង និងការបង្ខិតបង្ខំឡើយ។ ដាវ កាំបិត អាវុធផ្សេងៗ

---

[104] ដោយសារបញ្ហាខគម្ពីរទាំងនេះ និងខមួយចំនួនទៀត វាជារឿងដ៏អាក្រក់មួយដែលពួកអ្នកកែប្រែអត្ថបទគម្ពីរដោយដៃពួកគេផ្ទាល់ ហើយនិយាយដោយគ្មានភាពអៀនខ្មាសថា នេះជាបន្ទូលព្រះ។ គេចាត់ទុកគម្ពីរដូចសៀវភៅផ្សេងៗដែលមនុស្សជាអ្នកនិពន្ធ ហើយពួកគេហ៊ានបន្ថែមបន្ថយ ឬលុបតាមតែចិត្តពួកគេ។ ជាឧទាហរណ៍ក្នុងកណ្ឌគម្ពីរ ១សាំយ៉ូអែល ៦:១៩ សរសេរថា៖ *ព្រះយេហូវ៉ាប្រហារពួក**បេតសេម៉េស** ពីព្រោះពួកគេបើកមើលហិបរបស់ព្រះយេហូវ៉ា។ ព្រះអង្គបានប្រហារជីវិតគេអស់ប្រាំម៉ឺនចិតសិបនាក់។* ខនេះជាការបកប្រែរបស់ព្រះគម្ពីរបរិសុទ្ធភាសាខ្មែរឆ្នាំ២០១៦។ យ៉ាងណាមិញក្នុងព្រះគម្ពីរខ្មែរសម្រាយឆ្នាំ១៩៩៧ និងការបកប្រែជាភាសាខ្មែរមួយចំនួនទៀត ព្រមទាំងការបកប្រែជាភាសាអង់គ្លេស, បារាំង, អាល្លឺម៉ង់ និងអារ៉ាប់ បានសម្រេចថា ដោយសារតែមើលទៅខនេះព្រះមានលក្ខណៈឃោរឃៅពេកក៏បកប្រែដោយប្តូរជា *ប្រហារមនុស្សចិតសិបនាក់*ឬ *ចិតសិបក្នុងចំណោមប្រាំម៉ឺននាក់* វិញ។ អ្នកបកប្រែទាំងនេះយល់ថា គ្រាន់តែបើកមើលហិប ពុំគួរណាព្រះដាក់ទោសដោយសម្លាប់ច្រើនដល់ទៅប្រាំម៉ឺននាក់នោះទេ។ នៅពេលបច្ចុប្បន្ននេះ ទោះជាមានឧបករណ៍ជំនួយក្នុងការបកប្រែឱ្យសុក្រឹត្យ និងមានម៉ាស៊ីនបោះពុម្ពឱ្យដូចបេះបិតហើយគម្ពីរនៅតែមិនអាចរក្សាភាពដើមបាន ចុះទម្រាំកាលពីសម័យមុនដែលមានតែពួកបូជាចារ្យប៉ុណ្ណោះដែលគេអនុញ្ញាតឱ្យមើលគម្ពីរ តើយ៉ាងណាទៅវិញ?

មិនមែនជារបស់ដែលត្រូវប្រើលើអ្នកដែលមិនទទួលយកសេចក្ដីជំនឿ[105] ដោយការបង្ខិតបង្ខំពីវិហារកាតូលិកដែរ។ ព្រះអល់ឡោះទ្រង់បានបើកបង្ហាញរួចហើយនូវព្រះរាជសារចុងក្រោយរបស់ព្រះអង្គមកកាន់មនុស្សជាតិ៖ *គ្មានការបង្ខិតបង្ខំឡើយនៅក្នុងសាសនា។ ពិតប្រាកដណាស់ ភាពត្រឹមត្រូវបានលេចច្បាស់ជាងភាពខុសឆ្គង។* (គួរអាន ២:២៥៦)

សព្វថ្ងៃនេះយើងបានឃើញគ្រប់គ្នាហើយអំពីបញ្ហាថ្នាំញៀន, បញ្ហាឃាតកម្ម, ចោរកម្ម,ពេស្យាចារ, អំពើពុករលួយ, រំលោភសេពសន្ថវៈ, ការស្រឡាញ់ភេទដូចគ្នា គឺជាដើមចមចេញពី កង្វះការប្រកាន់ខ្ជាប់នឹងជំនឿសាសនាក្នុងចិត្តគំនិតមនុស្ស។ ដើម្បីឱ្យប្រទេសជាតិរីកចម្រើន មិនចាំបាច់ត្រូវតែប្រកាន់ខ្ជាប់នឹងជំនឿពីដូនតាមកនោះទេ។ ហេតុនេះហើយខ្ញុំសូមលើកឡើងនូវជម្រើសមួយ ដែលអាចជួយសង្គ្រោះជីវិតមនុស្ស

---

[105] គម្ពីរបរិសុទ្ធបានចែងចោទប្រកាន់លើព្យាការី **ដាវីឌ** ថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ទាំងដែលតាមពិតលោកជាស្ដេច និងជាព្យាការីសុចរិតម្នាក់។ ក្នុងកណ្ឌគម្ពីរ ២សាំយ៉ូអែល ១២:២៩-៣១ សរសេរថា៖ *ព្រះបាទដាវីឌប្រមូលទ័ពទាំងអស់ទៅវាយក្រុង**រ៉ាបាត** ហើយដណ្ដើមយកបាន។ ព្រះបាទដាវីឌយកបានមកុដដែលស្ថិតនៅលើព្រះសិរសាស្ដេចរបស់ជនជាតិ**អាំម៉ូន**។ មកុដនោះធ្វើអំពីមាស ទម្ងន់ជាងសាមសិបប្រាំគីឡូក្រាម ហើយមានដាំត្បូងពេជ្រទៀតផង។ គេយកមកុដនោះមកបំពាក់លើព្រះសិរសារបស់ព្រះបាទដាវីឌ។ ព្រះបាទដាវីឌក៏រឹបអូសយកជយភ័ណ្ឌយ៉ាងច្រើនពីក្រុងនោះ។ រីឯប្រជាជននៅក្រុងនោះវិញ ព្រះបាទដាវីឌបានកៀរយកមកធ្វើជាឈ្លើយ ព្រមទាំងបង្ខំពួកគេឱ្យអារឈើដាប់ថ្ម កាប់អុស និងធ្វើឥដ្ឋ។ ព្រះបាទដាវីឌធ្វើដូច្នេះ ចំពោះក្រុងឯទៀតៗរបស់ជនជាតិអាំម៉ូនដែរ។ បន្ទាប់មក ស្ដេចវិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញ ជាមួយកងទ័ពទាំងមូល។* ដូចគ្នាដែរបើមកអានកណ្ឌគម្ពីរ ១របាក្សត្រ ២០:៣ វិញសរសេរថា៖ *រីឯប្រជាជននៅក្នុងក្រុងនោះវិញ ព្រះបាទដាវីឌបានជន្លៀសយកមកជាឈ្លើយ ហើយបង្ខំឱ្យអារឈើ ដាប់ថ្ម កាប់អុស។ ព្រះបាទដាវីឌប្រព្រឹត្តដូច្នេះ ចំពោះក្រុងឯទៀតៗរបស់ជនជាតិអាំម៉ូនដែរ។ បន្ទាប់មក ស្ដេចវិលត្រឡប់មកក្រុងយេរូសាឡឹមវិញ ជាមួយកងទ័ពទាំងមូល។* នៅពេលអានរួចធ្វើឱ្យយើងឆ្ងល់ថា តើពិភពលោកមានសន្តិភាពម្ដេចបានបើអំពើអមនុស្សធម៌ អំពើប្រល័យពូជសាសន៍ត្រូវបានគេបញ្ចូលទៅក្នុងគម្ពីរសាសនា ហើយថែមទាំងថាព្យាការីព្រះជាអ្នកប្រព្រឹត្តផងនោះ?

បាន អាចស្តារសម្បទាមនុស្សញៀនស្រាបាន ហើយសំខាន់ទៀតនោះគឺអាចបង្រួបបង្រួមក្រុមគ្រួសារ និងសង្គមជាតិបាន។

ព័ត៌មានដ៏គួរឱ្យរន្ធត់ចិត្តមួយកាលពីឆ្នាំ២០០២ ទាក់ទិនទៅនឹងវិហារកាតូលិកនៅឯសហរដ្ឋអាមេរិក ដែលមានបូជាចារ្យមួយចំនួនបានប្រព្រឹត្តអំពើប្រទូស្តកេរខ្មាសទៅលើកុមារស្លូតត្រង់។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺ ពួកគណៈអភិបាលនៃបុរី**វ៉ាទីកង់**[106] មិនបានថ្លែងសារថ្កោលទោសថាជាអំពើឃោរឃៅអមនុស្សធម៌ឡើយ ផ្ទុយទៅវិញពួកគេព្យាយាមបិទបាំងរឿងនេះ ដោយប្រើលុយទៅបំបិទមាត់ជនរងគ្រោះ។ របាយការណ៍មួយដែលចេញផ្សាយប៉ុន្មានឆ្នាំមុននេះបង្ហាញថា មានពួកបូជាចារ្យច្រើនជាង៥ភាគរយនៅទូទាំងសហរដ្ឋដែលមានបទល្មើសប្រទូស្តកេរខ្មាសកុមារ។ យ៉ាងណាមិញ ច្រើនឆ្នាំកន្លងទៅទើបដំណឹងនេះក្លាយជាព័ត៌មានដែលដឹងសុសសាយទូលំទូលាយ។

មនុស្សជុំវិញពិភពលោកកាន់តែមានការរន្ធត់ចិត្តថែមទៀតនៅក្នុងឆ្នាំ ២០០៤ ដោយមានរបាយការណ៍មួយបង្ហាញថា ក្នុងរយៈកាល៥០ឆ្នាំកន្លងទៅនេះ មានពួកបូជាចារ្យច្រើនជាង៤០០០នាក់នៅសហរដ្ឋ មានជាប់ទាក់ទងនឹងបទល្មើសប្រទូស្តកេរខ្មាសកុមារ។ ស្ថិតិនេះគួរឱ្យចាប់អារម្មណ៍ខ្លាំងមែន ប៉ុន្តែមិនគួរឱ្យភ្ញាក់ផ្អើលនោះឡើយ។ គ្មានអ្វីគួរឱ្យសង្ស័យឡើយ បើមានកត្តាណាមួយគួរឱ្យបន្ទោសនោះ គឺគួរបន្ទោសគម្ពីរបរិសុទ្ធតែម្តង។ វាសំខាន់ដែលលោកអ្នកអានទាំងអស់គ្នាត្រូវដឹងថា ទង្វើអាក្រក់ទង្វើបាបទាំងឡាយ មិនមែនសុទ្ធតែប្រព្រឹត្តដោយមនុស្សមិនដឹងអីនោះទេ។ គម្ពីរបរិសុទ្ធចែងផ្តល់គំនិតឱ្យប្រព្រឹត្តអសីលធម៌ ដូចមានក្នុងសាច់រឿងនៃកណ្ឌគម្ពីរអេសេគាល ២៣:១ ជាដើម។ អំពើផិត និងសាហាយស្មន់ គឺជាទង្វើ២យ៉ាងដែលអាក្រក់ ហើយត្រូវបានគេចោទប្រកាន់ទៅលើព្យាការីរបស់ព្រះថាបានប្រព្រឹត្តរឿងទាំង

---

[106] បុរីវ៉ាទីកង់ជារដ្ឋស្វយ័តមួយដែលដឹកនាំដោយគណៈអភិបាលនៃសាសនាកាតូលិក ជាមជ្ឈមណ្ឌលកណ្តាលនៃសាសនាកាតូលិក។

នេះ។ ជាការពិត ក្នុងនាមយើងជាអ្នកមូស្លីម យើងបដិសេធទាំងស្រុងចំពោះគំនិតថា ព្យាការីរបស់ព្រះបានប្រព្រឹត្តទង្វើដ៏ស្មោគគ្រោកនេះ។

ខ្ញុំធ្លាប់បានសួរសំនួរខាងក្រោមនេះ ទៅកាន់គ្រិស្តបរិស័ទខ្លះដែលកំពុងរស់នៅក្នុងប្រទេស ឬសហគមន៍ដែលគេទទួលស្គាល់ជាទូទៅថាគម្ពីរបរិសុទ្ធជា គម្ពីរដ៏វិសុទ្ធបំផុត។ ខ្ញុំបានសួរពួកគេថា៖ *ហេតុអ្វីបានជាអត្រានៃឃាតកម្ម, ការរំលោភសេពសន្ថវៈ, ចោរកម្ម, បញ្ហាមនុស្សញៀនស្រា*[107]*, ពេស្យាចារ, ការស្រឡាញ់ភេទដូចគ្នា, សាហាយស្មន់ និងអំពើពុករលួយជាដើម មានអត្រាខ្ពស់ម្ល៉េះ បើធៀបនឹងប្រទេសដែលយកព្រះគម្ពីរគួរអានជាគោល?* នៅពេលខ្ញុំសួរយ៉ាងនេះ ពួកគេភាគច្រើនមានការភ្ញាក់ផ្អើលព្រោះមិនដែលនឹកគិតប្រៀបធៀបគ្នាយ៉ាងហ្នឹងសោះ។

ជាឧទាហរណ៍ នៅពេលដែលខ្ញុំសន្ទនាជាមួយជនជាតិអាមេរិកាំងម្នាក់ ខ្ញុំលើកឡើងពីរឿងមួយនៅប្រទេសអារ៉ាប៊ីសាអូឌីតដែលកាត់ទោសប្រហារជីវិតលើឧក្រិដ្ឋជន ៧នាក់ ដែលរំលោភស្ត្រីម្នាក់ក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង។ ខ្ញុំប្រាប់គាត់ថា នេះជាលទ្ធផលនៅពេលដែលច្បាប់ត្រូវបានគេយកមកអនុវត្តន៍យ៉ាងពេញលេញ នោះអាចជួយសង្គ្រោះស្ត្រីជាច្រើនឱ្យរួចផុតពីក្រញាំពួកឧក្រិដ្ឋជនទាំងនោះ។ គាត់ស្តាប់ហើយក៏ប្រកែកនឹងខ្ញុំថា ច្បាប់នេះតឹងរឹងពេកមិនអាចយកមកអនុវត្តន៍នៅសហរដ្ឋបាន

---

107 អ្នកបំភ្លែគម្ពីរបានបំពានយ៉ាងខ្លាំងទៅលើលោកយេស៊ូដោយការប្រមាថនិងមើលងាយបំផុតដែលគ្មានអ្នកមូស្លីមណាអាចទ្រាំបាននោះគឺការហៅលោកថា *ជាមនុស្សល្មោភស៊ី និងប្រមឹក* ដោយសរសេរថា៖ *កូនមនុស្សបានមកទាំងបរិភោគ និងផឹកស្រា ហើយអ្នករាល់គ្នាថា មើលចុះ! អ្នកនេះជាមនុស្សល្មោភស៊ីហើយជាមនុស្សប្រមឹក ជាសម្លាញ់របស់អ្នកទារពន្ធនិងមនុស្សមានបាប។* (លូកា ៧: ៣៤) បើយើងមើលក្នុងកណ្ឌគម្ពីរ សុភាសិត ២០:១ សរសេរថា៖ *សុរាតែងធ្វើឱ្យមនុស្សក្អេងក្អាង ហើយគ្រឿងស្រវឹងតែងតែធ្វើឱ្យមនុស្សឡូឡា។ មនុស្សប្រមឹកមិនអាចធ្វើជាអ្នកប្រាជ្ញបានឡើយ។* យើងគិតស្រមៃមិនកើតសោះថាតើមនុស្សជាតិធ្លាក់ដល់កម្រិតណា បើនាំគ្នាជឿថា ព្យាការីដ៏ពិសិដ្ឋរបស់ព្រះដូចជាលោកយេស៊ូ គឺជាមនុស្សប្រមឹក។

ឡើយ។ ខ្ញុំបានប្រាប់គាត់អំពីស្ថិតិផ្លូវការមួយនៅក្នុងប្រទេសរបស់គាត់ដែលបង្ហាញថា គិតត្រឹម៨ខែចុងក្រោយនេះ មានស្ត្រីច្រើនជាងកន្លះលាននាក់ត្រូវបានគេចាប់រំលោភ។ គាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំងហើយក៏ទទួលស្គាល់ពីឥទ្ធិពលនិងប្រសិទ្ធភាពនៃច្បាប់សាសនាអ៊ីស្លាម។ បើខ្ញុំមានឱកាសជជែកនឹងគាត់ម្តងទៀត ខ្ញុំនឹងប្រាប់គាត់ថា នៅក្នុងសាសនាអ៊ីស្លាម ឧបមាបើមានអ៊ីមុាំណាម្នាក់រំលោភកុមារ ដូចពួកបូជាចារ្យវិញ គាត់នឹងត្រូវគេប្រហារជីវិតដោយមិនពន្យារពេលឡើយ ដើម្បីសង្គ្រោះកុមារផ្សេងៗទៀតដែលមិនទាន់បានជួបរឿងនេះ។ ដោយខ្ញុំបានទទួលយកសាសនាអ៊ីស្លាម ខ្ញុំពិតជាមានអំណរក្នុងចិត្តរកនិយាយអ្វីមិនត្រូវ ហើយខ្ញុំមានមោទនភាពណាស់ដែលបានក្លាយជាអ្នកមូស្លីម។

# លិខិតចំហជូនដល់
# សម្ដេចប៉ាប និង
# មេដឹកនាំពិភពលោក

ខ្ញុំសូមចាប់ផ្ដើម ក្នុងព្រះនាមព្រះអល់ឡោះ ទ្រង់ដ៏សប្បុរស ដ៏មេត្តាករុណា។ សូមព្រះអង្គប្រទានពរដល់អស់អ្នកដែលដើរតាមមាគ៌ាដែលត្រឹមត្រូវ។

ខ្ញុំសូមសម្ដែងការអំពាវនាវនិងអញ្ជើញដល់សម្ដេចប៉ាប និងមេដឹកនាំពិភពលោកទាំងអស់ ជាពិសេសដល់អ្នកដែលដឹកនាំនិងគ្រប់គ្រងលើមនុស្សរាប់លាននាក់នៃសាសនាទាំងអស់ និកាយលទ្ធិនានា ខ្ញុំសូមអញ្ជើញអស់លោកអ្នកឱ្យទទួលយកសាសនាអ៊ីស្លាម។ នៅពេលមកកាន់សាសនាអ៊ីស្លាម លោកអ្នកនឹងបានសង្គ្រោះពីទណ្ឌកម្មនៃព្រះ ហើយនឹងទទួលបានការប្រោសប្រទានពីព្រះអង្គនូវស្ថានសួគ៌បរមសុខ។ បើលោកអ្នកជាសាសន៍យូដា ឬជាគ្រិស្តបរិស័ទ ព្រះអល់ឡោះនឹងប្រោសប្រទានដល់លោកអ្នកទ្វេឡើងនៅពេលដែលអ្នកទទួលយកសាសនាអ៊ីស្លាម។[108]

---

[108] បណ្ដាជននៃគម្ពីរ សំដៅលើអ្នកកាន់សាសនាយូដា និងសាសនាគ្រិស្ដ ត្រូវបានលើកឡើងយ៉ាងពិសេសក្នុងព្រះគម្ពីរគួរអានដើម្បីនឹងអំពាវនាវពួកគេដោយការជជែក និងដើម្បីឱ្យពួកគេទទួលយកសាសនាអ៊ីស្លាម ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *ចូរពួកអ្នកកុំជជែករកខុសត្រូវជាមួយនឹងបណ្ដាជននៃគម្ពីរ ក្រៅពីវិធី(នៃការជជែក)ណាដែលល្អប្រសើរបំផុត។*(គួរអាន ២៩:៤៦) ព្រះគម្ពីរគួរអានក៏បានលើកឡើងថា គ្រិស្តបរិស័ទជាអ្នកនៅកៀកជិតបំផុតនឹងអ្នកមូស្លីម៖ *អ្នកដែលនៅកៀកជិតនៃពួកគេ ហើយមានចិត្តស្រឡាញ់ចំពោះអ្នកមានជំនឿ ដែលពួកគេបាននិយាយថា ពិតប្រាកដណាស់ ពួក*

ព្យាការីមូហាំម៉ាត់លោកបានមានប្រសាសន៍ថា៖ *អ្នកដែលមកពីបណ្ដាជននៃគម្ពីរ (ពួកយូដា ឬគ្រិស្ដបរិស័ទ) ដែលគេនោះមានជំនឿលើព្យាការីរបស់ពួកគេ(លោកយេស៊ូ ឬលោកម៉ូសេ) ហើយបន្ទាប់មកគេជឿលើព្យាការីមូហាំម៉ាត់(ទទួលយកសាសនាអ៊ីស្លាម) នឹងទទួលផលបុណ្យទ្វេឡើង។*[109]

យ៉ាងណាមិញបើសិនលោកអ្នកបដិសេធការអញ្ជើញរបស់ខ្ញុំ លោកអ្នកនឹងទទួលខុសត្រូវលើទង្វើខ្លួន ព្រមទាំងទង្វើរបស់អ្នកក្រោមបង្គាប់និងអ្នកដើរតាមលោកអ្នកផង។

មិនខុសពីបងប្អូនមូស្លីមរួមជំនឿរបស់ខ្ញុំឡើយ ព្រះអល់ឡោះទ្រង់បានប្រទានឱ្យខ្ញុំនូវកាតព្វកិច្ចក្នុងការផ្សព្វផ្សាយព្រះរាជសាររបស់ព្រះអង្គ ទៅកាន់មនុស្សជាតិទាំងអស់ទៅតាមលទ្ធភាពរបស់ខ្ញុំ។ ទ្រង់មានព្រះបន្ទូលថា៖ *ចូរអ្នកពោលថា ឱបណ្ដាជននៃគម្ពីរ! ចូរពួកអ្នកត្រឡប់មករកពាក្យសំដីមួយដែលស្មើភាពគ្នារវាងពួកយើង និងពួកអ្នកគឺ ពួកយើងទាំងអស់គ្នាមិនត្រូវគោរពសក្ការៈម្ចាស់ផ្សេងពីព្រះអល់ឡោះ និងមិនត្រូវទុកអ្វីជាព្រះស្មើនឹងទ្រង់ឱ្យសោះ ហើយពួកយើងក៏មិនត្រូវយកគ្នាឯងធ្វើជាព្រះជាម្ចាស់ផ្សេងពីព្រះអល់ឡោះដែរ។ តែប្រសិនបើពួកគេនៅតែបែរចេញ(ពីការអំពាវនាវដ៏ល្អនេះ)ទៀត ចូរពួកអ្នក(អ្នកមានជំនឿ) និយាយទៅកាន់ពួកគេថា ចូរធ្វើបន្ទាល់ផងថា ពិតប្រាកដណាស់ ពួកយើងគឺជាមូស្លីម។* (គួរអាន ៣:៦៤)

ក្រោយពីបានបង្ហាញភស្តុតាងសំខាន់ៗនៅក្នុងជំពូកមុនៗរួចមក លោកអ្នកដែលមានចក្ខុវិស័យ និងបញ្ញាស្មារតីដែលអាចយល់បាននោះ ប្រាកដជានឹងជួបប្រសព្វនៅកន្លែងមួយដែលព្រះអល់ឡោះទ្រង់បានរៀបចំជាស្រេច ដើម្បីឱ្យមនុស្ស

---

*យើងជាគ្រិស្ដបរិស័ទ។ នោះគឺដោយសារតែពួកគេមួយចំនួនជាអ្នកចេះដឹងជ្រៅជ្រះផ្នែកសាសនា និងជាអ្នកគោរពសក្ការៈ ហើយពិតប្រាកដណាស់ ពួកគេនោះមិនក្រអឺតក្រទមឡើយ។* (គួរអាន ៥:៨២)

[109] និទានដោយ មូស្លីម ៣៤២។

គ្រប់គ្នាបានទទួលយកសេចក្ដីពិត។ ជាថ្មីម្ដងទៀត ខ្ញុំសូមបញ្ជាក់ថា នេះគឺជាកាតព្វកិច្ចនិងជាការទទួលខុសត្រូវរបស់ខ្ញុំ ក្នុងនាមជាមនុស្សម្នាក់ ដែលបានថ្វាយខ្លួនប្រាណ និងចិត្តគំនិត ជ្រកក្រោមបញ្ញត្តិនិងការបង្គាប់របស់ព្រះអល់ឡោះ ជាព្រះតែមួយអង្គគត់ ដែលមហាសប្បុរស មហាមេត្ដាករុណា ដើម្បីនឹងអំពាវនាវដល់មនុស្សគ្រប់គ្នាឱ្យបោះបង់ចោលការគោរពសក្ការៈព្រះក្លែងក្លាយក្ដី, ជំនឿជីវចល ឬអជីវចលក្ដី និងអ្វីៗផ្សេងទៀតដែលគ្រាន់តែជាការប្រតិដ្ឋឡើងរបស់មនុស្សប៉ុណ្ណោះ។ ក្រោយពេលសារភាពទោសកំហុសហើយ គ្រប់គ្នាត្រូវថ្វាយខ្លួនប្រាណនិងចិត្តគំនិតទាំងស្រុងទៅកាន់ព្រះអល់ឡោះ ជាព្រះពិតតែមួយអង្គគត់ ជាព្រះអាទិករបង្កើតនូវចក្រវាឡទាំងមូល។

យើងក៏គួរចងចាំដែរថា លុយកាក់ដ៏ច្រើនសន្ធឹកសន្ធាប់, កេរ្តិ៍ឈ្មោះ, ដំណែងតួនាទី និងអំណាចដែលអ្នកមិនមែនមូស្លីមមាននៅក្នុងដៃលើលោកិយនេះ តាមពិតទៅវាមិនគ្រប់គ្រាន់ និងមិនអាចទិញសំបុត្រចូលឧទ្យានស្ថានសួគ៌បានឡើយនៅថ្ងៃបរលោក។[110] អ្នកខ្លះជាអ្នកទីទ័លក្រនៅលើលោកិយនេះ ប៉ុន្តែគេបានធ្វើបន្ទាល់ថា

---

[110] មានតែអ្នកដែលបានបំពេញគោលបំណងនៃជីវិតរបស់គេ ដូចជាការគោរពសក្ការៈទៅចំពោះព្រះអល់ឡោះតែមួយអង្គជាដើម ទើបអាចនឹងទទួលបានសុភមង្គលពិតប្រាកដ និងភាពសុខសាន្តអស់កល្ប។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *អស់អ្នកណាហើយដែលបានប្រព្រឹត្តអំពើល្អក្នុងចំណោមបុរស ឬ ស្ត្រី ហើយគេជាអ្នកមានជំនឿទៀតនោះ គឺយើងពិតជានឹងធ្វើឱ្យគេមានជីវិតរស់នៅដ៏ល្អប្រសើរ និងតបស្នងឱ្យពួកគេនូវផលបុណ្យរបស់ពួកគេ ដោយសារតែអំពើល្អដែលពួកគេធ្លាប់បានសាង។*

(គួរអាន ១៦:៩៧) ទ្រង់មានព្រះបន្ទូលទៀតថា៖ *អស់អ្នកដែលមានជំនឿ និងបានប្រព្រឹត្តអំពើល្អនោះ សុភមង្គលនឹងមានសម្រាប់ពួកគេ ហើយជាកន្លែងវិលត្រឡប់ដ៏ល្អប្រពៃ។*(គួរអាន ១៣:២៩) ក្នុងជំពូកទី២០ វាក្យខណ្ឌ ១២៣ ដល់ ១២៤មានចែងថា៖ *នរណាហើយដែលបានដើរតាមការចង្អុលបង្ហាញរបស់យើងនោះ គឺគេមិនវង្វេង និងមិនលំបាកឡើយ។ តែបើអ្នកណាហើយបានងាកចេញពីការក្រើនរំឭករបស់យើង ពិតប្រាកដណាស់សម្រាប់គេគឺការរស់នៅយ៉ាងលំបាកវេទនា។* វាក្យខណ្ឌចុងក្រោយនេះពន្យល់យើងអំពីវិបត្តិផ្លូវចិត្ត និងមូលហេតុដែលអ្នកខ្លះមានទ្រព្យស្ដុកស្ដម្ភតែក៏ធ្វើអត្តឃាត។

*គ្មានព្រះឯណាដែលត្រូវគោរពសក្ការៈក្រៅពីព្រះអល់ឡោះ ហើយមូហាំម៉ាត់ជាព្យាការី របស់ទ្រង់* គេនឹងមានសេចក្ដីអំណរក្នុងជីវិត ហើយនឹងត្រូវគេលើកតម្កើងជាងអ្នកដែលមានទ្រព្យស្ដុកស្ដម្ភ ដែលមិនទទួលយកព្រះរាជសារចុងក្រោយរបស់ព្រះអល់ឡោះមកកាន់មនុស្សជាតិ។

ព្រះអល់ឡោះមានព្រះបន្ទូលក្នុងជំពូកទី ៣ វាក្យខណ្ឌទី ៨៥ ថា៖ *ហើយនរណាដែលស្វែងរកសាសនាផ្សេងក្រៅពីសាសនាអ៊ីស្លាម ព្រះអល់ឡោះនឹងមិនទទួលយកពីគេឡើយ។ ហើយនៅថ្ងៃបរលោកគេនឹងស្ថិតនៅក្នុងចំណោមពួកដែលខាតបង់។* ហើយនៅជំពូកទី ៥ វាក្យខណ្ឌ ៣៦ ដល់ ៣៧ ចែងថា៖ *ជាការពិតណាស់ពួកដែលគ្មានជំនឿ ប្រសិនបើពួកគេមានអ្វីៗទាំងអស់នៅលើផែនដីនេះ និងមានអ្វីដូចនេះថែមទៀតដើម្បីជាថ្លៃលោះខ្លួនពួកគេពីទណ្ឌកម្មនៅថ្ងៃបរលោកក៏ដោយ ក៏គេ(ព្រះ)មិនទទួលយកពីពួកគេដែរ ហើយពួកគេនឹងត្រូវទទួលទណ្ឌកម្មដ៏ឈឺចាប់។*

ដូចនេះហើយ ខណៈពេលដែលព្រលឹងវិញ្ញាណកំពុងស្ថិតក្នុងរាងកាយនៅឡើយ ហើយគេអាចដកដង្ហើមបាន អាចនិយាយបាន អាចគ្រប់គ្រងសកម្មភាពរបស់ខ្លួនបាន នោះក៏មានន័យថា គេអាចសារភាពទោសកំហុសរបស់គេទៅចំពោះព្រះអល់ឡោះបានដែរ។ បើការសារភាពទោសកំហុសនោះធ្វើឡើងដោយចិត្តស្មោះស ហើយគេព្រមធ្វើបន្ទាល់ថា *គ្មានព្រះឯណាត្រូវគេគោរពសក្ការៈក្រៅពីព្រះអល់ឡោះ ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់ទ្រង់* ហើយគេបោះបង់ចោលការប្រតិបត្តិសាសនាខុសឆ្គង ព្រះអល់ឡោះនឹងលើកទោសដល់គេ ទោះបីជាគេខ្វះតែមួយជំហានទៀតចូលស្ថាននរកក៏ដោយ។ ព្រះអល់ឡោះនឹងផ្លាស់ទង្វើអាក្រក់របស់គេមកជាអំពើល្អវិញ ហើយទ្រង់អនុញ្ញាតឱ្យគេបានចូលស្ថានសួគ៌ដ៏អស់កល្បជងដែរ។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ *លើកលែងតែអ្នកណាដែលបានសារភាពទោសកំហុសនិងមានជំនឿ ព្រមទាំងបានប្រព្រឹត្តអំពើល្អត្រឹមត្រូវ គឺអ្នកទាំងនោះហើយដែលព្រះអល់ឡោះនឹងប្តូរអំពើអាក្រក់របស់ពួកគេទៅជាអំពើល្អវិញ។ ហើយព្រះអល់ឡោះមហាអភ័យ*

*ទោស មហាអាណិតស្រឡាញ់។*(គួរអាន ២៥:៧០) *អស់អ្នកដែលមានជំនឿ និងបានប្រព្រឹត្តអំពើល្អនោះ យើងនឹងបញ្ចូលពួកគេទៅក្នុងស្ថានសួគ៌ដែលមានទន្លេជាច្រើនហូរពីក្រោម ដោយពួកគេរស់នៅក្នុងនោះអស់កល្ប។ ការសន្យារបស់ព្រះអល់ឡោះគឺជាការពិត។ តើនរណាដែលមានពាក្យសំដីពិតជាងព្រះអល់ឡោះទៀតនោះ?*(គួរអាន ៤:១២២) នេះជាការសន្យារបស់ព្រះអល់ឡោះ សម្រាប់នរណាហើយដែលចង់សារភាពទោសកំហុសដោយចិត្តស្មោះស ហើយចាប់ផ្ដើមជីវិតសារជាថ្មី។ ខ្ញុំសូមបិទបញ្ចប់លិខិតអញ្ជើញនេះ ដោយលើកយកវាក្យខណ្ឌមួយចំនួនចេញពីព្រះគម្ពីរគួរអានដែលព្រះអល់ឡោះទ្រង់ផ្ដល់ឱកាសដល់មនុស្សគ្រប់រូបដោយចិត្តស្មោះ ហើយទ្រង់ត្រាស់ហៅមនុស្សមានបាបទាំងឡាយឱ្យសារភាពកំហុស ដោយមិនគិតពីទំហំនៃបាបដែលគេបានបានប្រព្រឹត្តឡើយទ្រង់និងលើកទោសដល់គេ។

ក្នុងព្រះគម្ពីរគួរអានជំពូកទី ៣៩ វាក្យខណ្ឌទី ៥៣ និង ៥៤ ទ្រង់មានព្រះបន្ទូលថា៖ *ម្នាលអ្នកបម្រើទាំងឡាយរបស់យើង ដែលបានបំពានលើខ្លួនឯង(ដោយការប្រព្រឹត្តបាប)! ចូរពួកអ្នកកុំអស់សង្ឃឹមចំពោះក្ដីមេត្តាករុណារបស់ព្រះអល់ឡោះឱ្យសោះ។ ពិតប្រាកដណាស់ ព្រះអល់ឡោះនឹងអភ័យទោសនូវរាល់ទោសកំហុសទាំងអស់។ ពិតប្រាកដណាស់ ទ្រង់ជាព្រះអម្ចាស់មហាអភ័យទោស មហាអាណិតស្រឡាញ់។ ចូរពួកអ្នកវិលត្រឡប់(មកវិញ)ដោយសារភាពទោសកំហុសទៅចំពោះព្រះអម្ចាស់របស់ពួកអ្នក និងថ្វាយខ្លួនចំពោះទ្រង់មុននឹងទណ្ឌកម្មមកដល់ពួកអ្នក។ បន្ទាប់ពីនោះ ពួកអ្នកនឹងមិនត្រូវគេជួយឡើយ។*

ជាមួយគ្នានេះដែរ ព្រះអល់ឡោះទ្រង់បានឱ្យយើងដឹងថា ពេលវេលានៃការសារភាពទោសកំហុសគឺមានកំណត់ នៅពេលដែលសេចក្ដីស្លាប់បានចូលមកដល់ហើយ អ្នកនឹងលែងអាចទទួលបានការអភ័យទោសហើយ។

ជាចុងក្រោយ ព្រះអល់ឡោះទ្រង់បង្កើនការសន្យារបស់ទ្រង់ចំពោះការលើកទោសដល់អ្នកដែលមានជំនឿនឹងនរ និងបានប្រព្រឹត្តអំពើល្អ ដោយទ្រង់មានព្រះ

បន្ទូលថា៖ *ហើយពិតប្រាកដណាស់ យើងគឺជាព្រះដែលមហាអភ័យទោសចំពោះអស់អ្នកដែលបានសារភាពកំហុស និងមានជំនឿ ហើយនិងបានប្រព្រឹត្តអំពើល្អ បន្ទាប់មកគេប្រកាន់ខ្ជាប់លើផ្លូវដែលត្រឹមត្រូវ(រហូតដល់ស្លាប់)។*

ខ្ញុំសូមទូលអង្វរដល់ព្រះអល់ឡោះ ដែលជាព្រះអាទិករបង្កើតសព្វសារពើទាំងអស់ សូមព្រះអង្គចង្អុលបង្ហាញ និងដឹកនាំផ្លូវត្រូវដល់អ្នកដែលស្វែងរកសេចក្តីពិតទាំងអស់ ដែលចិត្តគំនិតរបស់ពួកគេកំពុងបើកចំហ។ ខ្ញុំទូលសុំដល់ព្រះអល់ឡោះ សូមទ្រង់ចង្អុលបង្ហាញណែនាំអ្នកទាំងអស់ និងកែប្រែស្ថានភាពរបស់ពួកគេឱ្យស្របតាមអ្វីដែលគាប់ព្រះទ័យទ្រង់។

| | |
|---|---|
| *ហើយយើងបានប្រទានចុះនូវព្រះគម្ពីរគួរអានឱ្យអ្នកយ៉ាងពិតប្រាកដ ដើម្បីបញ្ជាក់នូវអ្វីដែលមាននៅក្នុងគម្ពីរពីមុនមក និងបញ្ជាក់ពីភាពត្រឹមត្រូវនៃគម្ពីរទាំងនោះ។*(គួរអាន ៥:៤៨) | |
| **គម្ពីរបរិសុទ្ធ** | **ព្រះគម្ពីរគួរអាន** |
| **ទំពីរព្រះ** | |
| យើងជាព្រះអម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដីអស់រយៈពេលប្រាំមួយថ្ងៃ ហើយនៅថ្ងៃទីប្រាំពីរ យើងឈប់ធ្វើការហើយសម្រាក។ **(និក្ខមនំ ៣១:១៧)** | ហើយជាការពិតណាស់យើងបានបង្កើតមេឃជាច្រើនជាន់និងផែនដី ហើយនិងអ្វីៗដែលនៅរវាងវាទាំងពីរក្នុងរយៈពេលប្រាំមួយថ្ងៃ ហើយយើងពុំមានការនឿយហត់ឡើយ។ **(គួរអាន ៥០:៣៨)** |
| ពេលនោះ ព្រះអម្ចាស់តើនឡើង ដូចគេក្រោកពីដំណេក ឬដូចអ្នកចំបាំងដ៏ពូកែទើបនឹងស្វាងស្រាឡើងវិញ។ **(ទំនុកតម្កើង ៧៨:៦៥)** | ព្រះអល់ឡោះតែមួយអង្គគត់ គ្មានព្រះជាម្ចាស់ណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដផ្សេងពីទ្រង់ដែលគង់នៅជាអមតៈ ដែលជាព្រះអភិបាលឡើយ។ ទ្រង់គ្មានព្រះមិទ្ទៈ(ងងុយ) ហើយក៏ឥតផ្ទំដែរ។ **(គួរអាន ២:២៥៥)** |
| លោកយ៉ាកុបបោកចំបាប់ជាមួយព្រះហើយទទួលបានជ័យជម្នះ។ **(លោកុប្បត្តិ ៣២:២៨)** | ពួកគេឥតបានស្គាល់សមត្ថភាពនៃព្រះអល់ឡោះពិតប្រាកដឡើយ។ ពិតប្រាកដណាស់ ព្រះអល់ឡោះមហាខ្លាំងពូកែ មានអានុភាពបំផុត។**(គួរអាន ២២:៧៤)** |
| ព្រះអម្ចាស់គង់នៅជាមួយកុលសម្ព័ន្ធយូដា ហើយប្រទានឱ្យពួកគេត្រួតត្រាលើតំបន់ភ្នំ ប៉ុន្តែពួកគេពុំអាចបណ្ដេញប្រជាជនដែលរស់នៅតាមតំបន់ជ្រលងភ្នំបានទេ ព្រោះអ្នកទាំងនោះមានរទេះចម្បាំងធ្វើអំពីដែក។**(ចៅហ្វាយ ១:១៩)** | ហើយព្រះអល់ឡោះគ្មានអ្វីមួយនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដីធ្វើឱ្យទ្រង់អសមត្ថភាពពីអ្វីមួយបានឡើយ។ ពិតប្រាកដណាស់ ទ្រង់មហាដឹងជ្រាប មហាមានអានុភាព។**(គួរអាន ៣៥:៤៤)** |

| | |
|---|---|
| ...ខ្ញុំនឹងស្រដីចេញមក ដោយឈឺចាប់ក្នុងចិត្ត។ ...សូមប្រាប់ឱ្យទូលបង្គំដឹងផងថា តើព្រះអង្គមានមូលហេតុអ្វី ចោទប្រកាន់ទូលបង្គំ? តើមានប្រយោជន៍អ្វី បានជាព្រះអង្គសង្កត់សង្កិនទូលបង្គំ **(យ៉ូប ១០:១-៣)** | ពិតប្រាកដណាស់ ព្រះអល់ឡោះទ្រង់មិនបំពានលើមនុស្សលោកបន្តិចណាឡើយ ប៉ុន្តែមនុស្សលោកទេដែលបំពានលើខ្លួនឯងនោះ។ **(គួរអាន ១០:៤៤)** |
| ឱព្រះអម្ចាស់អើយ តើព្រះអង្គនៅតែភ្លេចទូលបង្គំដល់ពេលណា?**(ទំនុកតម្កើង ១៣:១)** | ព្រះអម្ចាស់របស់ខ្ញុំមិនភាន់ច្រឡំ ហើយក៏មិនភ្លេចភ្លាំងដែរ។**(គួរអាន ២០:៥២)** |
| ព្រះអម្ចាស់អើយ តើទូលបង្គំត្រូវស្រែកអង្វរ ព្រះអង្គដល់កាលណាទៀត បើព្រះអង្គមិនស្តាប់ទូលបង្គំដូច្នេះ?**(ហាបាគូក ១:២)** | ពិតប្រាកដណាស់ ព្រះអម្ចាស់របស់ខ្ញុំទ្រង់ព្រះសណ្តាប់នូវរាល់ការបួងសួងសុំ។ **(គួរអាន ១៤:៣៩)** |
| ...រហូតដល់ទៅលុបបំបាត់ពួកគេទាំងស្រុង ឬផ្តាច់សម្ពន្ធមេត្រី(ផ្តាច់សន្យា)ជាមួយពួកគេដែរ... **(លេវីវិន័យ ២៦:៤៤)** | នេះជាការសន្យានៃព្រះអល់ឡោះ។ ព្រះអល់ឡោះមិនដែលធ្វើឱ្យខុសការសន្យារបស់ទ្រង់ឡើយ... ។**(គួរអាន ៣០:៦)** |
| យោងតាមគម្ពីរ**លោកុប្បត្តិ ៣:៩** ព្រះឥតបានដឹងថាលោកអាដាំនៅឯណា ហើយក៏ឥតដឹងពីការណ៍ដែលលោកបរិភោគផ្លែឈើនោះដែរ។ ទ្រង់ហៅលោកមករួចសួរថា៖ អ្នកនៅឯណា? | ព្រះអល់ឡោះទ្រង់ជ្រាបដឹងរាល់សព្វសារពើ។ នៅពេលលោកអាដាំនិងភរិយាគាត់បរិភោគផ្លែឈើនោះ ទ្រង់ត្រាស់ហៅពួកគាត់មក ដោយជ្រាបដឹងច្បាស់ថាពួកគាត់បានធ្វើអ្វី។ ទ្រង់មានព្រះបន្ទូលថា៖ តើយើងមិនបានហាមឃាត់អ្នកទាំងពីរទេឬ អំពីដើមឈើនោះ និងហើយយើងមិនបានប្រាប់អ្នកទាំងពីរទេឬថា អារក្សបិសាចគឺជា សត្រូវយ៉ាងពិតប្រាកដចំពោះអ្នកទាំងពីរនោះ? **(គួរអាន ៧:២២)** |

| | |
|---|---|
| ព្រះត្រូវការសញ្ញាសម្គាល់ដើម្បីងអាចដឹងថា ផ្ទះណាជាផ្ទះសាសន៍អ៊ីស្រាអែល ផ្ទះណាជាផ្ទះសាសន៍អេស៊ីប។(**និក្ខមនំ ១២:១៣**) | វាគ្មានកំបាំងពីទ្រង់ឡើយ សូម្បីតែវត្ថុដែលមានទម្ងន់តូចនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដីក៏ដោយ ហើយក៏គ្មានវត្ថុដែលតូច ឬធំជាងនោះ សុទ្ធតែមាននៅក្នុងកំណត់ត្រាយ៉ាងជាក់ច្បាស់។(**គួរអាន ៣៤:៣**) |
| ព្រះឥតបានដឹងថាមានរឿងអ្វីនៅផែនដីទេ ទាល់តែយាងចុះមកផែនដីសិន៖ ពាក្យដែលគេចោទប្រកាន់ក្រុងសូដុម និងក្រុងកូម៉ូរ៉ា ធ្ងន់ធ្ងរណាស់ ហើយអ្នកក្រុងនោះក៏បានប្រព្រឹត្តអំពើបាបជាច្រើនដែរ។ យើងត្រូវតែចុះទៅមើល ដើម្បីដឹងថាអំពើដែលគេប្រព្រឹត្តនោះ ពិតដូចពាក្យដែលលាន់ឮមកដល់យើងឬយ៉ាងណា។ បើពិត ឬមិនពិត យើងមុខជាដឹងមិនខាន។<br>(**លោកុប្បត្តិ ១៨:២០-២១**) | ទ្រង់ជាព្រះអម្ចាស់ដែលដឹងអ្វីដែលលាក់កំបាំងនិងអ្វីដែលលាតត្រដាង (ហើយទ្រង់ជាព្រះអម្ចាស់)ដ៏មហិមា មហាឧត្តុង្គឧត្តម។ គឺ(ទ្រង់ដឹងជ្រាប)ដូចតែគ្នាទេចំពោះអ្នកដែលបាននិយាយខ្សឹប និងអ្នកដែលបាននិយាយខ្លាំង ហើយនិងអ្នកដែលលាក់កំបាំង(ទង្វើ)នៅពេលយប់ និងបើកចំហនៅពេលថ្ងៃក្នុងចំណោមពួកអ្នក។<br>(**គួរអាន ១៣:៩-១០**) |
| ក្នុងគម្ពីរ **១កូរិនថូស ១:២៥** លោកប៉ូលនិយាយថា៖ គំនិតលេលារបស់ព្រះជាម្ចាស់នោះ ប្រសើរលើសប្រាជ្ញារបស់មនុស្សទៅទៀត។ | ហើយកូនសោទាំងឡាយនៃប្រការអាថ៌កំបាំងស្ថិតនៅនឹងទ្រង់ ដែលគ្មាននរណាម្នាក់ដឹងក្រៅពីទ្រង់ឡើយ។ ទ្រង់ដឹងនូវអ្វីដែលមាននៅលើគោក និងមាននៅក្នុងសមុទ្រ។ រាល់ស្លឹកឈើមួយសន្លឹកដែលជ្រុះនោះ សុទ្ធតែទ្រង់ដឹងទាំងអស់ ហើយគ្រាប់ធញ្ញជាតិដែលនៅក្នុងទីងងឹតនៃដី និងអ្វីដែលស្រស់ ហើយនិងអ្វីដែលក្រៀមនោះ សុទ្ធតែត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់។(**គួរអាន ៦:៥៩**) ហើយពិតប្រាកដណាស់ ព្រះអល់ឡោះដឹងជ្រាបបំផុតនូវសព្វសារពើទាំងអស់។<br>(**គួរអាន ៥:៩៧**) |

| | |
|---|---|
| ក្នុងគម្ពីរ**អេសាយ ៧:២០** ពណ៌នាហាក់ដូចជាព្រះក្រីក្រណាស់ដោយត្រូវទៅជួលកាំបិតកោរពីគេមក៖ នៅគ្រានោះព្រះអម្ចាស់នឹងជួលកាំបិតកោរ ពីខាងនាយទន្លេអឺប្រាត គឺស្តេចស្រុកអាស្ស៊ីរី មកកោរសក់ កោររោមជើង និងកោរពុកចង្ការបស់ប្រជាជាតិនេះ។ | ម្នាលមនុស្សលោក! ពួកអ្នកគឺជាអ្នកដែលត្រូវការព្រះអល់ឡោះបំផុត។ ហើយព្រះអល់ឡោះទ្រង់មហាមានស្តុកស្តម្ភលើសលប់ជាទីកោតសរសើរ។(**គួរអាន ៣៥:១៥**) ជាការពិតណាស់ ព្រះអល់ឡោះទ្រង់ព្រះសណ្តាប់ឮនូវពាក្យសំដីពួក (យូដា)ដែលបាននិយាយថា ពិតប្រាកដណាស់ ព្រះអល់ឡោះក្រីក្រ ហើយពួកយើង(ពួកយូដា)គឺជាអ្នកមាន។ យើង(ព្រះ)នឹង កត់ត្រានូវពាក្យសំដីរបស់ពួកគេ និងការសម្លាប់របស់ពួកគេចំពោះបណ្តាព្យាការីដោយអយុត្តិធម៌...។ (**គួរអាន ៣:១៨១**) |
| គេពិពណ៌នាអំពីព្រះថា៖ មានផ្សែងហុយចេញមកពីព្រះនាសារបស់ព្រះអង្គព្រះអង្គផ្លុំភ្លើងដែលឆាបឆេះចេញមក ហើយក៏មានរងើកភ្លើងខ្ទាតចេញមក ពីព្រះឱស្ឋរបស់ព្រះអង្គដែរ។(**ទំនុកតម្កើង ១៨:៨**) នោះខ្ញុំ(ព្រះ)នឹងទៅពួនយំសោកស្តាយ... ខ្ញុំនឹងបង្ហូរទឹកភ្នែក សោកសង្រេង..។ (**យេរេមា ១៣:១៧**) ខ្ញុំ(ព្រះ)យំសោកសង្រេងខ្ញុំដើរជើងទទេ និងខ្លួនទទេ ខ្ញុំស្រែកលូដូចឆ្កែចចកហើយថ្ងូរដូចអូទ្រីស..។(**មីកា ១:៨**) នៅគ្រានោះព្រះអម្ចាស់នឹងហួចហៅហ្វូងរុយ ដែលនៅខាងចុងជ្រោយទន្លេនីល និងហ្វូងឃ្មុំនៅស្រុកអាស្ស៊ីរី។(**អេសាយ ៧:១៨**)ចំណែកឯយើង(ព្រះ)វិញយើងក៏នឹងទះដៃដែរ រហូតទាល់តែស្ងប់កំហឹងរបស់យើង។(**អេសេគាល ២១:១៧**) | ព្រះអម្ចាស់របស់អ្នកមហាស្អាតស្អំ ជាព្រះអម្ចាស់មហាខ្ពង់ខ្ពស់ផុតពីអ្វីដែលពួកគេនិយាយប្រតិដ្ឋ។(**គួរអាន ៣៧:១៨០**) គ្មានអ្វីមកប្រដូចនឹងព្រះអង្គបានឡើយ។ ហើយទ្រង់មហាសណ្តាប់ឮ មហាទតឃើញ។ (**គួរអាន ៤២:១១**) ទ្រង់គឺព្រះអល់ឡោះជាម្ចាស់ ដែលគ្មានព្រះណាត្រូវគេ គោរពសក្ការៈដ៏ពិតប្រាកដក្រៅពីព្រះអង្គដែលជាស្តេចដ៏វិសុទ្ធស្អាតស្អំគ្រប់លក្ខណ៍ ផ្តល់នូវសុវត្ថិភាព ត្រួតត្រារាល់ទង្វើនៃអ្នកបម្រើរបស់ទ្រង់ មានអានុភាពខ្លាំងពូកែ ខ្ពង់ខ្ពស់ ធុំថ្កើងបំផុត។ ព្រះអល់ឡោះទ្រង់មហាស្អាតស្អំអំពីអ្វីដែលពួកគេកំពុងធ្វើគោរពសក្ការៈខុសឆ្គងនោះ។ ទ្រង់គឺព្រះអល់ឡោះជាព្រះអម្ចាស់ដែលជាអ្នកបង្កើតជាអ្នកធ្វើឱ្យមានរូបរាង។ |

| | |
|---|---|
| | ទ្រង់មានព្រះនាមជាច្រើនដ៏ល្អប្រពៃ។ អ្វីៗនៅលើមេឃ ជាច្រើនជាន់ និងផែនដីសរសើរតម្កើងទ្រង់។ ហើយទ្រង់មហាខ្លាំងពូកែ មហាបញ្ញាញាណ។(**គួរអាន ៥៩:២៣-២៤**) |
| **អំពីលោកយេស៊ូ** | |
| លោកយេស៊ូត្រូវបានគេបំភ្លៃថា បានហៅម្ដាយដោយមិនសមរម្យដូចជា៖ ស្ត្រីអើយ នេះមិនមែនជារឿងរបស់យើងទាំងពីរទេ។(**យ៉ូហាន ២:៤**) ហើយគេចោទថាលោកមានលក្ខណៈផ្ដាច់ការ និងឃោរឃៅ ដូចជាមានសរសេរថា៖ កុំគិតថា ខ្ញុំមកដើម្បីនាំសេចក្ដីសុខសាន្តមកផែនដីឡើយ ខ្ញុំមិនមែននាំសេចក្ដីសុខសាន្តមកទេ តែខ្ញុំនាំដាវមកទេតើ! (**ម៉ាថាយ ១០:៣៤**) | ព្រះគម្ពីរគួរអានបានការពារលោកយេស៊ូផុតពីការចោទប្រកាន់នានា ដូចមានប្រសាសន៍របស់លោកថែងថា៖ ហើយព្រះអង្គបានប្រទានព្រះពរដល់ខ្ញុំគ្រប់ទីកន្លែងដែលខ្ញុំមានវត្តមាន... ហើយធ្វើឱ្យខ្ញុំក្លាយជាកូនកតញ្ញូចំពោះម្ដាយរបស់ខ្ញុំ ហើយទ្រង់មិនបានធ្វើឱ្យខ្ញុំក្លាយជាអ្នកក្អេងក្អាងប្រឆាំង(នឹងទ្រង់)ឡើយ។ (**គួរអាន ១៩:៣១-៣២**) |
| ការណ៍អស្ចារ្យដែលលោកយេស៊ូបានសម្ដែងដំបូងបង្អស់ក្នុងគម្ពីរបរិសុទ្ធនោះ គឺការប្រែទឹកឱ្យក្លាយជាស្រា ក្នុងពិធីមង្គលការមួយ ក្នុងភូមិកាណា ស្រុកកាលីឡេ។ (**យ៉ូហាន ២:៧-១១**) | ការណ៍អស្ចារ្យដែលលោកយេស៊ូបានសម្ដែងដំបូងបង្អស់ក្នុងព្រះគម្ពីរគួរអានគឺក្រោយកើតភ្លាម អាចនិយាយបានភ្លាមដើម្បីការពារម្ដាយលោកពីការចោទប្រកាន់ផ្ដេសផ្ដាស។ (**គួរអាន ១៩:៣០-៣១**) |
| **អំពីនាងម៉ារី** | |
| អ្នករាល់គ្នាធ្វើអ្វីដែលឪពុករបស់អ្នករាល់គ្នាធ្វើ។ ពួកគេជម្រាបលោក(យេស៊ូ)ថា យើងមិនមែនជាកូនឥតស្របច្បាប់(ដូចអ្នកទេ)...។ (**យ៉ូហាន ៨:៤១**) យ៉ាកុបជាឪពុករបស់យ៉ូសែបដែលជាប្ដីរបស់ | ព្រះគម្ពីរគួរអានការពារនាងម៉ារី ហើយបរិយាយថាអ្វីដែលគេនិយាយមកកាន់នាងជាការចោទប្រកាប់ខុសឆ្គងបំផុត៖ ហើយ(យើងបានដាក់ទណ្ឌកម្ម)ដោយសារតែការប្រឆាំងរបស់ពួកគេ និងពាក្យសំដីចោទប្រកាន់របស់ |

| | |
|---|---|
| ម៉ារី។ លោកយេស៊ូដែលហៅថាគ្រិស្តបានកើតពីម៉ារី។(**ម៉ាថាយ ១:១៦**)<br>ពេលដែលលោកយេស៊ូ... ហើយគេចាត់ទុកលោកជាកូនយ៉ូសែប យ៉ូសែបជាកូនហេលី។ (**លូកា ៣:២៣**) | ពួកគេទៅលើនាងម៉ារី ដោយការមួលបង្កាច់ដ៏ធ្ងន់ធ្ងរ។ (**គួរអាន ៤:១៥៦**) ព្រះគម្ពីរបញ្ជាក់ទៀតថា នាងជាស្ត្រីដែលព្រះបានលើកតម្កើងជាងគេបំផុតលើលោកនេះ៖ ហើយនៅពេលដែលទេវតាបានពោលថា ម៉ារីអើយ! ព្រះអល់ឡោះបានជ្រើសរើសនាង និងបានវិសុទ្ធនាង ហើយទ្រង់បានលើកតម្កើងនាងឱ្យលើសពីស្ត្រីផ្សេងៗនៅលើលោក។ (**គួរអាន ៣:១៤២**) |
| **អំពីសាវ័កលោកយេស៊ូ** | |
| អ្នកសរសេរគម្ពីរបានពិពណ៌នាអំពីពួកសាវ័កថា៖ ពេលនោះ ពួកសិស្សបោះបង់ព្រះយេស៊ូចោល ហើយរត់បាត់អស់ទៅ។(**ម៉ាកុស ១៤:៥០**) អ្នកសរសេរខ្លះសរសេថា លោកយេស៊ូមានប្រសាសន៍ទៅកាន់ពួកសាវ័កថា៖ មនុស្សមានជំនឿតិចអើយ! ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ?(**ម៉ាថាយ ៨:២៦**)<br><br>ប៉ុន្តែលោកបែរចេញ រួចប្រាប់ពេត្រុសថា៖ នែ! សាតាំង ចូរទៅឱ្យឆ្ងាយពីខ្ញុំទៅ! អ្នកកំពុងដាក់ឧបសគ្គរាំងខ្ញុំ ពីព្រោះអ្នកមិនគិតតាមគំនិតរបស់ព្រះទេ តែគិតតាមគំនិតរបស់មនុស្សវិញ។ (**ម៉ាថាយ ១៦:២៣**)<br><br>លោកយូដាសអ៊ីស្ការីយ៉ុត ជាសាវ័កម្នាក់ដែរ បានក្បត់លោកយេស៊ូដោយសារប្រាក់សាមសិបកាក់ ៖ បើខ្ញុំបញ្ជូនអ្នកនោះ(លោកយេស៊ូ)មកឱ្យអ្នក | ព្រះគម្ពីរគួរអានបានការពារពួកសាវ័កលោកយេស៊ូដោយបញ្ជាក់ពីការភាពគ្មានកំហុសក្នុងការក្បត់និងបញ្ហាជំនឿទន់ខ្សោយ៖ ហើយនៅពេលលោកយេស៊ូមានអារម្មណ៍ថាមានការគ្មានជំនឿកើតមានក្នុងចំណោមពួកគេ (ពួកសាវ័ក) លោកក៏បានពោលថា តើអ្នកណាជាអ្នកគាំទ្រខ្ញុំដើម្បីព្រះអល់ឡោះ? ពួកសាវ័កបានឆ្លើយថា ពួកយើងគឺជាអ្នកគាំទ្រព្រះអល់ឡោះ ពួកយើងមានជំនឿនឹងព្រះអល់ឡោះ ដូច្នេះសូមលោកធ្វើសាក្សីផងថា៖ ពួកយើងជាមូស្លីម(ថ្វាយខ្លួនដល់ព្រះ)។ បពិត្រព្រះអម្ចាស់នៃពួកយើង! ពួកយើងមានជំនឿលើអ្វីដែលទ្រង់បានប្រទានចុះមក ហើយពួកយើងបានបដិបត្តិតាមអ្នកនាំសារ ដូច្នេះសូមទ្រង់មេត្តាកត់ត្រាពួកយើងឱ្យ នៅជាមួយបណ្តាអ្នកដែលធ្វើសច្ចាផង។(**គួរអាន** |

| | |
|---|---|
| រាល់គ្នា តើអ្នកនឹងឱ្យអ្វីមកខ្ញុំ?។ ពួកគេបានព្រមព្រៀងគ្នាថា នឹងឱ្យ៣០កាក់ធ្វើពីប្រាក់។ **(ម៉ាថាយ ២៦:១៥)** | **៣:៥២-៥៣)** ម្នាលអស់អ្នកដែលជឿអើយ! ចូរពួកអ្នកគាំទ្រព្រះអល់ឡោះ ដូចដែលយេស៊ូកូនម៉ារីបានពោលទៅកាន់ពួកសាវ័ករបស់លោកថា តើអ្នកណាខ្លះចូលរួមជាមួយខ្ញុំគាំទ្រព្រះអល់ឡោះនោះ? ពួកសាវ័កបានឆ្លើយថា ពួកយើង គឺជាអ្នកគាំទ្រព្រះអល់ឡោះ។ **(គួរអាន ៦១:១៤)** |
| **ទំពីញាភាទិព្រះ** | |
| លោក(ណូអេ)បានពិសាស្រាទំពាំងបាយជូរ ហើយស្រវឹងរបូតខោអាវនៅក្នុងជំរំរបស់លោក។ **(លោកុប្បត្តិ ៩:២១)** លោកអប្រាហាំបានពោលភូតកុហក។**(លោកុប្បត្តិ ១២:១០-១៥ និង លោកុប្បត្តិ ២០:២)** | ពិតប្រាកដណាស់ ព្រះអល់ឡោះបានជ្រើសរើសអាដាំ និង ណូអេ និងពូជពង្សអប្រាហាំ ព្រមទាំងពូជពង្សអ៊ិមរ៉ន ជាមនុស្សដ៏ប្រសើរបំផុតនៅក្នុងសម័យកាលរបស់ពួកគេ។ **(គួរអាន ៣:៣៣)** |
| លោកឡុតបានផឹកស្រាស្រវឹងរួចរួមមេត្រីនឹងកូនស្រីបង្កើតខ្លួនឯងទាំង២នាក់ដើម្បីឱ្យមានគភ៌។ **(លោកុប្បត្តិ ១៩:៣០-៣៦)** | រីឯអ៊ីស្មាអែល អេលីសេ យ៉ូណាស និងឡុត យើងបានលើកតម្កើងអ្នកទាំងនេះឱ្យខ្ពង់ខ្ពស់ជាងគេនៅលើពិភពលោកទាំងមូល។ **(គួរអាន ៦:៨៦)** |
| លោកយ៉ាកុបបោកបញ្ឆោតឪពុកលោក ហើយលួចព្រះពរ និងសិទ្ធិកូនច្បងពីបងរបស់ខ្លួន។ **(លោកុប្បត្តិ ២៧:៣៥)** លោករូបេន ជាព្យាការីនិងជាកូនច្បងរបស់លោកយ៉ាកុប បានសាហាយស្មន់នឹងប្រពន្ធមួយទៀតរបស់ឪពុកខ្លួនឯង។**(លោកុប្បត្តិ ៣៥:២២ និង លោកុប្បត្តិ ៤៩:៣-៤)** | ហើយចូរអ្នកចងចាំពីបណ្ដាអ្នកបម្រើរបស់យើង អប្រាហាំ និងអ៊ីសាក ហើយនិងយ៉ាកុប ដែលជាអ្នកខ្លាំងពូកែ និងមានប្រាជ្ញាឈ្លាសវៃ។ ពិតប្រាកដណាស់ យើងបានជ្រើសរើសពួកគេដោយឱ្យពួកគេរំឭកចំពោះថ្ងៃបរលោក និងមានជំនឿនឹងវា។ ហើយពិតប្រាកដណាស់ ពួកគេគឺស្ថិតក្នុងចំណោមអ្នកដែល |

| | |
|---|---|
| លោកយូដាស ជាកូនទី៤របស់លោកយ៉ាកុប សាហាយស្មន់នឹងកូនប្រសារស្រីខ្លួនឯងរហូតបានកូន២នាក់ឈ្មោះ ពេរេស និង សេរ៉ាស។<br>**(លោកុប្បត្តិ ៣៨:១៥-១៨)**<br>គម្ពីរបរិសុទ្ធភ្ជាប់វង្សត្រកូលរបស់លោកយេស៊ូទៅនឹងលោកពេរេស(**ម៉ាថាយ ១:១-១៨**) មិនស្រប គ្នានឹងគម្ពីរ**ទុតិយកថា ២៣:២** ដែលចែងថា៖ កូនឥតខាន់ស្លាមិនអាចចូលរួមក្នុងក្រុមជំនុំរបស់ព្រះអម្ចាស់ទេ ទោះបីកូនចៅរបស់គេរហូតដល់ដប់តំណ ក៏មិនអាចចូលរួមក្នុងក្រុមជំនុំរបស់ព្រះអម្ចាស់បានដែរ។ | ត្រូវគេជ្រើសរើសដ៏ល្អប្រសើរបំផុតចំពោះយើង។(**គួរអាន ៣៨:៤៥-៤៧**) អ្នកទាំងនោះហើយដែលព្រះអល់ឡោះបានប្រោសប្រទានដល់ពួកគេឱ្យក្លាយជាព្យាការីក្នុងចំណោមពូជពង្សអាដាំ និងអំពីបណ្ដាអ្នកដែលយើងបានសង្គ្រោះជាមួយនឹងណូអេ និងពូជពង្សអប្រាហាំ និងអ៊ីស្រាអែល ហើយនិងអំពីបណ្ដាអ្នកដែលយើងបានចង្អុលបង្ហាញ និងបានជ្រើសរើស។ នៅពេលដែលមានគេសូត្រវាក្យខណ្ឌ របស់ព្រះអម្ចាស់មហាសប្បុរសឱ្យពួកគេស្ដាប់ ពួកគេបានក្រាបកាយចុះ និងបង្ហូរទឹកភ្នែក។(**គួរអាន ១៩:៥៨**) |
| ព្រះបានចោទប្រកាន់លោកម៉ូសេ និងលោកអើរ៉ុនថាបានប្រព្រឹត្តខុសនឹងព្រះ ៖ អ្នកទាំងពីរបានប្រព្រឹត្តខុសយ៉ាងធ្ងន់ចំពោះយើង នៅមុខជនជាតិអ៊ីស្រាអែល គឺអ្នកទាំងពីរពុំបានលើកតម្កើងយើងជាព្រះដ៏វិសុទ្ធ នៅក្នុងចំណោមជនជាតិអ៊ីស្រាអែលទេ។ (**ទុតិយកថា ៣២:៥១**) | សូមសុខសន្តិភាពកើតមានចំពោះម៉ូសេ និងអើរ៉ុន។ ពិតប្រាកដណាស់ យើងក៏តបស្នងដូច្នោះដែរចំពោះអ្នកដែលសាងអំពើល្អ។ ពិតប្រាកដណាស់ គេទាំងពីរគឺស្ថិតក្នុងចំណោមអ្នកបម្រើរបស់យើងដែលមានជំនឿ។<br>**(គួរអាន ៣៧:១២០-១២២)** |
| លោកម៉ូសេ សម្លាប់ជនជាតិអេស៊ីបម្នាក់ដោយចេតនា និងបានគ្រោងទុក។<br>**(និក្ខមនំ ២:១២)** | លោកម៉ូសេ មិនបានសម្លាប់ជនជាតិអេស៊ីបម្នាក់នោះដោយចេតនាឡើយ។<br>**(គួរអាន ២៨:១៥)**<br>ម្នាលអស់អ្នកមានជំនឿ! ចូរពួកអ្នកកុំធ្វើដូចពួកដែលបានធ្វើបាបម៉ូសេឱ្យសោះ។ ហើយព្រះអល់ឡោះបានធ្វើឱ្យលោកស្អាតស្អំពីអ្វីដែលពួកគេបានចោទប្រកាន់។ ហើយលោកមានឋានៈដ៏ឧត្តុង្គឧត្តមចំពោះព្រះ |

| | |
|---|---|
| | អល់ឡោះ។<br>**(គួរអាន ៣៣:៦៩)** |
| លោកអើរ៉ុន ជាអ្នកធ្វើរូបចម្លាក់កូនគោមាសដើម្បីឱ្យពួកអ៊ីស្រាអែលគោរពសក្ការៈនៅពេលលោកម៉ូសេមិននៅ។<br>**(និក្ខមនំ ៣២:១-៦)** | ព្រះគម្ពីរគួរអានការពារលោកអើរ៉ុនពីទង្វើទាំងនេះដោយបញ្ជាក់ថាអ្នកដែលនាំគ្នាគោរពសក្ការៈកូនគោមាសគឺពួក សាមីរីឯណោះទេ។<br>**(គួរអាន ២០:៨៥-៩៨)** |
| ស្តេចដាវីឌ សាហាយស្មន់នឹងប្រពន្ធមេទ័ពខ្លួន រួចរៀបឧបាយកលសម្លាប់មេទ័ពនោះ។<br>**(២សាំយ៉ូអែល ១១:៤-១៥)** | ហើយអ្នកត្រូវរំឭកអ្នកបម្រើរបស់យើងគឺដាវីឌ ដែលមានអំណាចខ្លាំងក្លា។ ពិតប្រាកដណាស់គេជាអ្នកដែលតែងតែសារភាពកំហុសជានិច្ច។<br>**(គួរអាន ៣៨:១៧)** |
| ស្តេចសាឡូម៉ុន មានស្នំមួយពាន់នាក់ហើយ ស្នំទាំងនោះបង្វែរចិត្តគំនិតស្តេចឱ្យងាកចេញពីព្រះហើយ ស្តេចបានសាងទីសក្ការៈសម្រាប់គោរពព្រះខុសឆ្គងផង។**(១ពង្សាវតាក្សត្រ ១១:១-៩)** បុត្ររបស់ស្តេចដាវីឌ គឺសម្តេចអាំណូន បានចាប់រំលោភប្អូនស្រីខ្លួនឈ្មោះ តាម៉ា។ **(២សាំយ៉ូអែល ១៣:១១-១៤)** បុត្រស្តេចដាវីឌម្នាក់ទៀតគឺសម្តេច អាប់សាឡុម រួមមេត្រីនឹងប្រពន្ធចុងឪពុកខ្លួន នៅចំពោះមុខមនុស្សប្រជាជនទាំងមូល។<br>**(២សាំយ៉ូអែល ១៦:២១-២២)** | ហើយជាការពិតណាស់ យើងបានផ្តល់ចំណេះដឹងដ៏ខ្ពង់ខ្ពស់ឱ្យដាវីឌនិងសាឡូម៉ុន។ ហើយលោកទាំងពីរបានពោលថា រាល់ការសរសើរគឺថ្វាយដល់ព្រះអល់ឡោះដែលបានលើកតម្កើងយើងខ្ញុំទាំងពីរ ច្រើនជាងគេក្នុងចំណោមអ្នកបម្រើរបស់ទ្រង់ដែលមានជំនឿ។<br>**(គួរអាន ២៧:១៥)** |

| | |
|---|---|
| លោកយ៉ូប គ្មានការអត់ធ្មត់ និងមិនទទួលយកការកំណត់របស់ព្រះ។ **(យ៉ូប ១០:១-២២)** | ពិតប្រាកដណាស់ យើងបានឃើញគេ(យ៉ូប) ជាអ្នកអត់ធ្មត់។ គេជាអ្នកបម្រើម្នាក់ដ៏ល្អប្រពៃ។ ពិតប្រាកដណាស់ គេគឺជាអ្នកដែលតែងតែសារភាពកំហុស។**(គួរអាន ៣៨:៤៤)** |
| លោកសាការី មិនជឿនឹងការណ៍អស្ចារ្យដែលព្រះបានធ្វើឱ្យលោកយ៉ូហានចាប់កំណើតឡើយ។ ព្រះក៏ដាក់ទោសគាត់ឱ្យនិយាយមិនរួចអស់ពេល ៩ខែ៖លោកនឹងទៅជាមនុស្សគ និយាយពុំកើត រហូតដល់ថ្ងៃដែលហេតុការណ៍ទាំងនោះបានសម្រេចតាមពេលកំណត់។**(លូកា ១:២០)** | ព្រះគម្ពីរគួរអានបានការពារលោកសាការី ដោយលើកឡើងថា ការដែលលោកនិយាយមិនរួចអស់ពេល៣ថ្ងៃនោះ គឺជាទីសម្គាល់ថានឹងមានការណ៍អស្ចារ្យកើតឡើងយ៉ាងពិត មិនមែនជាការដាក់ទោសលោកឡើយ៖ គេ(សាការី)បានពោលថា បពិត្រព្រះអម្ចាស់នៃខ្ញុំ! សូមទ្រង់មេត្តាផ្តល់ជាទីសម្គាល់ណាមួយ(ពីការមានគភ៌)ដល់ខ្ញុំផង។ ទ្រង់មានបន្ទូលថា ទីសម្គាល់របស់អ្នកគឺអ្នកមិនអាចនិយាយទៅកាន់មនុស្សលោកបានទេក្នុងរយៈពេលបីយប់ដោយមានសុខភាពធម្មតា។ **(គួរអាន ១៩:១០)** |
| លោកយេស៊ូ ត្រូវបានប្រសាសន៍ថាព្យាការីមុនលោកទាំងអស់គឺជាចោរ៖ អ្នកដែលមកមុនខ្ញុំទាំងប៉ុន្មាន សុទ្ធតែជាចោរលួចចោរប្លន់ទាំងអស់ ចៀមមិនបានស្តាប់សំឡេងអ្នកទាំងនោះឡើយ។**(យ៉ូហាន ១០:៨)** ព្រះបានចោទប្រកាន់ព្យាការីទាំងអស់ថាជាមនុស្សអាក្រក់ និងភូតភរ៖ ពួកព្យាការី និងពួកបូជាចារ្យសុទ្ធតែទុច្ចរិត សូម្បីតែនៅក្នុងដំណាក់របស់យើង ក៏ឃើញអំពើអាក្រក់របស់ពួកគេដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ ហេតុនេះហើយបានជាផ្លូវដែលគេដើរក្លាយទៅជាផ្លូវរអិល និងងងឹត ពួកគេនឹង | ព្រះគម្ពីរគួរអានផ្តល់តម្លៃដ៏ខ្ពង់ខ្ពស់ដល់ព្យាការីគ្រប់រូបរបស់ព្រះ និងមិននិទានរឿងខុសឆ្គងចំពោះពួកលោកឡើយ។ ការជឿនិងការគោរពដល់ព្យាការីទាំងអស់ជាកាតព្វកិច្ចដ៏សំខាន់ក្នុងសាសនាអ៊ីស្លាម។ ព្រះអល់ឡោះមានព្រះបន្ទូលថា៖ ចូរពួកអ្នក(អ្នកមានជំនឿ) និយាយថា ពួកយើងមាន ជំនឿនឹងព្រះអល់ឡោះ និងអ្វីៗដែលបានប្រទានចុះមកឱ្យពួកយើង ហើយនិងអ្វីៗដែលបានប្រទានចុះមកឱ្យអប្រាហាំ និងអ៊ីស្មាអែល និងអ៊ីសាក |

| | |
|---|---|
| ជំពប់ដើងដួល ដ្បិតនៅឆ្នាំដែលយើងត្រូវដាក់ទោសពួកគេ យើងនឹងធ្វើឱ្យគ្រោះកាចកើតមានដល់ពួកគេ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ នៅក្រុងសាម៉ារី យើងបានឃើញពួកព្យាការីប្រព្រឹត្តអំពើដ៏អាស្រូវ គឺពួកគេនាំគ្នាទាយក្នុងនាមព្រះបាល ពួកគេនាំអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង ឱ្យវង្វេង។ រីឯនៅក្រុងយេរូសាឡឹមវិញ យើងឃើញអំពើគួរឱ្យស្អប់ខ្ពើម គឺពួកព្យាការីប្រព្រឹត្តអំពើផិតក្បត់ ពួកគេនិយមការកុហក ពួកគេលើកទឹកចិត្តអ្នកប្រព្រឹត្តអំពើអាក្រក់ ដូច្នេះគ្មាននរណាអាចងាកចេញពីផ្លូវអាក្រក់របស់ខ្លួនបានឡើយ។ ចំពោះយើង ពួកគេទាំងអស់គ្នាប្រៀបដូចជា អ្នកក្រុងសូដុម ហើយអ្នកក្រុងយេរូសា-ឡឹមក៏ប្រៀបដូចជា អ្នកក្រុងកូម៉ូរ៉ាដែរ។ ហេតុនេះព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលស្ដីអំពីពួកព្យាការីថា៖ យើងនឹងឱ្យពួកគេបរិភោគផ្លែស្លែង និងឱ្យពួកគេផឹកទឹកដែលមានជាតិពុល ដ្បិតអំពើទុច្ចរិតបានរាលដាលពាសពេញស្រុកទាំងមូល ព្រោះតែពួកព្យាការីនៅក្រុងយេរ៉ូសាឡឹមនេះឯង។ ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ កុំស្ដាប់ពាក្យដែលព្យាការីទាំងនោះ ថ្លែងប្រាប់អ្នករាល់គ្នាឡើយ! ពួកគេធ្វើឱ្យអ្នករាល់គ្នាយល់ខុស ពួកគេរៀបរាប់អំពីនិមិត្តហេតុ តាមតែចិត្តរបស់គេនឹកឃើញ គឺមិនមែនជាពាក្យរបស់យើងទេ។<br>**(យេរេមា ២៣:១១-១៦)** | និងយ៉ាកុប ព្រមទាំងកូនចៅយ៉ាកុប និងអ្វីៗដែលបានប្រទានឱ្យម៉ូសេ និងយេស៊ូ និងអ្វីៗដែលគេបានប្រទានដល់បណ្ដាព្យាការីផ្សេងៗទៀតពីព្រះអម្ចាស់របស់ពួកគេ។ ពួកយើងពុំរើសអើងព្យាការី ណាម្នាក់ក្នុងចំណោមព្យាការីទាំងអស់នោះឡើយ ហើយចំពោះទ្រង់តែមួយអង្គគត់ដែលពួកយើងបានថ្វាយខ្លួន។**(គួរអាន ២:១៣៦)**<br>ព្រះអល់ឡោះទ្រង់បានលើកតម្កើងព្យាការីរបស់ទ្រង់ថា៖ ជាការពិតណាស់ យើងបានបញ្ជូនបណ្ដាអ្នកនាំសាររបស់ យើងជាមួយនឹងបណ្ដាភស្តុតាងយ៉ាងច្បាស់លាស់ ហើយយើងបានប្រទានចុះមកជាមួយពួកគេនូវគម្ពីរ និងជញ្ជីងយុត្តិធម៌ ដើម្បីឱ្យមនុស្សលោកទំនាក់ទំនងគ្នាដោយយុត្តិធម៌។<br>**(គួរអាន ៥៧:២៥)**<br>ព្រះអល់ឡោះមានព្រះបន្ទូលទៀតថា៖ ហើយយើងបានធ្វើឱ្យពួកគេក្លាយទៅជាអ្នកដឹកនាំដើម្បីចង្អុលបង្ហាញផ្លូវ(ដល់មនុស្សលោក)តាមបទបញ្ជារបស់យើង។ ហើយយើងបានបើកបង្ហាញដល់ពួកគេឱ្យសាងអំពើល្អ និងអធិដ្ឋានថ្វាយបង្គំ ហើយនិងបង់ហ្សាកាត់។ ហើយពួកគេគឺជាអ្នកដែល បានគោរពសក្ការៈមកចំពោះយើង។<br>**(គួរអាន ២១:៧៣)**<br>ព្រះអល់ឡោះទ្រង់បង្គាប់ឱ្យព្យាការីមូហាំម៉ាត់យកព្យាការីមុនៗធ្វើជាគម្រូ ទ្រង់មានព្រះបន្ទូលថា៖ អ្នកទាំងនោះ គឺជាអ្នកដែលព្រះ |

| | |
|---|---|
| | អល់ឡោះបានចង្អុលបង្ហាញ។ ដូច្នេះ ចូរអ្នក (មូហាំម៉ាត់)អនុវត្តតាមការចង្អុលបង្ហាញរបស់ពួកគេចុះ។(**គួរអាន ៦:៩០**) ព្រះគម្ពីរគួរអាន បានសង្គ្រោះជំនឿមនុស្សឱ្យលាងជម្រះកិត្តិយសរបស់ព្យាការីព្រះ។ យើងសាកស្រមៃទៅមើលថាសង្គមមនុស្សនឹងធ្លាក់ចុះសីលធម៌ប៉ុណ្ណា ប្រសិនបើព្យាការីព្រះប្រព្រឹត្តរឿងដូចដែលគម្ពីរបរិសុទ្ធបានលើកឡើង។ |
| **ទំពឺសមភាព** | |
| ដ្បិតយើងដែលជាព្រះអម្ចាស់នៃពួកពលបរិវារ ជាព្រះនៃជនជាតិអ៊ីស្រាអែល។ (**យេរេមា ១៦:៩**) | អ្វីៗសព្វសាររពើសរសើរតម្កើងទៅចំពោះព្រះអល់ឡោះ ជាព្រះអម្ចាស់នៃពិភពទាំងអស់។ (**គួរអាន ១:២**) |
| ខ្ញុំបាទដឹងច្បាស់ថា នៅលើផែនដីទាំងមូល ក្រៅពីព្រះរបស់ជនជាតិអ៊ីស្រាអែល គ្មានព្រះណាផ្សេងទៀតឡើយ! (**២ពង្សាវតាក្សត្រ ៥:១៥**) | ហើយរាល់ប្រជាជាតិនីមួយៗគឺតែងតែមានអ្នកដាស់តឿនព្រមានទៅដល់ពួកគេ។ (**គួរអាន ៣៥:២៤**) |
| ព្រះបានបង្គាប់ឱ្យជនជាតិផ្សេងទៀត ថ្វាយបង្គំជនជាតិយូដា ហើយលិឍធូលីនៃបាតជើងគេផង ៖ គេនឹងក្រាបមុខដល់ដីនៅមុខអ្នក ហើយលិឍធូលីដីដែលជាប់ជើងអ្នក...។ (**អេសាយ ៤៩:២៣**) | ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ដោយបង្គាប់ពួកគេឱ្យគោរពសក្ការៈចំពោះព្រះអល់ឡោះ និងចៀសវាងពីព្រះក្លែងក្លាយ។(**គួរអាន ១៦:៣៦**) យោងតាមវាក្យខណ្ឌនេះ ព្រះបានចាត់តាំងព្យាការីទៅគ្រប់ប្រជាជាតិទាំងអស់ មិនមែនសម្រាប់តែ |

| | |
|---|---|
| | ជនជាតិយូដាឡើយ ហើយក្នុងបំណងគោរពថ្វាយបង្គំទៅចំពោះព្រះ។ |
| មួយភាគបីនៃមនុស្សលោកបានជាប់បណ្ដាសាជាទាសករ នៅពេលដែលលោកហាំ ជាបុព្វបុរសជនជាតិកាណានបានត្រូវបណ្ដាសាហើយក្លាយជាទាសកររបស់លោកសិម និងយ៉ាផេត។ **(លោកុប្បត្តិ ២៣:១៨-២៧)** លោកយេស៊ូក៏បានបង្ហាញពីការរើសអើងនៅពេលដែលមានស្ត្រីជនជាតិកាណានម្នាក់មកសុំឱ្យលោកជួយព្យាបាលកូនស្រីដែលអារក្សចូល។ លោកយេស៊ូនិយាយទៅកាន់ស្ត្រីនោះថា៖ មិនគួរយកអាហាររបស់កូនចៅបោះទៅឱ្យកូនឆ្កែស៊ីឡើយ។**(ម៉ាថាយ ១៥:២២-២៦)** | ម្នាលមនុស្សលោក! ពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកពីបុរសនិងស្ត្រី(អាដាំ និងអេវ៉ា) ហើយយើងធ្វើឱ្យពួកអ្នកមានជនជាតិ និងកុលសម្ព័ន្ធជាច្រើន ដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ ពិតប្រាកដណាស់ អ្នកដែលថ្កុំថ្កើងជាងគេចំពោះព្រះអល់ឡោះ ក្នុងចំណោមពួកអ្នក គឺអ្នកដែលកោតខ្លាចព្រះអល់ឡោះជាងគេក្នុង ចំណោមពួកអ្នក។ ពិតប្រាកដណាស់ ព្រះអល់ឡោះមហាដឹង មហាជ្រួតជ្រាប។ **(គួរអាន ៤៩:១៣)** |
| គម្ពីរបរិសុទ្ធមានការរើសអើងរវាងបុរសនឹងស្ត្រីដូចមានចែងថា៖ ម្យ៉ាងទៀត អាដាមមិនបានត្រូវបោកបញ្ឆោតទេ តែស្ត្រីបានចាញ់បោកទាំងស្រុង ហើយបានធ្វើខុសនឹងបង្គាប់របស់ព្រះ។ **(១ធីម៉ូថេ ២:១៤)** យោងតាមគម្ពីរបរិសុទ្ធ ភាពកខ្វក់របស់ស្ត្រីដែលសម្រាលកូន គឺកខ្វក់លើសមនុស្សប្រុសទ្វេរដង ដូចមានចែងថា៖ ប្រសិនបើស្ត្រីម្នាក់មានផ្ទៃពោះ ហើយសំរាលបានកូនប្រុស នោះនាងនឹងទៅជាមិនបរិសុទ្ធ ក្នុងរយៈពេលប្រាំពីរថ្ងៃ។.. បន្ទាប់មក នាងត្រូវរង់ចាំអស់រយៈពេលសាមសិបបីថ្ងៃទៀត ដើម្បីធ្វើពិធីជម្រះកាយដោយសារការធ្លាក់ឈាម ក្នុងឱកាសដែលនាងសំរាលកូន។ ប្រសិនបើនាងសំរាលបានកូនស្រី | យោងតាមព្រះគម្ពីរគួរអាន ទាំងអាដាំ និងភរិយា សុទ្ធតែប្រព្រឹត្តបាបដូចគ្នា ហើយក៏បានសារភាពទោសកំហុស និងទទួលខុសត្រូវដូចគ្នាដែរ៖ ហើយអារក្សបិសាចបានធ្វើឱ្យពួកគាត់ទាំងពីរឃ្លាតចេញពីស្ថានសួគ៌ និងធ្វើឱ្យឃ្លាតឆ្ងាយពីអ្វីៗដែលពួកគេទាំងពីរធ្លាប់មាននៅទីនោះ។... **(គួរអាន ២:៣៦)** បពិត្រព្រះអម្ចាស់នៃពួកយើង! ពួកយើងបានបំពានលើខ្លួនឯងហើយ តែបើទ្រង់មិនអភ័យទោស និង មេត្តាករុណាដល់ពួកយើងទេនោះ ពួកយើងច្បាស់ជាស្ថិតក្នុងចំណោមអ្នកដែលខាតបង់ជាមិនខាន។ **(គួរអាន ៧:២៣)** ហើយអាដាំបានធ្វើខុសនឹង |

| | |
|---|---|
| នោះនាងនឹងទៅជាមិនបរិសុទ្ធ ក្នុងរយៈពេលពីរសប្តាហ៍... នាងត្រូវរង់ចាំអស់រយៈពេលហុកសិបប្រាំមួយថ្ងៃទៀត ដើម្បីធ្វើពិធីជម្រះកាយ ។ **(លេវីវិន័យ ១២:២-៥)** | បទបញ្ញានៃព្រះអម្ចាស់របស់គេ និងបានវង្វេង (ពីការពិត)។ ក្រោយមក ព្រះអម្ចាស់របស់គាត់បានជ្រើសរើសគាត់ ហើយ ទ្រង់បានអភ័យទោសឱ្យគាត់ និងបានចង្អុលបង្ហាញគាត់វិញ។ **(គួរអាន ២០:១២១-១២២)** |
| គម្ពីរបរិសុទ្ធប្រៀបធៀបថា ព្រះគឺជាក្បាលរបស់លោកយេស៊ូ រីឯបុរសគឺជាក្បាលរបស់ស្ត្រី។ ហើយស្ត្រីមិនត្រូវបានព្រះលើកតម្កើងដូចបុរស ហើយត្រូវព្រះបង្កើតមកសម្រាប់បុរស។ **(១កូរិនថូស ១១:៣-៩)** | ហើយប្រពន្ធមានសិទ្ធិ(ចំពោះប្តី) ដូចដែលពួកនាងមានភារកិច្ច(ប្រតិបត្តិចំពោះប្តី)ដោយអំពើល្អ។ **(គួរអាន ២:២២៨)** ដើម្បីសិក្សាបន្ថែមពីតួនាទីស្ត្រីក្នុងសាសនាអ៊ីស្លាម លោកអ្នកអាចអានជំពូកទី ៤ និងទី ៦៥ ក្នុងព្រះគម្ពីរគួរអាន។ |
| **អំពីវិទ្យាសាស្ត្រ** | |
| គម្ពីរបរិសុទ្ធមានចំណុចខ្វែងគ្នាច្រើនជាមួយនឹងវិទ្យាសាស្ត្រ ដូចជាការលើកឡើងថា បើគិតតាំងពីដើមដំបូងនៃផែនដីរហូតដល់សតវត្សរ៍ទី២១ ផែនដីមានអាយុកាលត្រឹមតែជាង៦០០០ឆ្នាំ ហើយថាមនុស្សកើតក្រោយផែនដីតែប៉ុន្មានថ្ងៃប៉ុណ្ណោះ។ យោងតាមភូគពវិទ្យា ផែនដីមានអាយុកាលប្រមាណ ៤៥៥០លានឆ្នាំ ហើយរយៈពេលដែលមនុស្សមានវត្តមានលើផែនដីគឺឆ្ងាយគ្នាខ្លាំងណាស់។ | ព្រះគម្ពីរគួរអានមិនមានការខ្វែងគ្នានឹងវិទ្យាសាស្ត្រទំនើបឡើយ។ ព្រះគម្ពីរមានផ្ទុកព័ត៌មានអំពីវិទ្យាសាស្ត្រជាច្រើនដែលគេទើបរកឃើញក្នុងពេលបច្ចុប្បន្ននេះដោយប្រើឧបករណ៍ទំនើបៗជាជំនួយផង។ សូមបើកមើលបណ្តាវាក្យខណ្ឌខាងក្រោមជាឧទាហរណ៍៖ ២:៧៤, ២:១៧៣, ២:២២២, ៤:៥៦, ៦:៩៩, ៦,១២៥, ១០:៩២, ១២:៤៧, ១៣:៤១, ១៥:១៤-២២, ១៦:៦៦, ១៧:១២, ២១:៣០-៣២, ២២:៥, ២៣:១២-១៤, ២៤:៤០, ២៤:៤៣, ២៧:៨៨, ៣០:១-៤, ៣៦:៣៧-៤០, ៣៩:៥-៦, ៤១:១១, ៥១:៤៧, ៥២:៦, ៥៥:១៩-២០, ៥៥: |

| | |
|---|---|
| | ៣៧, ៥៧:២៥, ៧៨:៦-៧, ៨៦:១-៣ និង ៩៦:១៦ ជាដើម។ |
| គម្ពីរបរិសុទ្ធលើកឡើងថា ព្រះបង្កើតពន្លឺ, ថ្ងៃ និង យប់(**លោកុប្បត្តិ ១:៣-៥**) មុនពេលបង្កើតភព ព្រះចន្ទ និងព្រះអាទិត្យ(**លោកុប្បត្តិ ១:១៤-១៨**) ក្នុងគម្ពីរ**វិវរណៈ ៧:១១** មានសរសេរថា៖ ក្រោយនោះមក ខ្ញុំឃើញទេវតា៤រូប ឈរនៅជ្រុងផែនដីទាំង៤ ទាំងទប់ខ្យល់នៅផែនដីទាំង៤ទិស...។ ដែលមានន័យថាផែនដីមានរាងជ្រុង រីឯគម្ពីរ**ម៉ាថាយ ៤:៨** ឯណោះវិញលើកឡើងថាផែនដីមានរាងសំប៉ែត ដោយចែងថា៖ មារក៏នាំព្រះអង្គទៅលើកំពូលភ្នំមួយយ៉ាងខ្ពស់ ហើយចង្អុលបង្ហាញនគរទាំងប៉ុន្មានក្នុងពិភពលោក ព្រមទាំងឱ្យព្រះអង្គឃើញភោគទ្រព្យរបស់នគរទាំងនោះផង។ | ព្រះគម្ពីរប្រើពាក្យសម្ដៅយ៉ាងច្បាស់រាងមូលរបស់ផែនដី ដោយបង្ហាញពីការត្រួតឈមគ្នារវាងយប់និងថ្ងៃ៖ ទ្រង់ធ្វើឱ្យពេលយប់គ្របព័ទ្ធលើពេលថ្ងៃ ហើយទ្រង់ធ្វើឱ្យពេលថ្ងៃគ្របព័ទ្ធលើពេលយប់។<br>(**គួរអាន ៣៩:៥**) |
| គម្ពីរបរិសុទ្ធលើកឡើងពីជនជាតិអ៊ីស្រាអែលដែលធ្វើដំណើរទៅស្រុកអេស៊ីបជាមួយលោកយ៉ាកុប ហើយពេលនោះមានបុរសស្ត្រីសរុបតែ ៧០នាក់ប៉ុណ្ណោះ។ ២ជំនាន់ក្រោយមក គ្រាន់តែចំនួនបុរសកើនឡើងដល់ ៦០៣៥៥០នាក់ ហើយបើយើងគិតទាំងចំនួនក្មេងប្រុសដែលស្ដេចផារ៉ាអុងបានសម្លាប់ទៀតនោះ សរុបទាំងបុរសទាំងស្ត្រី ទាំងក្មេងផង ប្រហែល៣លាននាក់ឯណោះ។ តើក្នុងពេលតែ២ជំនាន់ មនុស្ស៧០នាក់អាចបង្កើតកូនចៅបាន៣លាននាក់បានយ៉ាងដូចម្ដេច? | ព្រះអល់ឡោះមានព្រះបន្ទូលថា៖ យើងនឹងបង្ហាញឱ្យពួកគេឃើញនូវបណ្ដាភស្តុតាងនានារបស់យើង នៅក្នុងពិភពលោកនេះ និងក្នុងខ្លួនរបស់ពួកគេផ្ទាល់រហូតទាល់តែវាជាក់ច្បាស់សម្រាប់ពួកគេថា ពិតប្រាកដណាស់ វាគឺជាសេចក្ដីពិត។(**គួរអាន ៤១:៥៣**) ហើយអស់អ្នកដែលបាននូវចំណេះដឹងនឹងឃើញថា អ្វី(ព្រះគម្ពីរ)ដែលគេបានប្រទានចុះ ឱ្យអ្នកពីព្រះអម្ចាស់របស់អ្នក វាជាការពិត។ ហើយវាចង្អុលបង្ហាញទៅរកមាគ៌ារបស់ព្រះអម្ចាស់ |

| | |
|---|---|
| **(ទុតិយកថា ១០:២២ និង និក្ខមនំ ១២:៣៧ និង ជនគណនា ១:៤៦)**<br><br>ចំណុចផ្ទុយពីវិទ្យាសាស្ត្រមួយទៀតនោះគឺក្នុងគម្ពីរ**លេវីវិន័យ ១១:៦** ចែងថា៖ ទន្សាយព្រៃ ដ្បិតវាទំពាអៀង តែគ្មានក្រចកផែកទេ ដូច្នេះ ត្រូវចាត់ទុកវាជាសត្វមិនបរិសុទ្ធ។... | ដែលមហាខ្លាំងពូកែ ជាទីកោតសរសើរ។<br>**(គួរអាន ៣៤:៦)**<br><br>សូមរកអានសៀវភៅ The Bible, The Qur’an & Science និពន្ធដោយលោក Maurice Bucaille។ មានបញ្ញវន្តល្បីល្បាញជាច្រើនរូបទៀតអព្ភូតហេតុដ៏មហស្ចារ្យក្នុងព្រះគម្ពីរគួរអាន ដូចជា៖ បណ្ឌិត. Keith Moore, បណ្ឌិត. G.C. Goeringer, បណ្ឌិត. Marshall Johnson, បណ្ឌិត. Tagatat Tejasen, បណ្ឌិត. Alfred Kroner, បណ្ឌិត. William W. Hay, បណ្ឌិត.Yoshihide Kozai ហើយនិងបណ្ឌិត. Joe Leigh Simpson ជាដើម។ |
| **អំពីការរក្សាអត្ថបទគម្ពីរ** | |
| តើធ្វើម្ដេចឱ្យអ្នករាល់គ្នាអាចពោលថា ពួកយើងជាមនុស្សមានប្រាជ្ញា ដ្បិតពួកយើងមានក្រឹត្យវិន័យរបស់ព្រះអម្ចាស់ បើស្មៀនចម្លងគម្ពីរវិន័យ នាំគ្នាចម្លងទាំងបង្ខុសដូច្នេះ?<br>**(យេរេមា ៨:៨)** | នេះគឺជាព្រះគម្ពីរ(គួរអាន)ដែលឥតមានអ្វីត្រូវសង្ស័យឡើយ។ វាគឺជាការចង្អុលបង្ហាញចំពោះអស់អ្នកដែលកោតខ្លាចព្រះអល់ឡោះ។<br>**(គួរអាន ២:២)** |
| គឺមិនត្រូវពោលពាក្យ ព្រះអម្ចាស់ព្រមាន ទៀតឡើយ ដ្បិតអ្នកណាពោលពាក្យនេះ អ្នកនោះនឹងទទួលទោសតាមពាក្យរបស់ខ្លួន។ អ្នករាល់គ្នាបានបង្ខូចព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ គឺព្រះអម្ចាស់នៃពិភពទាំងមូល | ពិតប្រាកដណាស់ ព្រះគម្ពីរគួរអានជាព្រះគម្ពីរដ៏ពិសិដ្ឋ។ សេចក្ដីខុសឆ្គងមិនអាចមកដល់ទាំងនៅ ពីមុខនិងពីក្រោយវា(ព្រះគម្ពីរ) ឡើយ។ វាជាការប្រទានចុះមកពីព្រះអម្ចាស់មហាបញ្ញាញាណ ជាទីកោតសរសើរបំផុត។ **(គួរអាន ៤១:៤១-៤២)** ពិតប្រាកដណាស់ |

| | |
|---|---|
| ជាព្រះនៃយើង។<br>**(យេរេមា ២៣:៣៦)** | យើង(ព្រះ)បានប្រទានចុះព្រះគម្ពីរគួរអាន ហើយពិតប្រាកណាស់ យើងជាអ្នកថែរក្សាវា។(**គួរអាន ១៥:៩**) |
| គេថ្វាយបង្គំយើងឥតបានការអ្វីសោះ ព្រោះគេបង្រៀនតែក្បួនច្បាប់របស់មនុស្សប៉ុណ្ណោះ។<br>**(ម៉ាថាយ ១៥:៩)** | ហើយព្រះគម្ពីរគួរអាននេះមិនអាចត្រូវគេបង្កើតផ្សេងពីព្រះអល់ឡោះបានឡើយ ប៉ុន្តែវាបញ្ជាក់ពីអ្វីដែលមានពីមុនវា(គម្ពីរមុនៗ) ហើយវា អធិប្បាយបញ្ជាក់ពីក្បួនច្បាប់ដោយឥតមានមន្ទិល សង្ស័យសោះ មកពីព្រះអម្ចាស់នៃពិភពទាំងអស់។(**គួរអាន ១០:៣៧**) តើពួកគេឥតបានគិតពិចារណាអំពីព្រះគម្ពីរគួរអានទេឬ? ប្រសិនបើព្រះគម្ពីរនេះមិនមែនមកពីព្រះអល់ឡោះទេនោះ ពួកគេប្រាកដជារកឃើញនូវបដិវាទភាពជាច្រើននៅក្នុងវា។(**គួរអាន ៤:៨២**) |
| **អំពីការអភ័យទោស និងការទូលអង្វរ** | |
| មនុស្សលោកធម្មតាក៏អាចអភ័យទោសចំពោះអំពើបាបបានដែរ ដូចមានចែងថា៖ លុះមានប្រសាសន៍ហើយ លោកក៏ផ្លុំលើពួកគាត់ រួចមានប្រសាសន៍ថា ចូរទទួលឫទ្ធានុភាពបរិសុទ្ធរបស់ព្រះចុះ។ ប្រសិនបើអ្នករាល់គ្នាអភ័យទោសចំពោះការខុសឆ្គងរបស់អ្នកណា ការខុសឆ្គងរបស់អ្នកនោះនឹងត្រូវអភ័យទោស។ ប្រសិនបើអ្នករាល់គ្នាមិនអភ័យទោសចំពោះការខុសឆ្គងរបស់អ្នកណា ការខុសឆ្គងរបស់អ្នកនោះនឹងមិន | ព្រះអល់ឡោះតែមួយអង្គគត់ដែលអាចអភ័យទោសចំពោះបាបបាន៖ និងពួកដែលនៅពេលពួកគេធ្វើអំពើអាក្រក់អ្វីមួយ ឬពួកគេបំពានលើខ្លួនឯង គឺពួកគេនឹកឃើញព្រះអល់ឡោះ ហើយពួកគេសុំអភ័យទោសនូវរាល់ទោសកំហុសរបស់ពួកគេ។ ហើយគ្មានអ្នកណាដែលអភ័យទោសនូវរាល់កំហុសទាំងអស់ក្រៅពីព្រះអល់ឡោះឡើយ។ ហើយពួកគេមិនរឹងរូសចំពោះអ្វីដែល ពួកគេបានប្រព្រឹត្តនោះទេ ខណៈដែលពួកគេដឹងហើយនោះ។<br>(**គួរអាន ៣:១៣៥**) ហើយការសុំអភ័យទោស |

| | |
|---|---|
| ត្រូវអភ័យទោសទេ។ **(យ៉ូហាន ២០:២២-២៣)** | និងទូលអង្វរគឺធ្វើទៅចំពោះព្រះអង្គដោយផ្ទាល់តែម្តង៖ ហើយនៅពេលអ្នកបម្រើរបស់យើងសួរអ្នក(មូហាំម៉ាត់)អំពីយើង (ចូរអ្នកឆ្លើយថា) ពិតប្រាកដណាស់ យើងនៅកៀកជិតបំផុត។ យើងទទួលយកការបួងសួងសុំរបស់អ្នកដែលទូលអង្វរនៅពេលដែលគេបានបួងសួងសុំពីយើង។**(គួរអាន ២:១៨៦)** |
| **អំពីទ្រព្យសម្បត្តិ** | |
| អ្នកមានទ្រព្យច្រើនមិនអាចបានចូលរាជាណាចក្ររបស់ព្រះឡើយ៖ ខ្ញុំសុំប្រាប់អ្នករាល់គ្នាទៀតថា សត្វអូដ្ឋចូលតាមប្រហោងម្ជុល ងាយជាងអ្នកមានចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខទៅទៀត។**(ម៉ាថាយ ១៩:២៤)** | ហើយចូរអ្នកស្វែងរកផលបុណ្យចុះ សម្រាប់ថ្ងៃបរលោកនូវអ្វីដែលព្រះអល់ឡោះបានប្រទានឱ្យអ្នកចុះ តែកុំភ្លេចនូវចំណែក(ទ្រព្យសម្បត្តិ) របស់អ្នកនៅក្នុងលោកិយនេះឱ្យសោះ។ ហើយចូរអ្នកប្រព្រឹត្តអំពើល្អដូចអ្វីដែលព្រះអល់ឡោះបានធ្វើល្អចំពោះអ្នក។ **(គួរអាន ២៨:៧៧)** |
| **អំពីការបង្កវិនាសកម្ម** | |
| ឥឡូវនេះ ចូរទៅវាយជនជាតិអាម៉ាឡេកចុះ។ ត្រូវបំផ្លាញអ្វីៗទាំងប៉ុន្មានរបស់ពួកគេថ្វាយផ្តាច់ដល់ព្រះអម្ចាស់ ឥតត្រាប្រណីឡើយ គឺត្រូវសម្លាប់ចោលទាំងអស់ ទាំងប្រុស ទាំងស្រី ទាំងកូនក្មេង ទាំងទារក ទាំងគោ ទាំងចៀម ទាំងអូដ្ឋ និងលាផង។**(១សាំយ៉ូអែល ១៥:៣)** | ដោយមូលហេតុនេះហើយ ទើបយើងបានដាក់បញ្ញត្តិទៅ លើសាសន៍អ៊ីស្រាអែលថា ជាការពិតណាស់ អ្នកណាហើយបានសម្លាប់បុគ្គលណាម្នាក់ដោយគ្មានមូលហេតុ ឬបង្កវិនាសកម្មនៅលើ ផែនដី គឺហាក់បីដូចជាគេបានសម្លាប់មនុស្សលោកទាំងអស់។ ហើយអ្នកណាបានសង្គ្រោះជីវិតបុគ្គលណាម្នាក់ គឺ |

| | |
|---|---|
| | ហាក់បីដូចជាគេបានជួយសង្គ្រោះជីវិតមនុស្សលោកទាំងអស់។(**គួរអាន ៥:៣២**) |
| **អំពីចំណេះដឹង និងប្រាជ្ញា** | |
| តែមិនត្រូវបរិភោគផ្លែឈើពីដើម ដែលនាំឱ្យចេះដឹងស្គាល់ល្អស្គាល់អាក្រក់ឡើយ ដ្បិតថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន។ (**លោកុប្បត្តិ ២:១៧**) | ហើយចូរអ្នកពោលថា បពិត្រព្រះអម្ចាស់នៃខ្ញុំ! សូមទ្រង់មេត្តាបន្ថែមចំណេះដឹងដល់ខ្ញុំផង។ (**គួរអាន ២០:១១៤**) |
| ដ្បិតមានប្រាជ្ញាច្រើនមានទុក្ខកង្វល់ក៏ច្រើន ហើយមានការចេះដឹងច្រើន មានទុក្ខព្រួយក៏ច្រើនដែរ។(**សាស្តា ១:១៨**) | ព្រះអល់ឡោះនឹង លើកឋានៈអស់អ្នកដែលមានជំនឿនៅក្នុងចំណោមពួកអ្នក និង បណ្ដាអ្នកដែលត្រូវបានគេផ្ដល់ឱ្យនូវចំណេះដឹងឱ្យ។ (**គួរអាន ៥៨:១១**) |
| ចុងបញ្ចប់របស់ខ្ញុំ ក៏ដូចជាចុងបញ្ចប់របស់មនុស្សលេលាដែរ។ ដូច្នេះ បើខ្ញុំមានប្រាជ្ញាច្រើនតើបានប្រយោជន៍អ្វី? (**សាស្តា ២:១៥**) | អល់ឡោះប្រទាននូវសម្មាទិដ្ឋិដល់អ្នកណាដែលទ្រង់ មានចេតនា។ ហើយអ្នកណាដែលត្រូវបានគេប្រទានឱ្យនូវសម្មាទិដ្ឋិ អ្នកនោះប្រាកដជាត្រូវគេប្រទានឱ្យនូវកុសលដ៏ច្រើនលើសលប់។ ហើយការក្រើនរំឭកគ្មានប្រយោជន៍ឡើយ លើកលែង តែពួកដែលមានសតិបញ្ញាប៉ុណ្ណោះ។(**គួរអាន ២:២៦៩**) |
| **អំពីសាសនាដែលមានលក្ខណៈពេញលេញ** | |
| សព្វថ្ងៃនេះ យើងចេះដឹងត្រឹមតែមួយផ្នែកប៉ុណ្ណោះ ហើយយើងក៏ថ្លែងព្រះបន្ទូល បានត្រឹមតែមួយផ្នែកប៉ុណ្ណោះដែរ។ លុះដល់ពេលយើង | ថ្ងៃនេះ យើងបានបំពេញលក្ខណៈសម្រាប់ពួកអ្នកនូវសាសនារបស់ពួកអ្នក និងបានបង្គ្រប់សម្រាប់សពួកអ្នកនូវការប្រោសប្រទាន |

| | |
|---|---|
| ដឹងសព្វគ្រប់ហើយ អ្វីៗដែលយើងស្គាល់តែមួយផ្នែកនឹងអស់ខ្លឹមសារ។(**១កូរិនថូស ១៣:៩-១០**) | របស់យើងឱ្យពួកអ្នក ហើយយើងបានជ្រើសរើសសាសនាអ៊ីស្លាមជាសាសនារបស់ពួកអ្នក។(**គួរអាន ៥:៣**) |

# ផ្នែកបន្ថែម

| បញ្ជីរាយនាមបណ្ដាព្យាការី | | | |
|---|---|---|---|
| គម្ពីរបរិសុទ្ធ | | ព្រះគម្ពីរគួរអាន | |
| *សំណេរខ្មែរ* | *សំណេរអង់គ្លេស* | *សំណេរខ្មែរ* | *សំណេរអង់គ្លេស* |
| អដាំ/អាដាំ/អ័ដាំ | Adam | អាដាំ/អាដាម | Adam |
| ហេណុក/អេណុក | Enoch | អ៊ីទ្រីស | Idries |
| ណូអេ | Noah | ណួហ | Nuh |
| ឡុត | Lot | លូត | Lut |
| អប្រាហាំ/អ័ប្រាហាំ | Abraham | អ៊ីព្រហ៊ីម | Ibrahim |
| អ៊ីស្មាអែល | Ishmael | អ៊ីស្មាអ៊ីល | Ismail |
| អ៊ីសាក | Isaac | អ៊ីស្ហាក | Ishaq |
| យ៉ាកុប | Jacob | យ៉ាក់កូប | Yaqqub |
| យ៉ូប | Job | អៃយ៉ូប | Ayyub |
| យ៉ូសែប | Joseph | យូសុហ្វ | Yusuf |

| | | | |
|---|---|---|---|
| អេសេគាល | Ezekiel | ហ្សុលគីហ្វលី | Dhul-Kifl |
| ម៉ូសេ/ម៉ូសេស | Moses | មូសា | Musa |
| អើរ៉ុន | Aaron | ហារូន | Harun |
| ដាវីឌ | David | ដាវូត | Dawud |
| សាឡូម៉ុន | Solomon | ស៊ូឡៃម៉ាន | Sulayman |
| អេលីយ៉ា | Elijah | អ៊ីលយ៉ាស | Ilyas |
| អេលីសេ | Elisha | អ៊ីលយ៉ាសាក់ | Al-Yasa |
| យ៉ូណាស | Jonah | យូនូស | Yunus |
| សាការី | Zachariah | ហ្សាការីយ៉ា | Zakariyya |
| យ៉ូហាន | John | យ៉ះយ៉ា | Yahya |
| យេស៊ូ | Jesus | អ៊ីសា | Isa |
| | | មូហាំម៉ាត់ | Muhammad |

# ឯកសារពិគ្រោះក្នុងការបកប្រែ


- គម្ពីរអាល់គួរអាន បកប្រែជាភាសាខ្មែរ
- មហាគម្ពីរអាល់គួរអាននុលការីម
- ព្រះគម្ពីរដ៏វិសុទ្ធ ភាសាខ្មែរបច្ចុប្បន្ន
- ព្រះគម្ពីរខ្មែរសម្រាយ ឆ្នាំ១៩៩៧
- ព្រះគម្ពីរបរិសុទ្ធ ឆ្នាំ១៩៥៤
- ព្រះគម្ពីរដ៏វិសុទ្ធ ឆ្នាំ២០០៥
- ព្រះគម្ពីរបរិសុទ្ធ (កែសម្រួលថ្មីឆ្នាំ២០១៦)
- គម្ពីរបរិសុទ្ធ សេចក្តីបកប្រែពិភពលោកថ្មី

- The Meaning of The Holy Quran *by* Abdullah Yusuf Ali
- Qur an English *by* Sahih International
- The Clear Quran
- Translation of the meaning of The Noble Quran
- King James Bible

ចំណងជើងដើម

“My Great Love For Jesus Led me to Islam”

*by* Simon Alfredo Caraballo

លោកអ្នកអាចអានសៀវភៅនេះជាភាសា

*អង់គ្លេស អេស្ប៉ាញ បារាំង ហ្វីលីពីន*

ដោយចូលទៅកាន់គេហទំព័រ៖

myloveforjesus.com

ឬទាញយកកម្មវិធីទូរស័ព្ទសម្រាប់អានសៀវភៅនេះក្នុង

Available on the App Store

ANDROID APP ON Google Play

ផលិតដោយ

ឧបត្ថម្ភដោយ

«ដំណើររឿងនោះគឺយេស៊ូកូនប្រុសរបស់ម៉ារី។
វាគឺជាសេចក្តីពិតដែលពួកគេមានការសង្ស័យ។»

*-ព្រះគម្ពីរគួរអាន ១៩:៣៤*

«ម៉ារីអើយ! ព្រះអល់ឡោះបានជ្រើសរើសនាង និងបានវិសុទ្ធនាង ហើយ
ទ្រង់បានលើកតម្កើងនាងឱ្យលើសស្ត្រីផ្សេងៗទៀតលើលោកនេះ។»

*-ព្រះគម្ពីរគួរអាន ៣:៤២*

«ម៉ារីអើយ! ពិតប្រាកដណាស់ព្រះអល់ឡោះប្រទាននូវដំណឹងរីករាយដល់
នាងនូវព្រះបន្ទូលពីទ្រង់ នាមរបស់គេគឺគ្រិស្តយេស៊ូកូនម៉ារីដែលល្បីល្បាញ
ទាំងក្នុងលោកិយ និងថ្ងៃបរលោក និងជាអ្នកជំនិតម្នាក់ក្នុងចំណោមអ្នកជំនិត
ទាំងឡាយនៃព្រះអល់ឡោះ។»

*-ព្រះគម្ពីរគួរអាន ៣:៤៥*

ផលិតដោយ

មជ្ឈមណ្ឌលនៃក្តីមេត្តា
MERCY CENTER